# មេរៀនធម៌

# ជំនួយសតិភាគទី៦

រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ ប៊ុត សាវង្ស

**សម្រាប់ជាធម្មទាន**



មេរៀនធម៌ជំនួយសតិភាគទី៦ ត្រូវបានសម្តេចព្រះសង្ឃរាជគណៈមហានិកាយ បានអនុញ្ញាតហើយ ដើម្បីបោះពុម្ពជាធម្មទាន រំលឹកឆ្នាំសិក្សានូវព្រះធម៌ ក្នុងពុទ្ធសករាជ ២៥៤៤ ។

សិក្សានៅវត្តឧណ្ណាលោម

វត្តសំពៅមាស

រាជធានីភ្នំពេញ - កម្ពុជា

# ពាក្យប្រារព្ធអនុមោទនាព្រះធម៌

*ឆម្ពុទានជាត៌ព្វុលទាន* មនុស្សយើងកើតមកត្រូវម៉ែឪចិញ្ចឹមឱ្យរស់ផង ទេសនាឱ្យស្តាប់ផង ដូច្នេះម៉ែឪយើងជាបុព្វាចារ្យ គឺអាចារ្យដើមបង្អស់របស់យើងជាកូន ជាព្រះព្រហ្ម ព្រោះបានបង្កើតកូនហើយ គ្រប់គ្រងដោយព្រហ្មវិហារធម៌ ជាទេវតា ព្រោះមានតួនាទីចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសស្រី ជាអាហុនេយ្យៈ ជាក់ជាស្រែបុណ្យ ព្រោះក្រៃលែងទៅដោយគុណធ្ងន់ជាងព្រះធរណី ។

ខែឆ្នាំកន្លងទៅ ម៉ែឪត្រូវស្លាប់បាត់បង់ជីវិតអស់នៅសល់តែការចងចាំប៉ុណ្ណោះក្នុងវិញ្ញាណរបស់កូន ម៉ែឪតែងទូន្មានប្រៀនប្រដៅ ឱ្យកូនធ្វើជាមនុស្សល្អ ឱ្យកូនខំប្រឹងសិក្សារៀនសូត្រ ហាមកូនមិនឱ្យប្រព្រឹត្តអបាយមុខទុកវង្សត្រកូលឱ្យកូនរក្សា ស្រឡាញ់កូនប្រុសស្រីណាស់



ប៉ុន្តែមិនព្រាត់ប្រាស មិនបានឡើយ គឺដល់ពេលហើយមច្ចុរាជឥតប្រណី ។

ទោះបីម៉ែឪគាត់បានចែកឋានទៅហើយក៏ដោយប៉ុន្តែ មរតកឱវាទ និង មនោសញ្ចេតនាស្រឡាញ់កូនដោយស្មោះ បានស្ថិតនៅក្នុងហឫទ័យ បេះដូងរបស់កូនប្រុសស្រី ព្រមដោយការនឹករលឹក និង ការដឹងគុណដ៏ជ្រាលជ្រៅទៅរកលោកទាំងទ្វេ កូនបានត្រឹមតែធ្វើបុណ្យឧទ្ទិសកុសល សុំឱ្យលោកអ្នកដ៏មានគុណទាំងអស់នោះបានសោយនូវសម្បត្តិសុខ ក្នុងសួគ៌ទេវលោកកុំបីខានតែប៉ុណ្ណោះឯង ក្រៅអំពីហ្នឹង កូនមិនដឹងធ្វើដូចម្តេចទៀតទេ កូនចង់ដឹងសុខទុក្ខរបស់លោកឪពុកអ្នកម្តាយខ្លាំងណាស់ ប៉ុន្តែនេះវាជារឿងចែកឋានគ្នាទៅហើយ កូនមិនអាចមាននូវសមត្ថភាពដឹងបានឡើយ ។

ដើម្បីឱ្យស័ក្តិសមនឹងព្រះគុណដ៏ធំក្រៃលែង របស់មាតាបិតា កូនប្រុសស្រីត្រូវថែរក្សាវង្សត្រកូលឱ្យបានល្អត្រូវលើកស្ទួយកិត្តិយស កេរ្តិ៍ឈ្មោះពូជពង្សកុំឱ្យអន់អាប់

ត្រូវសិក្សាទទួលយកនូវឱវាទជាបន្ត ដ្បិតព្រះពុទ្ធសាសនា ជាសាសនាល្អ មាននៅសព្វថ្ងៃ ដូច្នេះ កូនប្រុសស្រីកុំគប្បី ប្រមាទ កុំឱ្យរំលងនូវព្រះធម៌ដែលជារតនៈដ៏ឧត្តមក្រៃលែងលើលោកឡើយ ។

ពុទ្ធកិច្ច៤៥ព្រះវស្សា ព្រះសម្មាសម្ពុទ្ធព្រះអង្គមានព្រះធម៌ទេសនា ជាធំជាប្រធានលើកិច្ចទាំងពួង ក្នុងវស្សាទី១ នៅនាព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ព្រះជិនស្រីសម្ដែងព្រះធម៌ស្រោចស្រង់សត្វលោក ទាំងមនុស្ស ទាំងទេវតា ទាំងព្រហ្ម ក្នុងកាលណោះ មានភិក្ខុសាវ័ក៦០អង្គជាព្រះអរហន្ត គឺបញ្ចវគ្គិយភិក្ខុ៥អង្គ ព្រះយស១អង្គ និងសម្លាញ់ព្រះយស៥៤អង្គ ។

នៅពេលចេញវស្សាទី១នោះហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទៅកាន់ភិក្ខុទាំង៦០អង្គថា , ម្នាលភិក្ខុទាំងឡាយតថាគតរួចហើយអំពីអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្ដី ទោះបីជារបស់មនុស្សក្ដី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសោតក៏បានរួចហើយ អំពីអន្ទាក់



ទាំងអស់ដែរ ទោះបីជារបស់ទេវតាក្ដី ទោះបីជារបស់មនុស្សក្ដី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក (គឺស្រុកនិងនិគម ព្រមទាំងរាជធានីហើយសម្ដែងព្រះធម៌) ដើម្បីជាប្រយោជន៍ និង សេចក្ដីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និង មនុស្សទាំងឡាយ អ្នកទាំងឡាយកុំទៅពីរអង្គតាមផ្លូវមួយជាមួយគ្នាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្ដែងព្រះធម៌ឱ្យពីរោះ បទដើម បទកណ្ដាល និង បទចុង អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និង ព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយដែលមានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មានដែរ សត្វទាំងនោះនឹងសាបសូន្យចាកមគ្គផល ព្រោះមិនបានស្ដាប់នូវព្រះធម៌ សត្វទាំងឡាយអ្នកបំរុងនឹងត្រាស់ដឹងនូវសច្ចធម៌ រមែងមានជាប្រាកដ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតក៏នឹង

ចូលទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេស ដើម្បីសម្តែងនូវព្រះធម៌ដែរ ។

ក្រោយអំពីព្រះពុទ្ធអង្គ ទ្រង់បញ្ជូនភិក្ខុសាវ័កទាំង ៦០អង្គ ចេញទៅផ្សព្វផ្សាយព្រះសាសនាហើយ ព្រះអង្គស្តេចយាងទៅឧរុវេលាសេនានិគម តែមួយព្រះអង្គគត់ ក្នុងចម្ងាយផ្លូវជាច្រើនយោជន៍ ។ ក្នុងរវាងផ្លូវ ទ្រង់ប្រោសនូវភទ្ទវគ្គិយ៣០រូប ឱ្យបានជាព្រះអរិយបុគ្គល និងបានជាឯហិភិក្ខុឧបសម្បទា រួចហើយព្រះអង្គទ្រង់យាងទៅដល់ឧរុវេលាសេនានិគម ទ្រង់ប្រោសជដិល ៣នាក់ ជាបងប្អូននឹងគ្នា រួមទាំងបរិវារ ១០០០រូប ឱ្យបានជាឯហិភិក្ខុឧបសម្បទា ទ្រង់សម្តែង អាទិត្តបរិយាយសូត្រ នៅនាតំបន់គយាសីលៈ ញ៉ាំងភិក្ខុទាំងអស់នោះឱ្យបានសម្រេចនូវព្រះអរហត្តផល ។

បន្ទាប់អំពីនោះ ព្រះពុទ្ធអង្គទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ ទ្រង់គង់ប្រថាប់នៅលដ្ឋិវ័នព្រៃត្នោតជំទង់ ជាមួយភិក្ខុបុរាណជដិល ១០០០អង្គ គ្រានោះព្រះបាទ



ពិម្ពិសារ ព្រមទាំងរាជបរិវារ ចេញមកគាល់ព្រះអង្គ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងមហានារទជាតក និងអរិយសច្ចៈ៤ ប្រោសអ្នកទាំងអស់នោះព្រមទាំងព្រះរាជា ចប់ព្រះធម៌ទេសនា មនុស្សជាងមួយម៉ឺននាក់រួមទាំងព្រះបាទពិម្ពិសារផង ត្រូវបានសម្រេចនូវសោតាបត្តិផល នៅមួយចំនួនទៀត ប្រកាសខ្លួនដល់នូវព្រះត្រៃសរណគមន៍ រួចហើយព្រះរាជាបានទូលអារាធនាព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃឆាន់ភត្តាហារនៅវេលាថ្ងៃស្អែក ។

ព្រឹកថ្ងៃស្អែកឡើង ព្រះពុទ្ធអង្គទ្រង់យាងចូលទៅទទួលមហាទាន ក្នុងព្រះរាជនិវេសន៍ ក្រោយអំពីភត្តកិច្ចស្រេចហើយ ព្រះបាទពិម្ពិសារបានថ្វាយនូវឧទ្យានវេឡុវ័នឱ្យជាព្រះអារាមទី១ក្នុងព្រះពុទ្ធសាសនា ។

ស្រង់ចាកសៀវភៅពុទ្ធកិច្ច៤៥ព្រះវស្សា **ឋស្សាទី ២ ឋស្សាទី៣ ឋស្សាទី៤** ទ្រង់គង់ប្រថាប់នៅវេឡុវ័នវិហារជិតក្រុងរាជគ្រឹះ

✵**ឋស្សាទី៥** ទ្រង់គង់នៅកូដាគារសាលា

នាមហាវ័ន ជិតក្រុងវេសាលី

❈វស្សាទី៦ ទ្រង់គង់នៅមហាមកុដបពឹត ដែនមគធៈ លើក្រុងរាជគ្រឹះ

❈វស្សាទី៧ ទ្រង់គង់នៅស្ថានត្រ័យត្រិង្ស សួគ៌ទេវលោក ប្រោសព្រះពុទ្ធមាតា

❈វស្សាទី៨ ទ្រង់គង់នៅភេសកឡាវ័ន ក្នុងភគ្គជនបទ

❈វស្សាទី៩ ទ្រង់គង់នៅឃោសិតារាម ជិតក្រុងកោសម្ពី

❈វស្សាទី១០ ទ្រង់គង់នៅក្រោមដើម សាលព្រឹក្ស ក្នុងព្រៃបារិលេយ្យកៈ

❈វស្សាទី១១ ទ្រង់គង់នៅស្រុកព្រាហ្មណ៍ ឈ្មោះឯកនាលា ដែនមគធៈ

❈វស្សាទី១២ ទ្រង់គង់នៅនាគល់ដើម ស្ពៅ ក្នុងស្រុកវេរញ្ជា



❈វស្សាទី១៣ ទ្រង់គង់នៅចាលិកបពឹត ក្នុងស្រុកចាលិកា

❈វស្សាទី១៤ ទ្រង់គង់នៅព្រះជេតវ័ន មហាវិហារ ជិតក្រុងសាវត្ថី

❈វស្សាទី១៥ ទ្រង់គង់នៅនិគ្រោធារាម ជិតក្រុងកបិលវត្ថុ

❈វស្សាទី១៦ ទ្រង់គង់នៅអគ្គាឡវ ចេតិយ ជិតក្រុងអាឡវី

αវស្សាទី១៧ ទ្រង់គង់នៅវេឡុវ័ន ជិត ក្រុងរាជគ្រឹះ

❈វស្សាទី១៨ ទ្រង់គង់នៅចាលិកបពឹត ក្នុងស្រុកចាលិកា

❈វស្សាទី១៩ ទ្រង់គង់នៅចាលិកបពឹត ក្នុងស្រុកចាលិកា ដដែលទៀត

❈វស្សាទី២០ ទ្រង់គង់នៅវេឡុវ័នជិត ក្រុងរាជគ្រឹះ

✵វស្សាទី២១ ដល់ទី៤៤ ទ្រង់គង់នៅ ជាប្រចាំនាវត្តជេតវ័ន មហាវិហារ និង បុព្វារាម ជិតក្រុងសាវត្ថី

✵វស្សាទី៤៥ ជាវស្សាចុងក្រោយ ទ្រង់គង់នៅនាវេឡុវគ្រាម ជិតក្រុងវេសាលី ។ ក្នុងមហាបរិនិព្វានសូត្រ បិដកខ្មែរយើងលេខ១៦ បានរៀបរាប់យ៉ាងពិស្តារ ក្រោយវស្សាទី៤៥ គួរពុទ្ធបរិស័ទ បានអានកុំគប្បីខានឡើយ ។

វគ្គមួយនៃមហាបរិនិព្វានសូត្រ ព្រះអង្គទ្រង់ត្រាស់ជាឱវាទដល់ភិក្ខុទាំងឡាយ ក្នុងថ្ងៃ ១៥កើត ខែ មាឃ បន្ទាប់អំពីព្រះអង្គដាក់ព្រះជន្មាយុសង្ខារ ចំពោះមុខមារ ហើយថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលដ៏យូរ គប្បីតម្កល់នូវអស់កាលជាអង្វែង ម្យ៉ាងទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ពពួកជនច្រើន ដើម្បីសេចក្តីសុខដល់ពពួកជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បី



សេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និង មនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយ ដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើនធ្វើឱ្យរឿយៗដោយប្រការដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលដ៏យូរ គប្បីតម្កល់នៅអស់កាលជាអង្វែង ម្យ៉ាងទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ពពួកជនច្រើន ដើម្បីសេចក្តីសុខដល់ពពួកជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និង មនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយ ដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឱ្យរឿយៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះតើដូចម្តេច ហើយមានអ្វីខ្លះ?

គឺសតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គ៧ អរិយមគ្គប្រកបដោយអង្គ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលដ៏យូរ គប្បីតម្កល់នៅអស់កាលជាអង្វែង ម្យ៉ាងទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ពពួកជនច្រើន ដើម្បីសេចក្ដីសុខដល់ពពួកជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតា និង មនុស្ស ទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្ដែងហើយ ដោយបញ្ញាដ៏ឧត្ដម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឱ្យរឿយៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្ដី



វិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញាំងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតនៅមិនយូរទៀតឡើយ កន្លង៣ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្ដាក៏ទ្រង់មានព្រះបន្ទូលដូច្នេះ បន្តទៅទៀតថា៖

ពួកជនណាៗ ទោះបីក្មេងក្ដី ចាស់ក្ដី ពាលក្ដី បណ្ឌិតក្ដី អ្នកមានក្ដី អ្នកក្រក្ដី ជនទាំងអស់នោះ តែងមានសេចក្ដីស្លាប់នៅពីខាងមុខ ។ ភាជន៍ដីដែលស្មូនផ្ទាំងធ្វើហើយ ទោះបីតូចក្ដី ធំក្ដី ឆ្អិនក្ដី ឆៅក្ដី ភាជន៍ដីទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

ព្រះបរមសាស្ដា ទ្រង់មានព្រះបន្ទូល ដូច្នេះតទៅទៀតថា៖

វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់

តថាគតមានប្រមាណតិច តថាគតនឹងលះបង់នូវអ្នកទាំងឡាយ ហើយទៅ ឯទីពឹងចំពោះខ្លួនតថាគត បានធ្វើទុកហើយ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានសេចក្តីត្រិះរិះតម្កល់ស្មើល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យរឿយៗចុះ ។

ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ ភិក្ខុនោះ នឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ បានពុំខានឡើយ ។

នៅថ្ងៃ ១៥កើត ខែ ពិសាខ មុននឹងព្រះអង្គយាងចូលព្រះនិព្វាន ក៏មានឱវាទបណ្តាំច្រើនណាស់ ដូចជាព្រះអង្គទ្រង់ត្រាស់ថាៈ

ម្នាលអានន្ទ បុគ្គលណាមួយ ទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវ



ធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ជាប្រក្រតី បុគ្គលនោះឈ្មោះថា ធ្វើសក្ការៈ គោរពរាប់អាន បូជាតថាគតដោយគ្រឿងបូជាដ៏ឧត្តម ម្នាលអានន្ទ ព្រោះហេតុនោះ បរិស័ទក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយ នឹងប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ជាប្រក្រតី ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

ពេលបរិនិព្វានរបស់ព្រះអង្គ កាន់តែកៀកណាស់ហើយ ចុតិចិត្តកាន់តែជិតមកដល់ ក្រោមពន្លឺដួងចន្ទពេញបូណ៌មី ជិតអស់មួយរាត្រី ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឱវាទផ្តាំផ្ញើរហូត សព្វគ្រប់កិច្ចការគ្មានចន្លោះ ព្រះអង្គផ្តាំហើយផ្តាំទៀត ប្រកបដោយព្រះមហាករុណាដ៏ធំធេងរកអ្វីប្រៀបប្រដូចពុំបានឡើយ ទោះបីជាព្រះអង្គទ្រង់ល្វិតល្វៃ អស់នូវព្រះកាយពលយ៉ាងណាក៏ដោយ ព្រះអង្គទ្រង់

ត្រាស់ស្ថាបនានូវព្រះធម៌ និង ព្រះវិន័យ ឱ្យជាសាស្តា ជំនួសព្រះអង្គ ទ្រង់ត្រាស់ថា:

ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយ មាននូវសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យប្រដៅ ដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ គ្រូរបស់យើងឈ្មោះថាមិនមានទៀតឡើយ ម្នាលអានន្ទ សេចក្តីនេះ អ្នកកុំយល់យ៉ាងនេះឡើយ ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌ និង វិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ។

ព្រះចន្ទកាន់តែបែរជ្រេ ទន់ទេរទាបទៅទិសបស្ចិម ជាវេលាបច្ចូសសម័យថ្ងៃជិតរះ ពេលនោះ ភិក្ខុជាច្រើនរយអង្គ សុទ្ធតែជាព្រះអរិយបុគ្គល គង់គាល់រហង់ជុំជិតព្រះសាស្តា នៅក្នុងឧទ្យានសាលវ័ន របស់មល្លក្សត្រ នគរកុសិនារា ព្រះដ៏មានព្រះភាគត្រាស់ថា ណ្ហើយចុះ ម្នាល



ភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឱ្យបានដឹង សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតាអ្នកទាំងឡាយ ចូរញុំាងកិច្ចទាំងពួងឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ។ នេះជាព្រះបច្ឆិមវាចារបស់ព្រះតថាគត ។

ព្រះគុណម្ចាស់ ញាតិញោមពុទ្ធបរិស័ទទាំងឡាយបច្ចុប្បន្ននេះ ពុទ្ធបរិស័ទមានព្រះធម៌ និង ព្រះវិន័យជាគ្រូគឺជាគ្រូនៅជាប់ជាមួយជានិច្ច ជួយរំលឹក ជួយដាស់តឿនឱ្យតែពុទ្ធបរិស័ទព្រមក្នុងចិត្តថានឹងបដិបត្តិតាម ពុទ្ធបរិស័ទក៏ឈ្មោះថា មានព្រះសាស្តាជាទីពឹង មានព្រះធម៌ជាទីពឹង មានព្រះសង្ឃជាទីពឹង និង មានខ្លួនឯងជាទីពឹងនៃខ្លួនឯង បានទៀតផង ។

នៅថ្ងៃ ១៥កើត ខែ ផល្គុន ព.ស. ២៥៤៤ ខ្សែអាត់សម្លេងព្រះធម៌ជាធម្មទាន មានការផ្សព្វផ្សាយជាច្រើនឆ្នាំមកហើយ តាមវិទ្យុនៅក្នុងប្រទេសយើង ក៏បានចូលដល់ ១០០០ខ្សែអាត់គត់ ត្រូវជា ១០០០ម៉ោង

ចាក់ផ្សាយ ២០០០ថ្ងៃ ក្នុងមួយថ្ងៃ ៣០នាទី មិនត្រឹមតែមួយប៉ុស្តិ៍ប៉ុណ្ណោះ មានច្រើនប៉ុស្តិ៍ទៀតផង ទាំងល្ងាចទាំងយប់ ព្រមទាំងជិតភ្លឺ រួមគ្នាទៅឃើញថា ច្រើនគួរសម ។

មិនមែនមាននៅតែភ្នំពេញទេ គឺមាននៅខេត្តបាត់ដំបងពីរប៉ុស្តិ៍ ប៉ៃលិនមួយប៉ុស្តិ៍ ក្រុងព្រះសីហនុមួយប៉ុស្តិ៍ ២ពេលទៀតផង ឯចំណែកខ្សែអាត់ធម្មទានទូទៅ ទាំងនៅក្នុងស្រុក ទាំងនៅក្រៅស្រុក ដោយបានចម្លងផ្សព្វផ្សាយ ចែកចាយតៗគ្នា ក៏បានច្រើនម៉ឺនខ្សែអាត់ផងដែរ ព្រមទាំងសៀវភៅជំនួយសតិជាដើមទៀត ដូច្នេះ ពុទ្ធបរិ-ស័ទ ក៏បានធ្វើបុណ្យអនុមោទនាធម្មទានរួមគ្នាមួយ នៅអាស្រមធុតង្គចំការដូង ប្រារព្ធធ្វើនៅថ្ងៃ ១៥ កើត ខែផល្គុន ព.ស ២៥៤៤ កម្មវិធីមានដាក់បាត្រព្រះសង្ឃ សម្តែងព្រះធម៌ទេសនា សុន្ទរកថារៀបរាប់អំពីប្រយោ-ជន៍ធម្មទាន និង មានការចែកសៀវភៅធម៌ជំនួយសតិភាគទី៦នេះឯង សូមពុទ្ធបរិស័ទទាំងអស់គ្រប់គ្នា ទាំង



នៅក្នុងប្រទេសកម្ពុជា ទាំងនៅក្រៅប្រទេស គប្បីបានជ្រាបហើយជ្រះថ្លា អនុមោទនា !

សូមព្រះគុណម្ចាស់ ញាតិញោម គ្រប់ព្រះអង្គ គ្រប់គ្នា បាននូវឧបនិស្ស័យសម្បត្តិក្នុងព្រះពុទ្ធសាសនា ជាតិនេះជាតិមុខ សូមឱ្យប្រកបជាមួយបញ្ញា មានជីវិតភ្លឺថ្លា រស់នៅក្នុងព្រះធម៌ យ៉ាងសុខដុមក្សេមក្សាន្ត ប្រៀបបានដូចនៅក្នុងវិមានអមតៈ ដោយអានុភាពនៃធម្មទាននេះឯងហោង ។

រាជធានីភ្នំពេញ,ថ្ងៃ ១៥ កើត

ខែ មាឃ ព.ស ២៥៥៤

**ខ្ញុំព្រះករុណា**

**ខ្ញុំបាទ ប៊ុត សាវង្ស**

*បោះពុម្ព ២០.០០០ក្បាល*
*សម្រាប់ជាធម្មទាន*

# មាតិកាធម៌

| ល,រ | ឈ្មោះវត្ថុនៃធម៌ | ទំព័រ |
|---|---|---|
| I- | **តួនាទីសំខាន់របស់មនុស្ស** ...................... | ១ |
| II- | **សន្តោស** ................................................... | ៨ |
| | * មុទុលក្ខណជាតក........................................ | ១២ |
| | *សេចក្តីក្សេមក្សាន្តបានប្រាកដក្នុងចិត្តព្រោះគំនិតយល់ត្រូវ...................................................... | ១៩ |
| | *ចិត្តដែលមានសេចក្តីសន្តោស ជាចិត្តមិនមានរោគ មិនមានទោស ជាចិត្តឆ្លាត មានផលជាសុខ . | ៣០ |
| | *កុំវង្វេងទុកដាក់ជីវិតជាល្បែងភ្នាល់ .................. | ៣៣ |
| | *លោភៈជាហេតុនៃការវង្វល់កង្វល់ មោរជាតករឿងក្ងោក ................................................. | ៣៨ |
| | *ការស្អប់ស្អល់មិនមែនជាសេចក្តីខ្ជិល ................. | ៥៩ |
| III- | **មេត្តា** ........................................................ | ៧២ |
| | *ខន្តិវាទិជាតក ............................................... | ៧៩ |
| | *សេចក្តីអត់ធន់មានក្នុងជាតកផ្សេងៗ ................ | ៩២ |
| | *អំពីទោសនៃសេចក្តីក្រោធ............................... | |
| | *នឹករលឹកដល់សេចក្តីល្អរបស់អ្នកដទៃ................. | ១១៣ |




*អ្នកខឹងក្រោធគឺធ្វើទុក្ខឱ្យខ្លួនឯង .................... ១២៣

*ពិចារណាកម្មផល........................................ ១៣១

*ញាតិក្នុងវដ្តសង្សារគួរពិចារណា ...................... ១៣៥

*ពិចារណាអានិសង្សមេត្តា ១១យ៉ាង ............... ១៤០

*ពិចារណាចែកធាតុ ..................................... ១៥៣

*បញ្ញត្តិ ២យ៉ាង ........................................... ១៦២

*វិញ្ញត្តិរូប ២ ............................................... ១៨៥

*ការឱ្យ និង ការព្រមទទួលជួយសង្គ្រមចិត្ត ........ ២១១

*បទគួរយល់ដឹងចុងក្រោយ ........................... ២២៨


❈ ជាមួយគ្នានឹងរបស់ធម្មតាដែលនៅជុំវិញខ្លួនយើង ត្រូវរៀនធ្វើជាមនុស្សធម្មតាម្នាក់ឱ្យបានកុំខាន ដើម្បីទទួលរបស់ធម្មតាគ្រប់យ៉ាង ដែលបានមកដល់ជីវិតនេះរាល់ថ្ងៃ ដោយសេចក្តីមិនញាប់ញ័រតក់ស្លុត ។

❈ ត្រូវខំប្រឹងកសាងខ្លួន បន្តិចម្តងៗ ដើម្បីឱ្យបានជាមនុស្សរឹងប៉ឹង គឺជាអ្នកមិនចេះទំនាស់ជាមួយនឹងរបស់ធម្មតា ព្រោះធម្មតា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ រមែងតែងតែយ៉ាងហ្នឹងឯង ។

❈ មានកិលេស ព្រោះនៅល្ងង់ ។

# តួនាទីសំខាន់របស់មនុស្ស

កើតមកជាមនុស្ស តែងជួបប្រទះនូវការងារដែលត្រូវធ្វើ តាមតែការងារនោះជាតួនាទីរបស់ខ្លួន ។ ប្រទីបនៃជីវិតដែលសម្រាប់ញុំាងការរស់នៅឱ្យមានពន្លឺរស្មី វាអាស្រ័យនៅលើការងារគោរពតួនាទីរបស់ខ្លួនហ្នឹងឯង ការងារតាមតួនាទីជាអាយុជីវិតរបស់មនុស្ស ជាគ្រឿងអលង្ការសម្រាប់លំអឱ្យជីវិត និង ជាមង្គលសិរីសួស្តីនៃជីវិតបុរសស្ត្រីគ្រប់គ្នា ។

មនុស្ស ជាសត្វដ៏វិសេស មានចំណេះដឹងព្រមដោយចិត្តគំនិតប្រសើរឧត្តម ដូច្នេះតួនាទីរបស់មនុស្ស មិនមែនជាឃាតករ មិនមែនជាចោរ មិនមែនជាអ្នកប្រព្រឹត្តអនាចារផ្សេងៗជាដើមឡើយ ។ ក្នុងមនុស្សម្នាក់ៗមានកិច្ចការដែលត្រូវបំពេញច្រើនយ៉ាង តាមដែលខ្លួនឯងមានតួនាទីជាអ្វីខ្លះ ក៏ត្រូវគោរពតួនាទីនោះៗ ដូចជាស្ត្រីម្នាក់ឬបុរសម្នាក់ ចាំបាច់ត្រូវមានសម្បជញ្ញៈដឹងខ្លួនឯងថាជាមនុស្ស មានតួនាទីធ្វើជា



មនុស្ស មិនត្រឹមតែប៉ុណ្ណោះ នៅធ្វើជាមាតាឬបិតារបស់កូនត្រូវមានតួនាទីសង្គ្រោះកូនប្រុសស្រី ខ្លួនឯងជាកូនក៏មានតួនាទីជាកូនត្រូវគោរពម៉ែឪ ខ្លួនឯងម្នាក់នៅមានតួនាទីជាប្រពន្ធឬជាប្ដីផង ជាគ្រូអាចារ្យផង ជាសិស្សផង ជាមិត្រផង ជាចៅហ្វាយផង ជាអ្នកបំរើការងារគេផង ជាពុទ្ធបរិស័ទផង ។ល។ នៅមានតួនាទីមួយទៀតសំខាន់ជាងគេទាំងអស់ គឺតួនាទីប្រដៅខ្លួនឯង បានដល់ការអប់រំទូន្មានចិត្ត ។

**ជំនួយចាំបាច់ក្នុងការអប់រំទូន្មានចិត្ត** គឺការស្ដាប់ព្រះធម៌ឬអានគម្ពីរធម៌ ។ ការស្ដាប់ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ ជាបច្ច័យនាំឱ្យកើតការយល់ដឹងក្នុងរឿងរបស់ជីវិត ការយល់ដឹងក្នុងរឿងរបស់ជីវិត ជាឧបករណ៍សម្រាប់បង្ហាត់ចិត្ត ឱ្យចិត្តមានបែបបទល្អ ចិត្តដែលបានបង្ហាត់ឱ្យមានបែបបទល្អហើយ រមែងនាំមកនូវសេចក្ដីសុខ ។

**ធម្មទានឈ្នះអស់ទានទាំងពួង** ឱវាទរបស់ព្រះពុទ្ធនាំឱ្យកើតបញ្ញា ដល់អ្នកស្ដាប់ដោយសេចក្ដីគោរព ។ បញ្ញាជារតនៈដ៏ប្រសើរជាទីបំផុត រតនៈផ្សេងៗក្នុងលោកមាន

មាស ប្រាក់ ត្បូង ពេជ្រ ជាដើម នាំមកនូវការវង្វេងស្មារតី ឱ្យដល់បុរសស្ត្រីដែលអត់បញ្ញា និងជាអន្ទាក់នៃសេចក្តីទុក្ខសោកសព្វបែបយ៉ាង ចំណែកបញ្ញាជារតនៈពិតឥតក្លែងក្លាយ ព្រោះនាំមកនូវភាពស្ងាត់ក្សេមតែម្យ៉ាងប៉ុណ្ណោះ ។

ទ្រព្យសម្បត្តិបច្ច័យ៤ មានដែនកំណត់នៃការប្រើប្រាស់ គឺត្រឹមតែដោះស្រាយនូវការមិនសុខផ្លូវកាយ ឯការមិនសប្បាយផ្លូវចិត្ត ត្រូវដោះស្រាយដោយការស្តាប់ព្រះធម៌ ពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ហើយជាអ្នកមិនប្រហែសធ្វេស នៅដោយស្មារតីជាគ្រឿងគ្រប់គ្រងចិត្ត ។ ជាការវង្វេងធំណាស់ដែលយល់ថា ខ្លួនមិនសប្បាយចិត្តព្រោះការខ្វះខាតទ្រព្យសម្បត្តិ ទាំងដែលខ្លួនឯងក៏ជាអ្នកមានផ្ទះនៅ មានបាយទទួលទានគ្រប់គ្រាន់ សម្លៀកបំពាក់ក៏ល្មមសមរម្យដែរនោះ ព្រោះការពិតវាស្ថិតនៅលើសេចក្តីមិនស្កប់ស្កល់ក្នុងចិត្ត សេចក្តីមិនស្កប់ស្កល់ជាមេរោគ បំផ្លាញសុខភាពរបស់ចិត្ត ធ្វើឱ្យដឹងខ្លួនរឿយៗថា មានការរសាប់រសល់ខ្វល់ខ្វាយក្នុងចិត្តជានិច្ច ។ មនុស្សដែលមិនចេះស្កប់ស្កល់ មិនដឹងថាចង់បានអ្វីពិតប្រាកដ



ឡើយ មុនដំបូងនឹកថារបស់នេះ លុះដល់បានមកមួយសន្ទុះថាមិនមែនទេ អានោះវិញ បានអានោះមកហើយ ក៏មិនប្រាកដ ទីបំផុតមិនដឹងថាខ្លួនឯងចង់បានអ្វីឱ្យប្រាកដផងទេ មានតែការអន្ទះសា ឆ្លេឆ្លារហូតដូច្នេះឯង ។

មនុស្សយើងកើតមកខំប្រឹងចិញ្ចឹមជីវិត ការពារជីវិត លើកស្ទួយជីវិត រហូតដល់ហ៊ានសម្លាប់គេដើម្បីរក្សាជីវិត ឬដើម្បីកិត្តិយសនៃជីវិត ប៉ុន្តែទីបំផុត ជីវិតជាទីស្រឡាញ់របស់យើងនេះ បានចែកមរតកឱ្យយើងគ្រប់គ្នាគឺ ចាស់ ឈឺ និងស្លាប់ នៅក្នុងរឿងនេះដើម្បីកុំឱ្យវង្វេងវិលវល់ មានតែពន្លឺព្រះធម៌ទេ ដែលអាចបកស្រាយឱ្យយើងបានសប្បាយចិត្ត ហើយចេះស្កប់ស្កល់ ព្រោះយល់ដល់ការពិត ។

ទ្រព្យសម្បត្តិមាសប្រាក់ធ្លាក់ចុះមកពីអាកាស ចូលពេញក្នុងផ្ទះយ៉ាងណាក៏ដោយ មិនអាចញ៉ាំងការឆ្អែតស្កប់ស្កល់ឱ្យដល់ម្ចាស់ទ្រព្យបានឡើយ ចំណែកសម្លេងព្រះធម៌ ឱវាទព្រះពុទ្ធ បានប្រកាសប្រាប់ការពិតអំពីជីវិត បកស្រាយពន្យល់ណែនាំ បើកផ្លូវ ជាមរតកអមតៈរបស់ព្រះពុទ្ធជាបិតា នាំមក

នូវបញ្ញាឃើញថា ការមិនស្កប់ស្កល់ព្រោះសេចក្តីល្ងង់ខ្លៅរបស់ខ្លួនឯង ។

សម្លេងព្រះធម៌ទេសនា ពីរោះជាងសម្លេងតូរ្យតន្ត្រីរបស់ទេវតាទៅទៀត តូរ្យតន្ត្រីនាំមកនូវការរំជួលចិត្ត នាំចិត្តឱ្យរាយមាយរវើរវាយ ចំណែកព្រះធម៌ទេសនា នាំមកនូវការយល់ដឹង ធ្វើចិត្តឱ្យនឹងធឹងស្ងប់ការក្រវល់ក្រវាយ មានចិត្តសប្បាយរីករាយក្នុងកុសលធម៌ ។ ការសប្បាយចិត្ត ជាចំណុចសំខាន់របស់មនុស្សគ្រប់គ្នា ជាបេះដូងនៃសុភមង្គល ជាខ្យល់ដង្ហើមនៃសិរីសួស្តី នេះពោលចំពោះតែការសប្បាយចិត្តណាដែលប្រាសចាកទោសប៉ុណ្ណោះ ការសប្បាយចិត្តនេះ ជាកំណប់មហាសាល ជាទិសដៅនៃអ្នកប្រព្រឹត្តធម៌តាមឱវាទព្រះសម្មាសម្ពុទ្ធ ។

បុគ្គលណា មិនអាចធ្វើចិត្តឱ្យសប្បាយបានទេនោះ បញ្ជាក់ថាបុគ្គលនោះ នៅខ្វះសមត្ថភាព មិនអាចអារាធនាព្រះពុទ្ធសាសនាឱ្យចូលមកកាន់ហឫទ័យរបស់ខ្លួនបានឡើយ ដរាបណា ចិត្តនៅតែក្រវល់ក្រវាយ ដោយសេចក្តីទុក្ខ សេចក្តី



ក្តៅក្រហាយព្រោះលោភៈ ព្រោះការខឹងក្រោធ ព្រោះការច្រណែន ព្រោះការវង្វេង ដរាបនោះក៏បញ្ជាក់ថា ជាការមិនបានចូលដល់ចំណុចទិសដៅពិតប្រាកដ របស់ព្រះពុទ្ធសាសនាឡើយ គួរឱ្យសោកស្តាយណាស់ ដែលកើតមកបានជួបនឹងព្រះពុទ្ធសាសនាហើយ តែមិនបានព្យាយាមបង្អោនទទួលយកនូវគុណប្រយោជន៍ដ៏ក្រៃលែង របស់ព្រះពុទ្ធសាសនាទុកជារបស់ខ្លួន យ៉ាងនេះមិនអាចឈ្មោះថា ជាអ្នកមានបញ្ញាបានឡើយ ។

បុគ្គលអ្នកមានបញ្ញា មានការយល់ដឹងច្បាស់លាស់ ជាអ្នកព្យាយាមចូលទៅរកសេចក្តីសំខាន់នៃព្រះពុទ្ធសាសនា បើមានការសប្បាយចិត្តទៅហើយនោះ តើវាមានអ្វីឱ្យសំខាន់ជាងហ្នឹងទៀតនៅក្នុងជីវិតនេះ ។ រាល់ថ្ងៃនេះដែលនាំគ្នាស្វែងរកសេចក្តីសប្បាយមិនបាន មកអំពីភ្លេចសេចក្តីសំខាន់របស់ចិត្ត ដែលជាការសប្បាយចិត្តហ្នឹងឯង ដូច្នេះត្រូវអប់រំចិត្តឱ្យសប្បាយជានិច្ចរឿយៗដោយបញ្ញា ។

ភាគច្រើនតែងគិតខុសថា ការហួងហែង ការប្រកាន់

ការប្រច័ណ្ឌ ការគិតខ្វល់ខ្វាយផ្សេងៗ ជាការចាំបាច់សម្រាប់ដោះស្រាយ នូវសេចក្តីលំបាកតិចច្រើនក្នុងជីវិតនេះ ព្រះធម៌បានដាស់តឿនរំលឹក ឱ្យមានការព្យាយាមលះបង់ នូវគំនិតយល់ខុសដ៏សែនចង្អៀតចង្អល់នេះចេញ ឱ្យត្រឡប់មកជាការយល់ត្រឹមត្រូវឡើងវិញថា ការសប្បាយចិត្ត សេចក្តីសុខស្ងប់គ្រប់រឿងរ៉ាវ ជាការសំខាន់ចាំបាច់ពិតប្រាកដនៃជីវិត គ្រប់រឿងរ៉ាវទាំងអស់ គ្រប់បញ្ហាដែលលំបាកលំបិន ត្រូវដោះស្រាយបានជាស្រេច ដោយការស្ងប់សប្បាយផ្លូវចិត្ត ។

សេចក្តីស្ងប់សប្បាយផ្លូវចិត្ត ពិតជារបស់កម្ររកបានមែនហើយ មិនមែននឹកចង់សប្បាយ នឹកចង់ឱ្យសុខចិត្ត ក៏បានសប្បាយ បានសុខចិត្តទៅនោះទេ ទាល់តែអាស្រ័យការព្យាយាមស្តាប់ព្រះធម៌ អប់រំទូន្មានចិត្តរឿយៗ **កសាងសេចក្តីសន្តោស ចម្រើនមេត្តានិងមានស្មារតី** ទើបអាចសម្រេចបាននូវសេចក្តីសុខសប្បាយ តាមផ្លូវចិត្តពិតប្រាកដ សូមមនុស្សទាំងឡាយ កុំភ្លេចនូវតួនាទីដ៏សំខាន់របស់ខ្លួន គឺកសាងខ្លួនឯងឱ្យបានល្អ ។



# សន្តោស

សេចក្តីសន្តោសប្រព្រឹត្តទៅក្នុងបច្ច័យ៤ ក្នុងវត្ថុរបស់របរប្រើប្រាស់ មានរបៀបច្រើនយ៉ាង ប៉ុន្តែសរុបមកគឺការមិនលោភ ការចេះស្គាល់ប្រមាណ ការចេះស្កប់ស្កល់ ការយល់ចូលចិត្តអំពីជីវិតដែលទាក់ទងនឹងបរិក្ខារប្រើប្រាស់ ។

**ធម្មទានមានឥទ្ធិពលផ្តល់គំនិត ឱ្យចេះគិតយល់អំពីទោសរបស់លោភៈ** ការឃើញទោសរបស់លោភៈ នាំឱ្យមានសេចក្តីសន្តោស នាំឱ្យមានសេចក្តីព្យាយាមប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីកំចាត់បង់នូវលោភៈក្នុងសន្តានរបស់ខ្លួន ។ នៅក្នុងគម្ពីរធម្មបទ មានសម្តែងរឿង **សប្បទាសត្ថេរ** ភិក្ខុអង្គនេះលោកចេះតែចង់សឹក អផ្សុកក្នុងការនៅបួស ព្រោះការផ្សែផ្សំរៀបចំដោយកម្មពៀររវេរារបស់លោក ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងអំពីបុព្វកម្ម

របស់សប្បទាសត្ថេរ អំពីជាតិមុនក្នុងសាសនានៃព្រះពុទ្ធកស្សបៈ ដោយក្នុងកាលនោះ មានភិក្ខុពីរអង្គជាមិត្តសម្លាញ់នឹងគ្នា ។ ភិក្ខុមួយអង្គលោកអផ្សុកចង់សឹក ចំណែកភិក្ខុជាសម្លាញ់ក៏បាននិយាយលួងលោម រំលឹកដល់ភិក្ខុដែលចង់សឹកនោះ ឱ្យឃើញទោសក្នុងការគ្រប់គ្រងផ្ទះ មានការលំបាកច្រើនយ៉ាង និង ប្រកបដោយគ្រឿងសៅហ្មងផ្សេងៗ ហើយពោលសរសើរនូវគុណរបស់នេក្ខម្មៈ ដោយប្រការផ្សេងៗផងដែរ ។ កាលបានស្តាប់នូវពាក្យរំលឹកដាស់តឿន អំពីភិក្ខុជាសម្លាញ់ លោកក៏សប្បាយចិត្តលែងចង់សឹកតទៅទៀតហើយ លោកបានយកបរិក្ខារមានបាត្រជាដើម មកជូតខាត់ដុសសម្អាតនៅក្បែរមាត់ស្រះ ដែលក្នុងពេលនោះ ភិក្ខុជាសម្លាញ់ ក៏បាននៅជិតៗនោះដែរ ។ ជូតបាត្របណ្តើរ និយាយបណ្តើរថា បើសិនជាខ្ញុំព្រះករុណាសឹកទៅហើយ បរិក្ខារទាំងអស់របស់ខ្ញុំព្រះករុណាប្រាកដជាប្រគេនដល់លោកម្ចាស់ជាសម្លាញ់ដោយពិត។ ដោយអំណាចនៃលោភៈជាប់ជំពាក់ចំពោះបរិក្ខារ ភិក្ខុដែលធ្លាប់តែពោលរំលឹកដាស់តឿនសម្លាញ់ ឱ្យឃើញទោសក្នុងការទៅគ្រប់



គ្រងផ្ទះ និង ប្រយោជន៍ធំធេងក្នុងការនៅបួសនោះ ក៏បែរត្រឡប់ជាពោលសរសើររឿយៗ អំពីអានិសង្សនៃការគ្រប់គ្រងផ្ទះ និង ទោសនៃការនៅបួសទៅវិញ ដូចជាបានពោលថា ការមានផ្ទះសម្បែង តែងបានសប្បាយជាមួយប្រពន្ធកូន និយាយលេងពីនេះពីនោះ បរិភោគកាមគុណ ទ្រព្យសម្បត្តិ ស៊ីចាយតាមសប្បាយ ចង់ធ្វើបុណ្យទានអ្វីៗក៏បាន មិនមែនដូចជានៅបួស ខ្វះនេះខ្វះនោះ គ្មានអ្វីសប្បាយសោះ រវល់តែកាន់អម្បែងដីដើរសុំគេរាល់តែថ្ងៃ ។ល។ លោកបានស្តាប់ឮយ៉ាងនេះ ក៏អផ្សុកចង់សឹកម្តងទៀត ប៉ុន្តែលោកបានគិតផងដែរថា ហេតុដូចម្តេចហ្ន៎ បានជាភិក្ខុសម្លាញ់ពោលមិនដូចមុន មានការផ្ទុយគ្នាស្រឡះយ៉ាងនេះ ក៏ភ្ញាក់ខ្លួនព្រើត ព្រោះដឹងថា ភិក្ខុជាសម្លាញ់ចង់បានបរិក្ខាររបស់ខ្លួនទើបពោលដូច្នេះ លោកពិចារណាឃើញទោសរបស់លោភៈ គឺថាលោភៈនេះនាំឱ្យធ្វើកម្មអាក្រក់ ជាផ្លូវទៅកាន់អបាយភូមិ លោកតក់ស្លុតចំពោះកិលេសដែលមានក្នុងសន្តាន ព្រោះមិនទាន់បានលះ លោកក៏ពិចារណាឃើញគុណនៃត្រៃសិក្ខា ដែលអាចប្រហារនូវកិលេស

បាន ដូច្នេះ លោកក៏ពេញព្រះទ័យដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងភេទជាអ្នកបួស ដោយមិនបានសឹកទៅគ្រប់គ្រងផ្ទះឡើយ ចំណែកភិក្ខុដែលបានពោលដោយលោភចិត្ត ជាប់ជំពាក់នឹងបរិក្ខារបន្តិចបន្តួច ហ៊ានពោលពាក្យសម្តីដើម្បីឱ្យភិក្ខុជាសម្លាញ់កើតការអផ្សុកក្នុងផ្នួសនោះ បានមកជាសប្បទាសត្ថេរក្នុងសាសនានេះឯង ។

ជោតិកសេដ្ឋីក្នុងសម័យពុទ្ធកាល មានសេចក្តីសង្វេគចំពោះវដ្តៈ ហើយបួសបានសម្រេចជាព្រះអរហន្ត ដោយបានប្រារព្ធទៅលើលោភៈរបស់ព្រះបាទអជាតសត្តុវេទេហីបុត្ត ។ ក្នុងកាលនោះព្រះរាជាបានសេពគប់ជាមួយភិក្ខុទេវទត្ត បានធ្វើឃាតព្រះបាទពិម្ពិសារជាបិតាបង្កើត គ្រប់គ្រងនូវរាជសម្បត្តិរួចហើយលើកទ័ពមករឹបអូសដណ្តើមសម្បត្តិជោតិកសេដ្ឋីទៀត ការដណ្តើមនោះពុំបានសម្រេចឡើយ ព្រោះជោតិកសេដ្ឋី បានកសាងនូវបុណ្យពិសេសមួយ ជាមួយព្រះសម្មាសម្ពុទ្ធវិបស្សី ដោយអំណាចនៃបុណ្យនោះ ចោរមិនអាចលួចប្លន់សម្បត្តិរបស់គាត់បានឡើយ ។ ព្រោះប្រារព្ធចំពោះអំពើលោភលន់របស់



ព្រះបាទអជាតសត្តុ លោកសេដ្ឋីមានឧបនិស្ស័យបួសជាភិក្ខុបានសម្រេចគុណធម៌ជាន់ខ្ពស់ កម្ចាត់លោភៈអស់អំពីសន្តាន ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានប្រារព្ធភិក្ខុមួយអង្គដែលចង់សឹក ទ្រង់ត្រាស់សំដែង **មុទុលក្ខណ-ជាតក** ។ ភិក្ខុមួយអង្គនោះលោកចង់សឹក ព្រោះលោកស្រឡាញ់ស្ត្រីក្នុងភូមិ ដោយសារលោកខ្វះការសង្រួមឥន្ទ្រិយនៅពេលលោកនិមន្តទៅបិណ្ឌបាត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងអំពីអំណាចនៃកិលេស ដោយសេចក្តីថា ចាំបាច់ពោលថ្វីចំពោះបុគ្គលទន់ខ្សោយយ៉ាងនេះ ថាកិលេសមិនបៀតបៀននោះ អម្បាលដូចមហាបុរស មានសមាបត្តិឫទ្ធិអភិញ្ញា អាចហោះទៅតាមអាកាសបាន ក៏គង់ត្រូវកិលេសបៀតបៀនឱ្យវង្វេងស្មារតីដែរ ព្រោះខ្វះការសង្រួមឥន្ទ្រិយនេះឯង ។ មហាបុរសគឺព្រះបរមពោធិសត្វ ក្នុងជាតិមុននោះ បានបួសជាតាបសសម្រេចសមាបត្តិ៨ អភិញ្ញាលោកិយ៥ កំពុងហោះទៅកាន់ប្រាសាទរបស់ព្រះរាជា នាក្រុងពារាណសី មិនបានប្រយ័ត្នក៏សម្លឹងមើលទៅក្នុងប្រាសាទតាមបង្អួច ។ ក្នុងកាលនោះ

ព្រះនាងមុទុលក្ខណាទេវី មហេសីរបស់ព្រះរាជា នៅក្នុងប្រាសាទចាំប្រគេនចង្ហាន់ដល់ព្រះតាបស ព្រះនាងឮសូរសំពត់សំបកឈើរលាស់ផ្លាប់ៗ ក៏ជ្រាបថា លោកម្ចាស់និមន្តមកហើយ នៅពេលស្ទុះក្រោកដោយប្រញាប់ សំពត់ដណ្តប់សាច់រអិល បានរបូតចាកព្រះកាយនៃព្រះនាង ព្រមពេលដែលព្រះតាបសសម្លឹងមើលទៅក្នុងប្រាសាទនោះឯង ។ អារម្មណ៍ដ៏ចំឡែកក៏បានប្រាកដដល់ភ្នែក ព្រះតាបសជាប់ភ្នែកភ្លេចស្មារតី សម្លឹងបន្តដកភ្នែកពុំរួចឡើយ កិលេសដែលស្ងប់រម្ងាប់យូរហើយ ក៏បានកម្រើក ប្រៀបដូចដើមឈើមានជ័រ ត្រូវកាំបិតចោះធ្លុះសំបកជ្រៅ ជ័រឈើក៏ហូរមកក្រៅយ៉ាងនោះឯង។ ព្រះតាបសត្រូវដាច់ឈាន ប្រៀបបាននឹងបក្សីដែលត្រូវព្រានព្រៃគ្រវែងឱ្យបាក់ស្លាប ពេលឈរទទួលចង្ហាន់ ក៏សម្លឹងមើលព្រះនាងពុំដាក់ភ្នែក កាន់យកនូវនិមិត្តនោះៗ ដោយសំគាល់ថា ស្អាតណាស់ៗ និមន្តដើរមកដល់អាស្រមវិញ លេបចង្ហាន់មិនចូលសោះ ព្រោះអំណាចរាគៈ ធ្វើឱ្យស្ទុះបំពង់ក ។ ព្រះតាបសបានអត់ចង្ហាន់អស់ ៧ថ្ងៃគត់ បន្ទាប់មកត្រូវបាន



ព្រះរាជា ស្តេចយាងមកសួរសុខទុក្ខ ព្រោះសេចក្តីស្រឡាញ់ធ្វើឱ្យហ៊ាននិយាយឥតខ្មាស បានពោលថ្វាយព្រះរាជាថា អាត្មាមិនមានរោគអ្វីទាំងអស់ ក្រៅអំពីរោគចិត្ត ព្រោះអាត្មាមានចិត្តប្រតិព័ទ្ធស្រឡាញ់មុទុលក្ខណាទេវី ។ ព្រះរាជាបានលើកមហេសីប្រគេនព្រះតាបស ក្នុងព្រះរាជបំណងដាស់តឿនស្មារតីនៃព្រះតាបស ដែលជាព្រះបរមពោធិសត្វ ព្រះរាជាបានប្រទានសញ្ញាសម្ងាត់ ឱ្យដល់ព្រះមហេសី ក្នុងន័យជួយដល់លោកម្ចាស់របស់យើង ដែលកំពុងវង្វេងស្មារតី ។ ព្រះតាបសបាននាំព្រះនាងមុទុលក្ខណាទេវីចុះអំពីប្រាសាទ កាលដែលព្រះទេវីសួររកផ្ទះជាទីអាស្រ័យ ព្រះតាបសមិនមានអ្វីទាំងអស់ ក៏ត្រឡប់មកសុំព្រះរាជា ស្តេចក៏បានប្រទានរោងចាស់បាក់បែកធ្លុះធ្លាយ ដែលពពួកជនយកធ្វើជាបង្គន់ ព្រះតាបសត្រូវជួសជុលរោងនោះ ត្រូវកើបលាមកចោល ធ្វើការសម្អាតសព្វគ្រប់ ត្រូវស្វែងរកគ្រែដេក រកកម្រាលគ្រែ នៅមានទៀតគឺព្រះទេវីបង្គាប់ឱ្យរកពាងទឹក រកប្រដាប់ដងទឹក ត្រូវដងទឹកដាក់ឱ្យពេញពាង ។ល។ អ្វីៗក៏សុទ្ធតែត្រូវទៅសុំអំពីព្រះរាជា

ទាំងអស់ ទីបំផុតនៅលើគ្រែទាំងពីរព្រះអង្គ ព្រះតាបសកំពុងសប្បាយព្រះទ័យ ដោយអាស្រ័យបាននៅរួមជាមួយស្រីដែលខ្លួនស្រឡាញ់ ព្រះនាងមុទុលក្ខណាទេវីពេលនោះ បានយកព្រហស្តទាំងពីរចាប់ស្មាព្រះតាបសពោធិសត្វ ទាញយកមុខព្រះតាបសមកទល់គ្នានឹងមុខព្រះនាង យ៉ាងកៀកជិត អង្រួនពញ្ញាក់ស្មារតី មានព្រះសវនីយ៍ដូច្នេះថា **លោកមិនដឹងខ្លួនថា ខ្លួនឯងជាសមណៈឬជាព្រាហ្មណ៍ទេឬ?** ព្រះបរមពោធិសត្វក្នុងពេលនោះ ក៏ត្រឡប់មាននូវស្មារតីឡើងវិញ ព្រោះតែលោភៈមួយពេលប៉ុណ្ណោះ ធ្វើឱ្យសេចក្តីទុក្ខសន្ធឹកសន្ធាប់ជាប់តាមមកជាមួយ ធ្វើឱ្យព្រះអង្គវង្វេងភ្លេចខ្លួន អស់កាលយូរដល់ម្លឹង ព្រះតាបសបានគិតឃើញថា តណ្ហានេះ កាលចម្រើនឡើងនោះ នឹងមិនឱ្យអាត្មាអញងើបក្បាលរួចអំពីអបាយភូមិទាំង៤ ឡើយ ។

ព្រះបរមពោធិសត្វ បានថ្វាយព្រះនាងទេវីឱ្យដល់ព្រះរាជាវិញ ហើយបានត្រាស់នឹងព្រះរាជាថា :

**កាលមុនដែលអាត្មាមិនទាន់បានព្រះនាង**



**មុទុលក្ខណា សេចក្តីប្រាថ្នាមានតែមួយ គឺប្រាថ្នាតែព្រះនាងមុទុលក្ខណាប៉ុណ្ណោះ គ្រាកាលដែលបានព្រះនាងហើយ ដែលព្រះនាងមានព្រះនេត្រល្អស្អាតអស្ចារ្យនោះ សេចក្តីប្រាថ្នាមួយមុន បានបង្កើតឱ្យមានសេចក្តីប្រាថ្នាផ្សេងៗ ក្នុងរបស់ច្រើនយ៉ាងទៀត ។**

ព្រះតាបសបានញុំាងឈានឱ្យកើតឡើងវិញ ហើយបាននិមន្តទៅកាន់ព្រៃហិមពាន្ត តាមផ្លូវអាកាស លែងមកកាន់ដែនដីជាទីនៅរបស់ពួកមនុស្សទៀតហើយ លុះអស់ជីវិតក៏ទៅកាន់ព្រហ្មលោក ។

ភិក្ខុដែលចង់សឹក បានស្តាប់មុទុលក្ខណជាតក ព្រមដោយការប្រកាសសច្ចធម៌របស់ព្រះសម្មាសម្ពុទ្ធ ក៏បានសម្រេចព្រះអរហត្តផល ។ ព្រះអង្គទ្រង់ប្រជុំជាតក ព្រះរាជាក្នុងកាលនោះ បានមកជាព្រះអានន្ទក្នុងកាលនេះ មុទុលក្ខណាទេវីបានមកជាឧប្បលវណ្ណា ចំណែកព្រះតាបសបានមកជាយើងតថាគត ។

αភ្លើងមិនឆ្អែតនឹងអុស សមុទ្រមិនឆ្អែតនឹងទឹកយ៉ាងណា សេចក្តីប្រាថ្នាដោយតណ្ហាក៏មិនឆ្អែតនឹងសម្បត្តិក្នុងលោកដែរ គួរហៅថាភ្លើងតណ្ហា ឬសមុទ្រតណ្ហា ជាការត្រឹមត្រូវណាស់ ។

αតណ្ហាជាការស្រេកឃ្លានដ៏អាក្រក់ រឹតតែស៊ី រឹតតែឃ្លាន រឹតតែបាន រឹតតែមិនគ្រប់ ។ ក្រពះតណ្ហាធំណាស់ ទោះបីសម្បត្តិក្នុងភពទាំងបី ( កាមភព . រូបភព . អរូបភព) ក៏មិនអាចដាក់ឱ្យពេញក្នុងក្រពះនេះបានឡើយ ព្រោះហេតុដូច្នេះហើយ បានជាមនុស្សយើងគ្រប់គ្នា ដែលមិនមានការសង្រួមនោះ ចេះតែដឹងខ្លួនឯងថា ខ្វះនេះខ្វះនោះជានិច្ច ។

αមនុស្សភាគច្រើនណាស់ ឱ្យតម្លៃតណ្ហា គិតថាតណ្ហាធ្វើឱ្យខ្លួនឯងថ្លៃថ្នូរ ចំរុងចំរើនទៅដោយលាភយស មុខមាត់ ។ល។ ហើយមិនឱ្យតម្លៃដល់សេចក្តីសន្តោសទេ ព្រោះគិតថាសេចក្តីសន្តោសមិននាំឱ្យមានការរីកចំរើនឡើយ មានតែនាំឱ្យក្ររហេមរហាម នាំឱ្យខ្លួនឯងជាមនុស្សអាប់ឱនទន់ទាប ។ ព្រះពុទ្ធសាសនាមិនបានឱ្យតម្លៃការក្រីក្រ ការខ្វះខាត ការ



លំបាករហេមរហាមនោះទេ ប៉ុន្តែ **ព្រះពុទ្ធសាសនាឱ្យតម្លៃចំពោះសេចក្តីសន្តោស** មនុស្សយើងមិនសូវនិយមពោលសរសើរដល់បុគ្គលណា ដែលមានសេចក្តីសន្តោសឡើយ ពោលសរសើរគ្នាតែអំពីលាភយស បុណ្យស័ក្តិ ទ្រព្យសម្បត្តិ រហូតដល់ថ្នាក់វង្វេងច្រឡំថា ខ្លឹមសារនៃជីវិត វាស្ថិតនៅលើបុណ្យស័ក្តិទ្រព្យសម្បត្តិទាំងនោះឯង តាមពិត លាភយស បុណ្យស័ក្តិ ទ្រព្យសម្បត្តិ ដែលក្នុងលោកនេះ គេចាត់ទុកថា ជារបស់សំខាន់នោះ ក៏ព្រោះដោយសារពាក្យសរសើរការបញ្ជោរគ្នាទៅវិញទៅមក រវាងមនុស្សដែលមានតណ្ហាក្រាស់ដូចគ្នាតែប៉ុណ្ណោះ ពោលគឺសំខាន់ខ្លឹមសារដោយសន្មតិ ។

αពិភពលោកសព្វថ្ងៃ មានការរីកចម្រើនទៅដោយសម្ភារៈ របស់ប្រើប្រាស់ទំនើបៗ ទាំងនេះវាជាលទ្ធផលនៃពាក្យសរសើរ ជាលទ្ធផលនៃការនិយមប្រើ របស់មនុស្សទាំងឡាយដែលក្រាស់ទៅដោយកិលេស ដែលរបស់ទាំងអស់នោះយកមកដោះស្រាយ ចាស់ ឈឺ ស្លាប់ ពុំបានឡើយ ។

αមនុស្សយើងវង្វេងនឹងពាក្យសរសើររបស់អ្នកដទៃ

ស្ពានថារបស់អ្វីៗក្នុងលោកនេះ វាល្អពិតមែន ។

៥មនុស្សយើងមានកំហុសមួយយ៉ាងធំ គឺខុសនៅត្រង់និយមសរសើរផ្ដេសផ្ដាស ព្រោះការវង្វេងខ្លួនឯង ធ្វើឱ្យអ្នកដទៃវង្វេងតាម ។

**សេចក្ដីក្សេមក្សាន្តបានប្រាកដក្នុងចិត្ត ព្រោះគំនិតយល់ត្រូវ** សេចក្ដីក្សេមក្សាន្ត មិនបានស្ថិតនៅក្នុងរបស់ខាងក្រៅ ឬទីកន្លែងផ្សេងៗឡើយ តាមពិតគឺវាស្ថិតនៅក្នុងចិត្ត ព្រោះគំនិតយល់ត្រូវ ។ ការបន្ធូរបន្ថយនូវលោភៈក្នុងសន្ដាន ប្រៀបបាននឹងដកព្រួញចេញអំពីចិត្ត ព្រមដោយការព្យាបាលនូវរបួសរបស់ចិត្តនោះ ដោយគំនិតយល់ត្រូវហ្នឹងឯង ។

មនុស្សយើងមិនត្រូវលោភលន់ពន់ប្រមាណទេ ព្រោះបានកើតមកជាមនុស្សទៅហើយ វាមិនមានសម្បត្តិអ្វីណាឱ្យប្រសើរជាងកំណើតមនុស្សនេះទៀតឡើយ បើយើងមិនបានកើតមកជាមនុស្សផងទេនោះ តើសម្បត្តិក្នុងស្រុកមនុស្សនេះសំខាន់សម្រាប់យើងយ៉ាងដូចម្ដេចទៅ ។ ដូច្នេះ មិនត្រូវ



ព្រោះតែមាសប្រាក់បុណ្យស័ក្តិកាមគុណ ធ្វើការបោះបង់ខ្លួនឯងចោលនោះទេ ពាក្យថាបោះបង់ខ្លួនឯងចោល គឺការមិនរក្សាខ្លួនដោយស្មារតី បណ្ដែតបណ្ដោយឱ្យកិលេសដឹកនាំអូសទាញ ទៅប្រព្រឹត្តអំពើឥតប្រយោជន៍ អំពើសៅហ្មងគ្រប់បែបយ៉ាង ។ ដើមឈើដែលមានឫសមិនល្អ ព្រោះនៅមាត់ច្រាំងត្រូវទឹកជំនន់ច្រោះ ព្រមដោយមែកច្រើនស្លឹកច្រើន និង ផ្លែផ្កាច្រើនផងនោះ វាងាយដួលរលំណាស់ ដោយគ្រាន់តែខ្យល់ល្មមៗប៉ុណ្ណោះ យ៉ាងណាមិញ មនុស្សយើងក៏ដូចដើមឈើមួយដើមដែរ គល់ដើមប្រៀបបានកំណើតមនុស្ស មែកស្លឹកផ្លែផ្កាច្រើននោះ ក៏ដូចជាលាភយសកេរ្តិ៍ឈ្មោះទ្រព្យសម្បត្តិកាមគុណ ចំណែកឫសមិនល្អ ឈ្មោះថាដើមឈើទុព្វល គឺប្រៀបដល់មនុស្សទន់ខ្សោយនូវស្មារតី សម្លឹងឃើញអ្វីៗក្នុងលោក ថាសុទ្ធតែល្អលេង មិនមានការសង្រួមឥន្ទ្រិយ ត្រូវបានកិលេសមារញាំញីខ្ទេចខ្ទីស្មារតីអស់ ប្រៀបដូចទឹកជំនន់ច្រោះឫសនៃដើមឈើ មិនមានជំហរមាំទាំព្រោះអស់ដីជាគ្រឿងទប់ ម្យ៉ាងទៀតក៏គួរសិក្សាផងដែរ ត្រង់ដែលដើមឈើនោះបានដុះនៅចំកន្លែង

ត្រូវអន្តរាយ គឺមុខទឹកច្រោះដី ដែលប្រៀបបីដូចជីវិតមនុស្ស រស់ក្នុងចំណោមជនពាល ឬប្រទេសមិនសមគួរ ថែមទាំងការពេញចិត្តក្នុងធមិអសប្បុរសទៀតផង ។ ឯចំណែកខ្យល់ដែលសម្រាប់បក់បោកផ្តួលរំលំនូវដើមឈើទុព្វលនោះ ក៏គឺជាឈ្មោះរបស់កិលេស ដែលជាបក្សពួកសត្រូវជាមួយទឹកជំនន់ គ្រាន់តែទឹកជំនន់ជាឈ្មោះនៃបរិយុដ្ឋានកិលេស គឺកិលេសរឹតរុំសន្តានចិត្តធ្វើឱ្យខ្សោយស្មារតី ឯខ្យល់វិញជាឈ្មោះនៃវីតិក្កមកិលេស គឺកិលេសគ្រោតគ្រាត នាំឱ្យប្រព្រឹត្តកន្លងច្បាប់ ល្មើសដោយកាយវាចា ត្រង់សេចក្តីនេះ បើភិក្ខុត្រូវអាបត្តិតូច ស្រាលកណ្តាល រហូតដល់បារាជិក ឬ លាសិក្ខា បើគ្រហស្ថក៏ទ្រុស្តនឹងសីលរបស់ខ្លួន ឬក៏ជាមនុស្សអាងលាភអាងយសអាងកម្លាំងនេះនោះបៀតបៀនអ្នកដទៃ ទាំងអស់នេះ ព្រោះអាស្រ័យខ្យល់កិលេសគ្រោតគ្រាត ។

កើតមកជាមនុស្ស ត្រូវពឹងពាក់ស្មារតី អាស្រ័យសតិសម្បជញ្ញៈជាគ្រឿងរក្សាខ្លួន ពោលគឺការរក្សាចិត្តឱ្យដូចជាគេបិទនូវទ្វារនគរ គេបិទទ្វារនគរការពារខ្មាំងសត្រូវ យ៉ាងណា



ប្រាជ្ញាស្មារតីជាគ្រឿងរក្សាចិត្ត បិទទ្វារ៦ មានទ្វារភ្នែកជាដើមការពារនូវអភិជ្ឈា និង ទោមនស្សក៏យ៉ាងនោះដែរ ។ ការសង្រួមទ្វាររារាំងកិលេស ជាការងារសំខាន់ណាស់ក្នុងព្រះពុទ្ធសាសនា មិនថាតែបព្វជិត ឬ គ្រហស្ថឡើយ គ្រប់គ្នាទាំងអស់ចង់បានសន្តិភាពក្នុងចិត្ត ត្រូវចេះការពាររក្សាចិត្ត ដូចបិទទ្វារផ្ទះការពារចោរអ៊ីចឹងឯង ។ រូបកាយដូចនគរមានទ្វារ៦ គឺទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ និង ទ្វារចិត្ត សតិសំវរៈការសង្រួមដោយស្មារតី ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា ដូចជាអ្នកយាមទ្វារនគរដ៏ប្រសើរ បើគិតទៅនឹងរឿងដើមឈើ សតិសម្បជញ្ញៈប្រៀបដូចជាឫស សម្រាប់ទប់ដើមកុំឱ្យរលំ ។

កំណើតមនុស្សក្រណាស់ នេះជាពាក្យរបស់ព្រះសម្មាសម្ពុទ្ធ ចង់អ្នកណាបដិសេធក៏ដោយចុះ ប៉ុន្តែសូមឱ្យមនុស្សគ្រប់គ្នាទទួលស្គាល់នូវចំណុចមួយ គឺខ្លួនឯងមិនអាចទាមទារនូវអាយុជីវិតដែលកំពុងតែរស់សព្វថ្ងៃ អំពីអ្វីក្នុងលោកនេះបានឡើយ ទាំងដែលបានរស់មកហើយ ទាំងដែលនឹងត្រូវរស់

បន្តទៅទៀតនោះ វាមិនមែនជារបស់ដែលមនុស្សគ្រប់គ្នាទាមទារបានមកនោះទេ តាមពិតអាយុជីវិត វាជាលទ្ធផលនៃវត្ថុអាថិកំបាំង ព្រោះវាកំបាំងពេកយ៉ាងនេះ ទើបមានមនុស្សច្រើនណាស់ នៅពាសពេញផែនដី មានសេចក្តីយល់ថា កំណើតមនុស្សព្រមទាំងសព្វសត្វទាំងអស់ កើតមកអំពីនេះ អំពីនោះ ផ្សេងអំពីការត្រាស់ដឹង និង ត្រាស់សម្តែងរបស់ព្រះពុទ្ធជាអង្គម្ចាស់ មានខ្លះក៏គិតយល់ថា ត្រឹមតែម៉ែឪប៉ុណ្ណោះ ជាអ្នកបង្កើត លុះដល់ពេលស្លាប់ក៏បញ្ចប់ជីវិតប៉ុណ្ណឹងទៅ ។

ទស្សនះគំនិតគិតយល់មានច្រើនយ៉ាងណាស់ ប៉ុន្តែការពិតនៃជីវិតសត្វលោក ត្រូវបានដឹងច្បាស់ដោយការចម្រើនបញ្ញា បើមិនមែនទាល់តែបញ្ញាទេ តើបញ្ញាវិសេសត្រង់ណាទៅ ។ បញ្ញាជាសភាវៈសម្រាប់ដឹងរបស់អាថិកំបាំងក្នុងជីវិត ព្រមដោយការកម្ចាត់បង់នូវកិលេស ឱ្យអស់អំពីសន្តានចិត្តផង ធ្វើជាមនុស្សត្រូវតែដឹងឱ្យច្បាស់ថា ខ្លួនមានកិលេស ព្រោះខ្លួនមិនទាន់ចេះ គឺនៅល្ងង់ពិតប្រាកដណាស់ បើបានដឹងដូច្នេះទៅ វាមិនសូវមានមានះពេក ហើយវាមិនសូវក្អេងក្អាងផងដែរ



ថែមទាំងចេះរកឧបាយសម្រាប់ឱ្យបញ្ញាចម្រើនពិតៗទៀតផង។

លក្ខណៈរបស់បញ្ញា គឺការដឹងច្បាស់នូវសភាវធម៌ពិតក្នុងជីវិត ហើយមានកិច្ចកម្ចាត់នូវភាពងងឹត បានដល់សេចក្តីល្ងង់ ព្រមទាំងកិលេសផ្សេងៗទៀត ឯការចេះដឹងក្នុងលោក បង្កើតនូវសម្ភារៈសព្វគ្រប់ ឆ្លាតឈ្លាសក្នុងភាសាបរទេសជាដើម វាជាតួ **មនសិការៈ** ដោយឡែកផ្សេងអំពីបញ្ញា មនសិការៈគឺការធ្វើទុកក្នុងចិត្ត ប្រកបជាមួយបញ្ញាក៏មាន មិនប្រកបជាមួយបញ្ញាក៏មានដែរ ប៉ុន្តែចំណែកបញ្ញាវិញ តែងប្រកបជាមួយយោនិសោមនសិការៈ គឺការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនងជានិច្ច ។

បញ្ញាមានច្រើនយ៉ាងណាស់ តែទោះជាយ៉ាងណា ក៏មិនប្រកបជាមួយលោភៈ ឬ ទោសៈ មោហៈ ឡើយ ឥឡូវក្នុងនាទីនេះ ខ្ញុំព្រះករុណាខ្ញុំបាទ សូមលើកយកនូវបញ្ញា ដែលជាសម្មាទិដ្ឋិការយល់ត្រូវ ត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះមកបញ្ជាក់ក្នុងចំណុចធម៌ដែលថា «សេចក្តីក្សេមក្សាន្តបានប្រាកដក្នុងចិត្ត ព្រោះគំនិតយល់ត្រូវ»ជាខ្លឹមសារនៃធម៌សន្តោសកំពុងសម្តែង។

ក្នុងកាយមនុស្សយើងម្នាក់ៗ វាមានការប្រជុំដោយរូបធម៌ច្រើនមុខ មាន ដី ទឹក ភ្លើង ខ្យល់ មានពណ៌សម្បុរ មានសម្លេង មានក្លិន មានរស មានបសាទរូប៥ និងមានហទយវត្ថុ ។ល។ ចំពោះរូបធម៌មួយមុខៗ គ្រាន់តែជាធាតុ គឺពុំមែនជាតួសត្វមនុស្សស្រីប្រុសឡើយ ក្នុងការប្រព្រឹត្តទៅនៃធាតុទាំងអស់នេះ វាជាប់ទាក់ទងអាស្រ័យជាមួយបច្ច័យ គឺធាតុដទៃផ្សេងទៀតជាអ្នកតាក់តែងបង្កើតឡើង ដូច្នេះធាតុមួយវាគ្រាន់តែជាផលរបស់ធាតុមួយផ្សេងទៀតប៉ុណ្ណោះ ក្នុងសេចក្តីនេះវាក៏ជាបច្ច័យទៅវិញទៅមកផងដែរ ។ មិនចំពោះតែរវាងរូបធាតុ និង រូបធាតុប៉ុណ្ណឹងទេ គឺរូបធាតុក្នុងកាយនេះ វាត្រូវជាប់ទាក់ទងអាស្រ័យជាមួយបច្ច័យ ដែលជាអរូបធាតុ ឬនាមធាតុទៀតផង ការចម្រើននៃរូបកាយ ព្រោះអាស្រ័យបាយ និងអាហារផ្សេងៗ ក៏ដោយសារនៅមានវិញ្ញាណជាបច្ច័យ និងឧបត្ថម្ភគ្រប់គ្រងហ្នឹងឯង ។ ឯចំណែកចិត្តវិញ្ញាណរួមដោយអរូបធាតុទាំងអស់នោះ ក៏ព្រោះអាស្រ័យរូបកាយនេះ ដែលមានវត្ថុរូប ជាទីកើតឡើងផងដែរ ពុំមែនកើតអំពីទីដទៃឡើយ



ប្រភពនៃកំណើតនៅមានទៀត ប៉ុន្តែដើម្បីឱ្យបានជាក់ច្បាស់ ថាតើវាពិតជាអ្វីនោះ គឺជាកិច្ចការនៃបញ្ញា ដែលត្រូវកម្ចាត់នូវអវិជ្ជាជាបណ្តើរៗ ទីបំផុតនៃកិរិតមួយរបស់បញ្ញាការភ្លឺស្វាងជាក់ច្បាស់ក៏បានប្រាកដឡើង ឃើញថា ការតក់ស្លុតភ័យខ្លាចក្នុងជីវិត និងការប្រាថ្នាផ្សេងៗ រមែងកើតអំពីអវិជ្ជា។

អវិជ្ជាមានលក្ខណៈមិនដឹង មិនឃើញ ជាធម៌បិទបាំងធ្វើឱ្យជីវិតមានអាថ៌កំបាំងរកគិតមិនយល់ រកថាមិនត្រូវ មានតួនាទីធ្វើឱ្យអរូបធម៌ដែលប្រកបជាមួយទាំងអស់ មានចិត្តជាដើមវង្វេង អវិជ្ជាក្នុងទីនេះគឺការមិនដឹងសេចក្តីពិតនៃរូប-ធាតុ និង អរូបធាតុក្នុងជីវិតនេះឯង ។ ដែលបានស្គាល់មុខអវិជ្ជា ក៏ព្រោះការតាមដានរបស់បញ្ញា ហើយបានដឹងថា ជាការមិនគួរសោះ ដែលក្នុងរូបធាតុ និង ក្នុងអរូបធាតុ មានសេចក្តីតក់ស្លុតកើតឡើង ចេះភ័យ ចេះខ្លាចផ្សេងៗ ព្រោះរកតែខ្លួនឯងមិនទាំងមានផង នេះដោយសារបច្ច័យទើបកើតឡើងទេតើ បើមិនអាស្រ័យបច្ច័យ ខ្លួនឯងជារូបនិងអរូបមាននៅទីណា ព្រោះហេតុតែបញ្ញាបានស្រាវជ្រាវយ៉ាងនេះឯង

ទើបអាចរកឃើញប្រភពនៃការប្រាថ្នា ការតក់ស្លុតក្នុងជីវិតនៃសត្វលោក ឯប្រភពនោះក៏គឺការមិនដឹងរូបធាតុ និងអរូបធាតុតាមពិត ការមិនដឹងនេះក៏ជាធាតុមួយដែរ ពុំមែនសត្វបុគ្គលឡើយ ។

ព្រោះហេតុសេចក្តីប្រាថ្នា ការតក់ស្លុតក៏កើតមានសេចក្តីប្រកាន់ផ្សេងៗ មានការប្រកាន់ថាខ្លួនអញជាដើមក៏មានដែរ ព្រមជាមួយនឹងអំពើកម្មគគ្រឹកគគ្រេង ព្រោះអំណាចនៃការ ប្រកាន់ហួងហែងនោះៗឯង បញ្ញាបានឃើញការកើតឡើងនៃអភិសង្ខារគឺកម្ម ព្រោះអវិជ្ជាជាបច្ច័យ ហើយក៏ដឹងផងដែរថា ការអស់ទៅនៃអភិសង្ខារគឺកម្ម ព្រោះអស់អវិជ្ជា បញ្ញាបានឃើញទៀតថា អវិជ្ជាពិតជាអាចអស់បាន កាលណាមានវិជ្ជាចម្រើនឡើងនោះ ។

បញ្ញាបានដឹងអំពីការកើតឡើងនៃអភិសង្ខារគឺកម្ម ព្រោះអវិជ្ជា ក៏មាននូវ**កម្មសទ្ធា** គឺការជឿកម្មច្បាស់លាស់ពិតប្រាកដ ព្រោះឧបនិស្ស័យនៃបញ្ញា កាលដែលមាននូវកម្មសទ្ធាហើយ **វិបាកសទ្ធា** ក៏បានដល់ព្រម ជឿផលកម្ម



គ្មានងាករេ ព្រោះជាសទ្ធាប្រកបដោយបញ្ញា ។ ការអប់រំបញ្ញាជាការចម្រើនប្រយោជន៍ដ៏ក្រៃលែងណាស់ បញ្ញាបានដឹងច្បាស់ថា បដិសន្ធិក្តី សុខទុក្ខមានក្រក្តី អាស្រ័យកម្មជាប្រភពនៃកំណើត កម្មជាអ្នកផ្តល់ផល ជាអ្នកចែកមរតក សត្វលោកជាទាយាទរបស់កម្ម គឺជាអ្នកទទួលនូវមរតកអំពីកម្ម បើពោលដោយបរមត្ថ កម្មជាបច្ច័យនៃបដិសន្ធិនិងកម្មជរូប ព្រមដោយសុខទុក្ខផ្លូវកាយប្រចាំថ្ងៃ ។ បញ្ញាបានឃើញកម្មជាប្រភពនៃកំណើតរបស់សត្វលោកទាំងឡាយ បើមិនមានកម្មអំពីជាតិមុនទេ មនុស្សលោកមិនអាចកើតក្នុងជាតិនេះបានឡើយ ព្រោះដែលឈ្មោះថាមនុស្ស ជាការសន្មតរូបធាតុ និងអរូបធាតុរួមគ្នា ដែលធាតុទាំងនេះសុទ្ធតែកើតអំពីបច្ច័យហើយក៏មិនមែនជាសត្វអ្វីដែរ សត្វឬមនុស្សជាឈ្មោះដាក់សន្មតឱ្យប៉ុណ្ណោះ ដូច្នេះមិច្ឆាទិដ្ឋិដែលយល់ឃើញថា មានបុគ្គលនេះ បុគ្គលនោះជាអ្នកសាងលោក ឬថាសត្វលោកកើតឡើងដោយឯងៗ ក៏ត្រូវលះបង់ដោយបញ្ញា ការសង្ស័យក្នុងខន្ធអតីតៈ អនាគត បច្ចុប្បន្ន ក៏មិនមានដែរ ។

កំណើតមនុស្សមានសេចក្ដីប្រសើរជាងកំណើតសត្វក្នុង អបាយភូមិ៤ កំណើតមនុស្សកើតអំពីបុណ្យ គឺអំពើល្អ កើតមកហើយមានជីវិតរស់បានប៉ុនណាៗ ក៏ព្រោះមានបុណ្យជាបច្ច័យ មានបាននូវសម្បត្តិតិចច្រើនយ៉ាងណាក្ដី គ្មានអ្វីដែលគួរឱ្យសង្ស័យឡើយ ព្រោះថា បើជីវិតនេះយើងមិនអាចទាមទារបានផង តើយើងអាចទាមទារអ្វីបានទៅ បើចេះទាមទារអាយុជីវិតបាន វាមិនមានអ្នកស្លាប់ទេ ហើយក៏មិនមានសត្វក្នុងអបាយភូមិដែរ គេទាំងអស់គង់នឹងទាមទារសុំយកកំណើតមនុស្សឬទេវតា ហើយសុំឱ្យមានជីវិតរស់នៅជារៀងរហូត ។

ចាស់ ឈឺ ស្លាប់ ព្រាត់ប្រាស ទុក្ខសោក រោគភ័យសព្វគ្រប់ វាជាវត្ថុបំណងដែលសត្វលោកគ្រប់រូបចង់បានឬ? ពុំមែនទេ ។ ចុះកំណើតសត្វតិរច្ឆាន កំណើតមនុស្សក្រីក្រលំបាករហេមរហាម ខ្លួនគេជាអ្នកជ្រើសរើសយកឬ? ក៏ពុំមែនដែរ។ បើអីចឹង កំណើតមនុស្សក្នុងត្រកូលខ្ពង់ខ្ពស់ កើតក្នុងគំនរទ្រព្យសម្បត្តិសព្វគ្រប់នោះ គេជាអ្នកជ្រើសរើស ទាមទារបានទាំងដែលអត់បានធ្វើបុណ្យទុកក្នុងជាតិមុនផងឬ? អ្នកឆ្លើយត្រូវ



ចំពោះសំនួរនេះ គឺជាអ្នកមានគំនិតយល់ត្រូវ មិនច្រណែនចំពោះលាភយសរបស់អ្នកដទៃ, មានចិត្តទន់ភ្លន់ដោយព្រហ្មវិហារ មានធម៌សន្ដោស មានសេចក្ដីអនុគ្រោះ កាន់យកការងារប្រាសចាកទោស ដែលជាធម៌របស់សប្បុរសទុកដូចជាឆ័ត្រធំ បាំងការពារភ្លៀង ឬ ការពារកំដៅ ពោលគឺការងារប្រាសចាកទោស ជាការងាររក្សាចិត្ត គ្រប់គ្រងចិត្ត ធ្វើឱ្យចិត្តមានសេចក្ដីសុខក្សេម ។

គំនិតយល់ត្រូវ ពិតជានាំមកនូវប្រយោជន៍ដ៏ច្រើនយ៉ាងសម្រាប់ទំនុកបម្រុងចិត្ត ការពាររក្សាចិត្ត គំនិតយល់ត្រូវជាសម្បត្តិដ៏ថ្លៃថ្លា ជាអ្នកនាំផ្លូវចេញចាកទុក្ខ គំនិតយល់ត្រូវនាំឱ្យធ្វើការងារប្រាសចាកទោស ការងារប្រាសចាកទោស គឺការងារដែលប្រាសចាកកិលេសជាគ្រឿងក្ដៅ សូមឱ្យមនុស្សលោកគ្រប់គ្នា ប្រឹងប្រែងស្វែងរកសេចក្ដីសុខ ក្នុងចិត្តរបស់ខ្លួនឯងតាមរយៈនៃការសិក្សាព្រះធម៌ ។

**ចិត្តដែលមានសេចក្ដីសន្ដោស ជាចិត្តមិនមានរោគ មិនមានទោស ជាចិត្តឆ្លាតមាន**

**ផលជាសុខ** ជាធម្មតារូបកាយមិនមានរោគ ជាលាភដ៏ល្អ នាំឱ្យចម្រើនការងារផ្សេងៗ មិនលំបាកឈឺ មិនខាតប្រាក់ ។ល។ ប៉ុន្តែការលោភលន់ពន់ប្រមាណ ជារោគរបស់ចិត្តដ៏ក្រៃលែង ចិត្តឈឺ ចិត្តលំបាក ចិត្តក្តៅក្រហាយ ចិត្តមិនស្ងប់ ចិត្តស្រេកឃ្លាន ចិត្តស្គមបុណ្យ ចិត្តញ័រញាក់ ញ័រចំប្រប់ដូចត្រីក្នុងទីដែលមានទឹកតិច ។ ដូច្នេះ នៅក្នុងតួនាទីរបស់មនុស្សម្នាក់ៗ ដែលចាំបាច់ត្រូវកសាងខ្លួនឱ្យបានល្អនោះ ត្រូវស្វែងរកនូវឱសថ គឺសេចក្តីសន្តោស ជាថ្នាំរម្ងាប់រោគលោភៈ រោគតណ្ហា ជាពិសេសត្រូវសិក្សាព្រះធម៌ ស្តាប់ព្រះធម៌ឱ្យបានរឿយៗ ឱ្យទាល់តែបានយល់ត្រូវថា តណ្ហាការលោភលន់ជារោគពិតៗ ព្រោះបើមិនបានដឹងថាខ្លួនឯងមានរោគពិតទេនោះ ប្រាកដជាព្រងើយជាមួយថ្នាំ គឺមិនផ្សំថ្នាំបរិភោគឡើយ ។

ចិត្តដែលមានសេចក្តីសន្តោស ជាចិត្តប្រាសចាកទោស ចិត្តក្សេមក្សាន្ត និង មានសេរីភាព ប្រៀបដូចជារូបកាយដែលស្រស់ស្អាត ប្រាសចាកទោសទាំងពួង មានសរីរាវយវៈគ្រប់គ្រាន់ មិនពិការខ្វាក់ខ្វិនថ្លង់គដូច្នោះឯង ។ ការស្រស់ស្អាតនៃ



រូបកាយ ព្រមដោយការមានសេរីភាព គ្មានទោសដែលត្រូវចោទប្រកាន់ចាប់ចង ដាក់ខ្នោះដាក់ឃ្នាងអ្វីទាំងអស់នោះ គឺជាលំអនៃរូបកាយ ជាកាយសម្បទា ដែលអ្នកផងទាំងពួងក្នុងលោកនិយមចូលចិត្ត ក្នុងរឿងនេះយ៉ាងណា ការដែលចិត្តមិនពិការស្មារតី មានសេចក្តីសន្តោស ចេះល្មមក្នុងរបស់ប្រើប្រាស់តាមមានតាមបាន ប្រើប្រាស់ចំពោះតែរបស់ដែលបានមកដោយអំពើសុចរិតយុត្តិធម៌ ជាចិត្តប្រាសចាកទោស មិនជាទាសៈរបស់តណ្ហា គ្មានការចងរួបរឹតអំពីកិលេស គឺជាចិត្តស្អាតចិត្តឥតសៅហ្មង ក៏យ៉ាងនោះដែរ ។

ចិត្តដែលមានសេចក្តីសន្តោស ជាចិត្តឆ្លាត ឈ្លាសវៃពូកែក្នុងការស្វែងរកសេចក្តីសុខ ការឆ្លាតក្នុងលោកដោយកិច្ចការនានា សិល្បវិទ្យាប្រមូលទ្រព្យធន មិនឆ្លាតដូចកុសលចិត្តដែលមានសេចក្តីសន្តោសឡើយ ។ សេចក្តីសន្តោសជាទ្រព្យដ៏ប្រសើររបស់ចិត្ត ធ្វើឱ្យចិត្តបានស្កប់ស្កល់ បានឆ្អែតបាត់ខ្វល់ចិត្តមានពន្លឺរស្មី ។ សម្បត្តិទ្រព្យក្នុងលោកនេះ ដើម្បីឱ្យគ្រប់គ្រាន់ ទាល់តែលែងចង់បាន ឈប់ត្រូវការ ហើយប្រឹងប្រែង

ស្តាប់ព្រះធម៌ អប់រំបញ្ញា បណ្តុះបណ្តាលនូវសេចក្តីសន្តោស បើមិនដូច្នេះទេ ជាមួយសម្បត្តិទ្រព្យ បុណ្យស័ក្តិ យសអំណាច មុខមាត់កេរ្តិ៍ឈ្មោះ សត្វលោកចេះតែខ្វះកន្លះជានិច្ច ជាទាសៈរបស់តណ្ហាតែរហូតហ្នឹងឯង ។

សត្វលោកមានការចង្អៀតចង្អល់ ខ្វាយខ្វល់ជ្រួលច្របល់ក្នុងចិត្ត ព្រោះគំនិតមិនឆ្លាត ចេះតែច្រឡំគិតថា គេឯណោះគ្រាន់បើជាងអញ ហើយក៏តូចចិត្តខ្លួនឯងទៅ គំនិតមិនឆ្លាតធ្វើបាបឱ្យតែខ្លួនឯង ។ មនុស្សយើងតាមពិត មិនត្រូវមើលងាយលាភយសរបស់ខ្លួនឯងឡើយ វាជាលទ្ធផលដែលខ្លួនខំប្រឹងព្យាយាមដាំដុះទុកមក ហើយក្នុងរឿងនេះ វាមិនមែនជាការប្រឡងប្រណាំងគ្នានោះទេ កុំយកជីវិតមកធ្វើជាល្បែងភ្នាល់ ត្រូវតម្កល់ជីវិតទុកជាទុនឱ្យបានល្អ បំពេញការងារដែលជាហេតុនាំមកនូវសេចក្តីសុខ ។

## កុំយកជីវិតមកធ្វើជាល្បែងភ្នាល់

ជីវិតមានតម្លៃដោយន័យច្រើនយ៉ាង ម្យ៉ាងព្រោះជីវិតមនុស្សយើងនេះ មានបុណ្យជាអ្នកតាក់តែង ទាំងឱ្យកើតមក ទាំង



ជួយឧបត្ថម្ភ ម្យ៉ាងទៀត មានតម្លៃព្រោះសេចក្តីស្រឡាញ់ហួងហែងរក្សាការពារ សុខចិត្តលះបង់សម្បត្តិទ្រព្យច្រើនៗ ដើម្បីរក្សាជីវិត និង ហ៊ានកាត់អវយវៈដៃឬជើងជាដើម ក្នុងប្រយោជន៍រក្សាជីវិតទៀតផង ក៏ប៉ុន្តែក្នុងរឿងតម្លៃនៃជីវិតនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា **ជីវិតនៃបុគ្គលណា ប្រកបដោយបញ្ញា ជីវិតនៃបុគ្គលនោះប្រសើរ** បុគ្គលមានបញ្ញាជាគ្រឿងអប់រំចិត្ត មានជីវិតរស់តែមួយថ្ងៃ ក៏ជាការប្រពៃ ព្រោះមួយថ្ងៃដែលមានបញ្ញា ឬសូម្បីតែមួយភ្លែតដែលមានបញ្ញានោះ អាចរំដោះគ្រោះឱ្យខ្លួនឯងបាន ពោលគឺញ៉ាំងចិត្តឱ្យរួចផុតចាកអាសវៈដោយប្រពៃពិត ឯចំណែកការរស់នៅអស់រយនៃឆ្នាំ នៃបុគ្គលដែលអប្បប្រាជ្ញា មិនជាការប្រសើរឡើយ ព្រោះបុគ្គលល្ងង់ខ្លៅ មានខ្លួនឯងជាសត្រូវ នាំមកនូវសេចក្តីទុក្ខឱ្យខ្លួនឯង ដ៏យ៉ាងក្រៃលែង។ បើជីវិតរស់នៅជាមួយនឹងបញ្ញា មានតម្លៃដ៏អស្ចារ្យយ៉ាងនេះ តើសមគួរដែរឬទេ ដែលទុកជីវិតនេះជាគ្រឿងភ្នាល់គ្នា ដោយការប្រៀបផ្ទឹម ប្រណាំងប្រជែងនោះ ។

ពាក្យថាទុកដាក់ជីវិតជាល្បែងភ្នាល់ បានដល់ការតម្កល់តម្កើងជីវិត ដោយការប្រកាន់មានះប្រៀបផ្ទឹមជាមួយនឹងអ្នកដទៃ រីករាយណាស់ ព្រោះបានដឹងច្បាស់ថា ខ្លួនឯងគ្រាន់បើជាងគេ ដោយលាភ ដោយយស ដោយកេរ្តិ៍ឈ្មោះ ឬដោយអ្វីៗដទៃផ្សេងទៀតនោះ ប្រៀបដូចជាការលេងបៀឈ្នះគេអ៊ីចឹងឯង ប៉ុន្តែក្រៃលែងសោកសៅ ដូចនៅក្នុងភ្លើងអ៊ីចឹងដែរ បើដឹងថាមានអ្នកដទៃជាដៃគូប្រកួត គ្រាន់បើជាងខ្លួនទៅវិញនោះ នេះឯងដែលឈ្មោះថា យកជីវិតជាល្បែងលេង ។

ល្បែងស៊ីសងចាញ់ឈ្នះដោយប្រាក់ ចំណែកល្បែងជីវិតចាញ់ឈ្នះដោយចិត្ត សោមនស្សឬទោមនស្សតាមតែគំនិតសារម្ភៈ ប្រែថាប្រណាំងវាសនា ។

ជីវិតសែនថោកទាបបំផុត បើប្រព្រឹត្តទៅជាមួយនឹងការធ្វើបាប គឺបាបកម្មធ្វើឱ្យជីវិតមានការសៅហ្មង ។ សេចក្តីនេះគួរតែពិចារណា ព្រោះគ្រប់គ្នាស្រឡាញ់ជីវិត គ្រប់គ្នាមិនចង់ស្លាប់ឡើយ ប៉ុន្តែទោះជាមហាសេដ្ឋីមានសម្បត្តិច្រើនប៉ុនណាក៏ដោយ ក៏មិនអាចយកទៅដូរអាយុជីវិត ដើម្បីឱ្យនៅរស់បន្ត



ទៀតបានដែរ តែដល់ពេលស្លាប់គឺវាស្លាប់ហើយ ព្រោះជីវិតមានតម្លៃជាងប្រាក់ បើជីវិតហ្នឹងមានតម្លៃថ្លៃពេកពន់អ៊ីចឹង ហេតុអ្វីបានជាបោះគ្រវែងជីវិតខ្លួនឯង ឱ្យចូលក្នុងរណ្តៅលាមក គឺអំពើបាបទៅវិញ ។

ការទុកដាក់ជីវិតខ្លួនឯងជាល្បែងលេង មានច្រើនបែបច្រើនយ៉ាង រហូតដល់ល្បែងថោកទាបបំផុត ដោយការប្រកបជីវិតក្នុងអំពើបាប តាមពិតគួរបដិសណ្ឋារៈទទួលជីវិតឱ្យបានល្អ ព្រោះជីវិតមនុស្សយើងមកដោយសារបុណ្យ ជាអ្នកបញ្ជូនមក គឺជាភ្ញៀវកិត្តិយសដ៏ខ្ពង់ខ្ពស់ ដូច្នេះត្រូវធ្វើទាន រក្សាសីល ចម្រើនភាវនា ស្តាប់ធម៌អប់រំបញ្ញា ជាការជប់លៀងទទួលភ្ញៀវជីវិត ឱ្យបានសមរម្យជាទីបំផុត ទើបជីវិតសមជាអ្នកថ្លៃថ្នូរ ជាពិសេសគឺអប់រំសតិប្បដ្ឋាន-វិបស្សនា ឱ្យដល់កម្រិតស្មើនឹងសេចក្តីពិតរបស់ជីវិត ។ ជីវិតបាននាំយកមេរៀនសំខាន់ៗមកជាមួយ បុគ្គលឆ្លាតសិក្សាមេរៀនជីវិត បានចេះដឹងអំពីខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ និង បដិច្ចសមុប្បាទ រំលត់អវិជ្ជា សេចក្តីល្ងង់ខ្លៅ សម្រេចបាននូវរង្វាន់ពិសេស គឺបានធ្វើដំណើរ

ទៅទស្សនាព្រះនិព្វាន តាមផ្លូវដ៏ប្រសើរបំផុត ជាផ្លូវចេញចាក លោក ។ រឿងរបស់ជីវិតនិយាយបានច្រើនបែប ចង់និយាយ អំពីជីវិតជាខ្មាំងសត្រូវក៏បាន បើពោលទៅលើទុក្ខទោស ដែល ជីវិតបាននាំយកមកជាមួយ មានជរា ព្យាធិ និង មរណៈ ជា ដើម ប៉ុន្តែក្នុងវគ្គដែលសំដែងអំពីតម្លៃនៃជីវិតនេះ សូមឱ្យបាន ជ្រាបថា ជីវិតមនុស្សជាទូតរបស់បុណ្យ អ្នកមានអរិយទ្រព្យ អាចធ្វើលិខិតឆ្លងដែនគឺមគ្គញ្ញាណ ទៅកាន់ព្រះនិព្វានបាន ។

ជាការសរុបន័យក្នុងសេចក្តីដែលថា កុំទុកជីវិតជាល្បែង ភ្នាល់គ្នានេះ គឺជីវិតមនុស្សជារបស់ក្រ មកដោយសារបុណ្យ នាំ យកមេរៀនមកជាមួយ គួរដល់ការសិក្សាពិសោធ ម្យ៉ាងទៀត សេចក្តីសុខក្សេមក្សាន្តនឹងកើតមានក្នុងចិត្ត បើមិនបានតម្កល់ ទុកជីវិតជាល្បែងថោកទាប ឬល្បែងភ្នាល់ទេនោះ ។ អ្នកឈ្នះ តែងប្រទះនូវពៀរ អ្នកចាញ់រមែងដេកជាទុក្ខ ចំណែកបុគ្គល អ្នកស្ងប់រម្ងាប់ កម្ចាត់បង់នូវការប្រណាំងប្រជែងក្នុងចិត្តបាន ហើយ មិនមានគំនិតប្រៀបធ្ងឹមយកការឈ្នះចាញ់ រមែងរស់ នៅជាសុខ ។



**លោភៈជាហេតុនៃការរវល់គវល់ ការស្អប់ស្អល់មិនមែនជាសេចក្តីខ្ជិល** លោភៈមួយពេល ខ្លី អាចនាំសេចក្តីទុក្ខកង្វល់មកប្រគល់ឱ្យអស់មួយជីវិត សេចក្តី នេះពិតណាស់ ព្រោះលោភៈជាឫសគល់នៃសេចក្តីទុក្ខព្រួយ ជាខ្លោងទ្វារនៃនរក មានច្រកទូលាយ និង ប្រដាប់តុបតែង តាមច្រកផ្លូវទៅដោយគ្រឿងល្បួងលោមបោកបញ្ឆោត ។

សត្វលោកវង្វេងស្មារតី អស់សេចក្តីតស៊ូ លែងចេះអត់ ទ្រាំ បាត់បង់បញ្ញា បាត់បង់ការងារប្រពៃ មានសេចក្តីតក់ស្លុត រន្ធត់ញាប់ញ័រ ដូចសត្វសុនខក្នុងចង្កូមខ្លា នៅពេលណាដែល សេចក្តីស្នេហាគ្របសង្កត់ ។

សត្វលោកទន់ខ្សោយចំណេះដឹង ទោះជាខំប្រឹងរើក៏រើពុំ រួច ក្រញាំតណ្ហាចិន្តាលោកីយ៍ ស្នេហារវាងបុរសនិងស្ត្រី ជា ចំណងដែរបស់មច្ចុរាជ ។ ក្នុងរឿងនេះ ព្រះបរមពោធិសត្វ មហាបុរសរ័ត្ន មិនបានប្រយ័ត្នក៏គង់ភ្លាត់ស្នៀត ជាញីកញយដង ដែរ នៅក្នុង **មោរជាតក** ខុទ្ទកនិកាយ ទុកនិបាត មាន សេចក្តីដូចជា រឿងព្រះតាបសពោធិសត្វ ជាមួយនឹងព្រះនាង

មុទុលក្ខណាទេវី អ៊ីចឹងឯង មានសេចក្ដីពិស្ដារដូចតទៅ :

ព្រះបរមសាស្ដាសម្មាសម្ពុទ្ធ កាលដែលទ្រង់គង់ប្រថាប់នៅនា ព្រះជេតវ័នមហាវិហារ ព្រះអង្គទ្រង់ប្រារព្ធភិក្ខុមួយអង្គដែលចង់សឹក ទើបជាហេតុដែលនាំឱ្យព្រះអង្គ ត្រាស់សំដែងព្រះជាតកនេះ ។

ភិក្ខុទាំងឡាយនាំភិក្ខុនោះ ទៅគាល់ព្រះសាស្ដា កាលព្រះអង្គត្រាស់សួរថា អ្នកអផ្សុកចង់សឹកពិតមែនឬ? ភិក្ខុក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតប្រាកដមែន ។ ព្រះអង្គត្រាស់សួរជាបន្តទៀតថា អ្នកឃើញអ្វីទើបបានជាអផ្សុកចង់សឹក? ភិក្ខុអង្គនោះបានក្រាបទូលថា ឃើញមាតុគ្រាមម្នាក់ ដែលប្រដាប់តាក់តែងរាងកាយ ។ ព្រះសាស្ដាទ្រង់ពុំបានស្ដីបន្ទោសអ្វី ឱ្យដល់ភិក្ខុនោះឡើយ ប៉ុន្តែព្រះអង្គបានត្រាស់សម្ដែងនូវព្រះធម៌ទេសនាថា ម្នាលភិក្ខុ ចំពោះមាតុគ្រាម មានរឿងអ្វីដែលថា មិនរំខានចិត្តមនុស្សដូចជាអ្នកនោះ ព្រោះសូម្បីតែបណ្ឌិតអំពីមុន គ្រាន់តែបានឮសម្លេងមាតុគ្រាម កិលេសដែលស្ងប់មកប្រាំពីរយឆ្នាំហើយ ក៏បាន



ឱកាសកំរើកឡើងទាន់ពេលភ្លាមនោះដែរ ។ សត្វទាំងឡាយសូម្បីបរិសុទ្ធ ក៏គង់សៅហ្មងបាន មានយស មានស័ក្តិដ៏ខ្ពង់ខ្ពស់ក៏ត្រូវវិនាសអស់ ចាំបាច់ពោលទៅថ្វី ចំពោះសត្វដែលមិនបរិសុទ្ធ រួចហើយទ្រង់ក៏បាននាំយករឿងក្នុងអតីតៈមកត្រាស់បន្តព្រះធម៌ទេសនា ។

ក្នុងអតីតកាល គ្រាព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វបានបដិសន្ធិក្នុងកំណើតជាសត្វក្ងោក ក្នុងវេលាជាពងមានសម្បុរសំបកពងស្រដៀងនឹងពណ៌ផ្កាកណ្ណិការក្រពុំ (ពណ៌លឿងស្រស់ត្រកាល) គ្រាកាលចោះសំបកពងចេញមកហើយ មានពណ៌ដូចមាស គួរឱ្យពេចពិលរមិលមើល គួរឱ្យជ្រះថ្លា មានឆ្នូតក្រហមក្នុងរវាងស្លាបទាំងគូ ។

ក្ងោកពោធិសត្វព្យាយាមប្រយ័ត្ន ការពារជីវិតរបស់ខ្លួនដ៏យ៉ាងហ្មត់ចត់ អាស្រ័យនៅនឹងជ្រលងដងភ្នំទណ្ឌកហិរញ្ញ ជិតជួរភ្នំទី៤ ដែលរំលងជួរភ្នំទី៣ទៅ នៅពេលព្រឹកព្រាងស្វាងរស្មីអរុណោទ័យមេឃស្រឡះ ព្រះពោធិសត្វក្ងោកពណ៌មាស ស្ថិត

នៅលើកំពូលភ្នំ សម្លឹងមើលព្រះអាទិត្យដែលកំពុងរះ ក្នុងពេលនោះ ព្រះបរមពោធិសត្វបានចងមន្តដ៏ប្រសើរ ដើម្បីរក្សាការពារខ្លួន ក្នុងភូមិភាគដែលជាកន្លែងស្វែងរកអាហារ ទើបបានពោលនូវគាថាដូចនេះថា :

**α ឧទេតយញ្ចក្ខុមា ឯករាជា**

**ហរិស្សវណ្ណោ បឋវិប្បភាសោ**

**តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ**

**តយជ្ជ គុត្តា វិហរេមុ ទិវសំ ៗ**

ព្រះអាទិត្យណា ជាដួងភ្នែករបស់សត្វលោក ជាឯករាជនៃពន្លឺភ្លឺស្វាង មានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងតែរះឡើង ព្រោះហេតុនោះ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យនោះ ដែលបានជះរស្មីពណ៌មាស បំភ្លឺពសុធា ខ្ញុំសូមឱ្យលោកគ្រប់គ្រងរក្សា នៅក្នុងថ្ងៃនេះ គប្បីខ្ញុំបាននៅជាសុខពេញមួយថ្ងៃ ។

ក្នុងបទទាំងនោះ បទថា **ឧទេតិ** បានដល់ ព្រះអាទិត្យរះឡើងអំពីទិសបូព៌ា ។ បទថា **ចក្ខុមា** បានដល់ មានដួង



ភ្នែកគឺដួងភ្នែកដែលឱ្យដល់ពពួកជន ព្រោះកម្ចាត់សេចក្តីងងឹតធ្វើឱ្យបុគ្គលនៅក្នុងចក្រវាឡទាំងអស់បានដួងភ្នែក។ បទថា **ឯករាជា** ដោយសេចក្តីថា ព្រះអាទិត្យជាឯករាជ ព្រោះប្រសើរជាទីបំផុត ក្នុងបណ្តាវត្ថុដែលធ្វើឱ្យលោកភ្លឺស្វាង ទូទៅក្នុងចក្រវាឡ ។ បទថា **ហរិស្សវណ្ណោ** គឺមានពណ៌ដូចមាស អធិប្បាយថា មានពណ៌ល្អដ៏ក្រៃលែង ។ បទថា **បឋវិប្បភាសោ** គឺមានពន្លឺរស្មីជះមកលើផែនដី ។ បទថា **តំ តំ នមស្សាមិ** គឺខ្ញុំសូមនមស្ការចំពោះព្រះអាទិត្យដ៏ចម្រើននោះ ។ បទថា **តយជ្ជ គុត្តា វិហរេមុ ទិវសំ** បានដល់ សូមឱ្យលោករក្សាគ្រប់គ្រងក្នុងថ្ងៃនេះ ខ្ញុំគប្បីនៅជាសុខពេញមួយថ្ងៃ ដោយការស្ថិតនៅគ្រប់ឥរិយាបថ។

ព្រះបរមពោធិសត្វ កាលដែលបាននមស្ការនូវព្រះអាទិត្យដោយព្រះគាថានេះហើយ ទើបបាននមស្សការនូវព្រះសម្មា-សម្ពុទ្ធ ដែលព្រះអង្គទ្រង់បរិនិព្វានទៅហើយ ក្នុងអតីតៈ និងព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ដោយព្រះគាថាទី២ថា :

α យេ ព្រាហ្មណា វេទគូ សព្វធម្មេ
តេ មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា
ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា ។

ព្រាហ្មណ៍ទាំងឡាយណា ជាអ្នកបានដល់នូវត្រើយនៃវេទ ក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ និងសូមព្រាហ្មណ៍ទាំងឡាយនោះ រក្សានូវខ្ញុំផង ។ ខ្ញុំសូមនមស្ការចំពោះដល់ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ខ្ញុំសូមនមស្ការចំពោះដល់ ព្រះពោធិញ្ញាណ ខ្ញុំសូមនមស្ការចំពោះដល់ បុគ្គលដែលបានរួចផុតទៅហើយ ខ្ញុំសូមនមស្ការចំពោះដល់ វិមុត្តិធម៌របស់អ្នកដែលបានរួចផុតទៅហើយនោះ ។

ក្ងោកពោធិសត្វនោះឯង ចម្រើននូវព្រះបរិត្តនេះរួចហើយ ទើបត្រាច់ទៅដើម្បីស្វែងរកអាហារ ។

ក្នុងបទទាំងអស់នោះ បទថា **យេ ព្រាហ្មណា** បានដល់ព្រាហ្មណ៍ដែលជាអ្នកបរិសុទ្ធ បណ្តេញបាបចោល



ស្រឡះអស់អំពីចិត្តហើយ ទាំងឡាយណា ។ បទថា **វេទគូ** នៅក្នុងទីនេះ មានសេចក្តីអធិប្បាយថា ព្រាហ្មណ៍ទាំងឡាយណាធ្វើសង្ខតធម៌ និង អសង្ខតធម៌ ដែលខ្លួនបានដឹងហើយ ឱ្យប្រាកដច្បាស់ហើយ ទម្លាយកំពូលកិលេសមារទាំងបី ញ៉ាំងមុឺនលោកធាតុឱ្យញាប់ញ័រ សម្រេចនូវសម្មាសម្ពោធិញ្ញាណនាគល់ព្រះពោធិព្រឹក្ស កន្លងត្រើយនៃសង្សារវដ្តបានហើយ ។ បទថា **តេ មេ នមោ** គឺសូមព្រាហ្មណ៍ទាំងអស់នោះទទួលនូវការនមស្ការរបស់ខ្ញុំ ។ បទថា **តេ ច មំ បាលយន្តុ** សេចក្តីថា ម្យ៉ាងទៀតសូមលោកដ៏ចម្រើនទាំងអស់នោះ ដែលខ្ញុំបាននមស្ការហើយ ចូររក្សា គឺចូរថែទាំគ្រប់គ្រងនូវខ្ញុំនេះ ។ បទថា **នមត្ថុ ពុទ្ធានំ ។ល។ នមោ វិមុត្តិយា** មានសេចក្តីថា សូមការនមស្ការរបស់ខ្ញុំនេះ ចូរមានដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ដែលស្តេចបរិ-និព្វានកន្លងទៅហើយ ចូរមានដល់ព្រះប្រាជ្ញាក្នុងការត្រាស់ដឹង គឺញាណក្នុងមគ្គទាំង៤ ផលទាំង៤ របស់ព្រះពុទ្ធជាម្ចាស់គ្រប់អង្គនោះ ម្យ៉ាងទៀត ចូរមានដល់បុគ្គលដែលរួចផុតទៅហើយ

ដោយការរួចផុតគឺអរហត្តផល និងសូមនមស្ការដល់ការរួចផុត ៥យ៉ាងរបស់បុគ្គលអ្នកដែលរួចផុតនោះគឺ **តទង្គវិមុត្តិ** ផុតមួយគ្រា១ **វិក្ខម្ភនវិមុត្តិ** ផុតដោយការគ្របទុក១ **សមុច្ឆេទវិមុត្តិ** ផុតដាច់ខាត១ **បដិបស្សទ្ធិវិមុត្តិ** ផុតដោយស្ងប់១ **និស្សរណវិមុត្តិ** ផុតដោយចេញទៅ១ សូមការនមស្ការរបស់ខ្ញុំ ចូរមានដល់ការរួចផុត ៥យ៉ាង របស់បុគ្គលអ្នកដែលរួចផុតទាំងអស់អង្គនោះ ។

ច្រើនបទដែលថា **ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា** នេះព្រះបរមសាស្តាព្រះអង្គត្រាស់ កាលដែលទ្រង់បានសម្រេចនូវអភិសម្ពោធិញ្ញាណហើយ បទទាំងនេះមានសេចក្តីអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ក្ងោកនោះគ្រាកាលចម្រើននូវព្រះបរិត្ត គឺសូធ្យធមិការពារនេះហើយ ទើបត្រាច់ទៅស្វែងរកអាហារ តាមបែបផ្សេងៗ មានផ្កាឈើផ្លែឈើជាដើម ក្នុងស្ថានទីស្វែងរកអាហាររបស់ខ្លួន ។

ក្ងោកព្រះពោធិសត្វ គ្រាកាលត្រាច់ទៅអស់មួយថ្ងៃ



យ៉ាងនេះហើយ នៅពេលល្ងាចទន់ទាបព្រះសុរិយា ក៏បានត្រឡប់ឡើងលើកំពូលភ្នំ សម្លឹងមើលដួងព្រះអាទិត្យ ដែលទៀបនឹងអស្តង្គតរលត់រស្មី ហើយរលឹកដល់ព្រះពុទ្ធគុណសាជាថ្មីទៀត នៅក្នុងពេលដែលចងមន្តដ៏ប្រសើរ ដើម្បីរក្សាការពារនាវេលារាត្រីកាល ។

ព្រះគាថារបស់ក្ងោកពោធិសត្វ ដែលសំរាប់សូធ្យការ-ពារ នៅពេលយប់ មានដូចតទៅ :

α **អបេតយញ្ចក្ខុមា ឯករាជា**
**ហរិស្សវណ្ណោ បឋវិប្បភាសោ**
**តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ**
**តយជ្ជ គុត្តា វិហរេមុ រត្តឹ ។**
α **យេ ព្រាហ្មណា វេទគូ សព្វធម្មេ**
**តេ មេ នមោ តេ ច មំ បាលយន្តុ**
**នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា**
**នមោ វិមុត្តានំ នមោ វិមុត្តិយា**
**ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយីតិ ។**

ព្រះអាទិត្យណា ជាដួងភ្នែករបស់សត្វលោក ជាឯករាជនៃពន្លឺភ្លឺស្វាង មានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងតែអស្តង្គតទៅ ព្រោះហេតុនោះ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យនោះ ដែលមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឱ្យលោកគ្រប់គ្រងរក្សា អស់វេលារាត្រីនៃថ្ងៃនេះ គប្បីខ្ញុំបាននៅជាសុខពេញមួយយប់ ។

ព្រាហ្មណ៍ទាំងឡាយណា ជាអ្នកបានដល់នូវត្រើយនៃវេទ ក្នុងធមិទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ និងសូមព្រាហ្មណ៍ទាំងឡាយនោះ រក្សានូវខ្ញុំផង ។

α ខ្ញុំសូមនមស្ការចំពោះដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ។

α ខ្ញុំសូមនមស្ការចំពោះដល់ ព្រះពោធិញ្ញាណ ។

α ខ្ញុំសូមនមស្ការចំពោះដល់ បុគ្គលដែលបានរួចផុតទៅហើយ ។

α ខ្ញុំសូមនមស្ការចំពោះដល់ វិមុត្តិធមិរបស់អ្នកដែលបានរួចផុតទៅហើយនោះ ។



ក្ងោកពោធិសត្វនោះឯង ចម្រើននូវព្រះបរិត្តនេះរួចហើយ ទើបបានសម្រេចការសម្រាកនៅ ។

ក្នុងបទទាំងអស់នោះ បទថា **អបេតិ** បានដល់ ការប្រាសទៅ កន្លងទៅ គឺលិចទៅ ។ សូម្បីបទថា **ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយិ** នេះព្រះសាស្តាក៏ព្រះអង្គត្រាស់ កាលបានសម្រេចនូវអភិសម្ពោធិញ្ញាណហើយដែរ បទនោះមានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ក្ងោកនោះគ្រាកាលដែលចម្រើននូវព្រះបរិត្ត គឺសូធ្យធមិការពារនេះហើយ ទើបសម្រាកនៅក្នុងលំនៅនោះ ។ ដោយអានុភាពនៃព្រះបរិត្តនេះ ក្ងោកពោធិសត្វពុំមានសេចក្តីខ្លាច ភ័យតក់ស្លុតអ្វីឡើយ រហូតទាំងយប់ទាំងថ្ងៃ ។

ក្នុងកាលសម័យនោះ មានព្រាននេសាទម្នាក់ នៅមិនឆ្ងាយពីក្រុងពារាណសីប៉ុន្មានឡើយ ហើយបានត្រាច់ទៅកាន់ហិមវន្តប្រទេស ឃើញក្ងោកពោធិសត្វ ទំនៅលើកំពូលភ្នំទណ្ឌកហិរញ្ញ ពេលត្រឡប់មកវិញក៏បានប្រាប់កូន ។ ក្រោយមកថ្ងៃមួយ ព្រះនាងខេមា ព្រះទេវីរបស់ព្រះបាទក្រុងពារា-

ណសី ទ្រង់សុបិនឃើញក្ងោកពណ៌មាសសម្តែងធម៌ ខណៈតើន ចាកព្រះក្រឡាបន្ទំ បានក្រាបទូលនូវព្រះសុបិនដល់ព្រះរាជា រួចហើយក៏បានក្រាបទូលជាបន្តថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មាន បំណងនឹងស្តាប់ធម៌របស់ក្ងោកពណ៌មាសនោះ ។ ព្រះរាជាទើប មានព្រះតម្រាស់សួរពួកអាមាត្យ ។ ពួកអាមាត្យបានក្រាប ទូលថា បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍គង់នឹងជ្រាប ពុំខាន។ កាលដែលព្រះរាជាត្រាស់សួររឿងនេះ ចំពោះដល់ ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ទើបនាំគ្នាក្រាបទូលថា បពិត្រ ព្រះករុណាថ្លៃវិសេសតម្កល់លើត្បូង ក្ងោកពណ៌មាសប្រាកដជា មានពិត ក្រាបទូល ។ ព្រះរាជាត្រាស់សួរពួកព្រាហ្មណ៍បន្ត ទៀតថា តើក្ងោកពណ៌មាសនោះមាននៅក្នុងទីណា? ព្រាហ្មណ៍ ក្រាបទូលថា ពួកព្រានព្រៃនឹងជ្រាប ក្រាបទូល ។

ព្រះរាជាត្រាស់បង្គាប់ឱ្យប្រជុំពួកព្រានទាំងឡាយ ហើយត្រាស់សួរ ។ គ្រានោះបុត្រព្រាននេសាទ បានក្រាបទូល ថា បពិត្រព្រះករុណាថ្លៃវិសេស ក្ងោកពណ៌មាសមានពិតក្រាប ទូល អាស្រ័យនៅទណ្ឌកបពិត សូមមហារាជជ្រាប ។ ព្រះរាជា



បានត្រាស់ថា បើដូច្នោះ អ្នកចូរទៅចាប់ក្ងោកនោះមក ប្រយ័ត្ន កុំឱ្យស្លាប់ ។ ព្រានទើបយកអន្ទាក់ទៅដាក់ទីនោះ ដែលជា ទីស្វែងរកអាហារនៃក្ងោកពោធិសត្វ ប៉ុន្តែក្ងោកពោធិសត្វពុំ បានជាប់អន្ទាក់ឡើយ ទោះបីដើរជាន់លើអន្ទាក់នោះក៏ដោយ ក៏អន្ទាក់មិនបានរួបរឹតដែរ។ ព្រានមិនអាចចាប់ក្ងោកពោធិសត្វ បាន ខំប្រឹងព្យាយាមរហូតដល់ ៧ឆ្នាំ ទាល់តែក្ស័យជីវិត នៅ ក្នុងព្រៃនោះទៅ សូម្បីព្រះនាងខេមា រាជទេវី កាលពុំបានសម តាមបំណង ក៏អស់ព្រះជន្មដែរទៅ ។ ព្រះរាជាទ្រង់ក្រោធជា មួយនឹងក្ងោកពណ៌មាស ព្រោះគិតថា ព្រះទេវីបានអស់ព្រះជន្ម ទៅ ព្រោះអាស្រ័យក្ងោកពណ៌មាសនោះ រួចហើយបានត្រាស់ បង្គាប់ឱ្យគេ ចារឹកអក្សរទុកក្នុងផែនមាសថា ក្នុងហិមវន្ត ប្រទេស មានភ្នំមួយឈ្មោះទណ្ឌកបពិត ភ្នំនោះមានក្ងោកមួយ ពណ៌មាសអាស្រ័យនៅ បុគ្គលណាបានបរិភោគនូវសាច់របស់វា បុគ្គលនោះនឹងមិនចាស់ មិនស្លាប់ឡើយ ហើយក៏ទុកផែនមាស នោះ ក្នុងហិបមាសមួយដ៏យ៉ាងល្អ ។

គ្រាព្រះរាជាសោយទិវង្គតទៅហើយ ព្រះរាជាអង្គដទៃ

ក៏គ្រងរាជសម្បត្តិបន្ត ទ្រង់អានសេចក្តីក្នុងផែនមាសនោះ រួចហើយក៏មានព្រះបំណង មិនចង់ចាស់ មិនចង់ស្លាប់ ទើបទ្រង់បញ្ជូនព្រានដទៃទៅ សូម្បីព្រាននោះទៅដល់ហើយ ក៏មិនអាចចាប់ព្រះពោធិសត្វបានឡើយ ហើយបានស្លាប់ទៅក្នុងទីនោះឯង ។ ដោយទំនងរបៀបគ្នានេះ ព្រះរាជាសោយទិវង្គតទៅ ៦ជួរព្រះអង្គ គឺ ៦ជំនាន់ គ្រាកាលអង្គជំនាន់ទី៧ គ្រងរាជសម្បត្តិ ទ្រង់ក៏បានបញ្ជូនព្រានម្នាក់ឱ្យទៅទៀត ព្រាននោះទៅដល់ហើយ ក៏បានដឹងដល់ភាវៈដែលក្ងោកមិនជាប់អន្ទាក់សូម្បីដើរជាន់លើអន្ទាក់ហើយក៏ដោយ គឺព្រានបានដឹងដល់ការចម្រើននូវព្រះបរិត្តការពារខ្លួន មុននឹងស្វែងរកអាហារ របស់ព្រះបរមពោធិសត្វ ។ ព្រានបានទៅដល់បច្ចន្តជនបទ ចាប់ក្ងោកញីមួយ យកមកបង្ហាត់ឱ្យចេះរាំ ដោយឮសូរសម្លេងទះដៃ និងឱ្យចេះរងាវ ដោយបានឮសូរសម្លេងផ្ទាត់ម្រាមដៃ គ្រាកាលដែលបង្ហាត់ក្ងោកញីនោះ បានស្ទាត់ជំនាញហើយ ទើបនាំយកទៅធ្វើជាផ្ទាក់ ។

ក្ងោកពោធិសត្វ នៅមិនទាន់បានចម្រើនព្រះបរិត្តផង



ព្រានបានដាក់អន្ទាក់រួចជាស្រេចនៅពេលស្រាងៗ ហើយបានធ្វើនូវសញ្ញាឱ្យក្ងោកផ្ទាក់រងាវ ក្ងោកព្រះពោធិសត្វក៏បានឮសម្លេងមាតុគ្រាម ដែលជាសត្រូវក្នុងពេលនោះឯង ។ សេចក្តីក្តៅរោលរាលដោយរាគៈ ក៏កើតឡើងចំពោះដល់ព្រះពោធិសត្វពេលនោះក្ងោកពោធិសត្វ មិនអាចចម្រើនព្រះបរិត្តបានឡើយ ហើយក៏ស្ទុះរឹង ហើរសំដៅទៅរកទីនោះ លើកនេះគ្មានអ្វីជួយទេ ត្រូវជាប់អន្ទាក់ព្រាន ។

ព្រានចាប់ក្ងោកពណ៌មាសបានស្រេចហើយ ក៏នាំយកទៅថ្វាយព្រះរាជាក្រុងពារាណសី ព្រះរាជាទតព្រះនេត្រឃើញរូបសម្បត្តិនៃសត្វក្ងោកនោះ ទ្រង់ក៏បានពេញព្រះទ័យ ព្រះរាជទានទ្រនំឱ្យព្រះពោធិសត្វទំ ។ ក្ងោកពោធិសត្វទំនៅលើបង្គងដែលគេចាត់ចែងឱ្យរួចហើយ ទើបទូលសួរព្រះរាជាថា បពិត្រមហារាជ ព្រោះហេតុអ្វី ទើបព្រះអង្គត្រាស់បង្គាប់ឱ្យព្រានចាប់ទូលបង្គំមក? ព្រះរាជាទ្រង់ត្រាស់ឆ្លើយថា យើងបានដឹងដំណឹងថា បុគ្គលណាបានស៊ីសាច់របស់ឯង បុគ្គលនោះនឹងមិនចាស់មិនស្លាប់ឡើយ ដូច្នេះ យើងត្រូវការសោយសាច់របស់ឯង ដើម្បី

កុំឱ្យយើងចាស់ស្លាប់ ទើបយើងបង្គាប់ឱ្យគេចាប់ឯងមក ។

**ក្ងោកទូលសួរថា –** បពិត្រមហារាជ មនុស្សទាំងឡាយបរិភោគសាច់របស់ទូលបង្គំហើយ មិនចាស់មិនស្លាប់នោះ សូមលើកទុកសិនចុះ ប៉ុន្តែចំណែកទូលបង្គំត្រូវស្លាប់ដែរឬទេ?

**ព្រះរាជាត្រាស់ថា –** ពិតណាស់ គឺឯងត្រូវស្លាប់ ។

**ក្ងោកសួរទៀតថា –** បពិត្រមហារាជ បើទូលបង្គំត្រូវស្លាប់ បុគ្គលដែលបរិភោគសាច់របស់ទូលបង្គំនោះ ធ្វើដូចម្ដេចទើបមិនស្លាប់ទៅ?

**ព្រះរាជាត្រាស់តបថា –** ក្ងោកឯងមានខ្លួនពណ៌មាស ព្រោះដូច្នោះទើបមានដំណឹងថា បុគ្គលដែលបានស៊ីសាច់របស់ឯងហើយ រមែងមិនចាស់មិនស្លាប់ ។

**ក្ងោកទូលព្រះរាជាថា –** បពិត្រមហារាជ ទូលបង្គំមានពណ៌មាស មិនមែនព្រោះអត់ហេតុនោះទេ គឺកាលទូលបង្គំជាស្ដេចចក្រពត្តិ នៅក្នុងនគរនេះឯង ខ្លួនឯងក៏រក្សាសីល៥ ហើយដឹកនាំឱ្យជនទាំងឡាយ ទូទៅក្នុងចក្រវាឡរក្សាសីលផងដែរ ទូលបង្គំអស់ជីវិតទៅបានកើតក្នុងស្ថានតាវត្តិង្ស ស្ថិតនៅក្នុងភពនោះរហូតអស់អាយុ ចុតិចាកទីនោះហើយ ទើបមកកើតក្នុងកំណើតសត្វក្ងោកនេះ ព្រោះផលនៃអកុសលកម្មឯណានីមួយ ប៉ុន្តែខ្លួនដែលមានសម្បុរពណ៌មាស ក៏ដោយអានុភាពនៃសីល៥ ដែលបានរក្សាអំពីមុនមកហ្នឹងឯង ។



**ព្រះរាជាសួរថា –** ក្ងោកឯងនិយាយថា ឯងជាស្ដេចចក្រពត្តិរក្សាសីល៥ ខ្លួនមានពណ៌ជាមាស ព្រោះផលនៃសីល រឿងនេះយើងនឹងជឿបានដូចម្ដេចទៅ? តើមានអ្វីជាព័ស្ដុតាង?

**ក្ងោកក្រាបទូលថា –** បពិត្រមហារាជ ព័ស្ដុតាងមាន គឺកាលទូលបង្គំជាស្ដេចចក្រពត្តិ ទូលបង្គំបានជិះរថសម្រេចដោយកែវ ៧ប្រការ ត្រាច់ទៅក្នុងអាកាស រថរបស់ទូលបង្គំនោះ លិចចុះទៅខាងក្រោមស្រះមង្គលបោក្ខរណី សូមទ្រង់ត្រាស់បង្គាប់ឱ្យគេលើករថនោះឡើង រថនោះជាជំនិះរបស់ទូលបង្គំ ។ ព្រះរាជាត្រាស់ថា ល្អណាស់ ហើយត្រាស់បង្គាប់ឱ្យបាចទឹកចេញអំពីស្រះបោក្ខរណី លើករថឡើងមកបានពិតប្រាកដមែន ហើយទ្រង់ក៏ជឿពាក្យរបស់ព្រះពោធិសត្វ ។

ព្រះពោធិសត្វសម្ដែងធម៌ថ្វាយព្រះរាជាថា មហាបពិត្រ

ធម៌ដែលតាក់តែងទាំងអស់ ក្រៅចាកអំពីអមតៈ មហានិព្វាន ហើយ ឈ្មោះថាមិនទៀង មានការអស់ទៅ និង សូន្យទៅជាធម្មតា មានហើយត្រឡប់ទៅជាមិនមានវិញ រួចទើបឱ្យព្រះរាជាតាំងនៅក្នុងសីល៥ ។ ព្រះរាជាទ្រង់ជ្រះថ្លា បូជាព្រះពោធិសត្វនូវរាជសម្បត្តិ ទ្រង់បានធ្វើសក្ការបូជាដ៏យ៉ាងក្រៃលែង ក្ងោកព្រះពោធិសត្វ ថ្វាយរាជសម្បត្តិឱ្យដល់ព្រះរាជាវិញ បានសំណាក់នៅពីរបីថ្ងៃ ទើបថ្វាយឱវាទដល់ព្រះរាជាថា បពិត្រមហារាជ សូមព្រះអង្គទ្រង់រក្សានូវសេចក្តីមិនប្រមាទចុះ ហើយក៏ហើរឡើងទៅលើអាកាស រួចហើរសំដៅទៅភ្នំទណ្ឌកហិរញ្ញវិញ ក្នុងពេលនោះឯងហោង ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ ប្រជុំជាតក ។ កាលចប់សច្ចធម៌ ភិក្ខុដែលបានស្រឡាញ់នូវមាតុគ្រាម ហើយមានបំណងចង់សឹកនោះ ក៏បានសម្រេចនូវអរហត្តផល ។ ព្រះរាជាស្តាប់ឱវាទព្រះពោធិសត្វក្នុងកាលណោះ បានមកជាព្រះអានន្ទក្នុងកាលនេះ ចំណែកក្ងោកពណ៌មាសក៏បានមកជាយើងតថាគតនេះឯង



៤លោភៈជាប្រភពនៃបញ្ហា ជាមេបណ្តាលឱ្យកើតការកង្វល់រវល់គ្មានឈប់ ជាឫសគល់នៃសេចក្តីលំបាកកាយ លំបាកចិត្ត លោភៈមុនជាឧបនិស្ស័យ បើកឱកាសឱ្យដល់លោភៈក្រោយៗ និង កិលេសដទៃផ្សេងទៀត ព្រមដោយសេចក្តីប្រមាទ ។

បុគ្គលមិនធ្ងន់ចិត្តក្នុងការធ្វើទាន កាន់សីលតែមិនគោរពសីល មានចំណូលចិត្តត្រឹមតែខ្លះៗប៉ុណ្ណោះក្នុងការស្តាប់ព្រះធម៌ ប៉ុន្តែមានប្រក្រតីចូលចិត្តរឿងសប្បាយ ដើរលេងក្អាកក្អាយ ប្រដាប់កាយតែងខ្លួន និង ស្វែងរកអារម្មណ៍ឆ្ងាញ់ៗតាមចំណង់ រឿងនេះជារឿងដែលខ្សោយបញ្ញា វាជាលក្ខណៈនៃបុគ្គលពិការស្មារតី ដែលជាលទ្ធផលនៃលោភៈ ព្រមដោយការប្រមាទអំពីមុនមក ។

កាលនៅវ័យក្មេងប្រឡែងលេងកាមគុណ លុះដល់អាយុច្រើន ទន់ខ្សោយស្មារតី រៀនធម៌មិនចាំ បន្ទោសថាមកអំពីខ្លួនឯងចាស់ ចំណែកកិលេសត្រូវរួចខ្លួន ព្រោះគេមិនបានឃើញទោសវា ។

ចិត្តអត់សទ្ធា មានបាបជាអាហារដ៏ឆ្ងាញ់ ប៉ុន្តែមានបុណ្យជាចំណីទាស់ ឬមិនចេះបរិភោគតែម្តង ម្ល៉ោះហើយចិត្តអត់សទ្ធា រមែងពេញណែនទៅដោយបាប មានបាបជាគភ៌ប្រសូតចេញជាកំណើតសត្វក្នុងអបាយភូមិ ។

លោភៈធ្វើចិត្តឱ្យអត់សទ្ធា ធម្មតាសទ្ធាជាអរិយទ្រព្យ ដូច្នេះ ចិត្តអត់សទ្ធា គឺជាចិត្តក្រខ្សត់ដ៏ក្រៃលែង រមែងជំពាក់បំណុលគេដោយការធ្វើបាប មានការសម្លាប់សត្វ ឬលួចប្លន់ជាដើម ជាធម្មតាបំណុលតែងមានម្ចាស់ ម្ចាស់បំណុលគឺកម្មពៀរ ហើយក្នុងលោកនេះមិនមានអ្នកណាជាម្ចាស់ គ្រប់គ្រងលើកម្មពៀរឡើយ កម្មពៀរតែងស្ថិតនៅក្នុងចិត្តសន្តាននៃអ្នកដែលបានធ្វើបាបហើយគ្រប់គ្នា ដូច្នេះ មិនមានអ្នកណាទទួលបាបជំនួសអ្នកណាទេ ព្រោះម្នាក់ៗមានចិត្តសន្តានផ្សេងៗគ្នា តាមពិតចិត្តហ្នឹងឯងដែលជាអណ្តូងរ៉ែនៃបាប បង្កើតបាប ទទួលបាប សន្សំបាប ធ្វើឱ្យបាបមានផល ។

លោភៈនាំឱ្យមានការយល់ខុសផ្សេងៗ លោភៈតែងតែប្រកបជាមួយនឹងការវង្វេង លោភៈដឹកនាំចិត្តឱ្យព្រមទទួល



យកនូវសត្វនិងសង្ខារ ដែលសត្វនិងសង្ខារនោះៗ នាំយកការរវល់កង្វល់មកប្រគល់ឱ្យ រវល់ដោយកាយ រវល់ដោយវាចា កង្វល់ដោយគំនិត លោភៈធ្វើឱ្យមិនព្រមទទួលយកនូវគុណធមិ គឺសេចក្តីសន្តោស ធ្វើឱ្យគិតខុសថា សេចក្តីសន្តោសធ្វើមនុស្សមិនឱ្យជឿនលឿន មិនឱ្យមានបាន ។

លោភៈនាំឱ្យមាននូវការប្រកាន់ទិដ្ឋិ ដំឡើងមានះ សំគាល់ខ្លួនឯងថាខ្ពង់ខ្ពស់ដោយលាភដោយយស ឬកពោចើង ម៉ឺងឆ្មើងឆ្មៃ និងមើលងាយអ្នកដទៃ តាមពិតខ្លួនយើងម្នាក់ៗ មិនផុតពីធាតុដី ទឹក ភ្លើង ខ្យល់ អាកាសធាតុ និង វិញ្ញាណ-ធាតុឡើយ ដោយឡែកផ្សេងគ្នាតែនាមបញ្ញត្តិប៉ុណ្ណោះ ។

លោភៈនាំឱ្យមាននូវសេចក្តីស្រវឹងនឹងឈ្មោះ តំណែងតែងតាំង ភ្លេចអស់នូវធាតុពិត គិតថាខ្លួនឯងគ្រាន់បើ ប៉ុន្តែធាតុពិត មហាភូតរូប៤ អាកាសធាតុ វិញ្ញាណធាតុ មិនចេះក្លាយទៅជាអ្វីៗតាមឈ្មោះនោះទេ វាជាសង្ខតធមិ គឺធមិមានបច្ច័យប្រជុំតាក់តែង មានការទ្រុឌទ្រោមរលាយបាត់ជាធម្មតា ដូច្នេះដែលគិតថាខ្លួនយើងមានពិត ជាសត្វជាបុគ្គល ជាអ្នកតូច

ជាអ្នកធំ គឺជាប្រភេទនៃកិលេសម្យ៉ាង សត្វបុគ្គលតួខ្លួននៅតែអត់ដដែលក្នុងធាតុពិតទាំងឡាយ ។

**ការស្លាប់ស្អាល់មិនមែនជាសេចក្តីខ្ជិល** មនុស្សខ្ជិលមិនអាចទទួលបាននូវការស្កប់ស្កល់ឡើយ មានតែមនុស្សមិនខ្ជិលទេដែលអាចទទួលបាននោះ ព្រោះការស្កប់ស្កល់ ជាលទ្ធផលនៃការងារ ប៉ុន្តែត្រូវតែជាការងារដោយប្រពៃ ទាំងការងារសម្រាប់រស់ ទាំងការងារសម្អាតចិត្ត ។

ពុំមានឱវាទណាមួយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅឱ្យមនុស្ស និង ទេវតា មានសេចក្តីខ្ជិលឡើយ ប៉ុន្តែទ្រង់ត្រាស់សំដែងអំពីមនុស្សពាល ព្រោះកាត់បង់នូវប្រយោជន៏ទាំងពីរ គឺប្រយោជន៏ក្នុងលោកនេះ និងប្រយោជន៏ក្នុងលោកខាងមុខ ។ ប្រយោជន៏ក្នុងលោកនេះ បានដល់ក្នុងលោកដែលកំពុងរស់នៅមានអត្តភាពជាមនុស្ស ត្រូវប្រកបការងារ ៤យ៉ាង ដើម្បីប្រយោជន៏ខ្លួនឯងផង និង ដើម្បីប្រយោជន៏សម្រាប់អ្នកដទៃផង ការងារ ៤យ៉ាងនោះគឺ :

**១-ឧដ្ឋានសម្បទា-** **ឧដ្ឋាន** ប្រែថា កិរិយាតាំងឡើង



កិរិយាក្រោកឡើង សេចក្តីព្យាយាម សេចក្តីក្រវើនក្រតើន ។ **សម្បទា** ប្រែថា កិរិយាដល់ព្រមឬធម្មជាតិជាហេតុដល់ព្រម ។

កិរិយាដល់ព្រមដោយសេចក្តីព្យាយាម គឺជាការងារទី១ សម្រាប់ប្រយោជន៏ក្នុងបច្ចុប្បន្ន ភាគច្រើនមនុស្សយើងតែងយល់ច្រឡំ ឧដ្ឋានសម្បទាជាមួយគ្នានឹងលោភៈ ដូច្នេះហើយទើបសេចក្តីក្នុងអត្ថបទណា ដែលពោលអំពីទោសរបស់លោភៈ គេតែងមានគំនិតទាស់ ព្រោះគិតថាអត្ថបទនោះ ពោលទោសសេចក្តីប្រឹងប្រែងព្យាយាមរបស់គេ មិនចង់ឱ្យគេមានបានក្នុងសេចក្តីនេះវាមានការខ្វះខាតផងដែរ ចំពោះការពោលអំពីសេចក្តីសន្តោសនៃបុគ្គលខ្លះ ដែលគ្រាន់តែពោលរំលឹកខ្លីៗថា «កុំឱ្យប្រឹងខ្លាំងពេក ស្លាប់ទៅមិនមែនយកទៅបានទេ» ។

ឧដ្ឋានសម្បទាមានការឧស្សាហ៏ជាលក្ខណៈ ប៉ុន្តែលោភៈមានការប្រកាន់ក្នុងអារម្មណ៏ដោយការជាប់ជំពាក់ជាលក្ខណៈ ។ ឧដ្ឋានសម្បទា មានការប្រឹងប្រែងស្វែងរកទ្រព្យសម្បត្តិ ដោយការងារប្រពៃ ប្រាសចាកទោស ប្រាសចាកការចិញ្ចឹមជីវិតខុស ជាសម្បត្តិដ៏ប្រសើរ មានឆន្ទៈពេញចិត្តក្នុងការងារដែលរក

ទោសពុំបាននោះ ជាគ្រឿងទ្រឱ្យកម្លាំងដល់សេចក្តីព្យាយាម ពុំដាក់ចុះនូវធុរៈព្រោះសេចក្តីខ្ជិលឡើយ ដូច្នេះ ឧដ្ឋានសម្បទា រមែងធ្ងន់ក្នុងហេតុ គឺការងារស្អាតស្អំ និងមិនមើលងាយចំពោះផលដែលបានមក ព្រោះជាផលនៃការងារដែលប្រាសចាកទោស ទោះបីជាផលនោះតិចឬច្រើនយ៉ាងណា១ក្តី ក៏មានសេចក្តីសន្តោស ត្រេកអរចំពោះសម្បត្តិដែលជាផលនោះ តាមមានតាមបាន ស្កប់ស្កល់ក្នុងចិត្ត បានយល់ដល់ការពិតថា ផលដែលបានសម្រេចមកនេះ សមគួរតាមហេតុ ប្រៀបដូចជាចំនួន ១០ វាជាផលរបស់ចំនួន៥ បូកនិងចំនួន៥ អ៊ីចឹងឯង ។

លោភៈពុំបានគិតផ្ចិតផ្ចង់ចំពោះហេតុ គឺការងារឱ្យបានស្អាតស្អំនោះទេ រមែងធ្ងន់ក្នុងផលដែលត្រូវបានសម្រេច ព្រោះការជាប់ជំពាក់ចិត្តយ៉ាងធ្ងន់ទៅក្នុងផលយ៉ាងនេះ ទើបវាជាបច្ច័យតាក់តែងឱ្យធ្វើនូវការងារសៅហ្មងបាន ដូចជាជំនួញ៥ប្រការជាដើម លក់ស្រា លក់ស្រី លក់គ្រឿងប្រហារ ថ្នាំពិស ថ្នាំបំពុល ចេះតែលក់គ្មានយល់អំពីទោសអ្វី១ទាំងអស់ មាន់ទាក្រពើជ្រូក ។ល។ ចិញ្ចឹមលក់ផងដែរ ម្យ៉ាងទៀតបើថារបស់របរនោះសមគួរនឹងលក់ហើយ ប៉ុន្តែដោយលោភៈនឹងចំណេញពេក ក៏ហ៊ានពោលកុហកដោយរបៀបផ្សេង១ មានមុខរបរខ្លះទៀត លួចលាក់បោកប្រាស់ បន្លំទម្ងន់ស៊ីភ្នែកជញ្ជីង របស់ក្លែងថាសុទ្ធ របស់កាឡៃថាពិត របស់ជិតថាមកអំពីនាយ ។ល។ និង ។ល។ ការងារសៅហ្មងប្រកបដោយទោស មានច្រើនទៀតណាស់ ព្រោះហេតុតែលោភៈជាប់ជំពាក់ក្នុងផលកម្រៃនេះឯង ។

ទោះបីការងារមិនបៀតបៀនសត្វដទៃមនុស្សដទៃក៏ដោយ ប៉ុន្តែលក្ខណៈរបស់លោភៈ គឺជាប់ជំពាក់ធ្ងន់ក្នុងសម្បត្តិដែលជាផល ញាប់ញ័រអន្ទះសាខ្វារក វាខុសអំពីឧដ្ឋានសម្បទាដែលធ្ងន់ក្នុងហេតុ គឺជំរះក្នុងកិច្ចការងារឱ្យស្អាតស្អំ មានសីលមានសម្មាទិដ្ឋិ ជាគ្រឿងគ្រប់គ្រង ពេញចិត្តក្នុងមុខរបរ ឬការចិញ្ចឹមជីវិត ដែលបរិសុទ្ធ សន្តោសចំពោះផលដែលត្រូវបានពោលគឺមិនឱ្យលាភសក្ការៈ ផលកម្រៃគ្របសង្កត់ចិត្ត ហើយចិញ្ចឹមជីវិតខុសនោះឡើយ ។

**២-អារក្ខសម្បទា-** ដល់ព្រមដោយការរក្សាថែទាំសព្វ

គ្រប់ ជាទូទៅនូវសម្បត្តិដែលមាន ដែលស្វែងរកបាន នេះមិនមែនជាលក្ខណៈនៃការប្រកាន់មាំ ឬស្ថិតកំណាញ់នោះទេ ប៉ុន្តែជារឿងមារយាទប្រពៃ មិនប្រហែសធ្វេស ។ ទ្រព្យសម្បត្តិដែលបានមកប្រកបដោយធម៌ ជាផលនៃឧដ្ឋានសម្បទា កាលណាបើគ្រប់គ្រងការពារបានល្អ វាធ្វើឱ្យមានលំនឹងក្នុងការងារដែលស្អាតស្អំ ដោយមិនគិតរាយមាយក្នុងការងារប្រចាំថ្ងៃ មិនមែនមិនឱ្យអស់ខ្លះទៅនោះទេ តែកុំឱ្យអស់ក្នុងអបាយមុខ កុំឱ្យអស់ដោយការធ្វេសប្រហែសផ្សេងៗ មិនមែនប្រឆាំងជាមួយធម៌អនិច្ចំទេ ប៉ុន្តែអារក្ខសម្បទាមានឧបការៈជួយដល់ឧដ្ឋាន-សម្បទា ក្នុងការប្រឆាំងជាមួយមិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតមិនបរិសុទ្ធរបស់ខ្លួនឯង ។

អារក្ខសម្បទាមិនមែនបដិសេធចោលនូវធម៌ជាអនត្តា ដែលថាមិនមែនតួខ្លួន មិនមានអ្វីជារបស់ខ្លួននោះទេ អនត្តាគឺជាលក្ខណៈនៃបរមត្ថធម៌ ឯចំណែកអារក្ខសម្បទាគឺជាមារ-យាទប្រពៃ ប្រព្រឹត្តទៅជាមួយមហាកុសលច្រើនបែប មានបញ្ញត្តិជាអារម្មណ៍ ។ មារយាទប្រពៃក្នុងការថែទាំរក្សានូវ



ទ្រព្យសម្បត្តិ ជាបុព្វហេតុនៃការធ្វើទានដោយគោរព រក្សាសីលដោយគោរព និង គោរពក្នុងបុណ្យកុសលផ្សេងៗទៀតផ្ទុយមកវិញ មនុស្សអត់មារយាទគឺមារយាទអន់ រមែងខ្ជីខ្ជាខ្ជះខ្ជាយនូវទ្រព្យសម្បត្តិ មិនប្រយ័ត្នត្រូវបាត់បង់ ឯចំណែករបស់ប្រើប្រាស់ ប្រើដៃធ្ងន់នាំឱ្យឆាប់ខូចខាត បានលុយមកសង្វាតរកថ្មី សូម្បីមុខរបររកទទួលទានក៏មិនឆ្លាត រកចេះតែខាត ទិញអស់លុយច្រើន លក់ទៅវិញបានលុយតិច ឃើញថាប្រឹងណាស់ដែរ ប៉ុន្តែជំពាក់ប្រាក់គេជុំទិស ម្ល៉ោះហើយមានទឹកចិត្តឯណាក្នុងការធ្វើទានរក្សាសីល ដូច្នេះមារយាទអន់ចូលក្នុងប្រធាននៃសេចក្តីវិនាស ។

អារក្ខសម្បទា គឺជាកិច្ចការដើម្បីប្រយោជន៍ក្នុងជីវិតបច្ចុប្បន្ន ជារបងឬជាអ្នកយាម ឱ្យបានគង់វង់នូវទ្រព្យសម្បត្តិសម្រាប់រស់ ជាកាំជណ្តើរឡើងទៅរកប្រយោជន៍អនាគត និងប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុត បានដល់ការរំលត់ទុក្ខទាំងពួង ។

អារក្ខសម្បទា ប្រៀបដូចជាភរិយាដែលជានារីគ្រប់លក្ខណ៍ មានមារយាទល្អ ចេះទុកដាក់ថែទាំនូវទ្រព្យសម្បត្តិ

ដែលស្វាមីស្វែងរកបានមក ឯចំណែកឧដ្ឋានសម្បទា ប្រៀបដូច ស្វាមីដែលប្រឹងប្រែងខ្មីឃ្មាត ធ្វើការប្រមូលទ្រព្យចិញ្ចឹមបុត្រ ភរិយាដោយល្អ ។

**៣-កល្យាណមិត្តតា** ជាអ្នកមាននូវមិត្តល្អ ជ្រើសរើស មនុស្សសម្រាប់សេពគប់ ដាច់ខាតត្រូវប្រយ័ត្នឱ្យណាស់ កុំឱ្យ សេពគប់ជាមួយមនុស្សផ្តេសផ្តាស ។

មិត្តល្អមានឧបការៈជួយឱ្យកិច្ចការបានសម្រេច ជួយ មិនឱ្យបាត់បង់នូវការងារល្អ ជួយដល់សម្បទាទាំងពីរខាងដើម ឱ្យកាន់តែចម្រើន ខ្ញុំព្រះករុណា ខ្ញុំបាទបានសរសេរច្រើនហើយ អំពីមិត្តប្លមនិងមិត្តល្អ ក្នុងសៀវភៅ**មនុស្សជាមួយនឹងការងារ** ដូច្នេះក្នុងសៀវភៅនេះមិនបានអធិប្បាយច្រើនទេ គ្រាន់តែ បញ្ជាក់ពួកធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង អំពី ប្រយោជន៍បច្ចុប្បន្នទាន់ភ្នែកតែប៉ុណ្ណោះ ។

ប្រយោជន៍គ្រប់យ៉ាងដែលត្រូវបានសម្រេច រមែង សម្រេចអំពីការងារដោយសេចក្តីប្រឹងប្រែងធ្វើការ មិនមែន បានមកអំពីការខ្ជិលច្រអូសឡើយ សូម្បីតែនៅក្នុងរឿង



កល្យាណមិត្តនេះ ក៏ព្រះសម្មាសម្ពុទ្ធត្រាស់សំដែងរឿយៗ អំពី គុណប្រយោជន៍ទាំងផ្លូវលោកទាំងផ្លូវធម៌ ដើម្បីឱ្យពុទ្ធបរិស័ទ យកចិត្តទុកដាក់ក្នុងរឿងសេពគប់ ត្រូវមានស្មារតីប្រឹងប្រែង ប្រុងប្រយ័ត្នក្រែងលោះបៀបដូចអជាតសត្រូ ដែលត្រូវទោស អនន្តរិយកម្ម ព្រោះសេពគប់ជាមួយទេវទត្ត ។

វល្លិល្វីងសោះទេ ប៉ុន្តែក្លាយទៅជាតំណាប់ ព្រោះនៅ ជាមួយស្កុរ សេះល្អទៅជាខ្ចកជើងព្រោះរៀនដើរតាមម្ចាស់ដឹក មុខ ដែលម្ចាស់នោះខ្ចកជើង សូម្បីគេមិនបានបង្រៀនវាក៏ ដោយ តែនេះព្រោះការនៅរួមជាមួយ ឬម្យ៉ាងទៀតដូចជា ផ្លែឈើឬផ្កាឈើ ក៏អាចកាត់ឆ្លងគ្នាបាន ដោយអំណាចការដុះ នៅជិតគ្នាដែរ ចាំបាច់និយាយថ្វីចំពោះមនុស្ស ដែលតែងតែ និយមធ្វើតាមៗគ្នានោះ ។

បុរសម្នាក់ត្រូវស្លាប់ដោយសារការយកខ្លាឃ្មុំជាមិត្ត នេះ តាមរឿងនិទាន ដែលមានសេចក្តីថា មានបុរសម្នាក់ត្រូវការ ដេកក្នុងព្រៃ ទុកឱ្យខ្លាឃ្មុំជាមិត្តនៅយាមការពារ ពេលគាត់ ដេកលក់ទៅ ក៏មានសត្វល្អិតមួយហើរមកទំខ្លួនគាត់ ខ្លាឃ្មុំយក

ចិត្តទុកដាក់ដេញសត្វល្អិតនោះណាស់ ប៉ុន្តែសត្វល្អិតពុំព្រមហើរទៅឆ្ងាយសោះ ដេញចុះដេញឡើងវាបានហើរមកទំត្រង់ចុងច្រមុះនៃបុរសនោះឯង ខ្លាឃ្មុំនឹកខឹងនឹងសត្វល្អិតនោះជាខ្លាំង «យីអើ! អាព្រហើននេះស្មានថាអញមិនហ៊ានសម្លាប់ឯងឬ» រួចទៅខ្លាឃ្មុំបានលើកដុំថ្មយ៉ាងធំ គប់សម្លាប់សត្វល្អិតដែលទំត្រង់ច្រមុះនោះ ចំណែកមនុស្សក៏ត្រូវបែកក្បាលស្លាប់ទៅដែរ នេះជាគតិប្រាប់កុំឱ្យទុកចិត្ត ឬសេពគប់ជាមួយនឹងមនុស្សល្ងង់ខ្លៅ ។

**៤-សមជីវិតា** : មានការចិញ្ចឹមជីវិតស្មោះស្មើដោយប្រពៃ មិនត្បិតត្បៀតពេក ហើយក៏មិនខ្ជះខ្ជាយពេកដែរ ។

គំនិតលៃលកថ្លឹងថ្លែងបែងចែក គឺជាជញ្ជីងជីវិត ការរស់នៅត្រូវមានតុល្យភាពក្នុងរឿងចំណូលនិងចំណាយ ។ ចូលច្រើនចាយតិចក៏គង់អស់ ព្រោះរបស់មិនទៀង ទាំងទ្រព្យសម្បត្តិទាំងជីវិត ប៉ុន្តែបើចំណូលនោះវាតិច ក៏ត្រូវរឹតត្បិតទៅតាមហ្នឹងដែរ ចាយខ្ជះខ្ជាយពេកក៏មិនកើត ដូច្នេះត្រូវចេះលៃលកកុំឱ្យមានឈ្មោះថា កំណាញ់ក្រៀតក្រម៉ា ឬថាមនុស្សកញ្ជើធ្លុះ ។



របស់របរប្រើប្រាស់ត្រូវចេះសន្សំសំចៃ កុំឱ្យអ្វីៗរកតែចាស់មិនទាន់ រហ័សរហាន់រកថ្មី ត្រូវចេះលៃលកទុកដាក់សម្រាប់ការពារពេលមានវិបត្តិផ្សេងៗ មិនមែនហាមមិនឱ្យចាយទេ ប៉ុន្តែកុំឱ្យសប្បាយតែពីរឿងចាយពេក របស់មានប្រើហើយប្រើសិនទៅ, បើថាប្រាក់នោះវាច្រើនណាស់ ក៏លៃលកធ្វើទានជួយអ្នកអត់អ្នកឃ្លាន ឬក៏ជួយដល់សង្គមក្រុមគ្រួសារ ឬថាសង្គមធំៗតទៅទៀតទៅ ។

មានមនុស្សច្រើនណាស់ កាលដែលមិនទាន់សម្បូររបស់ប្រើប្រាស់ ផ្ទះតូចអាចនៅបាន ដល់ទៅត្រូវរកលុយបានក៏ភ្លើតភ្លើននឹងសម្ភារៈ ផ្ទះតូចក៏ចង្អៀត ផ្ទះធំក៏ចង្អៀត ផ្ទះល្វែងថានៅមិនស្រួល ព្រោះវាហប់ ម្យ៉ាងទៀតថាព្រោះវានៅជាប់គ្នា គ្រឹះស្ថានថានៅមិនបានដែរ ព្រោះវាអ៊ូអែពេក ។ល។ ការមិនស្កប់ស្កល់ធ្វើឱ្យមនុស្សដោះបំណុលពុំរួច ត្រូវជំពាក់បំណុលកាមតណ្ហារហូត ។

សម្បទា៤យ៉ាងសម្រាប់ប្រយោជន៍បច្ចុប្បន្ន ជាការបញ្ជាក់ថា ព្រះពុទ្ធសាសនាមិនមែនប្រដៅមនុស្សឱ្យខ្ជិលទេ

ប៉ុន្តែប្រដៅឱ្យមនុស្សឧស្សាហ៍ព្យាយាមក្នុងផ្លូវត្រូវ ប្រដៅឱ្យមនុស្សមាននូវមារយាទល្អ ឱ្យមនុស្សចេះស្គាល់មនុស្សដែលគួរសេពគប់ឬមិនគួរ ព្រមទាំងប្រដៅឱ្យចេះស្គាល់ខ្លួនឯង ឱ្យចេះគោរពតួនាទីរបស់ខ្លួន ដឹងប្រមាណក្នុងការរស់នៅ ។

មនុស្សយើងរមែងប្រាថ្នា សុំឱ្យអាត្មាអញបាននូវភោគសម្បត្តិ បើបានមកប្រកបដោយធម៌រឹងរឹតតែប្រសើរ បំណងប្រាថ្នានេះ វាជាធម្មជាតិតែងមានជាធម្មតា សម្រាប់មនុស្សគ្រប់គ្នា បំណងប្រាថ្នានេះជាបរមត្ថធមិ ពុំមែនជាបុគ្គលណាឡើយ នេះជាបំណងប្រាថ្នាទី១ ។

មនុស្សយើងសម្បូរភោគសម្បត្តិហើយ សេចក្តីប្រាថ្នាពុំចប់ឡើយ នៅប្រាថ្នាសុំឱ្យអាត្មាអញប្រកបដោយយស ទោះជាកិត្តិយសក្តី បរិវារយសក្តី ឥស្សរិយយសក្តី ក៏មានសេចក្តីពេញចិត្តទាំងអស់ រួចទៅនៅប្រាថ្នាញាតិមិត្តព្រមទាំងកូនចៅទៀតផង នេះជាបំណងប្រាថ្នាទី២ ។

ទ្រព្យសម្បត្តិសម្បូរហើយ ព្រមទាំងយសសព្វគ្រប់ទាំងអស់ មានពួកញាតិ មានពួកគាំទ្រ មានកូនមានចៅ ប៉ុន្តែនៅ



ប្រាថ្នាសុំឱ្យអាត្មាអញអាយុវែង រស់នៅបានយូរ នេះជាបំណងប្រាថ្នាទី៣ ។

បំណងប្រាថ្នាទី៤ គឺក្រោយអំពីអាត្មាអញស្លាប់ទៅ សុំឱ្យបានទៅកាន់សុគតិភពទេវលោក ។ នេះឯងជាបំណងប្រាថ្នាជាទីត្រូវការ ជាទីស្រឡាញ់ ជាទីពេញចិត្ត រកបានដោយកម្រក្នុងលោកគឺ ចំពោះវត្ថុបំណងទាំង៤យ៉ាង ។

សម្បទា៤ យ៉ាងគឺ : សទ្ធាសម្បទា១ , សីលសម្បទា១ , ចាគសម្បទា១ និង បញ្ញាសម្បទា១ ជាហេតុនាំឱ្យបានសម្រេចនូវវត្ថុបំណង ៤ប្រការ ដូចដែលបានរៀបរាប់រួចហើយ បើសម្បទា ៤យ៉ាងនេះ មានអំពីជាតិមុនៗមក ក៏នាំឱ្យបានសម្រេចនូវវត្ថុបំណង ៤ប្រការក្នុងជាតិនេះ បើមានក្នុងជាតិនេះក៏ឱ្យសម្រេចប្រយោជន៍ទាំងក្នុងជាតិនេះ ទាំងក្នុងជាតិមុខវែងឆ្ងាយ ដូច្នេះសម្បទា ៤យ៉ាង គឺជាទីពឹងរបស់សត្វទាំងឡាយនៅពេលជិតស្លាប់ផង ជាទីពឹងក្នុងលោកខាងមុខទៀតផង ។

អត្ថបទពោលអំពីសេចក្តីសន្តោសនេះ ជាធម្មទានជួយឱ្យមនុស្សរស់នៅក្នុងសេចក្តីស្ងប់ សប្បាយជាប្រក្រតីក្នុងជីវិត

រាល់ៗថ្ងៃ មិននៅក្នុងការគ្របសង្កត់របស់លោភៈ មានសេចក្ដីក្សេមក្សាន្ត ព្រោះបាននូវគំនិតយល់ត្រូវ មានចិត្តសន្ដោសចេះសុំខមាទោស ចេះឱ្យអភ័យមានអធ្យាស្រ័យយោគយល់ ជាចិត្តមិនមានរោគ មិនមានទោស ជាចិត្តឆ្លាត ពោរពេញដោយកុសលមានផលជាសុខ, ចិត្តដែលមាននូវសេចក្ដីសន្ដោសចេះអនុគ្រោះអ្នកដទៃ មិនប្រណាំងវាសនា តម្កល់ជីវិតក្នុងគុណធម៌ និងមានសទ្ធាប្រារព្ធសេចក្ដីព្យាយាម ។

**សុភាសិតបណ្ឌិតប្រៀនប្រដៅ**

-អ្នកបរិភោគកាមជាគ្រហស្ថ បើខ្ជិលច្រអូសនោះពុំល្អ
បួសជាបព្វជិតភេទបវរ សង្រួមតាមធម៌ទើបប្រពៃ ។
-ព្រះរាជាឥតពិចារណា មុនធ្វើកិច្ចការឥតសិរី
បណ្ឌិតនៅក្រោធខ្វះខន្តី
ពុំមានសល់អ្វីដែលល្អឡើយ។



# មេត្តា

ដើម្បីជាការរស់នៅដោយសេចក្ដីសុខស្ងប់ ត្រជាក់ចិត្តសប្បាយក្នុងជីវិតប្រចាំថ្ងៃ ក៏ត្រូវអាស្រ័យមេត្តាចិត្តរបស់ខ្លួនឯង មានប្រក្រតីនៅដោយសេចក្ដីអត់ធន់ មានស្មារតីដាស់តឿនខ្លួនឯង ឱ្យឃើញទោសរបស់ទោសៈ ចេះនឹករលឹកឃើញរឿយៗ នូវគុណគឺសេចក្ដីល្អរបស់អ្នកដទៃ ដើម្បីស្ងប់សេចក្ដីខឹងក្រោធ ។

**សេចក្ដីអត់ធន់** គឺទ្រាំមិនក្រោធខឹងបាន ជាសក្ការបូជាដ៏ឧត្ដម សម្រាប់បូជាថ្វាយដល់ព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ជំនួសការក្រោធខឹងគឺចិត្តត្រជាក់ដោយមេត្តា ការចម្រើនមេត្តាចិត្ត ត្រូវមានសេចក្ដីអត់ធន់ជាប្រចាំ សេចក្ដីអត់ធន់មិនត្រឹមតែនាំឱ្យចម្រើននូវមេត្តាប៉ុណ្ណឹងទេ រមែងឱ្យចម្រើននូវគ្រប់កុសលធម៌ទាំងអស់ ញ៉ាំងកុសលកម្មគ្រប់យ៉ាងឱ្យសម្រេចបានល្អប្រពៃទៀតផង ។

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការនៃអ្នកប្រាជ្ញ បណ្ឌិត អ្នកប្រាជ្ញល្អរុងរឿងដោយសេចក្តីអត់ធន់ បើពពួកជនទាំងឡាយប្រដាប់កាយ ដោយមាសដោយពេជ្រ ឬដោយកែវមណី ប៉ុន្តែខ្វះខន្តីគឺសេចក្តីអត់ធន់ មិនល្អសោះឡើយ ដូច្នេះ សូមមនុស្សទាំងឡាយស្វែងយល់អំពីគ្រឿងអលង្ការ ដែលធ្វើឱ្យល្អទាំងតាមផ្លូវកាយ ទាំងតាមផ្លូវវាចា ទាំងជាអលង្ការរបស់ចិត្តបានដល់ធម៌ខន្តីនេះឯង ឱ្យបានជាក់ច្បាស់ប្រាកដ ។

សេចក្តីអត់ធន់ ជាគ្រឿងដុតបំផ្លាញនូវបាបទាំងឡាយទាំងពួង បើយើងខ្លាចបាប ឬថាបាបមិនជាទីពេញចិត្តរបស់យើងទេនោះ យើងត្រូវដុតបាបឱ្យឆេះខ្ទេចខ្ទី វិនាសអស់អំពីសន្តាន ដោយសេចក្តីអត់ធន់ មានមនុស្សក្នុងសាសនាដទៃសូម្បីមុនព្រះពុទ្ធបានត្រាស់ ឬក្រោយមកនោះ គេនិយមដេកឆ្អើរភ្លើង ដើម្បីឱ្យអស់កិលេស ប៉ុន្តែក្នុងសេចក្តីនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បដិសេធ ព្រោះមិនមែនជាឧបាយវិធីកំចាត់កិលេសបំបាត់ទុក្ខបាននោះឡើយ ព្រះអង្គទ្រង់ត្រាស់អំពីខន្តីគឺសេចក្តីអត់ធន់ ទើបជាគ្រឿងដុតបំផ្លាញនូវកិលេសក្នុងសន្តានបានពិតប្រាកដ ។



សេចក្តីអត់ធន់ គឺជាកម្លាំងរបស់សមណៈ សមណៈដែលស្ងប់រម្ងាប់នូវបាបបាន ព្រោះកម្លាំងនៃសេចក្តីអត់ធន់ ទង់ជ័យរបស់សមណៈដែលច្បាំងឈ្នះនូវកិលេស គឺសេចក្តីអត់ធន់ ចំណេះវិជ្ជាដ៏កំពូលក្នុងរឿងជីវិត អាចមានកម្លាំងទប់ចិត្តមិនឱ្យញាប់ញ័រ គឺសេចក្តីអត់ធន់ ខន្តីគឺសេចក្តីអត់ធន់ រមែងនាំមកនូវសេចក្តីសុខគួរជាទីពេញចិត្ត នាំមកនូវការព្រមព្រៀងរវាងពួកក្រុម អ្នកផងទាំងពួងចូលចិត្តគោរពរាប់អាន សម្បូរមិត្តចិត្តល្អក្រសត្រូវ រស់នៅជាសុខគ្រប់ឥរិយាបថ ប្រាកដផលល្អលើសលប់ក្រៃលែង សម្រេចនូវប្រយោជន៍ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ទាំងបរមត្ថប្រយោជន៍ គឺត្រាស់ដឹងនូវសច្ចធម៌ ។

សេចក្តីអត់ធន់ប្រព្រឹត្តទៅបាន ក៏ដោយអាស្រ័យការសិក្សាអំពីរឿងសត្វលោក និង រឿងរបស់សង្ខារលោក មានការឃើញត្រូវដោយប្រពៃ ចំពោះអ្វីៗដែលមានការកើតឡើង

ជាធម្មតា ដូចជាវាចាគឺពាក្យសម្តីរបស់បុរសស្ត្រីដែលតែងតែនិយាយ ពេលខ្លះមានប្រយោជន៍ ពេលខ្លះក៏និយាយឥតប្រយោជន៍ ជួនកាលនិយាយពាក្យពិត ជួនកាលនិយាយមិនពិត ពាក្យសម្តីពេលខ្លះត្រូវកាលសម្រាប់និយាយ ពេលខ្លះនិយាយខុសកាលខុសពេលវេលា ដោយឡែកទៀត ក្នុងលោកនេះរមែងមានពាក្យពីរោះ មានមិនពីរោះជាធម្មតា ខ្លះនិយាយដោយចិត្តមេត្តា ខ្លះទៀតនិយាយដោយឥតមេត្តា នេះជាវាចាតែងមានក្នុងលោក សរុបមក ពាក្យសម្តីដែលមិនល្អដោយប្រការណាមួយក៏ដោយ អ្នកដឹងច្បាស់នូវរឿងក្នុងលោក រមែងស្ងប់រម្ងាប់ចិត្ត មិនទាស់ទែងអ្វីឡើយ មានខន្តីជាកម្លាំងដ៏ប្រសើរ ។

វាចាមិនល្អ ៥យ៉ាងណាមួយនោះ ដូចដែលបានរៀបរាប់ហើយ គ្រាន់តែប្រៀបដូចគប់ភ្លើងតូចមួយ យកទៅកំដៅទឹកទន្លេគង្គា ដែលកំពុងតែជន់ពេញព្រៀបមាត់ច្រាំងតែប៉ុណ្ណោះ ព្រោះទឹកចិត្តបណ្ឌិតអ្នកមានសេចក្តីអត់ធន់ ជន់ជោរដោយទឹក



ចិត្តមេត្តា មិនបានក្តៅដោយសារវាចាមិនល្អទាំងអស់នោះឡើយ ។

ម្យ៉ាងទៀត ប្រៀបដូចគេគូររូបនឹងអាកាស ដោយសេចក្តីថា អាកាសមិនបានប្រឡាក់ដោយពណ៌ទាំងឡាយយ៉ាងណា ចិត្តមានអំណត់អត់ធន់ប្រកបដោយមេត្តា ក៏ដូចជាអាកាសអ៊ីចឹងដែរ គឺមិនប្រឡាក់ដោយការថ្នាំងថ្នាក់អាក់អន់ ឬទោមនស្សចំពោះពាក្យសម្តីមិនល្អណាមួយឡើយ ។

ក៏ដូចជាផែនដី ដែលគេមិនងាយធ្វើឱ្យទៅជាមិនមែនផែនដី ទោះជាបុរសស្ត្រីខំប្រឹងជីកដីដោយចបយ៉ាងណា ដោយក្នុងបំណងថាធ្វើផែនដីឱ្យវិនាស ក៏ផែនដីនៅតែជាផែនដីដដែល យ៉ាងណា ចិត្តមានអំណត់អត់ធន់ប្រកបដោយមេត្តា ជាចិត្តធំទូលាយ ដល់នូវសភាពធំដូចផែនដី ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ មានសត្វលោកទាំងអស់ជាអារម្មណ៍នៃមេត្តា ក្នុងសេចក្តីនេះព្រះ-សម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងហើយ ។

**ក្នុងកកចូបមសូត្រ** មានឱវាទនៃព្រះពុទ្ធអង្គដែល

ប្រៀបដោយរណារ (**ឥឥច** ប្រែថារណារ) ដូចព្រះពុទ្ធដីកាសម្ដែងតទៅថា ម្នាលភិក្ខុទាំងឡាយ បើពួកចោរដែលប្រព្រឹត្តអាក្រក់ នាំគ្នាអារអវយវៈតូចធំរបស់អ្នកទាំងឡាយ ដោយរណារដែលមានដងទាំងសងខាង ភិក្ខុណាមួយ ញុំាងចិត្តឱ្យប្រទូស្តចំពោះចោរទាំងអម្បាលនោះ ភិក្ខុនោះមិនឈ្មោះថាជាអ្នកធ្វើតាមសាសនារបស់តថាគតឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សា ក្នុងការបៀតបៀនរបស់ចោរនោះថា ចិត្តរបស់យើង នឹងមិនប្រែប្រួលផង យើងនឹងមិនបញ្ចេញវាចាអាក្រក់ផង ជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង និងជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ដល់នូវសភាពធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឱ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីធ្វើទុកក្នុងចិត្ត



ចំពោះឱវាទដែលប្រៀបដោយរណារនេះឯង ឱ្យរឿយៗចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនឃើញគន្លងនៃពាក្យតូចឬធំនោះ ដែលនាំឱ្យអ្នកទាំងឡាយអត់សង្កត់មិនបានទេឬ? បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះករុណាមិនឃើញគន្លងនៃពាក្យនោះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើទុកក្នុងចិត្ត ចំពោះឱវាទដែលប្រៀបដោយរណារនេះឯងឱ្យរឿយៗចុះ ការធ្វើទុកក្នុងចិត្តនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់អ្នកទាំងឡាយអស់កាលជាយូរអង្វែង ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ សម្ដែងត្រង់មេត្តាព្រហ្មវិហារ បានប្រាប់ឱ្យរលឹកដល់បុព្វចរិយា របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីប្រដៅខ្លួនឯងកុំឱ្យមានសេចក្ដីខឹងក្រោធ ព្រោះដោយអំណាចការគោរពព្រះបរមសាស្ដា មានការរលឹកដល់សេចក្ដីអត់ធន់កាលដែលព្រះអង្គនៅជាខន្តិវាទិតាបសជាដើម ។

ព្រះបរមសាស្ដា កាលព្រះអង្គគង់ប្រថាប់នៅនាព្រះជេតវ័នមហាវិហារ ទ្រង់ប្រារព្ធភិក្ខុមួយអង្គដែលច្រើន

ដោយសេចក្ដីខឹងក្រោធ ទើបត្រាស់នូវព្រះធម៌ទេសនាជាឱវាទ ព្រមទាំងព្រះជាតកផង ព្រះអង្គទ្រង់ត្រាស់ចំពោះភិក្ខុនោះថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនារបស់ព្រះពុទ្ធជាម្ចាស់ ដែលជាបុគ្គលមិនក្រោធ ព្រោះហេតុអ្វី ទើបអ្នកធ្វើនូវសេចក្ដីខឹងក្រោធដូច្នេះទៅវិញ បុរាណបណ្ឌិតទាំងឡាយ កាលគ្រឿងប្រហារទាំងពាន់ ធ្លាក់ចុះលើរាងកាយ កាលត្រូវគេកាត់ដៃកាត់ជើង កាត់ច្រមុះ កាត់ស្លឹកត្រចៀក ក៏នៅតែមិនក្រោធដល់អ្នកដទៃ រួចហើយទ្រង់នាំយករឿងក្នុងអតីតៈ មកសម្ដែងជាការសម្រេចនូវសេចក្ដីដូចតទៅនេះ :

ក្នុងអតីតកាល ព្រះបាទកាសីព្រះនាមថា **កលាពុ** គ្រងរាជសម្បត្តិនៅក្នុងនគរពារាណសី ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ មានទ្រព្យសម្បត្តិ ៨០កោដិ ជាមាណពឈ្មោះថា **កុណ្ឌលកុមារ** ។ ព្រះពោធិសត្វចម្រើនវ័យហើយ បានរៀននូវសិល្បៈគ្រប់យ៉ាងក្នុងនគរតក្កសិលា កាលមាតាបិតាធ្វើកាលកិរិយាទៅ ក៏នៅគ្រប់គ្រងទ្រព្យសម្បត្តិដោយខ្លួនឯង ។ ព្រះពោធិសត្វបានសម្លឹងមើលនូវ



គំនរទ្រព្យ ហើយគិតថា ញាតិទាំងឡាយរបស់យើងធ្វើទ្រព្យឱ្យកើតឡើង ហើយមិនបានកាន់យកទៅឡើយ ប៉ុន្តែយើងគួរនឹងកាន់យកនូវទ្រព្យនេះទៅ ទើបចាត់ចែងទ្រព្យសម្បត្តិទាំងអស់ ឱ្យដល់បុគ្គលដែលគួរឱ្យ ដោយអំណាចនៃទាន ហើយចូលទៅកាន់ព្រៃ ហិមពាន្ត បួសជាតាបស ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយផលាផល គឺផ្លែឈើតូចធំក្នុងព្រៃភ្នំ ។

ពេលវេលាកន្លងទៅជាយូរណាស់ ដែលព្រះបរមពោធិសត្វចិញ្ចឹមជីវិតដោយផ្លែឈើ កាលត្រូវការនូវរសជូររសប្រៃ ទើបនិមន្តទៅកាន់ដែនដីដែលមនុស្សរស់នៅ ដល់នគរពារាណសីដោយលំដាប់ រួចហើយបានអាស្រ័យនៅ ក្នុងព្រះរាជឧទ្យាន ។ ថ្ងៃស្អែកឡើង ក៏ត្រាច់ស្វែងរកនូវភិក្ខាក្នុងនគរ ដល់ទ្វារនៃនិវេសន៍របស់សេនាបតី ចំណែកសេនាបតីក៏បានជ្រះថ្លា ក្នុងឥរិយាបថរបស់ព្រះបរមពោធិសត្វនោះឯង បាននិមន្តឱ្យចូលទៅក្នុងផ្ទះ ឱ្យឆាន់នូវភោជនដែលគេចាត់ចែងទុកសម្រាប់ខ្លួន ឱ្យបានទទួលនូវការអនុញ្ញាតហើយ ក៏អាស្រ័យនៅក្នុងព្រះរាជឧទ្យាននោះឯង ។

ថ្ងៃមួយព្រះបាទ**កលាបុ**ទ្រង់ស្រវឹងទឹកច័ណ្ឌ (ទឹកក្តៅរោលរាលបានដល់សុរា) មានស្រីស្នំហែហម ស្តេចយាងទៅកាន់ព្រះរាជឧទ្យាន ដោយព្រះឥស្សរិយយសដ៏ខ្ពង់ខ្ពស់ ឱ្យក្រាលកម្រាលព្រះបន្ទំ លើផែនសិលាដែលជាមង្គល ហើយទ្រង់ព្រះបន្ទំកើយភ្លៅរបស់ស្រីស្នំម្នាក់ ក្នុងទីនោះឯង ចំណែកស្ត្រីអ្នករាំទាំងឡាយ ឆ្លាតក្នុងការច្រៀង ឆ្លាតក្នុងការប្រគំ ឆ្លាតក្នុងការរាំ ក៏ប្រកបការច្រៀងរាំជាដើមក្នុងទីនោះៗដែរ ព្រះបាទ **កលាបុ** ទ្រង់មានសម្បត្តិប្រៀបដូចសក្កទេវរាជ ស្តេចទ្រង់នូវព្រះបន្ទំលង់លក់ក្នុងពេលនោះទៅ ។

លំដាប់នោះ ស្ត្រីទាំងឡាយនាំគ្នាពោលថា ពួកយើងប្រកបការច្រៀងជាដើម ដើម្បីប្រយោជន៍ដល់ព្រះរាជាណា ព្រះរាជានោះក៏ទ្រង់បន្ទំលក់ទៅហើយ ប្រយោជន៍អ្វីដល់ពួកយើងក្នុងការច្រៀងរាំនេះ ទើបនាំគ្នាចោលគ្រឿងតូរ្យតន្ត្រីមានពិណជាដើម ទុកក្នុងទីនោះៗ ហើយគេចចេញទៅកាន់ទីផ្សេងៗ ត្រូវផ្កាឈើ ផ្លែឈើ និង ស្លឹកឈើជាដើមលួងលោមចិត្ត ទើបអភិរម្យនៅក្នុងព្រះរាជឧទ្យាននោះឯងទៅ ។



ក្នុងកាលនោះ ព្រះពោធិសត្វអង្គុយនៅដូចដំរីដ៏ប្រសើរញ៉ាំងពេលវេលាឱ្យកន្លងទៅ ដោយសេចក្តីសុខក្នុងបព្វជ្ជា នៅនាគល់ដើមសាលព្រឹក្ស មានផ្ការីកស្គុសស្គាយ ពេលនោះស្រីស្នំរបស់ព្រះរាជា ក៏បានជួបនឹងព្រះពោធិសត្វ រួចក៏បាននិយាយគ្នាថា មកពួកយើងទាំងអស់គ្នា លោកម្ចាស់របស់យើងជាបព្វជិត អង្គុយនៅត្រង់គល់ឈើនោះ ពួកយើងនាំគ្នាទៅអង្គុយជុំវិញ គង់តែនឹងបានស្តាប់ពាក្យអ្វីៗ អំពីលោកម្ចាស់យើងពុំខានឡើយ ដូច្នេះហើយ ពួកនាងទាំងនោះទើបបានទៅថ្វាយបង្គំ ជុំវិញព្រះពោធិសត្វ អង្គុយស្រួលបួលហើយទើបពោលថា សូមលោកម្ចាស់ពោលនូវអ្វីៗដែលគួរពោល ដល់ខ្ញុំម្ចាស់ទាំងឡាយ ព្រះពោធិសត្វក៏បានសម្តែងធម៌ដល់ស្ត្រីទាំងនោះ ។

គ្រានោះព្រះរាជាទ្រង់តើនចាកព្រះបន្ទំ ដោយស្រីស្នំម្នាក់នោះខ្វាំព្រះកាយ តើនឡើងពុំឃើញស្រីផ្សេងទៀតទាំងឡាយ ទើបត្រាស់សួរថា ពួកស្រីថោកទាបទាំងនោះទៅណាអស់ហើយ? នាងម្នាក់នោះទើបក្រាបទូលថា បពិត្រមហារាជពួកនាងទាំងអស់នោះទៅអង្គុយជុំវិញតាបសម្នាក់ក្នុងឧទ្យាន

នេះឯង ។ ព្រះរាជាទ្រង់ក្រោធ កាន់ព្រះខ័នហើយទ្រង់ប្រញាប់ទៅ ដោយតាំងព្រះទ័យថា នឹងកាត់ក្បាលរបស់ជដិលព្រហើននោះ លុះពេលស្តេចយាងទៅជិតដល់ ស្ត្រីទាំងនោះក៏បានដឹងថាព្រះរាជាទ្រង់ក្រោធ ក្នុងបណ្តាស្ត្រីទាំងអស់នោះ មានស្ត្រីម្នាក់ដែលព្រះរាជាទ្រង់សព្វព្រះទ័យជាងគេ បានស្ទុះទៅដណ្តើមព្រះខ័នអំពីព្រះរាជា លួងលោមឱ្យព្រះរាជាស្ងប់ព្រះទ័យ ។ ព្រះរាជាបានយាងទៅប្រថាប់ឈរក្នុងសំណាក់ព្រះពោធិសត្វហើយត្រាស់សួរថា សមណៈ លោកឯងមានវាទៈថាយ៉ាងដូចម្តេច? ព្រះពោធិសត្វទូលថា មហាបពិត្រ អាត្មាមានខន្តិវាទៈ ពោលសរសើរលើកតម្កើងនូវខន្តិ ។

**ព្រះរាជា –** ដែលឈ្មោះថាខន្តិនោះ គឺជាអ្វី?

**ព្រះពោធិសត្វ –** គឺការមិនក្រោធក្នុងពេលដែលគេជេរ គេវាយប្រហារ គេមើលងាយចំអកឡកឡឺយ ។

**ព្រះរាជា –** អើ! ឥឡូវនេះយើងនឹងបានឃើញការមានខន្តិរបស់លោកឯង ។ ហើយក៏បញ្ជាឱ្យហៅពេជ្ឈឃាតអ្នកសម្លាប់ចោរមក ពេជ្ឈឃាតនោះកាន់ពូថៅ និង រំពាត់បន្លា



តាមចរិតធម្មតារបស់ខ្លួន ស្លៀកពាក់សំពត់ជ្រលក់ពណ៌ក្រហម ពាក់ភួងមាល័យក៏ពណ៌ក្រហម មកថ្វាយបង្គំព្រះរាជា ហើយក្រាបទូលសួរថា ទូលបង្គំនឹងត្រូវធ្វើអ្វី?

**ព្រះរាជាត្រាស់ថា** អ្នកឯងចូរចាប់តាបសអាក្រក់ដូចចោរនេះ ទាញឱ្យដួលចុះទៅនឹងដី ហើយយករំពាត់បន្លារបស់ឯង វាយពីរពាន់រំពាត់ ទាំងមុខទាំងក្រោយ ទាំងសងខាងឆ្វេងស្តាំ ក្នុងពេលឥឡូវនេះភ្លាម ពេជ្ឈឃាតក៏បានធ្វើតាមព្រះរាជបញ្ជា ។

ស្បែកក្រៅរបស់ព្រះបរមពោធិសត្វត្រូវដាច់ ស្បែកក្នុងក៏ត្រូវខ្ទេចខ្ទី បែកខ្ចាយទាំងសាច់ ឈាមហូរជោកដី ដោយអាស្រ័យការទទួលរងនឹងរំពាត់បន្លា ដែលពេជ្ឈឃាតវាយពេញទំហឹងដៃក្នុងពេលនោះ ព្រះរាជាត្រាស់សួរទៀតថា តើលោកឯងមានវាទៈថាយ៉ាងម៉េចហាស់ ?

**ព្រះបរមពោធិសត្វ –** មហាបពិត្រ អាត្មាមានវាទៈលើកតម្កើងសរសើរខន្តិ ក៏ព្រះអង្គសំគាល់ថា ខន្តិមានក្នុងរវាងស្បែករបស់អាត្មាឬ ? តាមពិតខន្តិ មិនបានមានក្នុងរវាងស្បែក

របស់អាត្មាភាពឡើយ មហាបពិត្រ ខន្តិរបស់អាត្មាភាពតាំងនៅដោយចំពោះ ខាងក្នុងហឫទ័យ ដែលព្រះអង្គមិនអាចទតឃើញ ។ ពេជ្ឈឃាតទូលសួរទៀតថា បពិត្រព្រះសម្មតិទេពទូលបង្គំនឹងត្រូវធ្វើអ្វីទៀត?

**ព្រះរាជាត្រាស់បង្គាប់ថា** ចូរពេជ្ឈឃាតឯង កាត់ដៃទាំងសងខាងរបស់តាបសកំហូចនេះ ពេជ្ឈឃាតគ្រាន់តែបានឮព្រះរាជបញ្ជាភ្លាម ក៏លើកពូថៅយក្សកាប់គឹប១ ដាច់ដៃព្រះបរមពោធិសត្វ ត្រឹមកដៃទាំងពីរភ្លាមមួយរំពេច ពេលនោះព្រះរាជាត្រាស់ផ្ទួនភ្លាម១ថា កាត់ជើងទាំងសងខាងទៀត ពូថៅពេជ្ឈឃាតឥតប្រណី ជើងព្រះបរមពោធិសត្វក៏ត្រូវដាច់យ៉ាងទាន់ហន់ក្នុងពេលនោះដែរ ។

លោហិតហូរចេញចាកចុងដៃចុងជើងដែលដាច់ ដូចទឹកល័ក្តក្រហមហូរចេញអំពីឆ្នាំងធ្លុះអ៊ីចឹងឯង ។

**ព្រះរាជាត្រាស់សួរទៀតថា** លោកឯងមានវាទៈថាយ៉ាងម៉េចហាស់ ?

**ព្រះបរមពោធិសត្វទូលតបថា** មហាបពិត្រ អាត្មាមាន



វាទៈលើកតម្កើងសរសើរខន្តិ ក៏ព្រះអង្គសំគាល់ថា ខន្តិមាននៅត្រង់ចុងដៃចុងជើងនៃអាត្មា ប៉ុន្តែថាខន្តិនោះមិនមាននៅត្រង់កន្លែងហ្នឹងទេ គឺខន្តិរបស់អាត្មាតាំងនៅដោយចំពោះ ខាងក្នុងហឫទ័យជាកន្លែងដ៏ជ្រៅបំផុត មិនអាចកាត់ដាច់បានឡើយ ។

**ព្រះរាជាត្រាស់ថា**– ចូរកាត់ត្រចៀក និង ច្រមុះរបស់តាបសនេះ ពេជ្ឈឃាតក៏កាត់ស្លឹកត្រចៀក និង ច្រមុះ របស់ព្រះពោធិសត្វតាមព្រះរាជបញ្ជាឥតបង្អង់ដៃ ពាសពេញរាងកាយមានតែលោហិត ។

**ព្រះរាជាត្រាស់សួរទៀតថា**– ម្តេចដែរ តើលោកឯងមានវាទៈថាម៉េច ?

**ព្រះពោធិសត្វ**– មហាបពិត្រ អាត្មាមានវាទៈលើកតម្កើងសរសើរខន្តិ ប៉ុន្តែព្រះអង្គបានសំគាល់ថា ខន្តិតាំងនៅចំពោះចុងច្រមុះចុងត្រចៀក នៃអាត្មាភាពទៅវិញ តាមពិតខន្តិរបស់អាត្មាភាព តាំងនៅក្នុងហឫទ័យដ៏ជ្រៅឯណោះទេ ។

**ព្រះរាជាត្រាស់ថា**– យើស! ជដិលកោង ចាំងងើបអង្គុយមកពោលសរសើរ លើកតម្កើងខន្តិរបស់ឯងកន្លែងហ្នឹង

ចុះ រួចហើយយកព្រះបាទធាក់ជញ្ជ្រាំព្រះពោធិសត្វជាចុងក្រោ-យ ទើបស្ដេចចៀសចេញទៅ ។

កាលដែលព្រះរាជាស្ដេចចេញទៅបាត់ហើយ សេនាបតីជូតលោហិតអំពីរាងកាយរបស់ព្រះបរមពោធិសត្វ ហើយរើសប្រមូលចុងដៃចុងជើង ស្លឹកត្រចៀក និង ចុងច្រមុះ ទុកនឹងជាយសំពត់សាដក រួចបានសន្សឹមៗលើកគ្រាឱ្យព្រះពោធិសត្វអង្គុយ សេនាបតីថ្វាយបង្គំព្រះពោធិសត្វរួចហើយក៏បានពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើលោកម្ចាស់មានសេចក្ដីក្រោធ គួរក្រោធនឹងព្រះរាជាដែលជាអ្នកធ្វើខុសទៅចុះ មិនគួរក្រោធជាមួយនឹងអ្នកដទៃឡើយ ដើម្បីជាការអង្វរដល់ព្រះពោធិសត្វ លោកសេនាបតីទើបបានពោលនូវគាថាទី១ ថា :

**យោ តេ ហត្ថេ ច បាទេ ច កណ្ណនាសញ្ច ឆេទយិ**
**តស្ស កុជ្ឈ មហាវីរ មា រដ្ឋំ វិនស្ស ឥទំ ។**

បពិត្រលោកម្ចាស់មានព្យាយាមធំ បុគ្គលណាឱ្យកាត់ព្រះហស្ដទាំងពីរក្ដី កាត់ព្រះបាទទាំងពីរក្ដី កាត់ត្រចៀកនិងច្រមុះក្ដី របស់លោកម្ចាស់ សូមលោកម្ចាស់ក្រោធចំពោះតែនឹងបុគ្គលនោះចុះ សូមលោកម្ចាស់កុំញ៉ាំងដែននេះឱ្យវិនាសឡើយ។

បណ្ដាបទទាំងនោះ បទថា **មហាវីរ** ប្រែថា អ្នកមានសេចក្ដីព្យាយាមដ៏ធំធេង បទថា **មា រដ្ឋំ វិនស្ស ឥទំ** ដោយសេចក្ដីថា លោកម្ចាស់កុំធ្វើកាសិករដ្ឋដែលមិនមាននូវកំហុសនេះឱ្យវិនាសឡើយ ។

ព្រះបរមពោធិសត្វបានស្ដាប់ពាក្យរបស់សេនាបតីហើយទើបពោលនូវគាថាទី២ថា :

**យោ មេ ហត្ថេ ច បាទេ ច កណ្ណនាសញ្ច ឆេទយិ**
**ចិរំ ជីវតុ សោ រាជា ន ហិ កុជ្ឈន្តិ មាទិសា ។**

ព្រះរាជាអង្គណាដែលបង្គាប់ឱ្យកាត់ដៃទាំងពីរក្ដី កាត់ជើងទាំងពីរក្ដី កាត់ត្រចៀកនិងច្រមុះក្ដី របស់អាត្មាភាព សូមព្រះរាជាអង្គនោះ ទ្រង់មានព្រះជន្មយឺនយូរ បណ្ឌិតទាំងឡាយដូចយ៉ាងអាត្មាភាពមិនខឹងក្រោធឡើយ ។

បណ្ដាបទទាំងឡាយ បទថា **មាទិសា** ដោយសេចក្ដីថា បណ្ឌិតទាំងឡាយ ជាអ្នកប្រកបដោយកម្លាំងនៃខន្តិដូចយ៉ាងអាត្មាភាពរមែងមិនក្រោធខឹងថា បុគ្គលនេះបានជេរ

ប្រទេចយើង ពោលពាក្យមើលងាយមើលថោកដល់យើង ប្រហារយើង កាត់អវយវៈទំលាយរាងកាយរបស់យើង ដូច្នេះឡើយ ។

ក្នុងកាលដែលព្រះរាជាកលាបុ ស្តេចចេញចាកព្រះរាជឧទ្យាន ទើបតែកំបាំងគន្លងនៃចក្ខុរបស់ព្រះបរមពោធិសត្វប៉ុណ្ណោះ មហាប្រឹថពីដ៏សែនក្រាស់ក៏រហែកញែកជាពីរ អណ្តាតភ្លើងចេញអំពីអវីចីនរក លៀនមកចាប់ព្រះរាជា ដូចហ៊ុមដោយសំពត់កម្ពលក្រហម ព្រះរាជាត្រូវភ្លើងទាញចូលទៅក្នុងដី នៅត្រង់ទ្វារព្រះរាជឧទ្យាននោះឯង ហើយបានតាំងនៅដោយចំពោះក្នុងអវីចីមហានរក (ដោយកំណើតអកុសលវិបាក) ។

ព្រះពោធិសត្វក៏បានធ្វើកាលកិរិយា ក្នុងថ្ងៃនោះឯង ពួករាជបុរសនិងពួកអ្នកនគរទាំងឡាយ កាន់គ្រឿងក្រអូប ផ្កាឈើ ប្រទីប និង ធូប មកធ្វើឈាបនកិច្ច ចំពោះសរីរៈរបស់ព្រះបរមពោធិសត្វ ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងនូវព្រះគាថា ២គាថា បញ្ចប់សេចក្តីក្នុងរឿងនេះដូច្នេះថា :



**អហុ អតីតមទ្ធានេ សមណោ ខន្តិទីបនោ**
**តំ ខន្តិយាយេវ ឋិតំ កាសិរាជា អឆេទយិ ។**
**តស្ស កម្មផរុសស្ស វិបាកោ កដុកោ អហុ**
**យំ កាសិរាជា វេទេសិ និរយម្ហិ សមប្បិតោតិ ។**

សមណៈអ្នកសម្បូរដោយខន្តិ មានហើយក្នុងអតីតកាលដ៏យូរលង់ ព្រះបាទកាសីបានត្រាស់បង្គាប់ឱ្យចោរឃាតកៈសម្លាប់នូវសមណៈនោះដែលជាអ្នកតាំងនៅក្នុងខន្តិធម៌ ។

ព្រះបាទកាសីតាំងនៅក្នុងនរក សោយនូវផលនៃកម្មណា ផលនៃកម្មដ៏អាក្រក់នោះ ជាផលក្តៅក្រហាយ ។

បណ្តាបទទាំងនោះ បទថា **អតីតមទ្ធានំ** ប្រែថា ក្នុងអតីតកាលដ៏យូរអង្វែង បទថា **ខន្តិទីបនោ** បានដល់អ្នកដែលពោរពេញដោយអធិវាសនខន្តិ (អត់ទ្រាំបានដោយមិនខឹងក្រោធចំពោះអ្នកណាៗ) បទថា **អឆេទយិ** បានដល់បង្គាប់ឱ្យសម្លាប់ បទថា **សមប្បិតោ** បានដល់តាំងនៅចំពោះហើយ ។

ព្រះបរមសាស្តា គ្រាកាលព្រះអង្គនាំព្រះធម៌ទេសនា

នេះមកហើយ ទើបទ្រង់ប្រកាសនូវសច្ចធម៌ ហើយទ្រង់ប្រជុំជាតក ក្នុងពេលចប់សច្ចធម៌ ភិក្ខុដែលច្រើនដោយសេចក្តីក្រោធ ក៏បានសម្រេចនូវព្រះអនាគាមិផល ។

ព្រះបាទកាសីព្រះនាមកលាបុក្នុងគ្រានោះ បានមកជាព្រះទេវទត្ត ចំណែកសេនាបតីក្នុងគ្រានោះដែរ បានមកជាព្រះសារីបុត្រ រីឯតាបសដែលមានវាទៈលើកតម្កើងសរសើរនូវខន្តិ ក្នុងគ្រានោះ បានមកជាយើងតថាគត ដូច្នេះឯង ។

**ចប់ខន្តិវាទិជាតកព្រមដោយអដ្ឋកថា**

៨ ចូលច្រើនចាយតិចក៏គង់អស់ ត្បិតព្រោះរបស់វាមិនទៀង
ទំរាំឥតរកចាយដូចភ្លៀង តើគិតថាទៀងឬយ៉ាងណា? ។



# សេចក្តីអត់ធន់មានក្នុងជាតកផ្សេងៗ

ការដែលខន្តិវាទិតាបសជាមនុស្សធំ ហើយជាអ្នកបួសផងនោះ គប្បីធ្វើបានយ៉ាងនោះ រាប់ថាមិនអស្ចារ្យប៉ុន្មានឡើយ ប៉ុន្តែក្នុងចុល្លធម្មបាលជាតក ព្រះធម្មបាលកុមារពោធិសត្វ សូម្បីនៅជាក្មេងតូចអាយុ៧ខែ ក៏ត្រូវព្រះរាជាទ្រង់ព្រះនាម **មហាបតាប:** ជាបិតា ប្រើពេជ្ឈឃាតឱ្យកាត់ដៃកាត់ជើងដែរ ប៉ុណ្ណឹងហើយមិនទាន់គ្រប់គ្រាន់ល្មមនឹងព្រះទ័យខឹងក្រោធ នៅបង្គាប់ឱ្យកាត់ព្រះសិររបស់ព្រះពោធិសត្វទៀត ដោយត្រាស់ថា «អ្នកឯងចូរកាត់ក្បាលវាចោលទៅ» ព្រះបរមពោធិសត្វ កាលដែលតាំងនៅក្នុងសភាពបែបនេះនោះ ទើបដាស់តឿនខ្លួនឯងថា ឥឡូវនេះ គឺជាពេលដែលឯងធ្វើការសង្កត់ចិត្តខ្លួនឯង ទុកឱ្យតាំងមាំល្អហើយធម្មបាល អ្នកចូរជាបុគ្គលមានចិត្តស្មើក្នុងមនុស្សទាំង៤ គឺ ១-ព្រះបិតា ដែលជាអ្នកបង្គាប់ឱ្យកាត់ដៃកាត់ជើងនិងក្បាល ២-ពេជ្ឈឃាត ដែល

ធ្វើតាមតួនាទីរបស់ខ្លួន ៣-មាតាដែលកំពុងយំសោកពោលរៀបរាប់ថា បពិត្រព្រះសម្មតិទេព សូមលែងនូវធម្មបាលកូនខ្ញុំម្ចាស់មកវិញមក សូមកាត់ដៃ កាត់ជើង កាត់ក្បាល របស់ខ្ញុំម្ចាស់វិញចុះ និង ធម្មបាលខ្លួនឯងជាគំរប់៤ ព្រះបរមពោធិសត្វអធិដ្ឋាន **ខន្តីសមាទាន** គឺការសមាទានតាំងចិត្តឱ្យមាំខ្លាំង ប្រព្រឹត្តទៅស្មើក្នុងបុគ្គលទាំង៤ មិនយំមិនស្រែកអប់រំខន្តិ ចម្រើនមេត្តាឱ្យជាបុរេចារិក ។

រឿងរ៉ាវជាខាងដើមនៃព្រះជាតកនេះ គឺព្រះបាទមហាបតាបៈ គ្រងរាជសម្បត្តិនៅក្នុងនគរពារាណសី ចំណែកព្រះ-បរមពោធិសត្វ ក៏បានបដិសន្ធិក្នុងព្រះគភ៌នៃព្រះនាងចន្ទាទេវីដែលជាអគ្គមហេសីនៃព្រះបាទមហាបតាបៈនោះឯង ពេលដែលប្រសូតមក ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមដល់ព្រះពោធិសត្វថា **ធម្មបាល** ។ ក្នុងពេលដែលព្រះធម្មបាលនោះមានអាយុ៧ខែ ព្រះមាតាបានឱ្យស្រង់ទឹកដោយគ្រឿងក្រអូបដល់ព្រះពោធិសត្វ តែងព្រះអង្គហើយព្រះនាងប្រថាប់អង្គុយកម្សាន្តជាមួយនឹងបុត្រ ក្នុងពេលនោះ ព្រះរាជាស្តេចមក



កាន់ស្ថានទី ដែលព្រះទេវីគង់ប្រថាប់នៅ ព្រះទេវីកំពុងតែឱ្យព្រះពោធិសត្វជាបុត្រកម្សាន្តសប្បាយ ដែលព្រះនាងទ្រង់ពេញពោរទៅដោយសេចក្តីស្នេហាចំពោះបុត្រ សូម្បីបានឃើញព្រះរាជាស្តេចយាងមកហើយ ក៏ព្រះនាងពុំបានក្រោកឈរទទួលឡើយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឥឡូវនេះ នាងចន្ទាទេវីតម្កើងមានះប្រកាន់ខ្លួន ព្រោះអាស្រ័យបុត្រ មិនសំគាល់យើងក្នុងរឿងអ្វីៗឡើយ ក៏កាលបុត្រចម្រើនធំឡើងនាងនឹងមិនសំគាល់យើងថាជាមនុស្សក៏បានដែរ យើងនឹងសម្លាប់ធម្មបាលចោលក្នុងពេលនេះ ។

ព្រះរាជាមហាបតាបៈបានមកជាព្រះទេវទត្ត ព្រះនាងចន្ទាទេវីបានមកជាព្រះនាងមហាបជាបតិគោតមី ចំណែកធម្មបាលកុមារបានមកជាព្រះតថាគត ។

ការដែលព្រះធម្មបាលកុមារជាមនុស្ស ហើយធ្វើបានយ៉ាងនេះ ក៏រាប់ថានៅមិនទាន់អស្ចារ្យមែនទែនដែរ ប៉ុន្តែដូចដែលព្រះបរមពោធិសត្វ មានកំណើតជាសត្វតិរច្ឆាន ហើយអាចអត់ធន់មិនក្រោធបាន ទើបជាការអស្ចារ្យដ៏ក្រៃលែង ។

នៅក្នុង **ឆទ្ទន្តជាតក** ព្រះពោធិសត្វជាដំរី ទោះបីត្រូវព្រានបាញ់ដោយកូនព្រួញលាបដោយថ្នាំពិស ព្រួញពិសទម្លុះពោះព្រោះចូលតាមរន្ធនាភី (រន្ធផ្ចិត) យ៉ាងណាក្តី ក៏មិនបានញុំាងចិត្តឱ្យគិតប្រទូសរ៉ាយទៅរកព្រាន ដែលជាអ្នកធ្វើនូវសេចក្តីវិនាសឱ្យដល់ខ្លួនឡើយ កាលដែលព្រះពោធិសត្វបានដឹងថា ព្រះមហេសីរបស់ព្រះបាទកាសី បានបញ្ជូនព្រានមកព្រោះត្រូវការភ្លុកទាំងពីរ ដែលមានរស្មី៦ពណ៌នោះ ក៏ជួយឱ្យព្រានឆាប់អារភ្លុកទាំងពីរដាច់ នឹងប្រញាប់ឆាប់បានចេញអំពីទីនោះ ក្រែងលោដំរីដទៃមកទាន់ នឹងធ្វើសេចក្តីអន្តរាយដល់ព្រាន ។

នៅក្នុង **មហាកបិជាតក** ព្រះពោធិសត្វជាស្វាធំបានជួយបុរសម្នាក់ដែលធ្លាក់ក្នុងជ្រោះ កាលត្រូវបុរសដែលខ្លួនឯងជួយឱ្យរួចអំពីជ្រោះនោះ គប់ប្រហារដោយដុំថ្មចំត្រង់ក្បាល បំណងនឹងសម្លាប់យកសាច់បរិភោគ ក៏មិនបានញុំាងចិត្តឱ្យគិតប្រទូសរ៉ាយ ទៅរកមនុស្សអកតញ្ញូនោះដែរ នៅសម្លឹងមើលបុរសនោះដោយចិត្តអាណិត មិនគិតដល់សេចក្តីទុក្ខរបស់



ខ្លួនឡើយ យកដៃម្ខាងខ្ទប់របួស ហើយនាំផ្លូវបុរសនោះ បញ្ជូនទៅកាន់ទីដែលត្រូវទៅ ព្រោះបុរសនោះកាលដើមគឺដើរស្វែងរកគោដែលបាត់ រួចក៏វង្វេងផ្លូវត្រូវធ្លាក់ជ្រោះ ។

ក្នុង **ភូរិទត្តជាតក** ព្រះពោធិសត្វជានាគរាជឈ្មោះភូរិទត្ត អធិដ្ឋានឧបោសថសីល ហើយសំណាក់លើដំបូកមួយ ក្បែរមាត់ច្រាំងទន្លេយមុនា កាលត្រូវព្រាហ្មណ៍អាលម្ពាយប្រើថ្នាំ ព្រះពោធិសត្វក្តៅដូចត្រូវភ្លើងឆេះ តែព្រះពោធិសត្វពុំបានញុំាងចិត្តឱ្យក្រោធខឹងឡើយ ព្រោះខ្លាចខឹងក្រោធហើយ ធ្វើការប្រទូស្តតបទៅរកអាលម្ពាយ ត្រូវដាច់សីលដែលខំរក្សា ក្នុងកាលណោះព្រាហ្មណ៍អាលម្ពាយ បានធ្វើអំពើដ៏សាហាវព្រៃផ្សៃច្រើនប្រការទៀតណាស់ ដើម្បីចាប់ព្រះពោធិសត្វ យកទៅឱ្យមហាជនទស្សនា ដោយត្រូវការលាភផ្សេងៗ ។

ក្នុង **ចម្បេយ្យជាតក** វីសតិនិបាតក្តី **សង្ខបាល–ជាតក** ចត្តាឡីសនិបាតក្តី សុទ្ធតែមានសេចក្តីគួរឱ្យជ្រះថ្លាចំពោះព្រះបរមពោធិសត្វដែលមានកំណើតជាសត្វនាគ ធ្វើការ

រក្សាឧបោសថសីល ប្រព្រឹត្តតបះហាមឃាត់នូវសេចក្ដីក្រោធ គ្រប់គ្រងសីលមិនឱ្យវិនាស ដើម្បីឱ្យបានសម្រេចនូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺព្រះពោធិញ្ញាណ ។ ម្យ៉ាងទៀត មានសេចក្ដីគួរឱ្យយកចិត្តទុកដាក់ដ៏ក្រៃលែង ចំពោះកំណើតមនុស្សនេះ ព្រោះចម្បេយ្យនាគរាជក្នុងកាលណោះ ប្រព្រឹត្តតបធម៌មិនដើម្បីប្រាថ្នាវត្ថុកាមគុណណាៗទាំងអស់ ប៉ុន្តែសុំឱ្យបានកំណើតជាមនុស្សទើបខំប្រឹងធ្វើតបធម៌ ។ ព្រះពោធិសត្វក្នុងកំណើតជាចម្បេយ្យនាគរាជ ប្រាថ្នាសេចក្ដីបរិសុទ្ធ ប្រាថ្នាការសង្រួមក្នុងកំណើតមនុស្ស ដោយបានតាំងចិត្តថា កាលណាបានកំណើតជាមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិ និង មរណៈ ។ សង្ខបាលនាគរាជ ក៏ធ្វើតបះព្រោះចង់បានកំណើតមនុស្ស ដូចចម្បេយ្យនាគរាជអ៊ីចឹងដែរ ព្រោះថា ព្រះសម្មាសម្ពុទ្ធក្ដី ព្រះបច្ចេកពុទ្ធក្ដី ព្រះអគ្គសាវ័កក្ដី ព្រះមហាសាវ័កក្ដី បុគ្គលទាំងអស់មានតែក្នុងកំណើតជាមនុស្សប៉ុណ្ណោះ ដូច្នេះមនុស្សយើងគ្រប់គ្នា បានកើតជាមនុស្សហើយ ត្រូវខំព្យាយាមប្រព្រឹត្តកុសលធម៌ ដើម្បីឱ្យបានរួចផុតអំពីវដ្ដសង្សារ គួរពិចារណា



ឱ្យបានរឿយៗ កុំលោភលន់ទៅធ្វើអាក្រក់ផ្សេងៗ ត្រូវចេះអត់ធន់ ទុកដាក់ជីវិតជាទុនសម្រាប់ធ្វើបុណ្យ សាងនូវគុណគឺសេចក្ដីល្អ ដែលសេចក្ដីល្អមានច្រើនណាស់ក្នុងកំណើតជាមនុស្សនេះ គួររីករាយតែក្នុងអំពើល្អសព្វកាល ដូចជាសង្ខបាលនាគរាជ ខំប្រឹងរក្សាឧបោសថសីល ដាក់ចុះនូវអំណាចឥទ្ធានុភាពដ៏ខ្លាំងក្លារបស់ខ្លួន ខំអត់ទ្រាំនឹងសេចក្ដីទុក្ខ មិនឱ្យសីលកម្រើក មិនខឹង មិនក្រោធនឹងពួកកូនព្រានទាំងឡាយ១៦នាក់ ដែលបានធ្វើនូវអំពើបៀតបៀនដ៏សាហាវនោះ ។

ព្រះបរមពោធិសត្វទ្រង់បំពេញនូវគុណគួរអស្ចារ្យ មានប្រការដូចបានរៀបរាប់មកប៉ុណ្ណេះនោះ មានចំនួនតិចតួចណាស់ និង ដោយសង្ខេបៗទៀតផង ព្រះអង្គទ្រង់បានបំពេញនូវគុណសាងបារមី ច្រើនក្រៃជាអនេកទៀត ដែលគួរឱ្យអស្ចារ្យ និង គួរឱ្យគោរពចំពោះដល់ព្រះសាស្ដាដ៏ក្រៃលែង ការគោរពដល់ព្រះសាស្ដា ធ្វើនូវសក្ការបូជាដល់ព្រះអង្គនោះ គឺមានស្មារតីហាមឃាត់នូវសេចក្ដីក្រោធជាដើមហ្នឹងឯង ។

នៅក្នុងគម្ពីរវិសុទ្ធិមគ្គត្រង់មេត្តាព្រហ្មវិហារ បានសម្ដែង

ប្រាប់ឱ្យរលឹកដល់ទោសនៃសេចក្តីក្រោធ ដើម្បីប្រដៅខ្លួនឯង កុំឱ្យមានបដិឃៈថ្នាំងថ្នាក់ បន្ទាប់ទៅមានវិធីប្រដៅទូន្មានចិត្ត ហាមឃាត់នូវសេចក្តីក្រោធច្រើនយ៉ាងទៀត គឺរលឹកដល់សេចក្តីល្អរបស់អ្នកដទៃ, ដាស់តឿនខ្លួនឯងថា ធ្វើនូវសេចក្តីទុក្ខឱ្យខ្លួនឯងនៅពេលខឹងក្រោធ,ពិចារណាកម្មស្សកតា, ពិចារណាដល់សេចក្តីដែលធ្លាប់ទាក់ទងគ្នា ក្នុងសង្សារវដ្ត, ពិចារណានូវអានិសង្សមេត្តា, ពិចារណាធាតុផ្សេងៗដែលពុំមែនជាសត្វបុគ្គល, និងវិធីចុងក្រោយគឺការឱ្យទានបែងចែករំលែក ព្រមទាំងការទទួល ។

ΓαΓαΓαΓαΓαΓ
Γ Γ Γ Γ Γ
ΓαΓαΓαΓ
Γ Γ Γ
ΓαΓ
Γ



# អំពីទោសនៃសេចក្តីក្រោធ

ϖ បុគ្គលដែលជាសត្រូវនឹងគ្នា រមែងមិនប្រាថ្នាឱ្យគូបដិបក្ខមានពណ៌សម្បុរល្អឡើយ ប៉ុន្តែត្រេកអរចំពោះគូសត្រូវនោះ ដែលមានពណ៌សម្បុរអាក្រក់ ដូច្នេះសូមជ្រាបថា ក្នុងកាលដែលបុរសស្ត្រីមានសេចក្តីក្រោធ ត្រូវសេចក្តីក្រោធគ្របសង្កត់រួបរឹតហើយ ទោះបីបុរសស្ត្រីនោះតាក់តែងរាងកាយយ៉ាងណាៗក្តី ក៏បុរសស្ត្រីនោះនៅតែមានពណ៌សម្បុរអាក្រក់ ព្រោះហេតុតែសេចក្តីក្រោធគ្របសង្កត់ហ្នឹងឯង នេះឈ្មោះថាធម៌ធ្វើឱ្យសត្រូវត្រេកអរប្រការទី១ ។

ϖ បុគ្គលដែលជាសត្រូវនឹងគ្នា រមែងមិនប្រាថ្នាឱ្យគូបដិបក្ខដេកជាសុខឡើយ ប៉ុន្តែត្រេកអរចំពោះគូសត្រូវនោះដែលដេកជាទុក្ខ ដូច្នេះសូមជ្រាបនូវទោសនៃសេចក្តីក្រោធដែលធ្វើឱ្យសមតាមបំណងរបស់សត្រូវ ជាធម៌ធ្វើឱ្យសត្រូវត្រេកអរ គឺថា បើបុរសស្ត្រីមានសេចក្តីក្រោធហើយ ទោះបី

ដេកលើអ្វីក៏ដោយ ក្រៃពូកខ្ពស់ខ្នើយប្រណីតយ៉ាងណាក្តី ក៏បុរសស្ត្រីនោះនៅតែដេកជាទុក្ខ ព្រោះហេតុតែសេចក្តីក្រោធគ្របសង្កត់រូបរីតហ្នឹងឯង នេះឈ្មោះថា ធម៌ធ្វើឱ្យសត្រូវត្រេកអរប្រការទី២ ។

៙ សត្រូវរមែងប្រាថ្នាឱ្យគូបដិបក្ខ មិនមានសេចក្តីចម្រើន គេត្រេកអរសប្បាយចិត្តនៅពេលដឹងថា គូសត្រូវរបស់ខ្លួនប្រាសចាកនូវប្រយោជន៍ ដូច្នេះ សេចក្តីក្រោធជាធម៌ធ្វើឱ្យសត្រូវសមតាមបំណងប្រាថ្នា ប្រការទី៣ដោយពិត ព្រោះបុគ្គលដែលត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ រមែងកាន់យកនូវអំពើដែលមិនជាប្រយោជន៍ ដោយសំគាល់ថាជាប្រយោជន៍ ហើយលះបង់ចោលនូវអំពើដែលជាប្រយោជន៍ពិតៗ ព្រោះគិតថាឥតប្រយោជន៍ទៅវិញ នេះឯងជាសេចក្តីវិនាសរបស់បុរសស្ត្រីក្នុងលោក ។

៙ សត្រូវរមែងប្រាថ្នាឱ្យគូបដិបក្ខ មិនមាននូវភោគទ្រព្យ គេត្រេកអរសប្បាយចិត្តនៅពេលដឹងថា គូសត្រូវរបស់ខ្លួនវិនាសនូវទ្រព្យសម្បត្តិ ដូច្នេះ សេចក្តីក្រោធជាធម៌ធ្វើឱ្យ



សត្រូវសមតាមបំណងប្រាថ្នាប្រការទី៤ ព្រោះបុគ្គលដែលត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ ភោគៈទាំងឡាយណា ដែលបុគ្គលនោះបានមកដោយសេចក្តីប្រឹងប្រែង ព្យាយាមសន្សំកពូនដោយកម្លាំង បានមកប្រកបដោយការងារប្រាសចាកទោស ត្រូវវិនាសអស់ដោយប្រការផ្សេងៗ ដូចជាវាយចានវាយឆ្នាំង បោះបង់ចោលការងារ ដុតផ្ទះនៅខ្លួនឯង មានដល់ទៅសម្លាប់ខ្លួន សម្លាប់កូនប្រពន្ធទៀតផង ។

៙ សត្រូវរមែងប្រាថ្នាថា ឱហ្ន៎ សូមឱ្យសត្រូវរបស់អញកុំបាននូវយសឡើយ ទោះជាកិត្តិយសក្តី បរិវារយសក្តី ឥស្សរិយយសក្តី សេចក្តីនេះគឺថា សត្រូវរមែងមិនត្រេកអរដល់សត្រូវ ព្រោះការមានយស តែត្រេកអរដល់ការអត់យស ឬការវិនាសយសរបស់សត្រូវ ដូច្នេះ សេចក្តីក្រោធជាធម៌ធ្វើឱ្យសត្រូវសមតាមបំណងប្រាថ្នាប្រការទី៥ ព្រោះសេចក្តីក្រោធគ្របសង្កត់ហើយ រមែងថយយសឬត្រូវវិនាសអស់ ចំពោះយសទាំងឡាយដែលបានមក ដោយការមិនប្រមាទអំពីមុននោះ ។

៙សេចក្តីក្រោធជាធម៌ធ្វើឱ្យសត្រូវត្រេកអរក្នុងប្រការ

ទី៦ គឺការបាត់បង់មិត្ត ចំពោះមិត្តល្អកម្ររកណាស់ ប៉ុន្តែបើរកមិត្តល្អបានហើយ មិនបានប្រយ័ត្ន ត្រូវសេចក្តីក្រោធកើតឡើង បណ្តោយឱ្យសេចក្តីក្រោធគ្របសង្កត់ មិត្តល្អដែលរកបាននោះក៏ត្រូវបាត់បង់ទៅវិញ សូម្បីតែញាតិមិត្តសាច់សាលោហិតក៏បាត់បង់ដែរ ព្រោះគេខ្លាច គេមិនចូលចិត្ត គេវៀរពីចម្ងាយគេចមុខមិនចង់ជួប ចំពោះបុគ្គលដែលត្រូវសេចក្តីក្រោធគ្របសង្កត់នោះ នេះឈ្មោះថាធម៌ដែលធ្វើឱ្យសត្រូវត្រេកអរសមតាមបំណង ព្រោះសត្រូវតែងប្រាថ្នាឱ្យគូប្រឆាំងបាត់បង់នូវមិត្តល្អ ។

៙សេចក្តីក្រោធជាធម៌ធ្វើឱ្យសត្រូវត្រេកអរក្នុងប្រការទី៧ គឺក្រោយអំពីស្លាប់ត្រូវធ្លាក់ទៅអបាយភូមិ ចំពោះអបាយភូមិ៤ គឺ នរក១ ប្រេត១ តិរច្ឆាន១ អសុរកាយ១ វាជាអកុសលវិបាកបដិសន្ធិ ជាផលរបស់អកុសលកម្ម មានអកុសលកម្មជាបច្ច័យ ។

បុគ្គលដែលមានសេចក្តីក្រោធត្រូវសេចក្តីក្រោធរួបរឹតគ្របសង្កត់ រមែងប្រព្រឹត្តនូវទុច្ចរិតដោយកាយ ដោយវាចា ឬដោយចិត្ត ការប្រព្រឹត្តទុច្ចរិតជាអកុសលកម្ម ជាកម្មនាំឱ្យ



មានវិបាកជាទុក្ខ ជាការស្របសមតាមបំណងប្រាថ្នារបស់គូបដិបក្ខដែលជាសត្រូវ ។

៙ បុរសស្ត្រីក្នុងលោកមាននូវសេចក្តីក្រោធមិនល្អទេ គួរនឹកស្តាយប្រាក់ដែលបានចំណាយអស់យ៉ាងច្រើន ទៅលើគ្រឿងប្រដាប់កាយ ចង់ស្អាត ប៉ុន្តែបែរទៅជាមិនល្អ ម្យ៉ាងវិញទៀត ខំប្រឹងរកគ្រឿងប្រដាប់ដាក់ផ្ទះ ទីដេកទីអង្គុយសុទ្ធតែថ្លៃៗ ប៉ុន្តែក៏បែរទៅជាមិនសុខមិនត្រជាក់ ព្រោះសេចក្តីក្រោធ ដេកក៏ជាទុក្ខ អង្គុយក៏ជាទុក្ខ លែងលះប្តីប្រពន្ធ ចោលផ្ទះសម្បែង និង ប្រព្រឹត្តអំពើសាហាវផ្សេងៗ ណាមួយនោះ ត្រូវកាត់បង់នូវប្រយោជន៏ខ្លឹមសារនៃជីវិត បង់លាភបាត់យស សាបសូន្យកេរ្តិ៍ឈ្មោះ បែកបាក់ញាតិមិត្ត ហើយជាទីបំផុតត្រូវទៅកាន់អបាយភូមិដ៏សែនខ្លោចផ្សា អពមង្គលទាំងអស់នេះ ព្រោះទោសនៃសេចក្តីក្រោធខឹងហ្នឹងឯង ។

Γ Γ̄ Γ̄ Γ̄
ΓαΓαΓ
Γ Γ̄
Γ

α អនត្ថជននោ កោធោ    កោធោ ចិត្តប្បកោបនោ

ភយមន្តរតោ ជាតំ    តំ ជនោ នាវពុជ្ឈតិ ។

សេចក្តីក្រោធជាហេតុឱ្យកើតសេចក្តីវិនាស សេចក្តីក្រោធរមែងញាំុងចិត្តឱ្យកម្រើក ភ័យដែលបានកើតមកអំពីខាងក្នុង ជនអ្នកក្រោធខឹងមិនដឹងនូវភ័យនោះទេ ។

ភ័យរមែងកើតអំពីអាជ្ញារបស់ខ្លួនឯង អាជ្ញាគឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត សេចក្តីទុក្ខគឺជាភ័យធំរបស់សត្វទាំងឡាយ ការវិនាសនូវសេចក្តីចម្រើនក្តី ចិត្តញាប់ញ័ររន្ធត់ ភ័យតក់ស្លុតជ្រួលច្របល់ក្តី គឺជាទុក្ខ មិនជាទីប្រាថ្នារបស់សត្វទាំងឡាយឡើយ ។



αកុទ្ធោ អត្ថំ ន ជានាតិ  កុទ្ធោ ធម្មំ ន បស្សតិ

អន្ធតមំ តទា ហោតិ    យំ កោធោ សហតេ នរំ

បុគ្គលអ្នកក្រោធមិនដឹងនូវសេចក្តីចម្រើន បុគ្គលអ្នកក្រោធមិនឃើញនូវធម៌ សេចក្តីក្រោធគ្របសង្កត់នូវជនណា សេចក្តីងងឹតស្លុបរមែងមានប្រាកដ ដល់ជននោះ ក្នុងកាលនោះដែរ ។

ប្រយោជន៍ក្នុងលោកនេះក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍សម្រាប់ព្រះនិព្វានក្តី កុសលធម៌ទាំងឡាយទាំងពួងក្តី ជនប្រុសស្រីដែលត្រូវសេចក្តីក្រោធគ្របសង្កត់ មិនអាចដឹងមិនអាចឃើញបានឡើយ រមែងងងឹតឈឹងដូចបុគ្គលខ្វាក់ភ្នែកទាំងសងខាង ។

α យំ កុទ្ធោ ឧបរោធេតិ   សុករំ វិយ ទុក្ករំ

បច្ឆា សោ វិគតេ កោធេ   អគ្គិទឌ្ឍោវ តប្បតិ

បុគ្គលអ្នកក្រោធ កាលបៀតបៀននូវបុគ្គលណា ដោយការធ្វើនូវអំពើអាក្រក់ ហាក់ដូចជាអំពើល្អ បុគ្គលអ្នកក្រោធនោះ កាលបើសេចក្តីក្រោធប្រាសចេញហើយ រមែងក្តៅក្រហាយជាខាងក្រោយ ដូចជាត្រូវភ្លើងឆេះ ។

សេចក្តីក្រោធធ្វើឱ្យវង្វេងបាត់បង់ស្មារតី ហ៊ានធ្វើអាក្រក់បានដោយងាយៗ ដោយគិតថាជាអំពើត្រឹមត្រូវ លុះដល់ពេលបាត់ខឹងដឹងនូវកំហុស រមែងមានវិប្បដិសារៈគឺការក្តៅក្រហាយស្តាយក្រោយ នេះហើយទោសនៃសេចក្តីក្រោធ។



α ទុម្មង្កុយំ បឋមំ ទស្សេតិ   ធូមគ្គិមិវ បាវកោ

យតោ បតាយតី កោធោ   យេន កុជ្ឈន្តិ មាណវា

បុគ្គលក្រោធរមែងសម្តែងនូវមុខក្រញូវជាដំបូង ដូចភ្លើងមុននឹងឆេះសម្តែងផ្សែងសិន ក្នុងកាលណាសេចក្តីក្រោធកើតឡើង មាណពទាំងឡាយក៏ក្រោធខឹងក្នុងកាលនោះ (រមែងធ្វើនូវអំពើវិនាសផ្សេងៗ ដូចជាភ្លើងឆេះព្រៃឬឆេះភូមិអ្នកស្រុកអីចឹងឯង) ។

អសុរកាយគឺសេចក្តីក្រោធ អាស្រ័យនឹងបុគ្គលណា បុគ្គលនោះ មិនចេះខ្មាសបាប មិនចេះខ្លាចបាប មិនមានការគោរព ប្រាសចាកទីពឹង ងងឹតមុខឈឹងដូចយប់ងងឹត ។

α តបនីយានិ កម្មានិ យានិ ធម្មេហិ អារកា
តានិ អារោចយិស្សាមិ តំ សុណាថ យថាតថំ

កម្មទាំងឡាយណា ជាទីតាំងនៃសេចក្តីក្តៅក្រហាយ រមែងឃ្លាតឆ្ងាយអំពីកុសលធម៌ តថាគតនឹងសម្តែងប្រាប់នូវកម្មទាំងនោះ ចូរអ្នកទាំងឡាយចាំស្តាប់នូវធម៌នោះ តាមសេចក្តីពិតជាលំដាប់ទៅ ។

បុគ្គលក្រោធ សម្លាប់បិតាក៏បាន បុគ្គលក្រោធសម្លាប់មាតារបស់ខ្លួនក៏បាន បុគ្គលក្រោធសម្លាប់នូវព្រះខីណាស្រពគឺព្រះអរហន្តក៏បាន បុគ្គលក្រោធសម្លាប់នូវបុថុជ្ជនក៏បានទាំងអស់ ។

កូនខ្លះដែលម្តាយបានចិញ្ចឹម រហូតដល់បានបើកភ្នែកសម្លឹងមើលនូវលោកនេះ កូននោះមានកិលេសអាក្រក់ក្រៃកាលសេចក្តីក្រោធកើតឡើង ហ៊ានសម្លាប់សូម្បីតែម្តាយដែលជាអ្នកឱ្យនូវជីវិតគឺការរស់នៅដល់កូននោះឯង ។

ពិតណាស់ សត្វទាំងនោះមានខ្លួនជាគ្រឿងប្រៀបធៀប ព្រោះខ្លួនជាទីស្រឡាញ់ដ៏ក្រៃលែង បុគ្គលក្រោធកាលជ្រប់ទៅ



ក្នុងអារម្មណ៍ផ្សេងៗ រមែងសម្លាប់នូវខ្លួនឯង ដោយរបៀបវិធីច្រើនយ៉ាង មានសម្លាប់ដោយដាវ ទំពាស៊ីនូវថ្នាំពិស យកខ្សែចងក ទម្លាក់ខ្លួនចូលជ្រោះភ្នំជាដើម ។

ជនទាំងឡាយកាលធ្វើនូវអំពើ ជាហេតុនាំឱ្យសាបសូន្យចាកការចម្រើនផង និង ជាហេតុឱ្យស្លាប់ខ្លួនឯងផង ក៏មិនបានដឹងនូវសេចក្តីសាបសូន្យនោះ បុគ្គលដែលមានសេចក្តីក្រោធកើតឡើង រមែងវិនាសនូវប្រយោជន៍ផ្សេងៗ (ដូចភ្លើងតាំងឡើងពីក្នុងកាយ ហើយដុតរំលាយខ្លួនឯងទាំងដែលកំពុងនៅរស់ ឱ្យស្លាប់ទៅដូច្នោះ) ។

α ទីតកោធោ អនាយាសា វីតលោភា អនិស្សុកា
ទន្តា កោធំ បហត្វាន បរិនិព្វិស្សថ នាសខាតិ

កាលបើអ្នកជាបុគ្គលប្រាសចាកសេចក្តីក្រោធ មិនមានសេចក្តីចង្អៀតចង្អល់ ប្រាសចាកសេចក្តីលោភ មិនមានការច្រណែន មានការទូន្មានខ្លួនបានល្អហើយ បានសម្លាប់នូវសេចក្តីក្រោធហើយ អ្នកនឹងបានទៅជាបុគ្គលមិនមានអាសវៈ បរិ-និព្វានពុំខានឡើយ ។

បុគ្គលក្រោធខឹង ឈ្មោះថាជាប់អន្ទាក់នៃសេចក្តីស្លាប់ ដូច្នេះ បុគ្គលគួរផ្តាច់ផ្តិលនូវសេចក្តីក្រោធនោះឯង ដោយការទូន្មានចិត្ត ពោលគឺអប់រំចម្រើនវិបស្សនា មានការព្យាយាមផ្លូវកាយ និង ផ្លូវចិត្ត ប្រព្រឹត្តទៅដើម្បីសម្មាទិដ្ឋិជាលោកុត្តរ ។

αគថេទ ធម្មេ សិក្ខេថ មា នោ ទុម្មុខ្ខយំ អហុ

បុគ្គលគប្បីសិក្សានូវធម៌ទាំងឡាយដោយប្រការដូច្នេះឯង គឺយើងទាំងឡាយ កុំគប្បីមានមុខក្រញូវឡើយ ។

**ស្រង់ចាកកោធនាសូត្រ**

**អង្គុត្តរនិកាយ សត្តកនិបាត**

ΓΔΓΔΓΔΓΔΓ

ΓΔΓΔΓΔΓ

ΓΔΓΔΓ

ΓΔΓ

Γ



# ភ្លើងកំហឹង

αភ្លើងឆេះឡើងអាស្រ័យនឹងអុសណា រមែងដុតកម្ទេចនូវអុសនោះ យ៉ាងណាមិញ សេចក្តីក្រោធកើតឡើងអាស្រ័យនឹងបុគ្គលណា រមែងដុតកម្ទេចនូវបុគ្គលនោះ បំផ្លាញអស់នូវប្រយោជន៍ ក៏យ៉ាងនោះដែរ ។

ព្រោះអាស្រ័យសេចក្តីល្ងង់ ក៏រមែងមានវិវាទឈ្លោះទាស់ទែង ព្រោះតែមានវិវាទផ្សេងៗ ក៏រមែងមានសេចក្តីក្រោធចម្រើនឡើង កាលសេចក្តីក្រោធចម្រើនឡើង រមែងឆាបឆេះនូវបុគ្គលដែលអាប់អន់បញ្ញា មានការខឹងក្រោធនោះឯង ម្ល៉ោះហើយ សួស្តីនៃបុគ្គលនោះរមែងសាបសូន្យ ដូចជាស្មៅដែលត្រូវភ្លើងឆេះ ឬដូចព្រះចន្ទក្នុងកាឡបក្ខ ។

# និករលឹកដល់សេចក្ដីល្អរបស់អ្នកដទៃ

មនុស្សយើងដែលនៅមានកិលេស ពុំមែនចេះតែល្អទាំងអស់នោះទេ រមែងឆ្គាំឆ្គងជាធម្មតាដោយកាយវាចា ឬដោយចិត្ត នេះជារឿងរបស់ធម្មជាតិសុទ្ធៗ ទើបមានការបញ្ញត្តសត្វបុគ្គលថា ជាអ្នកល្អឬអ្នកអាក្រក់ ទៅតាមដំណើររបស់ធម្មជាតិនោះៗ ។ បុគ្គលបានសិក្សាអំពីធម្មជាតិ គឺការប្រព្រឹត្តទៅរបស់បរមត្ថធម៌ ចិត្ត ចេតសិក រូប ហើយបានយល់ចូលចិត្តច្រើនឡើងៗ ក៏រមែងកាត់បន្ថយនូវការប្រហួងហែង ការមើលងាយមើលថោកអ្នកដទៃ ជាបុគ្គលឆ្លាតឈ្លាសក្នុងឧបាយហាមឃាត់ការខឹងក្រោធ ។

ការនឹករលឹកទៅរកអំពើល្អរបស់អ្នកដទៃ ជាឧបាយដ៏ប្រសើរក្នុងការរក្សាចិត្ត ហាមឃាត់ការខឹងក្រោធបាន តាមពិតការខឹងក្រោធវាអាស្រ័យការគិតមិនល្អ ដូចបុគ្គលដើរមិនប្រយ័ត្នភ្លាត់ជើងរអិលដួលដូច្នោះ ព្រោះអាស្រ័យហេតុនេះបុគ្គលត្រូវប្រយ័ត្នការគិតរបស់ខ្លួនឯង ព្រោះគំនិតមិនល្អជាអ្នកសាងនូវទុក្ខកង្វល់ សេចក្ដីចង្អៀតចង្អល់ឱ្យដល់ខ្លួនរឿយៗ ទាំងយប់ទាំងថ្ងៃ បើយើងឧស្សាហ៍នឹកគុណព្រះរតនត្រ័យ និង នឹកដល់អំពើល្អរបស់អ្នកដទៃទៅវិញនោះ សេចក្ដីក្រវល់ក្រវាយចិត្ត រមែងស្ងប់រម្ងាប់ នៅជាសុខ មិនក្ដៅក្រហាយឡើយ ។

បុគ្គលដើរហាលថ្ងៃក្នុងគិម្ហៈរដូវ អាកាសធាតុក្ដៅត្រូវស្រេកទឹក កាលដែលស្វែងរកទឹកបំបាត់ការស្រេក ក៏បានមកជួបនឹងស្រះមួយដែលមានចកដុះណែនជិត បិទបាំងទឹកទុកខាងក្រោម បុគ្គលឡប់សតិខឹងនឹងស្រះនោះឯង ព្រោះវង្វេងស្មារតីគិតថា ស្រះនោះកំណាញ់ទឹក ឬក៏ខឹងជាមួយនឹងចក ថាចកប្រហួងហែងទឹកមិនឱ្យខ្លួនផឹក ប៉ុន្តែបុគ្គលដែលគេមិនឆ្កួតនោះគេបានវាចចកដោយដៃដងទឹកបរិភោគ បន្តដំណើរសុខសាន្តបានទៅដល់គោលដៅដូចប្រាថ្នា សេចក្ដីនេះយ៉ាងណា ការប្រព្រឹត្តឆ្គាំឆ្គងរបស់អ្នកដទៃ ប្រៀបបីដូចជាចកក្នុងស្រះទឹករីឯទឹកដ៏ថ្លាស្អាតនៅខាងក្រោមចកនោះ គឺជាឈ្មោះនៃសេចក្ដីល្អរបស់អ្នកដទៃដែលមានយ៉ាងនោះឯង ដូច្នេះ គួរបើឬទេ ?

កាលដែលទៅទាស់នឹងអំពើឆ្គាំឆ្គងរបស់គេ ធ្វើឱ្យតែខ្លួនឯងក្ដៅក្រហាយក្រវល់ក្រវាយ ដូចការស្រេកទឹកប៉ុន្តែមិនបានផឹកនោះ ។

ការទឹកស្រាវជ្រាវរាវរកអំពើល្អរបស់អ្នកដទៃ កាលរកឃើញហើយក៏បានដាក់ចិត្តជ្រះថ្លា អនុមោទនាចំពោះអំពើល្អនោះ មិនដាក់ចិត្តប្រកាន់អ្វីទៅលើសេចក្ដីខុសឆ្គាំឆ្គង ដូចវាចចកដោយដៃដងទឹកមកបរិភោគ កម្ចាត់ការស្រេកឃ្លានអ៊ីចឹងឯង ឯការបន្តដំណើររបស់អ្នកដែលបានបរិភោគនូវទឹករួចហើយនោះ គឺជាឈ្មោះនៃអ្នកចម្រើនមេត្តា គ្មានការចងពៀរ គ្មានការព្យាបាទ ជាអ្នកប្រព្រឹត្តទៅតាមផ្លូវសតិប្បដ្ឋាន ឯពាក្យថា បានដល់គោលដៅ ដែលជាទីបំផុតនៃផ្លូវដូចក្ដីប្រាថ្នា គឺជាឈ្មោះនៃការដល់នូវព្រះនិព្វាន តាមផ្លូវសតិប្បដ្ឋាន៤ ឬអរិយ-មគ្គប្រកបដោយអង្គ៨ ប្រការ ។

បុគ្គលដែលខ្វះនូវសំពត់ស្លៀកបិទបាំងរាងកាយ បានឃើញសំពត់នៅនឹងគំនរសំរាម ទោះបីសំពត់នោះមានចំណែកខ្លះប្រើមិនបានក៏ដោយ បុគ្គលដែលឆ្លាតក្នុងឧបាយ បានហែក



យកតែត្រង់កន្លែងល្អៗមកដេរផ្សំផ្គុំ ដើម្បីដណ្ដប់បិទបាំងរាងកាយ ប្រើប្រាស់សំពត់បង្សុកូលនោះការពារអន្តរាយផ្សេងៗបាន សេចក្ដីនេះយ៉ាងណា បុគ្គលអប់រំចម្រើននូវមេត្តា មិនមានពៀរ មិនមានព្យាបាទ ជាបុគ្គលឆ្លាតដោយមនសិការ មិនខ្វល់ខ្វាយក្ដៅក្រហាយចិត្ត ព្រោះហេតុតែរឿងអ្នកដទៃ ប្រៀបដូចជាសំពត់កន្លែងខ្លះដែលប្រើប្រាស់មិនបាន ក៏ហែកចោលទៅទុកនៅតែសំពត់ល្អសម្រាប់ផ្សំផ្គុំស្លៀកដណ្ដប់ នេះគឺជាឈ្មោះយោនិសោមនសិការៈ ដែលប្រព្រឹត្តទៅក្នុងការចម្រើនមេត្តា មិនប្រាថ្នាពៀរ មិនប្រាថ្នាការព្យាបាទ ក៏យ៉ាងនោះឯង ។

ការអប់រំចម្រើនមេត្តា គឺការប្រាថ្នាឱ្យអ្នកដទៃមានសេចក្ដីសុខ ដូចជាការប្រាថ្នាឱ្យខ្លួនឯងបានតែសេចក្ដីសុខអ៊ីចឹងឯង មេត្តាត្រូវអប់រំចម្រើនគ្រប់ឥរិយាបថទាំង៤ ជាអ្នកឆ្លាតឈ្លាសក្នុងបំណងរបស់អ្នកដទៃ ដែលត្រូវការនូវសេចក្ដីសុខដូចដែលខ្លួនឯងត្រូវការដែរ មានប្រក្រតីសម្លឹងមើលសត្វលោកដោយចិត្តស្រទន់ មិនតម្កើងមានៈ មិនឥស្សា ។

ជាធម្មតាសំពត់រុំសាកសព វាដោយឡែកអំពីសាកសព

គឺសំពត់ផ្សេង សាកសពផ្សេង មិនមែនវត្ថុតែមួយទេ យ៉ាងណា ការមិនល្អរបស់សត្វលោកដោយកាយវាចាចិត្ត ក៏ព្រោះអាស្រ័យកិលេស ដូច្នេះ កាយវាចាចិត្តផ្សេង ចំណែកកិលេសផ្សេង កិលេសប្រៀបដូចជាសាកសព រីឯកាយវាចាចិត្តដែលសៅហ្មង ប្រៀបដូចជាសំពត់រុំសាកសព យ៉ាងនោះឯង ។ ក្នុងសេចក្តីប្រៀបធៀបនេះ ចង់ពន្យល់ប្រាប់ថា ការសៅហ្មងឆ្គាំឆ្គងរបស់សត្វលោក មិនគួរជាអារម្មណ៍នាំឱ្យយើងខឹងក្រោធទាស់ទែងទេ ព្រោះការសៅហ្មងឆ្គាំឆ្គងនោះ ក៏ដោយអំណាចកិលេសដែលធ្វើឱ្យប្រឡាក់សៅហ្មងហ្នឹងឯង ត្រូវឃើញត្រឹមតែទោសរបស់កិលេសតែប៉ុណ្ណោះ ឯចំណែកមនុស្សសត្វដែលមានកាយវាចាចិត្តប្រព្រឹត្តសៅហ្មងយ៉ាងណាៗ ជារឿងដែលគួរឱ្យករុណា ព្រោះថាសត្វលោកមិនប្រាថ្នាការសៅហ្មងផ្សេងៗឡើយ ប៉ុន្តែនេះគឺសត្វលោកមានជម្ងឺ សត្វលោកត្រូវរោគបៀតបៀន សត្វលោកលំបាកខ្លាំងណាស់ វង្វេងស្មារតីអស់ហើយ បើយើងមិនដឹងរឿងនេះ ហើយនៅតែខឹងក្រោធជាមួយនឹងសត្វលោកទៀត នេះក៏មកអំពីយើងហ្នឹងជាអ្នកជម្ងឺ ត្រូវរោគ



បៀតបៀនដែរ ឬថាសុទ្ធតែជាក្រុមឡប់សតិទាំងអស់គ្នាក៏បានថាទៅគឺគ្មានខុសអ្វីទេ ព្រោះគេឯណោះសោះធ្វើខុស ស្រាប់តែឯងឯណេះខឹង មិនឱ្យថាអ្នកទាំងពីរហ្នឹងនៅក្រុមតែមួយយ៉ាងម៉េច ។

ក្នុងព្រះធម្មបទសហស្សវគ្គទី៨ ប្រារព្ធរឿងព្រះនាងកុណ្ឌលកេសី ព្រះជិនស្រីអរហន្តសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងនូវព្រះគាថា :

**យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**
**ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ**

បុគ្គលណា ឈ្នះមនុស្សមួយលាននាក់ក្នុងសង្គ្រាមក៏មិនឈ្មោះថាជាអ្នកប្រសើរនោះឡើយ ចំណែកឯបុគ្គលណាឈ្នះខ្លួនឯងតែម្នាក់បាន បុគ្គលនោះឯងជាកំពូលនៃអ្នកឈ្នះក្នុងសង្គ្រាម ។

ក្នុងលោកនេះ មនុស្សចេះអៀនខ្មាស ព្រោះច្បាំងចាញ់អ្នកដទៃ ប៉ុន្តែដែលគួរឱ្យខ្មាសណាស់នោះ គឺចាញ់ខ្លួនឯងទាំងមិនដែលនឹកធ្វើសង្គ្រាមជាមួយខ្លួនឯងផង ព្រោះមិនដឹងថា

ខ្លួនឯងដែលមានកិលេសនេះ ជាកំពូលសត្រូវជាមួយនឹងខ្លួនឯងប៉ុនណានោះ រឿងនេះគួរសិក្សា គួរពិចារណា ហើយសូមរំលឹកផងដែរថា បព្វជិតទាំងឡាយក្នុងសាសនានេះ គឺជាក្រុមអ្នកច្បាំង មានសីលជាទីតាំងទ័ព មានសទ្ធាជាដៃកាន់អាវុធ វិរិយៈជាជើងចូលសម្រុក សតិជាអាវក្រោះ សមាធិជាកម្លាំងកាយ បញ្ញាជាអាវុធ អរិយមគ្គសម្លាប់សត្រូវគឺកិលេស ជាកំពូលនៃការឈ្នះក្នុងសង្គ្រាម លើកឡើងនូវទង់ជ័យបានដល់ខន្តីសេចក្តីអត់ធន់ ចំណែកមេត្តាគឺជាចលនាវិច១របស់ទង់ដែលត្រូវខ្យល់បក់គួរឱ្យគយគន់ សូមបញ្ជាក់ថា មេត្តា និង ខន្តីអង្គធម៌គឺអទោសចេតសិកទាំងអស់គ្នា គ្រាន់តែ ខន្តីមានការកំចាត់សេចក្តីក្រោធជាកិច្ច រីឯមេត្តាមានការនាំប្រយោជន៍សុខឱ្យដល់សត្វទាំងឡាយជាកិច្ចប៉ុណ្ណោះ ប៉ុន្តែជាសភាវធម៌តែមួយគឺការមិនប្រទូស្តចំពោះអារម្មណ៍ហ្នឹងឯង សោរច្ចៈជាមោទន-ភាពរបស់អ្នកឈ្នះសង្គ្រាម ស្ងប់ស្ងៀមរៀបរយដោយល្អ គឺជាដងទង់មាស មានអលោភៈសេចក្តីសន្តោសជាគ្រឹះនៃដងទង់នោះ ចំណែកហិរិ និង ឱត្តប្បៈជាខ្សែបង្ហូតទង់ ហិរិខ្មាសបាប



ឱត្តប្បៈខ្លាចបាប ទាំងពីរជាលោកបាលធម៌ គាំទ្រនូវមេត្តា និងខន្តី ព្រមទាំងសេចក្តីល្អទាំងអស់ ។

ទោះបីនឹកឃើញដល់សេចក្តីល្អរបស់អ្នកដទៃបន្តិចបន្តួចក្តី ព្រះធម៌បានដាស់តឿនពុទ្ធបរិស័ទឱ្យឆ្លាត កុំធ្វើសេចក្តីល្អរបស់គេនោះឱ្យជាអារម្មណ៍នៃការមិនស្ងប់ ត្រូវតែជាអ្នកប៉ិនប្រសប់អប់រំចិត្តរបស់ខ្លួន រក្សាសេចក្តីល្អរបស់អ្នកដទៃ សូម្បីគេមានតែបន្តិចបន្តួចក៏ដោយ ត្រូវក្រេបយកគុណគឺសេចក្តីល្អនោះ១អំពីមនុស្សគ្រប់គ្នា ប្រមូលផ្តុំដោយចិត្តជ្រះថ្លា អប់រំបាននូវធម៌មេត្តា ឧបមាដូចក្បាលទឹកឃ្មុំ ។

ជាធម្មតាមេឃ្មុំ ក្រេបលំអងកេសរផ្កាឈើយកមកធ្វើក្បាលទឹក ប្រឹងប្រែងព្រឹកល្ងាច មេឃ្មុំទាំងនោះមិនរវល់អំពីរឿងអ្វីនៃដើមឈើទេ គិតតែអំពីកិច្ចការរបស់ខ្លួនដែលត្រូវធ្វើប៉ុណ្ណោះ យ៉ាងណាមិញ មនុស្សល្អ រមែងតែងតែពិចារណានូវកិច្ចការរបស់ខ្លួន គោរពក្នុងការងារដែលត្រូវធ្វើ កំណត់នូវវិបាកកម្មក្នុងជីវិតប្រចាំថ្ងៃ មាននូវស្មារតី សន្សំសេចក្តីស្ងប់ ក៏យ៉ាងនោះដែរ ដូច្នេះសូមសាធុជនរៀនយកចំណេះផ្សេង១

អំពីធម្មជាតិ ដូចគតិរបស់មេឃ្មុំជាដើម វាមិនបៀតបៀននូវផ្កាឈើឱ្យខូចពណ៌ខូចក្លិនអ្វីទាំងអស់ មិនត្រឹមតែប៉ុណ្ណោះ វាថែមទាំងបាននូវប្រយោជន៍អំពីផ្កាឈើនោះទៀតផង ។

ធម្មជាតិជុំវិញជីវិតដែលប្រាកដសេចក្ដីឱ្យដឹងបាន ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គទ្រង់លើកយកមកប្រកាសសំដែងជាការប្រៀបប្រដូចសព្វបែបយ៉ាង ក្នុងបំណងដាស់តឿននូវស្មារតីនៃពុទ្ធបរិស័ទ ដូចជា អំពីផែនដី ព្រៃភ្នំ ទន្លេសមុទ្រ ព្រះអាទិត្យព្រះចន្ទ មេឃផ្កាយពពកខ្យល់ ទឹកសន្សើម ភ្លៀងរលឹមផ្គររន្ទះ ផ្លេកបន្ទោរឥន្ទធនូ ថ្ងៃត្រជាក់ថ្ងៃក្ដៅថ្ងៃបណ្ដើរកូន ដុំថ្មដុំដីស្លឹកឈើមែកឈើ ទឹកហូរពពុះទឹក ភ្លើងផ្សែងធូលីដី ត្រីក្ដាមឆ្លាមក្រពើសត្វស្រុកសត្វព្រៃបក្សាបក្សី ។ល។ ព្រះធម៌ទេសនាឱវាទទូន្មានរបស់ព្រះអង្គ ក្នុងរឿងអប់រំចិត្ត សត្វលោកស្ដាប់ឆាប់យល់ ព្រោះនឹកដល់ការប្រៀបប្រដូចផ្សេងៗ សូម្បីទឹកដក់ក្នុងក្រឡុកនៃដានជើងគោក៏ជាឧបមាដ៏ល្អក្នុងធម៌ទេសនាប្រដៅសត្វលោកដែរ ។

បុរសស្ត្រីស្រេកទឹកខះក ទាំងទឹកនោះក្រមិនងាយរកបាន កាលដែលបានជួបទឹកបន្តិចក្នុងក្រឡុកដី ជាដានជើងគោ បុរសស្ត្រីដែលឈ្លាស មិនយកអ្វីដួសឬដៃក្បង់ឡើយ ព្រោះវានាំឱ្យកករល្អក់ ប៉ុន្តែគេលុតជង្គង់ ឱនកាយក្រេបផឹក យ៉ាងហោចក៏បានមួយក្អឹកបំបាត់ខះកដែរ រឿងនេះប្រៀបប្រដូច នឹងរឿងក្រេបសេចក្ដីល្អរបស់អ្នកដទៃ ក្នុងអត្ថន័យដូចដែលបានសម្ដែងរួចហើយ ដូច្នោះឯង ។

# ទឹកមួយប្រឡង់

-ទឹកមួយប្រឡង់កុំក្បង់នឹងដៃ នាំឱ្យចង្រៃល្អក់វវឹក
គួរលុតជង្គង់បង្អោនក្រេបផឹក គង់បានមួយក្អឹកបំបាត់ខះក។
-ជីវិតមានតិចកុំបិចធ្វើបាប ថ្នាក់ថ្នមសុខភាពសម្រាប់សាងល្អ
សន្សំធម៌ស្អាតសង្វាតធម៌ស ឱ្យដូចជាស្ករក្បាលសផ្អែម ។

*ដោយលោក : ឆឹង កាន*

# វេរកខឹងក្រោធគឺធ្វើទុក្ខឱ្យខ្លួនឯង

១-បើយើងត្រូវចោរ ឬសត្រូវបៀតបៀន ឬក៏ត្រូវទទួលទារុណកម្មយ៉ាងណា១ ក៏ចំពោះតែតាមផ្លូវកាយប៉ុណ្ណោះ ដែលត្រូវទទួលរងនូវសម្ពស្សបាតដៃជុំដីដំបង ឬសស្ត្រារុំផ្សេង១ រឿងការបៀតបៀនឬទារុណកម្មទាំងនេះ វាគួរឱ្យស្រៀវស្លុតភ័យខ្លាចណាស់ទៅហើយ ថែមទាំងទុក្ខវេទនាលំបាកទ្រាំទ្រៀតផង ប៉ុន្តែគេអាចធ្វើចំពោះយើងបានតែតាមផ្លូវកាយដោយពិត ឯចំណែកខ្លួនឯងវិញ ព្រោះការខឹងក្រោធកើតឡើង ក៏បានធ្វើការប្រហារបៀតបៀន ញាំញីខ្ទេចខ្ទាំវក់វីតាមផ្លូវចិត្ត ឱ្យដល់ខ្លួនឯង ម្ល៉ោះហើយ ចិត្តក៏ឈឺផ្សាជាទុក្ខលំបាក ក្តៅរោលរាលដោយភ្លើងកំហឹង ការខឹងក្រោធរមែងដុតចិត្តឱ្យស្វិតក្រៀមក្រំ សោកសៅសង្រេងសង្រែរឹងរៃ នេះជាស្នាដៃខ្លួនឯងធ្វើបាបខ្លួន សូមជ្រាបថា ការប្រហារបៀតបៀនផ្លូវចិត្ត មិនមែនជាវិស័យនៃសត្រូវខាងក្រៅឡើយ ។



ការខឹងក្រោធធ្វើចិត្តឱ្យទុក្ខលំបាកក្រៃលែងផង មានបាបកម្មច្រើនប្រការផង ជាហេតុនៃសេចក្តីទុក្ខលំបាកផ្លូវកាយផង ដូច្នេះបុរសស្ត្រីត្រូវខំអប់រំទូន្មានចិត្តដោយបញ្ញា ដោយការព្យាយាម និង ដោយសម្មាទិដ្ឋិ ។

២-កាលដែលព្រះគុណម្ចាស់ចេញបួស ព្រមលះបង់ពពួកញាតិ មាតាបិតា ដែលជាអ្នកមាននូវឧបការគុណច្រើន ប្រាថ្នាសេចក្តីសុខក្សេមក្សាន្តក្នុងផ្នួស ប៉ុន្តែព្រះគុណម្ចាស់ ម្តេចក៏មិនលះបង់នូវសត្រូវគឺសេចក្តីក្រោធ ដែលសត្រូវនេះធ្វើនូវសេចក្តីវិនាសឱ្យព្រះគុណម្ចាស់ដ៏ក្រៃលែង ដើម្បីឱ្យព្រះគុណម្ចាស់បានស្ងប់ក្នុងផ្នួសពិតប្រាកដផង ។

៣-ក្នុងការដែលយើងគាំទ្រសេចក្តីខឹងក្រោធ នៅក្នុងរឿងអ្វីមួយ ដែលសេចក្តីក្រោធខឹងនោះឯង ជាតួកាត់បំផ្លាញនូវឫសគល់នៃសីលទាំងឡាយរបស់យើង តើយើងហ្នឹង ល្ងង់ប៉ុនណាទៅ យើងគប្បីពិចារណាក្នុងសេចក្តីនេះមើលផងចុះ ។

៤-យើងកើតទុក្ខមិនសុខចិត្ត ក្តៅក្រហាយក្នុងគំនិត ថាអ្នកដទៃធ្វើអំពើព្រៃផ្សៃ រំលោភបំពានមកលើយើង ប៉ុន្តែសូម

កុំភ្លេចថា កាលដែលយើងកំពុងខឹងក្រោធហ្នឹងឯង គឺជាបុគ្គលព្រៃផ្សៃដ៏ក្រៃលែង បៀតបៀនខ្លួនឯងផង បំណងសងសឹកផង និង ការប្រព្រឹត្តព្រៃផ្សៃដ៏ខ្លាំងក្លាម្យ៉ាងទៀតនោះ គឺកម្ចាត់នូវគុណធម៌ក្នុងសន្តាននៃខ្លួនឯង ដូច្នេះ ការក្រោធខឹងជាប្រធាននៃសេចក្ដីវិនាស ។

៥-អ្នកដទៃដែលគេចង់បៀតបៀនយើង គេប្រើល្បិចកលផ្សេងៗដើម្បីឱ្យយើងខឹងក្រោធ កាលបើយើងមានចំណុចខ្សោយត្រង់នេះ ឈ្មោះថាយើងញ៉ាំងមនោរថគឺបំណងរបស់គេឱ្យសម្រេច ដូច្នេះ បើទោះជាកិលេសរបស់យើង នៅមិនទាន់លះដាច់យ៉ាងណាក៏ដោយ ត្រូវយើងកុំឱ្យខ្សោយពេក ត្រូវប្រឹងប្រែងជួយខ្លួនឯង គឺកុំឆាប់ខឹង ព្រោះបើយើងឆាប់ខឹង យើងនឹងដល់នូវសេចក្ដីវិនាសដោយប្រការផ្សេងៗ ។ ក្រោធមួយពេល អាចនាំមកនូវសេចក្ដីលំបាកឱ្យខ្លួនឯង អស់មួយជីវិតក៏មានដែរ ។

៦-គួរឱ្យតិះដៀលចំពោះខ្លួនឯងដែលជាបុគ្គលល្ងង់នេះណាស់ ព្រោះនៅពេលដែលយើងខឹងនឹងអ្នកដទៃ យើងនឹងធ្វើ



សេចក្ដីទុក្ខឱ្យគេឬមិនធ្វើក៏ដោយ ប៉ុន្តែខ្លួនឯងពេលក្រោធហ្នឹងតែម្ដង កំពុងតែបៀតបៀនដល់ខ្លួនឯង ។ មនុស្សយើងស្រឡាញ់ខ្លួនឯងណាស់ លើសអ្វីៗទាំងអស់ ដូច្នេះត្រូវចេះជួយខ្លួនឯង បើយើងបៀតបៀនខ្លួនឯងទៅហើយ តើមានអ្នកណាក្នុងលោកនេះអាចមកជួយយើងបាន ដាច់ខាតកុំបោះបង់ខ្លួនឯងចោលឱ្យសោះ ព្រោះមានតែយើងម្នាក់គត់ ដែលអាចជួយខ្លួនយើងបាន ។

៧-បើដឹងថាពួកអ្នកក្រោធទាំងឡាយ បានឡើងកាន់ផ្លូវមរណៈ ផ្លូវគ្រោះថ្នាក់ ផ្លូវប្រកបដោយភ័យ ផ្លូវមានសត្រូវ ផ្លូវចម្រូង ផ្លូវបន្លា ផ្លូវមានវិបត្តិ ផ្លូវកង្វល់ ផ្លូវធ្លាក់ជ្រោះ ទៅហើយនោះ ហេតុអ្វីយើងត្រូវទៅតាមផ្លូវនោះដែរ ? ឬមួយយើងមិនដឹងថា សេចក្ដីក្រោធជាផ្លូវនៃសេចក្ដីវិនាសទេឬ ?

បុគ្គលណា ក្រោធតបទៅរកអ្នកដែលក្រោធមុនហើយនោះ បុគ្គលនោះអាក្រក់ជាងអ្នកដែលក្រោធមុននោះទៅទៀត ចំណែកបុគ្គលណា មិនក្រោធតបទៅរកអ្នកដែលក្រោធហើយនោះទេ បុគ្គលនោះ ឈ្មោះថាជាអ្នកឈ្នះនូវសង្គ្រាម ដែលកម្រ

នឹងបានឈ្នះ ។ បុគ្គលណា ដឹងថាអ្នកដទៃក្រោធហើយ ក៏មានសតិរម្ងាប់ចិត្តរបស់ខ្លួនឯងបាន ដោយមិនមានការក្រោធតបបុគ្គលនោះ ឈ្មោះថាជាអ្នកប្រព្រឹត្តធ្វើនូវប្រយោជន៍ទាំងពីរខាង គឺទាំងខាងអ្នកដទៃផង ទាំងខាងខ្លួនឯងផង ដូច្នេះ បុគ្គលគប្បីឃើញទោសនៃការខឹងក្រោធ ឃើញអានិសង្សនៃការមិនក្រោធខឹង ហើយគប្បីសមាទាននូវអំណត់គឺសេចក្ដីអត់ធន់ និងចម្រើនមេត្តាភាវនា ផ្សាយភាពត្រជាក់ចេញអំពីចិត្តរបស់ខ្លួនឱ្យទៅដល់សត្វលោកគ្រប់គ្នា បីដូចមាតាបិតារក្សានូវបុត្រស្ងួនភ្ងាពិសី ។

៨- អ្នកដទៃធ្វើនូវអំពើមិនជាទីពេញចិត្តឱ្យដល់យើងដោយខន្ធទាំងឡាយណា ខន្ធទាំងឡាយនោះក៏រលត់ទៅហើយព្រោះសង្ខារធម៌ទាំងឡាយប្រព្រឹត្តទៅជាខណៈៗ មានការកើតឡើងហើយព្រោះអាស្រ័យបច្ច័យ រមែងមានការរលត់ទៅវិញមិនទៅតាំងនៅក្នុងទីណាឡើយ ឥឡូវនេះ តើយើងក្រោធជាមួយនឹងបុគ្គលណាដែរ ? មានតែក្រោធជាមួយខន្ធបច្ចុប្បន្នដែលក្នុងគំនិតគិតប្រកាន់ថា ជាបុគ្គលដែលគួរឱ្យយើងក្រោធ



តាមពិតទៅ ដោយបរមត្ថធម៌ សត្វបុគ្គលក្នុងខន្ធអតីតៈ អនាគត និង បច្ចុប្បន្ន ពុំមានឡើយ ប៉ុន្តែដែលយើងចេះតែក្រោធខឹងនឹងបុគ្គលនេះ ឬបុគ្គលនោះ ព្រោះមិនឆ្លាតនៅក្នុង **អត្ថគ្គហណមនោទ្វារវិថី** បានដល់វិថីចិត្តក្នុងមនោទ្វារកើតឡើង កាន់យកនូវអត្ថប្បញ្ញត្តិជាអារម្មណ៍ និង មិនឆ្លាតនៅក្នុង **នាមគ្គហណមនោទ្វារវិថី** បានដល់វិថីចិត្តក្នុងមនោទ្វារកើតឡើងដែរ ប៉ុន្តែមានការកាន់យកនូវឈ្មោះគឺសទ្ទប្បញ្ញត្តិជាអារម្មណ៍ ។

៩-ព្រោះយើងកើត ទើបយើងមានទុក្ខ មានសត្រូវណាមកធ្វើទុក្ខឱ្យយើងបាន បើយើងមិនបានកើតមកទេនោះ អធិប្បាយថា ព្រោះបញ្ចក្ខន្ធកើតឡើង ទុក្ខរមែងកើតឡើង ទុក្ខរមែងមិនកើតឡើង ព្រោះការមិនកើតឡើងនៃបញ្ចក្ខន្ធហ្នឹងឯង ។ បញ្ចក្ខន្ធជា **ឧបធិ** គឺជាគ្រឿងទ្រទទួលនូវទុក្ខសព្វបែបយ៉ាង បើពោលដោយអនត្តលក្ខណៈ បញ្ចក្ខន្ធពុំមែនជាសត្វបុគ្គលតួខ្លួន សត្វបុគ្គលតួខ្លួនមិនមាននៅក្នុងបញ្ចក្ខន្ធហើយសត្វបុគ្គលតួខ្លួនក៏មិនមែនអ្វីដទៃផ្សេងអំពីបញ្ចក្ខន្ធទៀត

ដែរ សរុបមក សត្វបុគ្គលតួខ្លួនមិនមានក្នុងបរមត្ថលោកនេះឡើយ ដូច្នេះហើយ មានបុគ្គលណាមកធ្វើសេចក្ដីទុក្ខឱ្យយើងបាន បើខ្លួនយើងជាសត្វបុគ្គលពុំមានផងទេនោះ តើយើងក្រោធខឹងជាមួយអ្នកដទៃអំពីរឿងអ្វី ? ត្រូវចោទអ្នកដទៃឬក៏ត្រូវចោទខ្លួនឯងដែលមានសក្កាយទិដ្ឋិវិញ ? (សក្កាយទិដ្ឋិបានដល់សេចក្ដីប្រកាន់ថាមានខ្លួនជាសត្វបុគ្គលពិត) ។



# ប្រាំបួនចំណុចគួរចងចាំ

១-ប្រហារផ្លូវចិត្តខ្លួនឯងព្រោះសេចក្ដីក្រោធ

២-លះបង់អ្នកមានគុណបាន តែលះបង់សត្រូវគឺសេចក្ដីក្រោធពុំបាន

៣-គាំទ្រសេចក្ដីក្រោធ ដែលកាត់ឫសគល់នៃកុសលសីលរបស់ខ្លួនឯង

៤-ធ្វើអំពើព្រៃផ្សៃឱ្យដល់ខ្លួនឯង ព្រោះសេចក្ដីក្រោធ

៥-សេចក្ដីក្រោធជាចំណុចខ្សោយមួយ ក្នុងបណ្ដាចំណុចខ្សោយទាំងឡាយ

៦-គួរឱ្យតិះដៀលខ្លួនឯងណាស់ ព្រោះបៀតបៀនខ្លួនឯងដោយសេចក្ដីក្រោធ

៧-មានសេចក្ដីក្រោធ ឈ្មោះថាឡើងកាន់ផ្លូវទៅរកគ្រោះថ្នាក់

៨-បញ្ចក្ខន្ធមិនទៀង បុគ្គលសម្រាប់ឱ្យយើងក្រោធនោះមិនមានទេ

៩-បញ្ចក្ខន្ធជាឧបធិ មិនមានអ្នកណាធ្វើទុក្ខឱ្យខ្លួនយើងឡើយ ។

# ពិចារណាកម្មផល

យើងគួរកុំភ្លេច **កម្មស្សកតា** ដែលមានសេចក្ដីថា សត្វលោកប្រព្រឹត្តទៅតាមកម្ម ដែលខ្លួនបានធ្វើទុកហើយ ។ មនុស្សយើងកើតមកទទួលនូវទ្រព្យមរតករបស់កម្ម ដែលខ្លួនឯងបានសន្សំទុកអំពីជាតិមុនមក ទ្រព្យមរតក គឺជាទ្រព្យរបស់អ្នកដែលស្លាប់ទៅហើយ ត្រូវបានមកដល់អ្នកដែលនៅរស់ទទួលយក ក្នុងន័យនេះ អ្នកដែលបានស្លាប់ទៅហើយនោះ គឺខ្លួនយើងអំពីជាតិមុនហ្នឹងឯង កាលអំពីជាតិមុនយើងបានធ្វើកម្មអ្វីខ្លះ កម្មនោះមានឱកាសជាបច្ច័យ ក៏បានញ៉ាំងផលឱ្យកើតឡើង ជាមរតកឱ្យដល់ខ្លួនយើងដែលជាអ្នកបានធ្វើហើយនោះទទួលផ្ទាល់ក្នុងជាតិនេះ មិនមានអ្នកដទៃណាទទួលជំនួសបានទេ ក៏ដូចជាការកើតចាស់ឈឺស្លាប់អីចឹងដែរ មិនមានអ្នកណាទទួលជំនួសអ្នកណាឡើយ ដូច្នេះក្នុងសេចក្ដីនេះ មនុស្សយើង



ម្នាក់ៗ រៀងៗខ្លួន ជាអ្នកវេចស្ពាយនូវសម្ពាយកម្មត្រាច់រង្គាត់ក្នុងវដ្ដសង្សារ ជាផ្លូវកន្តារឆ្ងាយបំផុត និងក្រៃលែងទៅដោយគ្រោះថ្នាក់ទៀតផង ។

បញ្ជាក់សេចក្ដីមកប៉ុណ្ណេះ ព្រោះហេតុនេះ យើងខឹងក្រោធនឹងអ្នកដទៃតើយើងធ្វើអ្វីគេបាន?

កម្មទាំងឡាយដែលមានទោសៈជាហេតុ វារមែងប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាសដល់ខ្លួនឯងជាអ្នកធ្វើតែប៉ុណ្ណោះ ចំណែកអ្នកដទៃ គេទទួលនូវវិបាកកម្មរបស់គេទេតើ មិនមែនយើងធ្វើកម្ម ស្រាប់តែអ្នកដទៃផ្សេង ទទួលផលកម្មដែលយើងបានធ្វើនោះឡើយ ម្យ៉ាងទៀត កម្មដែលមានទោសៈជាហេតុនេះ នឹងញ៉ាំងយើងដែលជាអ្នកធ្វើឱ្យបានសម្រេចនូវសម្មាសម្ពោធិញ្ញាណក៏ទេ បច្ចេកពោធិញ្ញាណក៏ទេ ឬថាឱ្យបានជាអគ្គសាវ័ក មហាសាវ័ក ព្រះឥន្ទព្រះព្រហ្ម ឬទេវតាថ្នាក់ណាមួយក៏ទេដែរ បន្តមកទៀត សូម្បីតែឱ្យបានត្រឹមកំណើតមនុស្សមិនបានខ្ពង់ខ្ពស់ក៏ហីទៅចុះ ក៏ទេដែរ ចំពោះអំពើកម្មដែលមានទោសៈជាហេតុនេះ មានតែញ៉ាំងយើងឱ្យឃ្លាតចាកអំពី

ព្រះសាសនា និង ញុំាងទុក្ខផ្សេងៗដ៏ខ្លាំងក្លា មានទុក្ខក្នុងនរក
ជាដើម ឱ្យដល់យើងតែប៉ុណ្ណោះ ។ យើងប្រាថ្នាឱ្យអ្នកដទៃ
រលាកភ្លើង ដោយខ្លួនយើងផ្ទាល់លោតចូលក្នុងរណ្ដៅរងើក
ភ្លើង យើងចង់ឱ្យអ្នកដទៃស្អុយ ដោយការលោតចូលក្នុងរណ្ដៅ
លាមកខ្លួនឯង ទាំងនេះគឺជាអំពើល្ងង់ខ្លៅរបស់អ្នកល្ងង់មែន
ទែន យ៉ាងណាមិញ ការប្រព្រឹត្តធ្វើនូវអំពើកម្ម របស់អ្នកដែល
ខឹងក្រោធ ក្នុងបំណងបៀតបៀនអ្នកដទៃ ក៏មានន័យយ៉ាង
នោះឯង ។

បុគ្គលពាលណា ប្រទូសរ៉ាយដល់បុគ្គលដែលបរិសុទ្ធមិន
មានការគិតអាក្រក់ ផលដ៏សែនក្ដៅក្រហាយ ក៏រមែងត្រឡប់
មកដល់បុគ្គលពាលនោះឯងវិញ ដូចធូលីដែលល្អិតផង់ ដែល
បុគ្គលបាចបញ្ច្រាសខ្យល់ ក៏រមែងត្រឡប់មកដល់ បុគ្គលអ្នក
បាចនោះវិញ អ៊ីចឹងឯង ។



# គាថាធម្មបទប្រារព្ធនាយនន្ទគោបាល

៤ទិសោ ទិសំ យន្តំ កយិរា   វេរី វា បន វេរិនំ
មិច្ឆាបណិហិតំ ចិត្តំ   បាបិយោ នំ តតោ ករេ ៕

ចិត្តដែលតម្កល់ទុកខុសហើយ រមែងធ្វើនូវបុគ្គលអ្នក
តម្កល់ចិត្តខុសនោះ ឱ្យអាក្រក់សៅហ្មងក្រៃលែង ជាងសេចក្ដី
វិនាសនៃការប្រទូសរ៉ាយរបស់ចោរនិងចោរ ឬបុគ្គលមានពៀរ
នឹងគ្នា បានជួបប្រទះឃើញគ្នាទៅទៀត ។

ចិត្តដែលតម្កល់ទុកនូវមិច្ឆាទិដ្ឋិ ឬបាបកម្មផ្សេងៗដែល
ចិត្តបានសន្សំទុកហើយ មិច្ឆាទិដ្ឋិនោះក្ដី បាបកម្មផ្សេងៗទៀត
ក្ដី វាអាក្រក់ សាហាវឃោរឃៅ ក្រៃលែងជាងចោរសត្រូវ
ខាងក្រៅណាៗទាំងអស់ នៅក្នុងរឿងនេះ គួរឱ្យស្រណោះ
សត្វលោកយើងណាស់ ខំធ្វើផ្ទះមានទ្វារចាក់សោ ធ្វើរបង
កំពែងការពារ មានអ្នកយាមរក្សាទាំងយប់ទាំងថ្ងៃ ប៉ុន្តែខ្លួន
ឯងបែរជាប្រមូលសត្រូវ យកមកឱ្យនៅក្នុងចិត្តដោយមិនញញើត
ព្រោះហេតុតែល្ងង់មិនដឹងបាបកម្មជាកំពូលសត្រូវរបស់ខ្លួន ។

# ញាតិក្នុងវដ្ដសង្សារគួរពិចារណា

នៅក្នុងសំយុត្តនិកាយ និទានវគ្គ អនមតគ្គសំយុត្ត មានសំដែងអំពីទីបំផុតខាងដើមនៃសង្សារវដ្ដ ដែលបុគ្គលមិនអាចដឹងបាន ព្រះពុទ្ធទ្រង់ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនធ្លាប់ជាមាតា មិនធ្លាប់ជាបិតា មិនធ្លាប់ជាបងប្អូនប្រុស មិនធ្លាប់ជាបងប្អូនស្រី មិនធ្លាប់ជាបុត្រមិនធ្លាប់ជាធីតា របស់យើងទាំងឡាយមិនងាយរកបានឡើយ ។

ព្រោះហេតុដូច្នេះ បុគ្គលគួរចម្រើននូវមេត្តាចិត្តទៅរកសត្វទាំងឡាយ ឱ្យកើតឡើងក្នុងបុគ្គលនោះៗថា បុគ្គលនេះជាមាតាអំពីអតីតជាតិរបស់យើង រក្សាយើងនៅក្នុងផ្ទៃជាច្រើនខែ កើតចាកផ្ទៃមកហើយ មិនសំដែងអាការៈខ្ពើមឆ្អើមក្នុងគ្រឿងបដិកូលទាំងឡាយ មានមូត្រលាមក គម្រើក្អួតឈ្លក់ជាដើមឡើយ ចាប់ដោយដៃយ៉ាងស្និទ្ធ បីដូចលំអិតខ្លឹមចន្ទន៍



ក្រហម បានឱ្យយើងដេកអែបនឹងដើមទ្រូងគាត់ បីយើងបំបៅដោះ ដាក់អង្រឹងយោលបំពេ ថ្នាក់ថ្នមល្បួងលោមថើបថៃថ្នូន ព្រឹកល្ងាចយប់ថ្ងៃរហូតដល់ដឹងក្ដី គ្រប់គ្រងបន្តចិញ្ចឹមបីបាច់ថែរក្សា ចំណែកបិតាចាត់ចែងកិច្ចការងារ ដើរផ្លូវលំបាកផ្លូវឆ្ងាយ ផ្លូវមានអន្តរាយ ប្រកបការលក់ដូរធ្វើស្រែចំការកម្មករលីសែង ធ្វើការលំបាកផ្សេងៗដើម្បីជាប្រយោជន៍ដល់យើង គិតថានឹងចិញ្ចឹមកូនតូច ប្រឹងប្រែងព្យាយាមប្រមូលទ្រព្យដោយឧបាយនោះៗ ។

ដោយហេតុយើងជាកូនក្នុងកាលណោះ ម៉ែយើងហ៊ានឈ្លោះឪយើងហ៊ានប្រកែកជាមួយអ្នកដទៃ ព្រោះហួងហែងកូនប្រុសស្រី សន្សំទ្រព្យទុកសំរាប់កូន មិនធ្វើទាន មិនរក្សាសីល ភ្លាត់គតិខ្លួនឯងទៅនរក ឬប្រេតតិរច្ឆានមនុស្សកំសត់ រឿងនេះពិតមែនតែជាកិលេសរបស់គាត់ ប៉ុន្តែព្រោះជំពាក់នឹងយើងជាកូន ក៏ក្លាយជាអ្នកទោសក្នុងសង្សារវដ្ដរហូតសព្វថ្ងៃនេះ ។

រឿងសង្សារវដ្ដ មិនមែនជារឿងព្រេងគ្រាន់តែនិយាយ

កំដរកូនក្មេងនោះទេ វាជារឿងដែលគួរឱ្យសង្វេគតក់ស្លុតក្រៃលែង ប៉ុន្តែសម្រាប់អ្នកដែលមានសទ្ធា និង បញ្ញាតែប៉ុណ្ណោះ ដែលមានសេចក្តីសង្វេគនោះ ព្រោះបញ្ញាបានឃើញហេតុដែលញ៉ាំងបញ្ចក្ខន្ធឱ្យកើតឡើង បានដល់អវិជ្ជា និង តណ្ហា ។

អវិជ្ជា និង តណ្ហាពុំមែនទើបតែមាននៅក្នុងជាតិនេះទេ បើទើបតែមាននៅក្នុងជាតិនេះ តើមានអ្វីញ៉ាំងអត្តភាពបច្ចុប្បន្ននេះ ឱ្យកើតមកបាននោះ ដូច្នេះមនុស្សយើងម្នាក់ៗគឺជាក្រសែនៃសង្សារវដ្ត ដែលមិនដឹងទីបំផុតខាងដើម ដឹងត្រឹមតែថា អវិជ្ជាតណ្ហាជាហេតុតែប៉ុណ្ណោះ ។

ដរាបណា អវិជ្ជា និង តណ្ហាមិនទាន់បានលះ ដរាបនោះទីបំផុតនៃផ្លូវកន្តាររនៅតែមិនទាន់បានដល់ ប៉ុន្តែការលះបង់នូវសម្បត្តិទាំងពួង ក្នុងមួយជាតិៗ រមែងប្រព្រឹត្តទៅជានិច្ច សត្វលោកមិនមានអ្វីជារបស់ខ្លួនឡើយ ត្រូវលះបង់នូវរបស់គ្រប់យ៉ាងហើយទៅ ។

ជាការពិតប្រាកដណាស់ បើយើងនិយាយត្រឹមតែលោក ៦ គឺលោកភ្នែក លោកត្រចៀក លោកច្រមុះ លោកអណ្តាត



លោកកាយ និង លោកចិត្ត ក្នុងជីវិតប្រចាំថ្ងៃ វាមានដំណើរនៃវិថីចិត្ត ឬខណៈចិត្តបន្តគ្នាមិនដាច់ វាមានការលះបង់ចោលទៅនូវលោកឯណានីមួយ មានលោកភ្នែកជាដើម ដោយមិនដែលឈប់បង្អង់នៅឡើយ ។

ដំណើរនៃខណចិត្តត្រាច់រង្គាត់ក្នុងលោក ប្រព្រឹត្តទៅរហ័ស គឺខណៈមួយរលត់ទៅ បានញ៉ាំងខណៈមួយទៀតឱ្យកើតឡើងបន្តគ្នា ដោយអំណាចបច្ច័យផ្សេងៗ អំណាចនៃបច្ច័យនេះខ្លាំងក្លាជាទីបំផុត វាបានរួមប្រជុំគ្នាបង្កើតសង្ខារធម៌ឱ្យទៅជាខ្សែ ដែលហៅថាវដ្តសង្សារបាន ។

# ព្រះគាថាធម្មបទប្រារព្ធដំរីបាវេរកៈ

**αអប្បមាទរតា ហោថ　　　សចិត្តមនុរក្ខថ**

**ទុគ្គា ឧទ្ធរថត្តានំ　　　បង្កេ សន្នោវ កុញ្ជរោ ។**

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូរតាមរក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចាកភក់ ដូចជាដំរីដែលជាប់ភក់ហើយ ខំប្រឹងរើខ្លួនឱ្យរួចផុតអំពីភក់ យ៉ាងដូច្នោះឯង ។

ដំរីបាវេរកៈរបស់ព្រះបាទកោសល បានជាប់ក្នុងអន្លង់ភក់រើខ្លួនមិនរួច ព្រះរាជាទ្រង់បានបង្គាប់ឱ្យហត្ថាចារ្យទៅជួយដំរីនោះ ហត្ថាចារ្យទៅហើយ សម្តែងអាការៈចម្បាំងដូចចូលសង្គ្រាម មានទូងស្គរស្រែកហ៊ោជាដើម ដំរីបាវេរកៈមានជាតិជាសត្វអង់អាចក្នុងពេលនោះប្រឹងឡើងដូចចូលកាន់សមរភូមិ ក៏បានរួចចាកអន្លង់ភក់ តាំងនៅលើគោកបាន ព្រោះប្រារព្ធរឿងនោះ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំរីនោះអាចរើខ្លួនចាករណ្តៅភក់បាន យ៉ាងណាមិញ អ្នកទាំងឡាយដែលបានធ្លាក់ក្នុងរណ្តៅភក់គឺកិលេស ព្រោះហេតុដូច្នេះ អ្នកទាំងឡាយគប្បីព្យាយាមដោយឧបាយត្រូវទំនងល្អ រើខ្លួនចាករណ្តៅភក់គឺកិលេស ក៏យ៉ាងនោះដែរ រួចទ្រង់ត្រាស់នូវព្រះគាថាធម្មបទ ។



# ពិចារណាអានិសង្សមេត្តា

**អានិសង្ស ១១ប្រការ ចាកអង្គុត្តរនិកាយឯកាទសកនិបាត**

**ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង**

**១-សុខំ សុបតិ** ដេកលក់ជាសុខ

**២-សុខំ បដិពុជ្ឈតិ** ភ្ញាក់ឡើងជាសុខ

**៣-ន បាបកំ សុបិនំ បស្សតិ** មិនយល់សប្តិអាក្រក់

**៤-មនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់របស់ពួកមនុស្ស

**៥-អមនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់របស់ពួកអមនុស្ស

**៦-ទេវតា រក្ខន្តិ** ពួកទេវតាតែងរក្សា

**៧-នស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី មិនបានចូលមកជិតកាយ ធ្វើនូវអន្តរាយ ឡើយ

**៨-តុចដ្ដំ ចិត្តំ សមាធិយតិ** ចិត្តរមែងតាំងមាំដោយឆាប់

**៩-មុខវណ្ណោ វិប្បសីទតិ** សម្បុរមុខស្រស់ថ្លា

**១០-អសម្មូឡ្ហោ កាលំ ករោតិ :** ជាអ្នកមិនវង្វេងក្នុងពេលធ្វើការកិរិយា

**១១-ឧត្តរី អប្បដិវិជ្ឈន្តោ ព្រហ្មលោ-កូបគោ ហោតិ** កាលបើមិនទាន់ត្រាស់ដឹងនូវគុណធមិជាន់ខ្ពស់គឺលោកុត្តរទេ រមែងចូលទៅកាន់ព្រហ្មលោក ។

ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលបានសេពគប់ បានចម្រើន បានធ្វើឱ្យច្រើន បានធ្វើឱ្យដូចជាយានបានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ អានិសង្សទាំង ១១ ប្រការនេះ រមែងកើតប្រាកដ ។



# ដេកលក់ជាសុខដោយអានិសង្សមេត្តា

បើយើងខឹងក្រោធនឹងអ្នកដទៃ ប្រៀបបីដូចជាត្រូវថ្នាំពិស ដេកមិនលក់បក់មិនល្ហើយ ប៉ុន្តែបើយើងមិនក្រោធ រមែងដេកជាសុខ រមែងមិនសោយសោក មិនក្ដៅក្រហាយ ។

**អភយទាន** ជាទានមានអ្នកទទួលទាំងសងខាង គឺទាំងខ្លួនឯងអ្នកឱ្យ ទាំងអ្នកដទៃក៏បាននូវសេចក្ដីក្សេម ដូច្នេះយើងគួរអប់រំចិត្តឱ្យមានសីលល្អ មានទិដ្ឋិត្រង់ រៀនកាន់យកនូវនិមិត្តដែលនាំឱ្យមានមេត្តា ប្រាថ្នាការមិនមានភ័យឱ្យដល់អ្នកដទៃ ព្រោះថា សត្វទាំងឡាយមិនចង់បាននូវភ័យទេ ។

សត្វទាំងឡាយប្រាថ្នាសេចក្ដីសុខ បុគ្គលមានខ្លួនឯងជាគ្រឿងប្រៀបធៀប បានត្រឹមត្រូវល្អហើយ ឈ្មោះថាកាន់យកនូវមេត្តានិមិត្ត មេត្តានិមិត្តជាអត្ថប្បញ្ញត្តិ ជាធម្មារម្មណ៍នាំឱ្យមនោទ្វារវិថីចិត្ត ប្រកបដោយមេត្តា ។

**ត្រូវចាំទុកថា** បើយើងមិនមានមេត្តាដល់អ្នកដទៃទេ ព្រោះគិតថាមេត្តាគេមិនបាន ក៏គួរកុំភ្លេចមេត្តាខ្លួនឯង សូមឱ្យខ្លួនឯងបានដេកលក់ជាសុខផងចុះ សូមឱ្យអភ័យដល់ខ្លួនឯងផង ព្រោះថា ខ្លួនឯងក៏មិនចង់បាននូវភ័យដែរ ។

# ភ្ញាក់ឡើងជាសុខដោយអានិសង្សមេត្តា

បើយើងមានរឿងនាំឱ្យខឹងក្រោធ យើងអត់ក្រោធមិនបាន សូម្បីកន្លងមួយពេលដេកលក់ទៅហើយក៏ដោយ កាលភ្ញាក់ឡើងនៅចាំរឿងនោះ ក៏ក្រោធឡើងជាថ្មីទៀត ព្រោះឧបនិស្ស័យនៃសេចក្ដីក្រោធមុនជាបច្ច័យ ជួនកាលក្ដៅក្រហាយចិត្ត ព្រោះគិតដល់អំពើឆ្គួតលីលារបស់ខ្លួន ដែលបានធ្វើនៅពេលខឹងក្រោធនោះ ឬនៅពេលដែលមានរាគៈ ។

ចំពោះបាបកម្មដែលបានធ្វើហើយ វាមិនមែនបាបត្រឹមតែពេលដែលប្រព្រឹត្តហ្នឹងប៉ុណ្ណឹងទេ វានាំឱ្យសន្សំបាបក្នុងចិត្តនៅពេលដែលនឹកឃើញដល់បាបកម្មនោះ ហើយក្ដៅក្រហាយស្ដាយក្រោយ សភាពនៃចិត្តនៅសែនឆ្ងាយអំពីវិវេក គឺសេចក្ដីស្ងប់ស្ងាត់ មុននឹងដេកលក់ក្ដី កំពុងដេកលក់ក្ដី ភ្ញាក់ឡើងក្ដី ចិត្តចម្រើនទៅដោយសេចក្ដីសៅហ្មង ។

រាគៈ ទោសៈ មោហៈ ជាគ្រឿងធ្វើចិត្តឱ្យសៅហ្មង សូមពុទ្ធបរិស័ទរៀនអប់រំសតិប្បដ្ឋាន សិក្សាសភាវធម៌ កម្ចាត់បង់សេចក្ដីប្រកាន់ និង សេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ព្រមដោយការចម្រើននូវមេត្តា ធ្វើឱ្យមានការភ្ញាក់ឡើងជាសុខ ដូចផ្កាឈូកកំពុងរីក ញញឹមទទួលរស្មីនៃព្រះអាទិត្យ ។



# មិនយល់សប្តិអាក្រក់ដោយអានិសង្សមេត្តា

បុគ្គលអ្នកចម្រើនមេត្តា សូម្បីតែយល់សប្តិ ក៏យល់សប្តិឃើញតែរឿងដែលចម្រើនប៉ុណ្ណោះ ដូចជាថ្វាយបង្គំព្រះចេតិយ ដូចជាកំពុងធ្វើការបូជា ឬដូចជាកំពុងស្ដាប់ធម៌ជាដើម រមែងមិនយល់សប្តិឃើញអាក្រក់សម្រាប់ខ្លួនឡើយ ។

ការយល់សប្តិអាក្រក់ នាំឱ្យភ័យខ្លាចញ័ររន្ធត់ ដូចជាឃើញចោរនាំគ្នាមកចាប់ ឃើញសត្វដេញ ឬឃើញថាខ្លួនឯងធ្លាក់ជ្រោះជាដើម ទាំងនេះ ព្រោះវាជាអកុសលជវនក្នុងមនោ-ទ្វារ ដែលមិនអាចហាមឃាត់បានឡើយ ដោយអាស្រ័យមកអំពីការសន្សំចិត្តបាបរឿយៗរាល់ថ្ងៃ ។

សុបិនមនោទ្វារវិថីចិត្ត កើតឡើងនឹកគិតនូវអារម្មណ៍ដែលធ្លាប់បានឃើញ ធ្លាប់បានស្ដាប់ឮជាដើម និង ការចាំរឿងផ្សេងៗ ព្រមដោយកិលេសនិមិត្តនូវរឿងនេះរឿងនោះ តាមការគិតនឹកនៅពេលយល់សប្តិនោះផង វាជាការបញ្ជាក់ឱ្យយើងដឹងផងដែរថា សន្ដានចិត្តរបស់យើងបានសន្សំបាបច្រើន ឬសន្សំបុណ្យច្រើន បើជាអ្នកសន្សំមេត្តា រមែងមិនយល់សប្តិឃើញអ្វីដែលអាក្រក់នោះទេ គឺមិនមែនជាអកុសលចិត្តដែលយល់សប្តិ។

# ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ

នេះជាអានិសង្សរបស់មេត្តាប្រការមួយទៀត គឺរមែងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មនុស្សទាំងឡាយ ប្រៀបបីដូចជាពេជ្រទាំងគ្រាប់ ឬប្រៀបបីដូចជាទេវតា បានដល់បុគ្គលដែលសេពនូវមេត្តាចេតោវិមុត្តិហ្នឹងឯង ។

បុគ្គលខ្លះទោមនស្សអន់ចិត្ត ព្រោះគិតថា អញខំធ្វើល្អប៉ុណ្ណឹងហើយ គេនៅតែស្តីបន្ទោសឱ្យទៀត ក្នុងសេចក្តីនេះគប្បីជ្រាបថា អ្នកដទៃបានត្រឹមតែបន្ទោសប៉ុណ្ណោះ ម្យ៉ាងទៀតវាជាធម្មតារបស់ត្រចៀក និង សម្លេង ប៉ុន្តែខ្លួនឯងដែលទោមនស្ស គឺឈ្មោះថាមិនចេះថែទាំខ្លួនឯង មិនចេះរបៀបស្រឡាញ់ខ្លួន ចង់ឱ្យតែគេស្រឡាញ់ប៉ុណ្ណោះ ។

បុគ្គលខ្លះទៀតនោះ ចង់ឱ្យអ្នកដទៃស្រឡាញ់ខ្លួនឯងច្រើន១ ប៉ុន្តែបានជាភ្លេចថា ខ្លួនឯងក៏ត្រូវរៀនឱ្យចេះស្រឡាញ់អ្នកដទៃដូចគ្នាដែរ ដូច្នេះ ជំនួសចំណង់ដែលចង់ឱ្យអ្នកដទៃស្រឡាញ់ មានមេត្តាមកដល់ខ្លួននោះ គឺខ្លួនឯងត្រូវមានឆន្ទៈអប់រំមេត្តា មានការស្រឡាញ់អ្នកដទៃជាប្រក្រតី កាលបើយ៉ាងនេះ ចិត្តយើងក៏មិនក្តៅក្រហាយ យើងក៏ឈ្មោះថា ចេះស្រឡាញ់ខ្លួនពិតប្រាកដ និងជាហេតុឱ្យអ្នកដទៃស្រឡាញ់ផង។



# ជាទីស្រឡាញ់របស់ពួកអមនុស្ស

ឆន្ទៈមានការពេញចិត្តក្នុងកិច្ចការដែលត្រូវធ្វើ ដូចជាការអើពើជួយអនុគ្រោះបុគ្គលដទៃ ចម្រើនមេត្តាចិត្តជាប្រក្រតី មានលក្ខណៈផ្សេងអំពីលោភៈ លក្ខណៈរបស់លោភៈគឺត្រូវការប្រាថ្នាជាប់ជំពាក់ ដូចជាត្រូវការប្រាថ្នាចង់ឱ្យខ្លួនឯងមានគេស្រឡាញ់ចូលចិត្តច្រើនជាដើម បុគ្គលមិនអប់រំចម្រើនសតិប្បដ្ឋានរមែងមិនបានដឹងលក្ខណៈឆន្ទៈក្នុងកុសលចិត្ត ដែលខុសគ្នាអំពីលោភៈនោះឡើយ លោភៈនេះជាប់ជំពាក់នៅក្នុងកុសលក៏មាន ជាប់ជំពាក់នឹងផលរបស់កុសលក៏មាន ព្រោះដឹងថា ធ្វើកុសលហើយរមែងបានផលផ្សេង១ មានសម្បត្តិមនុស្ស សម្បត្តិទេវតាជាដើម ចិត្តសង្ឃឹមផលរបស់កុសលនោះជាតួលោភៈ ។

ឆន្ទៈក្នុងការចម្រើនកុសលធម៌ មិនមែនត្រូវការកុសលដូចលោភៈទេ តែជាការពេញចិត្តក្នុងកិច្ចការងារចម្រើនកុសលដោយមិនសង្ឃឹមផល ព្រោះជាអធ្យាស្រ័យពិត១ ចង់មនុស្សឬអមនុស្សស្រឡាញ់ក៏ដោយ មិនស្រឡាញ់ក៏ដោយ វាជារឿងអធ្យាស្រ័យរបស់អ្នកដទៃ ឯចំណែករឿងសំខាន់គឺចម្រើននូវកុសលធម៌ ប្រយុទ្ធជាមួយនឹងកិលេសក្នុងចិត្តសន្តានរបស់ខ្លួន **កសាងខ្លួនឯងមិនឱ្យមានបដិបក្ខ ជាមួយនឹងរបស់ជុំវិញខ្លួន** យ៉ាងនេះ រមែងជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ ពួកទេវតាតាមថែរក្សា ។

# ទេវតានាំងឡាយរមែងគ្រប់គ្រងរក្សា

ដូចបានសម្តែងក្នុងអានិសង្សខាងដើមហើយ ថាមិនមែនជាការប្រាថ្នាដើម្បីឱ្យមនុស្សឬអមនុស្សទាំងពួង មកចោមរោមស្រឡាញ់នោះទេ ប៉ុន្តែមេត្តាដែលបុគ្គលបានចម្រើនល្អហើយនោះឯង ធ្វើឱ្យចិត្តច្រើនទៅដោយកុសល ជាហេតុឱ្យមនុស្ស និង អមនុស្ស ព្រមទាំងទេវតា ស្រឡាញ់ជ្រះថ្លារក្សាថែទាំ ទេវតារក្សាអ្នកចម្រើនមេត្តា ដូចមាតាបិតារក្សាបុត្រ ។

ទោះបីមានទេវតារក្សា ក៏រក្សាគ្រប់គ្រងចិត្តសន្តានឱ្យយើងពុំបានដែរ ប៉ុន្តែមេត្តាចិត្តព្រមទាំងកុសលគ្រប់យ៉ាងទៀត ប្រសើរក្រៃលែងជាងទេវតា ព្រោះថា មេត្តាចិត្តក្តី សតិប្បដ្ឋានក្តី កុសលទាំងឡាយទាំងពួងទៀតក្តី អាចគ្រប់គ្រងរក្សាចិត្តរបស់យើងបាន ឱ្យតែយើងចម្រើននូវកុសលនោះៗ ។

មានពាក្យមួយឃ្លាបានសម្តែងហើយដែរថា កសាងខ្លួនឯងមិនឱ្យមានបដិបក្ខ ជាមួយនឹងរបស់ជុំវិញខ្លួន ការកសាងខ្លួនបានយ៉ាងនេះ ក៏ព្រោះបានដឹងថា អ្វីៗទាំងអស់ជុំវិញខ្លួនវាជាធម្មតា គឺធម្មតាភ្នែកគូនឹងរូប ធម្មតាត្រចៀកគូនឹងសម្លេង ធម្មតាពន្លឺរមែងភ្លឺ ធម្មតាសម្លេងរមែងលាន់។ល។ យល់ដឹងយ៉ាងនេះ ទើបមិនតាំងខ្លួនជាអ្នកទាស់ជាមួយរបស់ធម្មតា ជាអ្នកមានចិត្តស្ងប់ ។



# មេត្តាការពារអន្តរាយខាងក្រៅបាន

កុសលចិត្តដែលស្អាតផូរផង់ ជាមេត្តាពិតៗនោះ សូម្បីមិនទាន់បានសម្រេចដល់សមាធិថ្នាក់ខ្ពស់ ក៏អាចនាំឱ្យបានសុខមិនសម្បូរសត្រូវ ព្រោះខ្លួនឯងមិនទៅរករឿងអ្នកដទៃ មានប្រក្រតីនៅដោយសេចក្តីអត់ធន់ ស្ងប់ស្ងាត់ស្លូតបូតសុភាពរាបសា មិនឈ្លោះប្រកែកទាស់ទែងជាមួយនឹងបុគ្គលណា មានតែការប្រាថ្នាឱ្យអ្នកដទៃបានសុខ បានចេះដឹង បានចម្រើនប៉ុណ្ណោះ។

ការចម្រើននូវមេត្តា បើបានសម្រេចដល់អប្បនាសមាធិ អាចការពារបាននូវអន្តរាយផ្សេងៗ មិនឱ្យគ្រោះថ្នាក់ដល់រូបកាយ ដូចជាអន្តរាយដែលកើតអំពីភ្លើង ថ្នាំពិស គ្រឿងសស្ត្រាវុធជាដើម នេះជាអំណាចអានុភាពរបស់មេត្តាចេតោវិមុត្តិ ។ ចំពោះអន្តរាយដែលបានពោលមកនេះ វាគ្រាន់តែជាអន្តរាយខាងក្រៅប៉ុណ្ណោះ ចំណែកអន្តរាយខាងក្នុងនោះបានដល់កិលេសក្នុងសន្តាន កិលេសបានញ៉ាំងកម្មពៀរឱ្យកើតឡើង ដែលកម្មពៀរនេះមានកម្លាំងដ៏ខ្លាំងក្លា ដូច្នេះ គួរសាធុជនគប្បីយល់ដឹងអំពីកម្មពៀរ ហើយខំប្រឹងអប់រំនូវមេត្តាចិត្ត ព្រមដោយសតិប្បដ្ឋានវិបស្សនា ដើម្បីលះបង់ឱ្យអស់នូវកម្មពៀរវេរា បានដល់បរមសុខគឺព្រះនិព្វាន ។

# ចិត្តរមែងតាំងមាំបានឆាប់

ជាធម្មតាឈានលោកិយរមែងកម្រើក ត្រូវសាបសូន្យវិនាសដោយប្រការផ្សេងៗ មានការរវល់ថៃជម្ងឺ ឬកិលេសកំរើបរំជួលជាដើម ប៉ុន្តែដោយអំណាចអានិសង្សនៃមេត្តា បានធ្វើឱ្យឈានដែលសាបសូន្យទៅនោះ មិនចំពោះតែឈានណាឡើយ រមែងតាំងមាំឡើងវិញដោយឆាប់ នៅពេលដែលធ្វើទុកក្នុងចិត្តទៅរកអារម្មណ៍កម្មដ្ឋាននោះៗ ។

ជារឿងល្អិតល្អន់ក្រៃលែង ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងឱ្យពុទ្ធបរិស័ទចម្រើនមេត្តា ព្រោះមេត្តាគឺជាកុសលឧប-និស្ស័យ ញ៉ាំងកុសលដទៃផ្សេងៗទៀត ឱ្យកើតឡើងសន្ទឹកសន្ធាប់បាន ដូចជាចេះអាណិតអ្នកដទៃនៅពេលមានទុក្ខ មានការចម្រើនករុណាព្រហ្មវិហារ មានប្រក្រតីជួយសង្គ្រោះអ្នកដទៃដោយអាមិសទានឬធម្មទាន ចេះមានចិត្តទន់ភ្លន់ មិនច្រណែនទៅរកអ្នកដទៃណាៗ ដែលគេបានលាភយសសរសើរសុខ ជាដើម ចិត្តរមែងតាំងមាំក្នុងកុសលធម៌ បានទៅជាចិត្តឆ្លាត ។

ចិត្តមានមេត្តាជាចិត្តឆ្លាតក្នុងនិមិត្តទាំងពួង មនុស្សប្រុសស្រី គ្រហស្ថ បព្វជិត សត្វមានជីវិតទាំងអស់ជានិមិត្ត ដែលជាអារម្មណ៍នៃកុសលចិត្ត ព្រោះចិត្តឆ្លាត ប៉ុន្តែបើចិត្តមិនឆ្លាតទៅវិញ មួយថ្ងៃៗច្រើនទៅដោយ លោភៈ ទោសៈ មោហៈ ក្នុងអារម្មណ៍និមិត្តនោះៗ ។



# សម្បុរមុខស្រស់ថ្លាព្រោះមានមេត្តា

រូបារម្មណ៍មានសមុដ្ឋាន៤ គឺ : កម្ម ចិត្ត ឧតុ អាហារ បើចិត្តខឹងក្រោធសម្បុរមុខអាក្រក់ ព្រោះរូបារម្មណ៍ក្នុងពេលនោះវាមានទោសចិត្តជាសមុដ្ឋាន ផ្ទុយមកវិញសម្បុរមុខស្រស់ថ្លាព្រោះមានមេត្តាចិត្តជាសមុដ្ឋាន សូម្បីរូបស្រស់ស្អាតអំពីកំណើតក៏ព្រោះកម្មប្រកបដោយមេត្តាជាបច្ច័យហ្នឹងឯង ។

កូនប្រុសស្រីគួរបំរើមាតាបិតា ដោយទឹកមុខល្អស្រស់ថ្លាប្រកបដោយការពេញចិត្ត ព្រោះសូម្បីទឹកមុខស្រស់ថ្លានេះក៏ជាទេយ្យធម៌ដែរ ទាំងដែលជារបស់សំខាន់ទៀតផង ក្នុងការបូជាដល់ព្រះដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមនោះ ។

ពុទ្ធបរិស័ទគួរអប់រំស្មារតី ដើម្បីមិនវង្វេងក្នុងការទទួលអារម្មណ៍តាមទ្វារទាំង៦ ត្រូវនឹករលឹករឿយៗចំពោះឱវាទដែលព្រះអង្គទ្រង់ត្រាស់សម្ដែង ប្រៀបដោយរណារ ឬនឹករលឹកដល់ខន្តិបារមីរបស់ព្រះបរមពោធិសត្វ ដែលមិនក្រោធនៅពេលស្ដេចកលាបុបង្គាប់ឱ្យពេជ្ឈឃាតកាត់ដៃកាត់ជើងជាដើម **ត្រូវរៀនធ្វើជាមនុស្សធម្មតា** គឺមិនតម្កើងខ្លួនដោយមានៈ ព្រោះថា ធម៌ជុំវិញខ្លួនក៏សុទ្ធតែជារបស់ធម្មតាទាំងអស់ដែរ បើយើងមានការប្រកាន់ខ្លួនឱ្យខុសអំពីធម្មតា វានឹងមានការប៉ះទង្គិចដល់ផ្លូវចិត្តដោយមកអំពីគិតទៅលើរបស់ធម្មតា មានការប្រព្រឹត្តដោយកាយវាចានៃអ្នកដទៃជាដើម ថាមិនសមនឹងឋានៈស័ក្តិយសរបស់ខ្លួន។

# មិនខ្វែងពេលឡើបនឹងស្លាប់

ដូចបានពោលរួចហើយថា ត្រូវរៀនធ្វើជាមនុស្សធម្មតា យ៉ាងនេះ ទើបអាចទទួលនូវរបស់ធម្មតាបានគ្រប់យ៉ាង អ្វីៗជុំវិញខ្លួនវារមែងមានការប្រែប្រួលជាធម្មតា ម្យ៉ាងទៀត វាតែងតែមានគូរបស់វាជាធម្មតាផងដែរ ព្រោះវាជាអាយតនៈ ។

ពាក្យបុរាណខ្មែរបានពោលថា «ចូលស្ទឹងតាមបទ ចូលស្រុកតាមប្រទេស» បានសេចក្ដីថា ត្រូវចេះសម្របខ្លួនតាមសង្គមនោះៗ ទើបបានសុខ ដូចថែវទូកត្រូវបត់តាមស្ទឹងអីចឹងឯង ប៉ុន្តែព្រះសម្មាសម្ពុទ្ធបរមសាស្ដា ទ្រង់បង្រៀនយើងឱ្យចេះដឹងជ្រៅជ្រះជាងនេះទៅទៀត គឺឱ្យចេះដឹងក្នុងរឿងធម្មជាតិជុំវិញជីវិតរស់នៅ ឱ្យមានសម្មាទិដ្ឋិឃើញត្រូវថា «របស់ណាមានការកើតឡើងជាធម្មតា របស់នោះសុទ្ធតែមានការវិនាសទៅវិញជាធម្មតា» ។

សេចក្ដីស្លាប់គឺជាធម្មតាម្យ៉ាងក្នុងរឿងនៃជីវិត សេចក្ដីស្លាប់បានទុកពេលឱ្យយើងត្រៀមរៀបចំចិត្តទទួល ឱ្យបានស្រួលល្អក្នុងរយៈកាលក៏ល្មមដែរ ព្រោះបានឱ្យសញ្ញាតាំងតែពីពេលកើតមកម្ល៉េះ ថាសេចក្ដីស្លាប់នឹងមកតាមក្រោយដោយពិតពុំខាន យូរបន្តិចក្រមកដល់ សេចក្ដីស្លាប់បានបញ្ជូនជរា រួចហើយ ព្យាធិមកបន្តបន្ទាប់ ដើម្បីរំលឹកក្រែងយើងភ្លេច ដូច្នេះយើងត្រូវតម្កល់ខ្លួនយើងឱ្យជាមនុស្សបម្រុងនឹងស្លាប់ម្នាក់ តាមធម្មតានៃសេចក្ដីស្លាប់ដែលនឹងមកដល់ ពោលគឺតម្កល់ស្មារតីមានសីលល្អ មានសេចក្ដីត្រិះរិះតម្កល់ស្មើល្អ តាមរក្សាចិត្តរបស់ខ្លួន មិនឱ្យវង្វេងនឹងសេចក្ដីស្លាប់ ។



# អានិសង្សទី១១របស់មេត្តា

ទិសដៅនៃការបដិបត្តិក្នុងព្រះពុទ្ធសាសនា គឺការត្រាស់ដឹងអរិយសច្ចធម៌ សម្រេចនូវព្រះអរហត្តកម្ចាត់កិលេសអស់ពីសន្ដាន ប៉ុន្តែបើពុំទាន់បានសម្រេចសព្វគ្រប់ទេនោះ ត្រូវនៅមានជាតិកំណើតកើតបន្ត រមែងបដិសន្ធិក្នុងព្រហ្មលោក ដោយអំណាចអប្បនាឈានដែលបានសម្រេច ក្នុងការចម្រើនមេត្តា ។

អានិសង្សរបស់មេត្តាភាវនាទី១១នេះ មានការបញ្ជាក់ច្បាស់លាស់ណាស់ អំពីកិច្ចបដិបត្តិនៃពុទ្ធបរិស័ទ គឺការបដិបត្តិមិនមែនដើម្បីឱ្យបាននូវសម្បត្តិអ្វីមួយក្នុងភពដែលជាទីបំផុតនោះទេ ទោះជាឧបចារសមាធិឬអប្បនាសមាធិ ដែលខ្ពស់យ៉ាងណាក៏ដោយ ព្រោះនៅជាសង្ខតធម៌នៅឡើយ ប៉ុន្តែគ្រប់កុសលទាំងអស់ ពុទ្ធបរិស័ទអប់រំចម្រើនដើម្បីជាឧបការៈដល់សតិប្បដ្ឋានដែលជាផ្លូវទៅកាន់ព្រះនិព្វានជាអសង្ខតធម៌ ។

ពុទ្ធបរិស័ទបំពេញនូវកុសលអ្វីក៏ដោយ ដើម្បីឱ្យពុទ្ធបរិ-ស័ទចេញផុតចាកលោក ទាល់តែមានកុសលថ្នាក់សតិប្បដ្ឋានដែលអាចដឹងបានថា នេះជាកុសល នេះជាបច្ច័យនៃកុសលជាដើម ពុំមានសត្វបុគ្គលតួខ្លួន ក្នុងបរមត្ថធម៌ឡើយ បើពុំមានសតិប្បដ្ឋានចម្រើនជាប្រក្រតីទេនោះ អ្វីក៏ជាខ្លួននិងជារបស់ខ្លួនដែរដោយអំណាចនៃការប្រកាន់មាំ ពុំបានដឹងសង្ខតធម៌ឡើយ ហើយរឹតតែមិនអាចបានដឹងអសង្ខតធម៌តាមដែលពិតប្រាកដ។

# ពិចារណាចែកធាតុ

ដើម្បីជាជំនួយក្នុងការហាមឃាត់នូវសេចក្តីក្រោធ សម្រេចនូវការចម្រើនមេត្តា គម្ពីរវិសុទ្ធិមគ្គបានប្រាប់ឧបាយក្នុងការពិចារណា គឺបានដល់ការចែកធាតុ ព្រោះថា នេះជាការពិតដែលក្នុងមនុស្សសត្វម្នាក់ៗ មានសុទ្ធតែធាតុរួមប្រជុំគ្នាប៉ុណ្ណោះ ដូច្នេះតើគួរក្រោធជាមួយសក់រោមក្រចកធ្មេញស្បែក អាហារថ្មីអាហារចាស់ មូត្រលាមកឬ? ឬក៏ត្រូវក្រោធជាមួយរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធជាដើម ? បើការពិត បុគ្គលសម្រាប់ឱ្យយើងក្រោធពុំមានផងនោះ ។

ជាបន្តទៅនេះ ពុទ្ធបរិស័ទនឹងបានសិក្សាអំពីការចែកខន្ធធាតុ អាយតនៈផង សិក្សាអំពីវិថីចិត្តដែលមានអារម្មណ៍ផ្សេងគ្នាផង ក្រោយអំពីបានសិក្សាពិចារណាល្អហើយ ពុទ្ធបរិស័ទនឹងបានជ្រាបថា រឿងរ៉ាវទាំងអស់ក្នុងជីវិតនេះ ដែលចេះតែកើតមានមិនដាច់នោះ ព្រោះមកអំពីវាមាននូវអាយតនៈយ៉ាងពិត ។



# សំយុត្តនិកាយ សគាថវគ្គ
# ភិក្ខុនីសំយុត្ត សេលាសូត្រទី៩

❖សាវត្ថីនិទាន ។ គ្រានោះសេលាភិក្ខុនីស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយត្រឡប់មកពីបិណ្ឌបាត ក្នុងបច្ឆាភត្តក៏ដើរសំដៅទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុងទីនោះ លុះចូលទៅកាន់ព្រៃអន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។

គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យសេចក្តីតក់ស្លុត និង សេចក្តីព្រឺរោម ឱ្យកើតឡើងដល់សេលាភិក្ខុនី លុះចូលទៅដល់ហើយ ក៏បានពោលគាថានឹងសេលាភិក្ខុ (មានសេចក្តីប្រែ) ថា:

ពុម្ព គឺអត្តភាពនេះ អ្នកណាតាក់តែងឡើង បុគ្គលតាក់តែងនូវពុម្ពឋិតនៅក្នុងទីណា ពុម្ពកើតឡើងក្នុងទីណា ពុម្ពរលត់ទៅក្នុងទីណា ។

លំដាប់នោះ សេលាភិក្ខុនីមានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្សឬជាអមនុស្ស មកពោលគាថាដូច្នេះ ។ ទើបសេលាភិក្ខុនីមានសេចក្តីយល់ចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប ប្រាថ្នាញុំាងភ័យ សេចក្តីតក់ស្លុត និង សេចក្តីព្រឺរោម ឱ្យកើតឡើងដល់អាត្មាអញ និង ប្រាថ្នាឱ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលគាថា ។ លុះសេលាភិក្ខុនី ដឹងច្បាស់ថា នេះជាមារមានចិត្តបាបហើយ ទើបបានពោលនូវគាថាទាំងឡាយ នឹងមារមានចិត្តបាបថា:

**នយិទំ បកតំ ពិម្ពំ នយិទំ បកតំ អឃំ**
**ហេតុំ បដិច្ច សម្ភូតំ ហេតុភង្គា និរុជ្ឈតិ ។**

ពុម្ពគឺអត្តភាពនេះ ឥតមានអ្នកណាតាក់តែងទេ អឃៈគឺអត្តភាពដែលជាទីតាំងនៃទុក្ខនេះ ឥតមានអ្នកណាធ្វើទេ កើតឡើងបានព្រោះអាស្រ័យហេតុ រលត់ទៅវិញព្រោះបែកធ្លាយនៃហេតុ ។

**យថាបិ អញ្ញតរំ ពីជំ ខេត្តេ វុត្តំ វិរូហតិ**
**បថវីរសញ្ច អាគម្ម សិនេហញ្ច តទូភយំ ។**



ពូជណាមួយដែលគេព្រោះក្នុងស្រែ រមែងដុះឡើងបានព្រោះអាស្រ័យនូវធម្មជាតិ ២យ៉ាងគឺ រសនៃផែនដី១ ជ័រនៃពូជ ១ យ៉ាងណាមិញ ។

**ឯវំ ខន្ធា ច ធាតុយោ ឆ ច អាយតនា ឥមេ**
**ហេតុំ បដិច្ច សម្ភូតា ហេតុភង្គា និរុជ្ឈរេតិ ។**

ធមិទាំងនេះគឺ ខន្ធ ធាតុ និង អាយតនៈ៦ កើតឡើងបានព្រោះអាស្រ័យហេតុ រលត់ទៅវិញព្រោះបែកធ្លាយនៃហេតុ យ៉ាងនោះឯង ។

លំដាប់នោះ មារមានចិត្តបាបដឹងថា សេលាភិក្ខុនីស្គាល់នូវអញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ។

## បណ្ឌិតភាសិត

៥ អំពៅរសផ្អែមវិសេសណាស់ ផ្អែមស្រើលល្អះលើសអំពៅ
ភាសិតបណ្ឌិតពោលប្រដៅ ផ្អែមលើសពំពៅនិងស្រើល្អ ។

# វជិរាសូត្រទី១០

សេចក្ដីខាងដើមនៃសូត្រនេះគឺ ខ្ញុំបានស្ដាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ វជិរាភិក្ខុនី ... (មានរឿងរ៉ាវដូចសេលាភិក្ខុនីដែរ) មារមានចិត្តបាបបានពោលគាថានឹងវជិរាភិក្ខុនី (មានសេចក្ដីប្រែ) ថា :

សត្វនេះ បុគ្គលណាជាអ្នកតាក់តែង បុគ្គលជាអ្នកតាក់តែងនូវសត្វ ឋិតនៅក្នុងទីណា សត្វកើតឡើងក្នុងទីណា សត្វរលត់ទៅក្នុងទីណា ។

(រួចហើយបន្ទាប់មកវជិរាភិក្ខុនី ក៏យល់សេចក្ដីដូចសេលាភិក្ខុនីដែរ) បានពោលនូវព្រះគាថាទាំងឡាយ ឆ្លើយតបទៅរកមារមានចិត្តបាប ដូច្នេះថា :

**កឹ នុ សត្តោតិ បច្ចេតិ　　មារ ទិដ្ឋិគតំ នុ តេ**
**សុទ្ធសង្ខារបុញ្ជោយំ　　នយិធ សត្តូបលព្ភតិ ។**



**យថា ហិ អង្គសម្ភារា　　ហោតិ សទ្ទោ រថោ ឥតិ**
**ឯវំ ខន្ធេសុ សន្តេសុ　　ហោតិ សត្តោតិ សម្មុតិ ។**

ម្នាលមារ ទិដ្ឋិរបស់អ្នកយល់ថា សត្វមែនឬ នេះជាគំនរនៃសង្ខារធម៌សុទ្ធ ក្នុងគំនរនៃសុទ្ធសង្ខារនេះ អ្នករកសត្វមិនឃើញឡើយ ដូចសទ្ទប្បញ្ញត្តិ (បញ្ញត្តិឈ្មោះអាស្រ័យសម្លេងជាលោកវោហារ) ថា រថ ដូច្នេះ ក៏ព្រោះមកអំពីការរួបរួមអង្គ (មានកង់ ទូក ប្រែកជាដើម) យ៉ាងណាមិញ កាលបើខន្ធទាំងឡាយមាន ការសន្មតថាសត្វក៏រមែងមានដែរ យ៉ាងនោះឯង ។

**ទុក្ខមេវ ហិ សម្ភោតិ　　ទុក្ខំ តិដ្ឋតិ វេតិ ច**
**នាញ្ញត្រ ទុក្ខា សម្ភោតិ　　នាញ្ញត្រ ទុក្ខា និរុជ្ឈតីតិ។**

(តាមបរមត្ថសច្ចៈ) មានតែទុក្ខទេដែលបានកើតឡើង មានតែទុក្ខទេដែលបានតាំងនៅ និង វិនាសទៅ ធម្មជាតិដទៃក្រៅអំពីទុក្ខ មិនមានអ្វីកើត ធម្មជាតិដទៃក្រៅអំពីទុក្ខ មិនមានអ្វីរលត់ឡើយ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា វជិរាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្ដីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

# អដ្ឋកថា សេលាសូត្រទី៩

បទថា **ពិម្ពំ** លោកពោលសំដៅទៅលើអត្តភាព (ជាតិកំណើតមួយៗដែលមានខន្ធបន្តគ្នា តាំងអំពីកើតរហូតដល់ស្លាប់ ហៅថា អត្តភាព) បទថា **អឃំ** លោកពោលចំពោះអត្តភាពហ្នឹងឯង ព្រោះជាទីតាំងនៃទុក្ខ បទថា **ហេតុំភង្គា** បានដល់រលត់ហេតុ ព្រោះបច្ច័យពុំគ្រប់គ្រាន់ (កាលណាអស់អវិជ្ជាតណ្ហាហើយ មិនមានបច្ច័យអ្វីតាក់តែងនូវអត្តភាពថ្មីដទៃទៀតបានឡើយ នេះពាក្យថា «ហេតុរលត់ ព្រោះបច្ច័យពុំគ្រប់គ្រាន់» ពាក្យថា **«ហេតុំភង្គា»** គឺអស់ហេតុដែលនាំឱ្យបង្កនូវអត្តភាពជាថ្មី ជាការសម្ដែងដល់ **និរោធសច្ចៈ**) ។



# អដ្ឋកថា វជិរាសូត្រទី១០

បទថា **នយិធ សត្តូបលព្ភតិ** មានសេចក្ដីថា ក្នុងកងសង្ខារសុទ្ធនេះ បើពោលដោយបរមត្ថ ពុំមែនជាសត្វឡើយ (បើសត្វពុំមានដោយបរមត្ថសច្ចៈយ៉ាងនេះ តើមានអ្នកសាងលោកមកពីណា សូម្បីមាតាបិតាដែលឈ្មោះថាអ្នកបង្កើតកូនក៏ជាការសន្មតដែរ តាមពិត ធម៌ទាំងឡាយកើតអំពីហេតុ) បទថា **ខន្ធេសុ សន្តេសុ** ដោយសេចក្ដីថា កាលបើខន្ធ៥ នៅមាន លោកកំណត់យកដោយអាការៈនោះៗ (សន្មតទៅតាមអត្ថប្បញ្ញត្តិ) បទថា **សម្មុតិ** គឺគ្រាន់តែ(នាមប្បញ្ញតិ) កំណត់សន្យាគ្នាឱ្យឈ្មោះហៅថាសត្វប៉ុណ្ណោះ (ទៅតាមអាការៈរបស់ខន្ធ ដែលឱ្យដឹងដោយប្រការនោះៗ ជាអារម្មណ៍នៃ **អត្ថគ្គហណមនោទ្វារវិថីចិត្ត** រួចហើយទើបដឹងឈ្មោះតាមវោហាររបស់លោកថាសត្វជាដើម ដោយអំណាចការកើតឡើងនៃ **នាមគ្គហណមនោទ្វារវិថីចិត្ត**) បទថា **ទុក្ខំ**

(ក្នុងពាក្យដែលថាមានតែទុក្ខទេដែលកើតឡើង) បានដល់ទុក្ខ គឺខន្ធ៥ បទថា **នាញ្ញត្រ ទុក្ខា** សេចក្តីថា ក្រៅអំពីទុក្ខ សភាវៈយ៉ាងដទៃ មិនមានកើត មិនមានរលត់ ។

### ចប់អដ្ឋកថានៃព្រះសូត្រទាំងពីរ



## គាថាសម្តែងអំពីបញ្ញត្តិទាំងពីរក្នុងអភិធម្ម

វចីឃោសានុសារេន សោតវិញ្ញាណវីថិយា
បវត្តានន្តរុប្បន្ន- មនោទ្វារស្ស គោចរា
អត្ថា យស្សានុសារេន វិញ្ញាយន្តិ តតោ បរំ
សាយំ បញ្ញត្តិ វិញ្ញេយ្យា លោកសង្កេតនិម្មិតាតិ ។

អត្ថទាំងឡាយ ជាអារម្មណ៍នៃមនោទ្វារវិថីចិត្ត (ដែលមនោទ្វារវិថីចិត្តនេះ) បានកើតឡើងក្នុងលំដាប់នៃការប្រព្រឹត្តទៅរបស់សោតវិញ្ញាណវិថីចិត្ត ដោយក្រសែសម្លេងផ្លូវវាចា តអំពីនោះ បុគ្គលទាំងឡាយរមែងដឹងបាន ដោយក្រសែនៃនាមប្បញ្ញត្តិណា នាមប្បញ្ញត្តិនោះ ក៏គប្បីជ្រាបថា ជាបញ្ញត្តិដែលធ្វើទុកតាមការកំណត់របស់ពពួកជនក្នុងលោក ដូចនេះឯង ។

## អធិប្បាយបញ្ញត្តិពីរយ៉ាង

### បញ្ញត្តិពីរយ៉ាងគឺ:

### ១-បញ្ញាបិយត្ថា បញ្ញត្តិ ឬអត្ថប្បញ្ញត្តិ

## ២-បញ្ញាបនតោ បញ្ញត្តិ ឬសទ្ទប្បញ្ញត្តិ

បញ្ញត្តិ ២យ៉ាងនេះ ផ្សេងគ្នា ដោយអត្ថដែលបណ្ឌិតគួរពោល នេះម្យ៉ាង និង ម្យ៉ាងទៀត ជាស័ព្ទ(សម្លេង) ពោលដល់អត្ថទាំងឡាយ ដើម្បីឱ្យអ្នកស្តាប់ដឹងរឿង ដឹងសេចក្តី ។

ពាក្យថា **បញ្ញាបិយត្តា** ប្រែថា ព្រោះជាអត្ថ ដែលបណ្ឌិតគប្បីដឹង ដោយប្រការនោះៗ មិនមែនជាបរមត្ថធម៌ឡើយ ប៉ុន្តែវាជាស្រមោលរបស់បរមត្ថ មិនចាំបាច់ទាល់តែបណ្ឌិតទេ ទើបបានដឹងនូវអត្ថប្បញ្ញត្តិនេះ មនុស្សសត្វទាំងអស់រមែងបានដឹងជាធម្មតា ព្រោះវាជាអាការៈ វិការនៃបរមត្ថធម៌ទ្រង់ទ្រាយសណ្ឋាននៃមហាភូតរូប ការប្រជុំរួមគ្នានៃសម្ភារៈរបស់មហាភូតរូប ឬកាយវិញ្ញត្តិ (ការកំរើកកាយឱ្យដឹងសេចក្តីថាជាអ្វី) វចីវិញ្ញត្តិ (ការកំរើកវាចាឱ្យដឹងសេចក្តីថា និយាយរឿងអ្វី) ឬម្យ៉ាងទៀត ដូចជានិមិត្តទាំងឡាយ គឺសេចក្តីអ្វីៗដែលមានក្នុង មនុស្ស សត្វ វត្ថុ ជាគ្រឿងសំគាល់ឱ្យដឹងដោយប្រការផ្សេងៗ ហើយសេចក្តីស្រឡាញ់ ស្អប់ ស្ងប់ចិត្តជាដើម បានប្រព្រឹត្តទៅក្នុងអត្តគ្គហណមនោទ្វារវិថីចិត្ត កាន់យកនូវ



និមិត្តប្បញ្ញត្តិនោះៗជាអារម្មណ៍កើតឡើងប៉ុណ្ណេះជាដើម ។

ដើម្បីជាការច្បាស់លាស់ដោយសព្វគ្រប់ សូមពុទ្ធបរិស័ទគប្បីជ្រាបនូវអត្ថប្បញ្ញត្តិ ៦ក្រុមគឺ :

**១-សន្តានប្បញ្ញត្តិ** អាការៈនៃមហាភូតរូប មានការរីកធំ ឬរួមតូចជាដើម ដូចជា ផែនដី ព្រៃ ភ្នំ ស្ទឹង ទន្លេ សមុទ្រ ។ល។ ដែលប្រព្រឹត្តទៅដោយអំណាចនៃការបន្តគ្នា (សន្តតិនៃបរមត្ថ) ។

ឧទាហរណ៍- នៅពេលមើលឃើញភ្នំ ចក្ខុទ្វារវិថីចិត្តគឺចិត្តកើតតាមផ្លូវភ្នែកមានវណ្ណរូប(ពណ៌) ជាអារម្មណ៍បច្ចុប្បន្ន (រូបារម្មណ៍ផ្លូវភ្នែកមិនមែនភ្នំទេ) កាលក្រសែចិត្តធ្លាក់ចុះកាន់ភវង្គ ផុតចាកចក្ខុទ្វារហើយ ក៏ឡើងកាន់មនោទ្វារវិថី មាននូវរូបារម្មណ៍ដែលកន្លងទៅផុតពីផ្លូវភ្នែកអំបាញ់មិញជាអារម្មណ៍ វិថីទាំងពីរគឺចក្ខុទ្វារវិថី និង មនោទ្វារវិថី កើតផ្លាស់ប្តូរគ្នាត្រឡប់ចុះត្រឡប់ឡើង ច្រើនលើកយ៉ាងរហ័សជាទីបំផុត រួចទៅមានវិថីមួយទៀត ជាមនោទ្វារវិថីដែរ កើតឡើងប្រមូលរួបរួមនូវរូបារម្មណ៍ ដែលបានឃើញហើយ កន្លងទៅៗ

(រូបារម្មណ៍ប៉ះខ្ទប់នឹងភ្នែកហើយ ចក្ខុទ្វារវិថីចិត្តកើតឡើងដឹងនូវរូបារម្មណ៍នោះ រួចរលត់ទៅ កន្លងទៅ ទាំងវិថីចិត្ត ទាំងរូបារម្មណ៍ យ៉ាងនេះជាធម្មតា) វិថីចិត្តទី៣ នេះក៏កើតច្រើនដងដែរ ក្នុងការប្រមូល រួបរួមនូវរូបារម្មណ៍ ។

**សូមរៀបរៀងវិថីចិត្តទាំង៣ តាមលំដាប់គឺ :**

១-*ចក្ខុទ្វារវិថីចិត្ត*: ដឹងរូបារម្មណ៍ជាបច្ចុប្បន្ន

២-*អតីតគ្គហណមនោទ្វារវិថីចិត្ត* : វិថីចិត្តកើតក្នុងមនោទ្វារ (មិនមែនទ្វារភ្នែក) ដឹងនូវរូបារម្មណ៍ដែលរលត់ទៅភ្លាមនោះ (ដោយអំណាចសញ្ញាចាំទុកនូវរូបដែលបានឃើញហើយ) ។

៣-*សមូហគ្គហណមនោទ្វារវិថីចិត្ត* : វិថីចិត្តកើតឡើងក្នុងមនោទ្វារ រួបរួមរូបារម្មណ៍ដែលកន្លងទៅហើយច្រើនរូប (ក៏ព្រោះសញ្ញាចាំទុកនូវរូបា-រម្មណ៍នោះៗហ្នឹងឯង) ។

*៤ វិថីចិត្តទាំង៣នេះមានអារម្មណ៍ជាបរមត្ថ តាមសេចក្តីពិតនៃរូបារម្មណ៍* មិនមែនភ្នំ រូបារម្មណ៍មិន



មែនមហាភូតរូប៤ទេ គ្រាន់តែអាស្រ័យនឹងមហាភូតរូប៤ប៉ុណ្ណោះ មិនមែនសម្លេង មិនមែនក្លិន មិនមែនរស ហើយក៏មិនមែនជាធម្មារម្មណ៍ដែរ ប៉ុន្តែដែលថាមើលទៅឃើញភ្នំព្រោះវិថីចិត្តទី៤ កើតឡើងបន្តកាន់យកអាការៈទ្រង់ទ្រាយសណ្ឋាន តាមដែលវិថីចិត្តទី៣ បានប្រមូលរួបរួមព្រោះការចាំទុកនូវរូបារម្មណ៍នោះ បានទៅជាអារម្មណ៍នៃចិត្តុប្បាទគឺការកើតឡើងនៃចិត្តក្នុងវិថីទី៤ មួយវិថីទៀត ។ វិថីចិត្តទី៤ នេះឯងដែលឈ្មោះថា ***អត្ថគ្គហណមនោទ្វារវិថីចិត្ត*** ជាវិថីចិត្តក្នុងមនោទ្វារ កើតឡើងកាន់យកអត្ថគឺសេចក្តីឱ្យដឹងថា រូបារម្មណ៍ដែលអាស្រ័យនឹងមហាភូតរូប៤ កើតប្រាកដតាមទ្វារភ្នែកបន្តគ្នានោះ វាជាអ្វីទៅតាមទ្រង់ទ្រាយសណ្ឋានមានអត្ថឱ្យដឹងបានថាជាភ្នំ ។ ទ្រង់ទ្រាយសណ្ឋានមិនមែនរូបារម្មណ៍ទេ នេះដោយអំណាចរូបច្រើនកើតបន្តគ្នា និង ដោយអំណាចវិថីចិត្តទី៣ ជាឧបនិស្សយប្បច្ច័យ ធ្វើឱ្យវិថីចិត្តទី៤ កើតឡើងកាន់យកសេចក្តី(អត្ថ)មួយដែលឱ្យដឹងដោយប្រការនោះៗ គឺមានអត្ថប្បញ្ញត្តិជាអារម្មណ៍ ក៏ដឹងថាជាភ្នំ និង ម្យ៉ាងទៀត

ដោយអំណាចវិថីចិត្តទាំង៤នេះ កើតផ្លាស់ប្តូរគ្នាយ៉ាងលឿនរហ័សនោះ គឺវិថីចិត្តនីមួយៗកើតច្រើនលើក ត្រឡប់ចុះត្រឡប់ឡើង ក៏ហាក់ដូចជាមានភ្នំមួយដ៏ធំ កំពុងតែមើលឃើញ សូម្បីតែការនិយាយគ្នា ក៏និយាយឱ្យងាយស្តាប់បាន ថាមើលឃើញភ្នំអីចឹងទៅ ។

សេចក្តីនេះឯង ដែលសត្វលោកមិនបានចម្រើនសតិប្បដ្ឋាន រមែងមានការច្រឡំនូវអត្ថគ្គហណមនោទ្វារវិថី ថាជាចក្ខុទ្វារវិថីទៅវិញ ទើបមានការប្រកាន់ថា ភ្នំមាន ផែនដី ព្រៃឈើ មនុស្ស សត្វ ជាដើមមានពិត ព្រោះខ្លួនបានមើលឃើញច្បាស់នឹងភ្នែក ចាប់ប៉ះពាល់ក៏បានទៀតផង ។ ជាធម្មតាចក្ខុវិញ្ញាណឃើញតែរូបារម្មណ៍ សោតវិញ្ញាណឮតែសម្លេង ឃានវិញ្ញាណធុំតែក្លិន ជីវ្ហាវិញ្ញាណដឹងតែរស កាយវិញ្ញាណដឹងតែផោដ្ឋព្វៈ អារម្មណ៍តាមបញ្ចទ្វារជាបរមត្ថធមិសុទ្ធ ប៉ុន្តែដោយអំណាចមនោទ្វារវិថីចិត្តជា **តទនុវត្តិក** (មនោទ្វារវិថីប្រព្រឹត្តទៅតាមបញ្ចទ្វារវិថី) បិទបាំងវិថីចិត្តតាមបញ្ចទ្វារ សេចក្តីវង្វេង និង ការប្រកាន់ ក៏កើតមានជាប្រចាំសន្តានចិត្ត



រហូតមក បើមិនចម្រើនសតិប្បដ្ឋាន រលឹកដឹងនូវសភាវធមិតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ឱ្យបានដឹងច្បាស់ប្រាកដទេនោះ សេចក្តីវង្វេង និង ការប្រកាន់នឹងមានបន្តទៅទៀត ។

វិថីចិត្តទី៤ ដែលឈ្មោះថា អត្ថគ្គហណមនោទ្វារវិថី ដឹងសេចក្តី ដឹងរឿងរ៉ាវ ប៉ុន្តែមិនដឹងឈ្មោះរបស់អត្ថប្បញ្ញត្តិនោះៗទេ ដូច្នេះដែលដឹងថា សភាវៈនេះមានឈ្មោះថារូបារម្មណ៍ក្តី អត្ថប្បញ្ញត្តិ (សេចក្តីឱ្យដឹង) នេះគេហៅថាភ្នំក្តី អាស្រ័យវិថីចិត្តទី៥ កើតបន្តអំពីវិថីចិត្តទី៤ ។ វិថីចិត្តទី៥នេះកើតឡើងដឹងនាមប្បញ្ញត្តិ ឈ្មោះថា ***នាមគ្គហណមនោទ្វារវិថី*** មនោទ្វារវិថីចិត្តកាន់យកឈ្មោះបញ្ញត្តិជាអារម្មណ៍កើតឡើង ។

សត្វបុគ្គលគ្រហស្ថបព្វជិត ពុំមានកើតឡើងដឹងអ្វីៗក្នុងលោកនេះឡើយ មានតែវិថីចិត្តប៉ុណ្ណោះដែលបានកើតឡើងនោះ វិថីចិត្តមុនកើតឡើងហើយ ក៏អស់ទៅវិញ បាត់ទៅវិញ វិថីចិត្តថ្មីៗកើតបន្ត នេះជាតំណនៃសង្ខារធមិសុទ្ធ ។

រូបធមិ និង នាមធមិតាមផ្លូវ ភ្នែក ត្រចៀក ច្រមុះ

អណ្តាត កាយ ចិត្ត មានការកើតហើយរលត់ទៅវិញយ៉ាងលឿនរហ័សជាធម្មតា ឯចំណែកផែនដី ព្រៃភ្នំ ទន្លេ សមុទ្រ មនុស្ស សត្វ ពិតជាពុំមានដោយបរមត្ថ គឺមានតែវិថីចិត្តទី៤ និង ទី៥ ប៉ុណ្ណោះដែលបានកើតឡើង ព្រោះបញ្ញត្តិដែលឱ្យដឹងដោយប្រការនោះៗ ជាអារម្មណប្បច្ច័យនៃវិថីចិត្តទី៤ និង ទី៥ នេះឯង ។

ដោយអំណាចតំណនៃនាមរូបលឿនរហ័សផង និង ដោយអំណាចមានវិថីចិត្តទី៤ និង ទី៥ កើតឡើងផង និង ម្យ៉ាងទៀត ដោយអំណាចអវិជ្ជាផង សួរថា តើក្នុងលោកនេះងងឹតប៉ុនណាទៅ ?

**ចម្លើយ –** ក្នុងលោកនេះងងឹតក្រៃលែង សូម្បីពន្លឺរស្មីនៃព្រះអាទិត្យ៧ដួងផ្គុំគ្នា ក៏មិនអាចបំភ្លឺលោក៦នេះឱ្យភ្លឺបានឡើយ សភាពងងឹតក្នុងលោកយ៉ាងនេះ គឺងងឹតជាង *លោកន្តរនរក* ។ ដោយអំណាចសេចក្តីងងឹត តណ្ហា ឧបាទាន កម្ម រមែងមានការធ្លាក់ចុះរឿយៗជានិច្ចមិនដាច់ក្នុងលោក លោកនេះត្រូវភ្លើងឆេះ ពោលគឺភ្លើងកិលេស ឆេះក្រៃលែងជាងភ្លើង



*អវិចីនរក* ទៅទៀត ព្រោះភ្លើងនរកមិនអាចឆេះកុសលធម៌បានទេ ប៉ុន្តែភ្លើងកិលេសរមែងឆេះនូវកុសលធម៌បាន ។ លោកនេះក្តៅខ្លាំងណាស់ វាក៏ក្តៅជាងភ្លើងនរកផងដែរ គឺក្តៅដោយរាគៈ ក្តៅដោយទោសៈ ក្តៅដោយមោហៈ ក្តៅដោយជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខទោមនស្ស និង ក្តៅដោយការចង្អៀតចង្អល់ ។ លោកនេះជារណ្តៅជ្រោះដ៏ធំជ្រៅ ជាជ្រោះមរណៈ សត្វលោកមិនងាយចេញរួចពីជ្រោះនេះឡើយ ។

**២–សមូហប្បញ្ញត្តិ** អាការៈប្រជុំនៃសម្ភារៈទាំងឡាយ ដូចជាទព្វសម្ភារៈនៃផ្ទះ ឬរទេះជាដើម សម្តែងអាការៈសណ្ឋានឱ្យដឹងថា ជាផ្ទះ ឬជារទេះ ហៅថា អត្ថប្បញ្ញត្តិ ផ្នែកខាងប្រជុំរួមនៃសម្ភារៈ ។

អត្ថប្បញ្ញត្តិ មិនមែនជាឈ្មោះបញ្ញត្តិនោះទេ វាគ្រាន់តែការរួបរួមនៃអង្គសម្ភារៈជាដើម ហើយឱ្យដឹងដោយប្រការនោះៗ សូម្បីសត្វតិរច្ឆាន ឬទារកតូច មិនដឹងអត្ថនោះឈ្មោះអ្វីក៏ដោយ ប៉ុន្តែអត្ថនោះវាជាអារម្មណ៍នៃអត្ថគ្គហណមនោទ្វារ-

វិថី ក៏មានការដឹងនូវសេចក្តីផ្សេងៗទៅ ដូចជា គោ ក្របី វាមិនដឹងឈ្មោះនៃអាការៈនោះ មានឈ្មោះថាទ្រុង ឈ្មោះថាក្រោល ឈ្មោះថាខ្សែជាដើម ប៉ុន្តែវានៅតែមានបញ្ញត្តិជាអារម្មណ៍ ដឹងរឿង ដឹងសេចក្តីផ្សេងៗ ឬដូចជាទារកបៅដោះ ទោះជាមិនដឹងថា ហ្នឹងគេហៅថាទឹកដោះ ហ្នឹងគេហៅមាតា តែថា ទារកនៅតែមានការដឹងនូវសេចក្តីនោះ ដឹងរឿងនេះរឿងនោះ រហូតទារកធំបន្តិចម្តងៗមក ក៏ដឹងឈ្មោះវត្ថុនេះឈ្មោះរបស់នោះទៅតាមលោកវោហារ រហូតដឹងសេចក្តីជារឿងរ៉ាវច្រើនសន្ធឹកសន្ធាប់ តាមការបានស្តាប់អំពីពាក្យសំដីដែលអ្នកដទៃនិយាយ។

មនុស្សមានការរីកចំរើនដោយចំណេះដឹង ខុសអំពីសត្វតិរច្ឆាន ក៏ព្រោះអត្តគ្គហណមនោទ្វារវិថីចិត្តហ្នឹងឯង វិថីចិត្តនេះ ទោះបីជាសត្វតិរច្ឆានមានក៏ដោយ ក៏វាមិនរីកចម្រើននូវចំណេះដឹង ដូចជាមនុស្សនោះទេ វាអាចគ្រាន់បើបានខ្លះៗ ដោយការកាន់យកសេចក្តីដែលមនុស្សព្យាយាមបង្ហាត់វា ។ រឿងដែលសត្វតិរច្ឆានមិនបានរីកចម្រើន នូវចំណេះដឹង ព្រោះវាមានបដិសន្ធិជា *អកុសលវិបាកចិត្ត* ដោយអំណាចអកុសលកម្មជា



បច្ច័យ ម្ល៉ោះហើយវាត្រូវខ្វះនូវឧបនិស្ស័យនៃការរីកចម្រើនផ្នែកចំណេះដឹងទូទៅ ។ ចំណែកមនុស្សយើងវិញ អត្តគ្គហណ-មនោទ្វារវិថី មានសេចក្តីចម្រើនច្រើនដ៏ក្រៃលែង រហូតដល់អាចធ្វើជាព្រះសម្មាសម្ពុទ្ធបានទៀតផង រឿងនេះព្រោះមនុស្សមានបដិសន្ធិដោយ *កុសលវិបាកចិត្ត* សម្បូរដោយឧប-និស្ស័យនៃការចេះដឹង ជំរុញមកពីអតីតៈ ព្រោះកុសលវិបាកបដិសន្ធិបើកឱកាសឱ្យ និង ម្យ៉ាងទៀត ការដឹងឈ្មោះបញ្ញត្តិបានច្រើន ដោយអំណាចនាមគ្គហណមនោទ្វារវិថីចិត្ត ក៏ជាបច្ច័យដល់អត្ថគ្គហណមនោទ្វារវិថី កាន់យកសេចក្តីទៅតាមឱវាទរបស់មាតាបិតា ឬតាមការបង្ហាត់បង្រៀនពីគ្រូអាចារ្យតាមសាលារៀនផ្សេងៗ ។

ពុទ្ធបរិស័ទសិក្សាបរិយត្តិធម៌ គឺរៀនឱ្យដឹងឈ្មោះរបស់បរមត្ថធម៌ផង ឈ្មោះនៃបញ្ញត្តិផង ដូចជា បរមត្ថធម៌នេះ មានលក្ខណៈយ៉ាងនេះ ឈ្មោះថារូប បរមត្ថធម៌នេះ មានលក្ខណៈយ៉ាងនេះ ឈ្មោះថាសម្លេង ជាដើម គឺរៀនឱ្យដឹងនៃបរមត្ថធម៌ច្រើន ឬក៏ឈ្មោះនៃបុគ្គលប្បញ្ញត្តិ មានឈ្មោះថា បុថុជ្ជន

ព្រះអរិយៈ ព្រះសោតាបន្នជាដើម ការដឹងឈ្មោះ (សទ្ទ-ប្បញ្ញត្តិ) ច្រើនៗគឺជានាមគ្គហណមនោទ្វារវិថីចិត្ត ។ ដោយបរមត្ថពុំមែនសត្វបុគ្គលណា ជាអ្នកដឹងនូវសទ្ទប្បញ្ញត្តិនោះឡើយ ការដឹងនូវសទ្ទប្បញ្ញត្តិច្រើននេះ ជាបច្ច័យដល់អត្ថគ្គហ-ណមនោទ្វារវិថី ដឹងរឿងរ៉ាវ ដឹងសេចក្តី យល់ធម៌យល់វិន័យជាដើម ព្រោះអាស្រ័យហេតុនេះ ទើបព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ទ្រង់ត្រាស់សំដែងព្រះធម៌ទេសនា ៤៥ព្រះវស្សា ពន្យល់សេចក្តី បង្ហាត់បង្រៀន បើកផ្លូវគ្រប់ន័យគ្រប់កិច្ចការ ដែលព្រះធម៌ទេសនារបស់ព្រះអង្គនោះ គឺជាសទ្ទប្បញ្ញត្តិទាំងអស់នៅក្នុង *អភិវចនា ធម្មា* (ពួកធម៌ជាពាក្យសំដី) មានសទ្ទរូបគឺសម្លេង និង វចីវិញ្ញត្តិរូប គឺការកំរើកវាចាជាប្រធាន ឬជាអង្គធម៌ដោយបរមត្ថ (សទ្ទប្បញ្ញត្តិមិនមែនជាបរមត្ថ ប៉ុន្តែអាស្រ័យនូវសទ្ទៈគឺសម្លេងដែលមានចិត្តជាសមុដ្ឋាន ទើបអ្វីៗទាំងអស់នោះមានឈ្មោះទៅបាន) ដូច្នេះព្រះបរិយត្តិធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង បានដល់សទ្ទប្បញ្ញត្តិ គឺ *សទ្ទរូបបង្អោនទៅក្នុងអត្ថទាំងឡាយ គឺទាំង*



*បរមត្ថ ទាំងអត្ថប្បញ្ញត្តិ មានគុណដល់អ្នកស្តាប់ទាំងឡាយដ៏ក្រៃលែង ធ្វើឱ្យអ្នកស្តាប់ដោយសេ-ចក្តីគោរព រួចផុតចាកលោក៦ មានលោកភ្នែកជាដើមបាន ព្រោះមិនប្រកាន់មាំ ។*

**៣-សម្មតិប្បញ្ញត្តិ** កន្លែងខ្លះហៅថា សត្តប្បញ្ញត្តិ គឺជាបញ្ញត្តិអាស្រ័យខន្ធ៥ ព្រោះគំនរនៃសង្ខារធម៌សុទ្ធ និងព្រោះតំណនៃសង្ខារធម៌សុទ្ធៗនេះ ទើបមានអត្ថសម្តែងឱ្យដឹងថាជាសត្វលោក បានដល់ សម្មតិសច្ចៈគូគ្នានឹងបរមត្ថសច្ចៈ ។

បុគ្គលសម្រាប់ឱ្យយើងខឹងក្រោធនោះ ពុំមានសោះឡើយ តើយើងក្រោធនឹងរូបឬ ? ក្រោធនឹងវេទនាឬ ? ក្រោធនឹងសញ្ញាឬ ? ក្រោធនឹងសង្ខារឬ ? ក្រោធនឹងវិញ្ញាណឬ ?

**ចម្លើយ:** ខ្ញុំក្រោធនឹងបុគ្គលនោះ ។

តើរូបជាបុគ្គលនោះឬ ? វេទនាជាបុគ្គលនោះឬ ? សញ្ញាជាបុគ្គលនោះឬ ? សង្ខារជាបុគ្គលនោះឬ ? វិញ្ញាណជាបុគ្គល នោះឬ ?

**ចម្លើយ:** មិនមែនទេ ។

តើបុគ្គលនោះនៅក្នុងរូបឬ? បុគ្គលនោះនៅក្នុងវេទនាឬ? បុគ្គលនោះនៅក្នុងសញ្ញាឬ? បុគ្គលនោះនៅក្នុងសង្ខារឬ? បុគ្គលនោះនៅក្នុងវិញ្ញាណឬ?

**ចម្លើយ:** មិនមែនទេ ។

តើបុគ្គលនោះនៅដទៃផ្សេងអំពីរូបឬ? បុគ្គលនោះនៅដទៃផ្សេងអំពីវេទនាសញ្ញាឬ ? បុគ្គលនោះនៅដទៃផ្សេងអំពីសង្ខារឬ ? បុគ្គលនោះនៅដទៃផ្សេងអំពីវិញ្ញាណឬ ?

**ចម្លើយ:** មិនមែនទេ ។

តើបញ្ចក្ខន្ធជាបុគ្គលនោះឬ?

**ចម្លើយ:** មិនមែនទេ ។

តើបុគ្គលនោះនៅដទៃផ្សេងអំពីបញ្ចក្ខន្ធឬ?

**ចម្លើយ:** មិនមែនទេ ។

បើយើងរកបុគ្គលនោះមិនឃើញយ៉ាងនេះ តើយើងក្រោធជាមួយនឹងបុគ្គលណា ម្យ៉ាងទៀត សូម្បីខ្លួនយើងក៏មិនមានដោយពិត នេះជាការកើតឡើងនូវគំនរនៃសង្ខារធម៌សុទ្ធ។ សេចក្ដីនេះគឺជាបទពិចារណាក្នុងការចែកធាតុ ចែកខន្ធ បើពុទ្ធ



បរិស័ទឆ្លាត ក្នុងអត្ថគ្គហណមនោទ្វារវិថីចិត្ត ពុទ្ធបរិស័ទនឹងមិនសង្ស័យអំពីសត្វមិនមានដោយបរមត្ថ ព្រោះពុទ្ធបរិស័ទបានយល់ថា សត្វមិនមែនជាបញ្ចក្ខន្ធដោយពិត គ្រាន់តែជាអត្ថប្រភេទមួយ ដែលអត្ថគ្គហណមនោទ្វារវិថីកាន់យកជាអារម្មណ៍ប៉ុណ្ណោះ ។

**៤-ទិសាកាលាទិប្បញ្ញត្តិ** ទិសទាំងឡាយ មានទិសបូព៌ា អាគ្នេយ៍ជាដើម ឱ្យដឹងដោយអំណាចព្រះអាទិត្យព្រះចន្ទជាដើម កាលគឺ ពេលព្រឹក ពេលល្ងាចជាដើម ឱ្យដឹងដោយប្រការនោះៗ ខែក្ដី រដូវក្ដី ឆ្នាំក្ដី សុទ្ធតែមានអត្ថឱ្យដឹង។

នៅក្នុងអត្ថប្បញ្ញត្តិនេះ មានកាល រដូវជាដើម ពពួកសត្វតិរច្ឆានអាចដឹងបានច្រើន ដោយ *សភាវគតិ* គឺដំណើរប្រព្រឹត្តទៅនៃអត្ថគ្គហណមនោទ្វារវិថីចិត្តហ្នឹងឯង សូម្បីពពួកសត្វទាំងនោះមិនបានស្គាល់ឈ្មោះក៏ដោយ ប៉ុន្តែដែលថាមិនបានស្គាល់ឈ្មោះនេះ គឺព្រោះនាមគ្គហណមនោទ្វារវិថីចិត្តមិនបានកើតឡើង ។

មួយថ្ងៃៗមានការទទួលភ្ញៀវមិនដឹងជាច្រើនប៉ុនណា

ទៅទេ ប៉ុន្តែសុទ្ធតែជាភ្ញៀវបរមត្ថ ។ ចក្ខុទ្វារវិថីចិត្តទទួលដឹងរូប រួចហើយរលត់ទៅ មនោទ្វារវិថីចិត្តកើតបន្តដឹងរឿងរបស់រូប ។ សោតទ្វារវិថីចិត្តទទួលដឹងសម្លេង រួចហើយរលត់ទៅ មនោទ្វារវិថីចិត្តកើតបន្តដឹងរឿងរបស់សម្លេង ។ ឃានទ្វារវិថីចិត្តទទួលដឹងក្លិន រួចហើយរលត់ទៅ មនោទ្វារវិថីចិត្តកើតបន្តដឹងរឿងរបស់ក្លិន ។ ជីវ្ហាទ្វារវិថីចិត្តទទួលដឹងរស រួចហើយរលត់ទៅ មនោទ្វារវិថីចិត្តកើតបន្តដឹងរឿងរបស់រស ។ កាយទ្វារវិថីចិត្តទទួលដឹងផោដ្ឋព្វៈ រួចហើយរលត់ទៅ មនោទ្វារវិថីចិត្តកើតបន្តដឹងរឿងរបស់ផោដ្ឋព្វៈ និង *សុទ្ធកមនោទ្វារវិថីចិត្ត* គឺមនោទ្វារវិថីចិត្តសុទ្ធ នឹកគិតរឿងផ្សេងៗ ដោយពុំបានជាប់តាមបញ្ចទ្វារវិថីចិត្តទេ ឬដឹងនូវធម្មារម្មណ៍ ដែលជាអារម្មណ៍ប្រចាំទ្វារ ។

រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ចិត្ត ចេតសិក រូប បរមត្ថទាំងអស់នេះ**មាន** រឿងរ៉ាវសេចក្តីផ្សេងៗ ក្រៅអំពីបរមត្ថធម៌ដែលកើតរលត់នោះ រឿងរ៉ាវសេចក្តីផ្សេងៗនោះ **មិនមានទេ** ប៉ុន្តែ អត្ថគ្គហណមនោទ្វារវិថីចិត្ត **ជាបរមត្ថ**



**មានពិត** សូមពុទ្ធបរិស័ទឆ្លាតឈ្លាសនៅក្នុងវិថីចិត្ត ដែលជាធម៌ទទួលភ្ញៀវគឺអារម្មណ៍ទាំងអស់ ជាប្រក្រតីប្រចាំថ្ងៃនេះ ដោយការចម្រើនសតិប្បដ្ឋាន៤ ។

**៥–អាកាសប្បញ្ញត្តិ** អាចហៅម្យ៉ាងទៀតថា កូបគុហាទិប្បញ្ញត្តិ អាការៈដែលមហាភូតរូបមិនទល់គ្នា មានតែអាកាសយ៉ាងនេះ ក៏ឱ្យដឹងដោយប្រការនោះៗ ដូចជាអណ្តូង រូង រន្ធ គុហាជាដើម ។

**៦–និមិត្តប្បញ្ញត្តិ** និមិត្តគឺគ្រឿងសំគាល់ឱ្យដឹងដោយប្រការនោះៗ មានច្រើនយ៉ាងណាស់ និមិត្តជាអារម្មណ៍នៃសមថកម្មដ្ឋាន ដូចជាកសិណនិមិត្តជាដើម ដែលប្រព្រឹត្តទៅជាឧគ្គហនិមិត្ត (ចិត្តក្នុងមនោទ្វារបានកាន់យក) និង បដិភាគនិមិត្ត (ជានិមិត្តដែលចិត្តក្នុងមនោទ្វារ បានសេពយ៉ាងមាំរមែងទៅតាមភាវៈដូចឧគ្គហនិមិត្តនោះ) និមិត្ត គ្រឿងសំគាល់ថាស្អាតហៅថាសុភនិមិត្ត និមិត្ត គ្រឿងសំគាល់ថាមិនស្អាតហៅថា អសុភនិមិត្ត មានច្រើនទៀតណាស់ សុទ្ធតែគ្រឿងសំគាល់ដែលឱ្យដឹងបាន ឥត្ថីនិមិត្ត បុរិសនិមិត្ត មេត្តានិមិត្ត

បដិឃនិមិត្ត ។ល។

ក្នុងចិត្ត ចេតសិក រូប មិនមានមនុស្សស្រី មនុស្សប្រុសទេ មានតែអត្ថគ្គហណមនោទ្វារវិថីចិត្ត កើតឡើងកាន់យកនូវនិមិត្តនៃមហាភូតរូបហ្នឹងឯង ។ នៅក្នុងបញ្ចក្ខន្ធពុំមានសត្វបុគ្គលទេ ដែលអាចមានវិញ្ញត្តិគឺការកម្រើកឱ្យដឹងដោយប្រការផ្សេងៗ ព្រោះមានចិត្តជាសមុដ្ឋាន ញ៉ាំងឱ្យកម្រើកមហាភូតរូបឡើង ហាក់ដូចជាសត្វមានមែនទែន ចេះដេកដើរឈរអង្គុយលូន វារ ជាដើម ។ អ្នកប្រព្រឹត្តអំពើអាក្រក់ក្តី ល្អក្តី តាមផ្លូវកាយ ឬតាមផ្លូវវាចា គ្រាន់តែសន្មតថាមានអ្នកប្រព្រឹត្តតែប៉ុណ្ណោះ ប៉ុន្តែកាយវាចាមិនអាចកម្រើកបានឡើយ បើគ្មានចិត្តជាបច្ច័យឱ្យកម្រើកទេនោះ ។

ក្នុងមួយថ្ងៃៗពិតមែនតែមិនមានមនុស្សសត្វ គឺមានតែបរមត្ថ៣ បានដល់ ចិត្ត ចេតសិក រូប ប៉ុន្តែត្រូវប្រយ័ត្នចំពោះអត្ថគ្គហណមនោទ្វារវិថីនោះ បើមិនបានសង្រួមប្រយ័ត្នដោយល្អទេ ជវនៈក្នុងអត្ថគ្គហណមនោទ្វារ សុទ្ធតែលាមក គឺបាបអកុសលពេញណែន ដោយការសន្សំក្នុងសន្តាន ។



មិនមែនហាមមិនឱ្យដឹងនិមិត្តទេ ព្រោះនេះវាជាទំនៀមរបស់វិថីចិត្ត (ចិត្តនិយាម) ប៉ុន្តែពាក្យថា មិនកាន់យកនូវនិមិត្តគឺមិនកាន់យកឱ្យជាវត្ថុនៃកិលេស អភិជ្ឈាទោមនស្ស ត្រង់នេះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង ឱ្យប្រយ័ត្ន ឱ្យសង្រួមខ្លាំងណាស់ ក្នុងការដឹងអារម្មណ៍តាមទ្វារទាំង៦ ទ្វារណាមួយក៏ដោយ កុំបណ្តែតបណ្តោយឱ្យកាន់យកនូវនិមិត្តដោយអភិជ្ឈាគឺលោភៈ ឬទោមនស្សគឺទោសៈ ។ ការសង្រួមទ្វារ៦ ព្រះអង្គទ្រង់ត្រាស់សំដែងថា ជាគ្រឿងសម្រាប់ឱ្យសទ្ធាជាគ្រាប់ពូជដុះបានល្អ មានផលជាលោកុត្តរ ។ កិលេសមារ មិនអាចគ្របសង្កត់នូវបុគ្គលណា ដែលមានប្រក្រតីឃើញថាមិនស្អាតក្នុងកាយ កាន់យកនូវអសុភនិមិត្តហាមឃាត់នូវរាគចិត្ត មានការបិទទ្វារ៦ មានទ្វារភ្នែកជាដើម ដើម្បីរារាំងនូវអភិជ្ឈា និងទោមនស្ស ស្គាល់ប្រមាណនូវភោជន មានសទ្ធាក្នុងព្រះសាស-នាមាំ ប្រារព្ធសេចក្តីព្យាយាម ដូចខ្យល់មិនអាចបក់ឱ្យរលំនូវភ្នំថ្មតាន់ ដូច្នោះឯង ។

កាលដែលជីវិតរស់នៅ មានមនុស្សសត្វជុំវិញយ៉ាងនេះ

គួររៀនយកនូវមេត្តានិមិត្ត គឺយល់ដល់បំណងរបស់សត្វដែលចង់បានសុខ ព្រោះសេចក្ដីនេះ មិនមែនជារឿងហាមនូវអត្ថគ្គហណមនោទ្វារវិថីទេ គ្រាន់តែរៀនអប់រំចម្រើនឱ្យមានមេត្តាក្នុងកាលដែលមនោទ្វារវិថីកាន់យកអត្ថ ឱ្យដឹងថាសត្វ ជាអារម្មណ៍កើតឡើង ចំណុចសំខាន់គឺកុសលធម៌ជំនួសអកុសលធម៌ ព្រោះបើមិនរៀនអប់រំឱ្យមានមេត្តាទេនោះ អត្ថគ្គហណមនោទ្វារ នៅតែកើតឡើងជាធម្មតា ប៉ុន្តែប្រទូសរ៉ាយ ខឹងក្រោធ ប្រកាន់ទិដ្ឋិ តម្កើងមានះ អំនួតអួតអាង គ្មានសុជីវធម៌ជាមួយនឹងអារម្មណ៍បញ្ញត្តិនោះៗ ។ ពិតមែនតែនៅក្នុងបរមត្ថមិនមានមនុស្សសត្វដោយពិតប្រាកដ តែអកុសលកើតឡើងវាជាទោស វាជាហេតុនៃសេចក្ដីទុក្ខ ហើយនៅក្នុងពួកកងនៃអកុសលធម៌ទាំងនោះ វាមានអកុសលមួយប្រភេទដែលបិទបាំង មិនឱ្យដឹងនូវបរមត្ថធម៌តាមពិត អាស្រ័យសេចក្ដីនេះឯងទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ប្រាប់ ឱ្យចម្រើននូវកុសលធម៌គ្រប់យ៉ាង ទោះបីមានអ្វីជាអារម្មណ៍ក៏ដោយ *សំខាន់គឺដណ្ដើមកន្លែងបាប* ។



សរុបសេចក្ដីមក អត្ថប្បញ្ញត្តិទាំង៦ក្រុម នៅក្នុងព្រះគាថាខាងដើម (ព្រះគាថាសម្ដែងអំពីបញ្ញត្តិទាំងពីរ) *បានសម្ដែងថា អត្ថទាំងឡាយជាអារម្មណ៍នៃមនោទ្វារវិថីចិត្ត* ។

តាមន័យរបស់ព្រះគាថា អត្ថគ្គហណមនោទ្វារវិថី ត្រូវកើតឡើងបន្ទាប់អំពីការដឹងសទ្ទប្បញ្ញត្តិរួចហើយ បានសេចក្ដីថា នាមគ្គហណមនោទ្វារវិថីកើតមុន រួចទើបអត្ថគ្គហណមនោទ្វារវិថីកើតបន្តតាមក្រោយ ចំណែកនាមគ្គហណមនោទ្វារវិថីទៀតសោត ក៏ត្រូវកើតតាមក្រោយជាលំដាប់នៃការប្រព្រឹត្តទៅរបស់សោតវិញ្ញាណវិថីចិត្តដែរ ។ ពាក្យថា *សោតវិញ្ញាណវីថិយា* ជាការសម្ដែងរួមនូវវិថីទី១គឺ *សោតទ្វារវិថីចិត្ត* មានសម្លេងបច្ចុប្បន្នជាអារម្មណ៍ និង វិថីទី២គឺ *អតីតគ្គហណមនោទ្វារវិថីចិត្ត* មានសម្លេងដែលកន្លងទៅហើយជាអារម្មណ៍ ព្រមទាំងវិថីទី៣គឺ *សម្ហូហគ្គហណមនោទ្វារវិថីចិត្ត* ប្រមូលរួបរួមនូវសម្លេងដែលកន្លងទៅនោះ ចាប់ពី ២ព្យាង្គឡើងទៅ ប៉ុន្តែបើពាក្យនោះមានតែមួយ

ព្យាង្គ ដូចពាក្យថា មាន់ ទា គោ ចេក ដូង ត្នោត នំ ទុំ ទៅ នៅ នាង ដេក ដើរ ឈរ ប៉ុណ្ណោះ ជាដើម វិថីទី៣ មិនបានកើតឡើងទេ ព្រោះសម្លេងតែមួយម៉ាត់ គឺបន្ទាប់ពីអតីតគ្គហណមនោទ្វារវិថីរលត់ទៅ ត្រូវនាមគ្គហណមនោទ្វារវិថីកើតឡើងតែម្តង មានសទ្ទប្បញ្ញត្តិជាអារម្មណ៍ រួចទៅទើបដឹងសេចក្តីនៃពាក្យមួយម៉ាត់នោះ ដោយការកើតឡើងនៃអត្ថគ្គហណមនោទ្វារវិថីចិត្ត ។

សរុបសេចក្តីនៃព្រះគាថាទាំង២ ចាប់តាំងអំពី **ឧចិ–ឃោសាទ្ទសារេន** មក គឺបានសេចក្តីថា ក្រសែសម្លេងផ្លូវវាចា ជាសទ្ទរូបបង្អោនទៅរកអត្ថទាំងឡាយ នាំឱ្យវិថីចិត្ត៤ឬ៥វិថីកើតឡើង ក្នុងវិថីចិត្តទាំងនោះ ពីរវិថីចុងក្រោយមានបញ្ញត្តិជាអារម្មណ៍ ពិតមែនតែក្រសែសម្លេងផ្លូវវាចា មានតែសម្លេងបញ្ចេញមកក៏ដោយ ប៉ុន្តែសម្លេងនោះ បង្អោនទៅរកអត្ថទាំងឡាយ ដូច្នេះបន្ទាប់អំពីវិថីចិត្តពីរឬបីវិថីកើតឡើង មានសម្លេងជាអារម្មណ៍បរមត្ថរួចហើយ ពីរវិថីចុងក្រោយគឺនាមគ្គហណ-មនោទ្វារវិថី និង អត្ថគ្គហណមនោទ្វារវិថី មានបញ្ញត្តិជា



អារម្មណ៍ ។

នាមប្បញ្ញត្តិ ឬសទ្ទប្បញ្ញត្តិ ជាពាក្យសំដីដែលពោលនូវឈ្មោះបរមត្ថថា រូប វេទនា ជាដើមក្តី ពោលនូវឈ្មោះសម្មតិសច្ចៈថា មនុស្ស សត្វ គ្រហស្ថ បព្វជិត ឬផែនដី ព្រៃភ្នំជាដើមក្តី គឺពោលតាមលោកវោហារ ទោះជាពោលភាសាអ្វីក៏ដោយ ឱ្យតែអ្នកស្តាប់ដឹងនូវសេចក្តីបាន ឈ្មោះថា សទ្ទប្បញ្ញត្តិ(ឱ្យដឹងនូវអត្ថបានអាស្រ័យសទ្ទរូប) ដោយប្រការដូច្នេះឯង ។

αក្នុងបរមត្ថធម៌ ចិត្ត ចេតសិក រូប ដែលបានសន្មត ថា មនុស្សប្រុសស្រីរាល់ថ្ងៃនេះ គឺមិនមានមនុស្ស មិនមាននិយាយ មិនមានពាក្យសរសើរ មិនមានពាក្យនិន្ទា មិនមានសើច មិនមានយំ មិនមានញញឹម មិនមានក្រញ៉ូវ មិនមានដេក មិនមានដើរ មិនមានឈរ មិនមានអង្គុយ មិនមានឥរិយាបថណាមួយទាំងអស់ បរមត្ថធម៌មានតែការកើតឡើង ហើយរលត់ទៅវិញតែប៉ុណ្ណោះ ប៉ុន្តែ *បញ្ញត្តិបាំងបរមត្ថ* ។

ឧទាហរណ៍- មនុស្សម្នាក់កំពុងតែនិយាយ បរមត្ថធម៌មាន វិញ្ញត្តិរូប សទ្ទរូប ចិត្តជាសមុដ្ឋានជាដើម វិញ្ញត្តិរូបមាន២

គឺ :

**១-កាយវិញ្ញត្តិរូប** : វិញ្ញត្តិ ប្រែថា សម្តែងឱ្យដឹង ឬ ប្រកាសឱ្យដឹង បានសេចក្តីថា អាការៈពិសេសដែលធ្វើឱ្យដឹងនូវបំណងដោយកាយ ។

កាយវិញ្ញត្តិ ជា **អសភាវរូប** គឺមិនមានសភាវលក្ខណៈបានដល់ការមិនមានភាវលក្ខណៈរបស់ខ្លួនឯង គ្រាន់តែជាវិការៈ ឬអាការៈនៃសភាវរូបដែលកើតអំពីចិត្តប៉ុណ្ណោះ។ យើងត្រូវការឱ្យមានសេចក្តីសំគាល់ផ្សេងៗ សម្តែងចេញតាមផ្លូវកាយ ក៏មានចិត្តគិតថា ត្រូវបក់ដៃ ឬញាក់ភ្នែកជាដើម ពេលនោះ ចិត្តបានញ៉ាំងចិត្តជរូប (រូបកើតអំពីចិត្ត) ឱ្យកើតឡើងព្រមគ្នានឹងការកើតឡើងនៃចិត្ត វាយោធាតុដែលមានចិត្តជាសមុដ្ឋាន កើតក្នុងកលាបរូបគឺក្នុងសំណុំនៃរូបនោះ បានគាំទ្របានញ៉ាំងនូវរូបកាយដែលកើតព្រមជាមួយនឹងខ្លួនឯង ឱ្យញ័រឱ្យកម្រើក ឱ្យប្រព្រឹត្តទៅផ្សេងៗ អាការៈដែលអាចញ៉ាំងឱ្យរូបកើតព្រមនឹងខ្លួនឯងកំរើកបាន ឈ្មោះថា កាយវិញ្ញត្តិរូប ។

កាយវិញ្ញត្តិរូប មិនមែនជាវាយោធាតុ មិនមែនជាតួ



សភាវរូបទាំងអស់ ប៉ុន្តែត្រង់ដែលចិត្តមានកម្លាំង អាចញ៉ាំងសភាវរូបឱ្យកើតឡើង ទាំងដែលអាចញ៉ាំងឱ្យសភាវរូបដែលបានកើតឡើងនោះ មានការញ័រកម្រើក សម្រេចបានជាកាយទ្វារ គឺជាទ្វារនៃកាយកម្ម ហើយក៏អាចជាទ្វារនៃវចីកម្ម និងមនោកម្មបានទៀតផង *ការកម្រើកនៃសភាវរូបដែលកើតអំពីចិត្តនោះឯង ជាកាយវិញ្ញត្តិ ឬជាកាយទ្វារ* ។

**២-វចីវិញ្ញត្តិរូប** : ប្រកាសឬសម្តែងឱ្យដឹងដោយវាចា ដោយសេចក្តីថា អាការៈពិសេសដែលធ្វើឱ្យដឹងសេចក្តីបានដោយវាចា ។

វចីវិញ្ញត្តិ ជាអសភាវរូប គឺមិនមានភាវលក្ខណៈរបស់ខ្លួន តែជាវិការៈ ឬអាការៈរបស់សភាវរូបដែលកើតអំពីចិត្តគិតនិយាយ ។ ក្នុងខណៈដែលចិត្តកើតឡើងគិតថា «យើងនឹងនិយាយនូវពាក្យនេះ» រមែងញ៉ាំងរូបឱ្យតាំងឡើង ព្រមជាមួយនឹងការកើតឡើងនៃចិត្ត បឋវីធាតុដែលមានចិត្តជាសមុដ្ឋានកើតក្នុងសំណុំនៃរូបនោះ បានប៉ះខ្ទប់ជាមួយកម្មជរូបត្រង់

កន្លែងឱ្យកើតសម្លេង ក៏បានធ្វើឱ្យសម្លេងកើតឡើង សម្លេងមិនមែនជាវចីវិញ្ញត្តិរូបទេ ប៉ុន្តែត្រង់ដែលអាការៈនៃការប៉ះខ្ទប់គ្នាកន្លែងសម្លេងហ្នឹងឯង ដែលមានចិត្តគិតនិយាយជាសមុដ្ឋាននោះ ឈ្មោះថា វចីវិញ្ញត្តិរូប ។

អាការៈប៉ះខ្ទប់រវាងធាតុដីដែលកើតអំពីចិត្តគិតនិយាយជាមួយនឹងកម្មជរូប (រូបកើតអំពីកម្មត្រង់កន្លែងនៃសម្លេង) សម្រេចបានជាវចីទ្វារ គឺជាទ្វារនៃវចីកម្ម ហើយក៏អាចជាទ្វារនៃកាយកម្ម និង មនោកម្មបានផងដែរ *អាការៈប៉ះខ្ទប់នៃសភាវរូបដែលមានចិត្តគិតនិយាយ ជាសមុដ្ឋានហ្នឹងឯង ជាវចីវិញ្ញត្តិ ឬជាវចីទ្វារ* ។

**វិញ្ញត្តិរូបទាំងពីរ** កើតឡើងជាកាយទ្វារ វចីទ្វារ ជាទ្វារនៃចេតនាផ្សេងៗ ពុំមែនតាំងនៅបានយូរនោះឡើយ មានការប្រព្រឹត្តទៅតាមចិត្តដែលកើតរលត់ (ចិត្ត ៣២ដួងគឺៈ អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខាវេទនា ១ដួង កាមជវន ២៩ដួង អភិញ្ញា ២ដួង) លឿនរហ័សក្រៃលែងណាស់ ពិតមែនតែវាជាអាការៈនៃសភាវរូប ប៉ុន្តែវាមិនបាន



កើតរលត់ជាមួយសំណុំនៃសភាវរូបនោះទេ ព្រោះវាជាអសភាវរូបផង ជាទ្វារនៃចេតនាផង ម្ល៉េះហើយ វិញ្ញត្តិរូបនេះរមែងប្រព្រឹត្តទៅតាមចេតនា ឬតាមចិត្តដែលជាសមុដ្ឋាន ។

វិញ្ញត្តិរូបទាំងពីរជាបរមត្ថធម៌ កាយវិញ្ញត្តិរូប មិនមែនដេក ដើរ ឈរ អង្គុយទេ ព្រោះដេក ដើរ ឈរ អង្គុយ គឺជាអាការៈទ្រង់ទ្រាយសណ្ឋានដោយអំណាចតំណនៃរូប បានញុំាងអត្ថគ្គហណមនោទ្វារវិថីចិត្តឱ្យកើតឡើង ដូច្នេះឥរិយាបថយ៉ាងនេះ យ៉ាងនោះ យ៉ាងណាមួយក៏ដោយ គ្រាន់តែជាអារម្មណ៍របស់ អត្ថគ្គហណមនោទ្វារវិថីចិត្តតែប៉ុណ្ណោះ ។

វចីវិញ្ញត្តិរូប ក៏មិនមែនជា ពាក្យសំដីស្តីជេរ សរសើរ ឬនិន្ទាអ្វីទាំងអស់ដែរ ព្រោះពាក្យសំដីផ្សេងៗ មានការសរសើរ ឬនិន្ទាជាដើម ជានាមប្បញ្ញត្តិ ឬសទ្ទប្បញ្ញត្តិ គឺមិនមែនដោយបរមត្ថណាមួយឡើយ នៅពេលដែលដឹងថាមានគេស្តីបន្ទោសឱ្យយើងនោះ គឺដឹងដោយនាមគ្គហណមនោទ្វារវិថីចិត្ត ជាវិថីចិត្តក្នុងមនោទ្វារកាន់យកឈ្មោះ យកពាក្យសំដីជាអារម្មណ៍ ប៉ុន្តែអ្វីដែលកើតឡើងចេញអំពីអ្នកដទៃ ដែលកំពុងស្តីបន្ទោស

ឱ្យយើងនោះ  មានតែសម្លេងប៉ុណ្ណោះដែលមកប៉ះនឹងសោត-ប្បសាទ  ដែលសម្លេងនោះមានចិត្តជាសមុដ្ឋានកើតឡើងហើយ ក៏រលត់ទៅវិញយ៉ាងលឿនរហ័ស ។ ដោយបរមត្ថធមិពុំមានអ្នកណាស្តីថាឱ្យយើងឡើយ ពាក្យសំដីស្តីជេរ សរសើរ ឬនិន្ទា  មិនមានចិត្តជាសមុដ្ឋានដូចសម្លេងទេ  ព្រោះជាបញ្ញត្តិធម្មតា  បញ្ញត្តិទាំងអស់  មិនមានការកើតក្នុងលោកឡើយដូច្នេះ ពាក្យសំដីអ្វីៗគ្រប់យ៉ាង ជារឿងរ៉ាវផ្សេងៗ មានសេចក្តីយ៉ាងណានោះ  រមែងមាននៅតែក្នុងនាមគ្គហណមនោទ្វារវិថីនិង អត្ថគ្គហណមនោទ្វារវិថីតែប៉ុណ្ណោះ ។

ប្រៀបឧបមាអំពីរោងល្ខោនមួយ  មានតួល្ខោនកំពុងតែសម្តែងសាច់រឿង ហើយក៏មានអ្នកមើលនូវល្ខោនក្នុងរោងនោះដែរ  ព្រោះជាប់ចិត្តនឹងសាច់រឿង  អ្នកមើលក៏ជាប់ចិត្តនឹងតួសម្តែងផងដែរទៅ ឧបមានេះយ៉ាងណា សូមពុទ្ធបរិស័ទពិចារ-ណាឱ្យបានយល់ដឹងសេចក្តីក្នុងរឿងជីវិតនេះផងចុះ ។

រោងល្ខោនជាឈ្មោះនៃលោក៦  គឺលោកភ្នែក  លោកត្រចៀក លោកច្រមុះ លោកអណ្តាត លោកកាយ  និង  លោក



ចិត្ត  ។  តួល្ខោនជាឈ្មោះនៃអារម្មណ៍បរមត្ថដែលប្រព្រឹត្តទៅតាមទ្វារ៦  គឺរូបារម្មណ៍  សទ្ទារម្មណ៍  គន្ធារម្មណ៍  រសារម្មណ៍ផោដ្ឋព្វារម្មណ៍ និង ធម្មារម្មណ៍ ។ សាច់រឿងយ៉ាងណាៗ ដែលតួអង្គកំពុងតែសម្តែងនោះ  ជាឈ្មោះនៃបញ្ញត្តិទាំងពីរ  គឺអត្ថ-ប្បញ្ញត្តិ  និង  សទ្ទប្បញ្ញត្តិ  ។  ទស្សនិកជន  អ្នកមើលនូវល្ខោនក្នុងរោងនោះ ជាឈ្មោះនៃវិថីចិត្តដែលប្រព្រឹត្តទៅតាមទ្វារទាំង៦  ។  ការជាប់ចិត្តនឹងមើលតួល្ខោនក្តី  ជាប់ចិត្តនឹងសាច់រឿងក្តីជាឈ្មោះនៃលោភៈប្រកបដោយមោហៈ   ដែលលោភៈនេះជាទុក្ខសមុទយសច្ចៈ   នាំឱ្យអ្នកមើលគឺវិថីចិត្តមកកាន់រោងល្ខោនរាល់ថ្ងៃ គឺលោក៦ រាល់ជាតិ រាល់កំណើត មានកំណើតក្នុងគតិជាដើម ។

រឿងក្នុងជីវិត ពិតជាដូចរឿងល្ខោន ប៉ុន្តែសាច់រឿងជីវិតវែងអន្លាយក្រៃលែងណាស់  ជាសាច់រឿងមួយសង្សារវដ្ត  មានអភិសង្ខារគឺកម្ម  (កុសលាកុសលកម្ម=បុណ្យនិងបាប)  ជាអ្នករៀបចំឱ្យមានជារោងសម្រាប់សម្តែងតួ   បានដល់លោក៦នេះព្រមទាំងរបៀបវារៈនៃការសម្តែងយ៉ាងណាៗ ញ៉ាំងសាច់រឿង

ជីវិតឱ្យមានការប្រព្រឹត្តទៅជារឿងកម្សត់ រឿងទារុណកម្ម យំយែកស្រែកទួញ និង ជារឿងសប្បាយរីករាយ មានបាន សម្បត្តិសម្បូរពោរពាស ត្រូវដូរផ្លាស់ជាមួយរឿងកម្សត់ មាន ជួប មានព្រាត់ ម្តងជាសេដ្ឋី ម្តងជាអ្នកសុំទាន ជួនកាលជាប្រុស ជួនកាលជាស្រី ជួនកាលទៀតនោះ ត្រូវសម្តែងតាមសាច់រឿង ជាតួប្រេត តួនរក ជាសត្វតិរច្ឆានសព្វគ្រប់ ឬជាអសុរកាយ ពេលខ្លះក៏ត្រូវសម្តែងជាតួអង្គព្រះរាជា ជាទេវតា ជាព្រះឥន្ទ ជាព្រះព្រហ្ម ប៉ុន្តែឥឡូវនេះកំពុងតែនៅក្នុងសាច់រឿងជាមនុស្ស **សួរថា** តើមនុស្សនេះជាតួអង្គពិត ឬគ្រាន់តែជាសាច់រឿង ? តួអង្គពិតជាអង្គបរមត្ថធម៌ បានដល់ខន្ធអាយតនៈ ធាតុ ឬ ចិត្ត ចេតសិក និង រូប ឯចំណែកសាច់រឿង គឺជាអត្ថប្បញ្ញត្តិ និង នាមប្បញ្ញត្តិ (សទ្ទប្បញ្ញត្តិ) ។

**ចម្លើយថា** :មិនមែនជាតួអង្គពិតទេ ព្រោះតួអង្គពិតគឺ ជាអង្គបរមត្ថធម៌ រូបារម្មណ៍កើតហើយរលត់ទៅវិញ សទ្ទា-រម្មណ៍កើតហើយរលត់ទៅវិញ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋ-ព្វារម្មណ៍ និង ធម្មារម្មណ៍ ក៏សុទ្ធតែកើតឡើងហើយរលត់ទៅ



វិញដែរ ប្រៀបដូចតួល្ខោនចេញមកសម្តែង រួចហើយវិលចូល ទៅក្នុងវាំងននឆាកវិញ អ៊ីចឹងឯង ដូច្នេះ មនុស្សគ្រាន់តែជា សាច់រឿងមួយ ដែលមានតួអង្គអ្នកសម្តែង ច្រើនគ្នា ពោលគឺ មានអង្គបរមត្ថធម៌ច្រើន ប្រាកដផ្លូវភ្នែកផង ផ្លូវត្រចៀកផង ផ្លូវច្រមុះផង ផ្លូវអណ្តាតផង ផ្លូវកាយផង និង ផ្លូវចិត្តផង ជាអារម្មណ៍បរមត្ថទាំង ៦ទ្វារ រួបរួមគ្នាដោយមនោទ្វារវិថីចិត្ត ក៏ដឹងនូវសាច់រឿងថា ជាមនុស្ស ហើយមនុស្សនេះយ៉ាង ណាៗ រមែងមានការដឹងដោយអត្ថគ្គហណមនោទ្វារវិថី និង នាមគ្គ-ហណមនោទ្វារវិថី សេចក្តីនៃរឿង និង ឈ្មោះទាំងអស់ វានៅ លើវិថីពីរនេះ ដែលសម្រាប់ដឹងនូវអារម្មណ៍បញ្ញត្តិគ្រប់ យ៉ាង ហ្នឹងឯង ។

សរុបសេចក្តីឧបមាមក គឺថា សាច់រឿងល្ខោនមិនមែន ជារោងឬឆាកល្ខោនទេ មិនមែនជាតួអង្គអ្នកសម្តែងទេ មិន មែនជាទស្សនិកជន អ្នកមើលនូវល្ខោននោះទេ ប៉ុន្តែអាស្រ័យ កាយវិការសម្តែង សម្លេងនិយាយឆ្លើយឆ្លងជាដើម ក៏ទៅជា រឿងឱ្យអ្នកមើលបានដឹង អ្នកមើលល្ខោនដឹងសាច់រឿង

អាស្រ័យតួសម្ដែង យ៉ាងណា មនោទ្វារវិថីចិត្តដឹងអារម្មណ៍បញ្ញត្តិ ក៏អាស្រ័យបរមត្ថធម៌កើតរលត់តាមទ្វារ៦ យ៉ាងនោះឯង ។

រឿងរ៉ាវនៅក្នុងសារពតិមាន(កាសែត)ក្ដី ក្នុងទូរទស្សន៍ក្ដី គឺសុទ្ធតែជាបញ្ញត្តិទាំងអស់ ដែលមនោទ្វារវិថីចិត្តកើតឡើងដឹងរឿងផ្សេងៗ មិនចំពោះតែក្នុងទូរទស្សន៍ទេ ដែលមិនមាននូវមនុស្ស សត្វ ឬ ព្រៃភ្នំ ទន្លេ សមុទ្រ ជាដើមនោះ សូម្បីតែពិភពលោកទាំងមូលនេះ ក៏ដូចជាទូរទស្សន៍មួយគ្រឿងអ៊ីចឹងឯង គ្រាន់តែថា អារម្មណ៍ជាបរមត្ថក្នុងទូរទស្សន៍ មានតែរូបា-រម្មណ៍(ពណ៌)និង សទ្ទារម្មណ៍(សម្លេង) តែប៉ុណ្ណោះ ឯចំណែកអារម្មណ៍ជាបរមត្ថក្នុងពិភពលោកនេះ គឺមានទាំងពណ៌ ទាំងសម្លេង ទាំងក្លិន ទាំងរស ទាំងផោដ្ឋព្វៈ ទាំងធម្មារម្មណ៍ តែទោះបីជាមាននូវអារម្មណ៍ច្រើនយ៉ាងណាក៏ដោយ ក៏មនុស្សសត្វ ឬ ព្រៃភ្នំ ទន្លេ សមុទ្រ ជាដើមនោះ វាមិនមានដូចនៅក្នុងទូរទស្សន៍អ៊ីចឹងដែរ ដូច្នេះ សូមពុទ្ធបរិស័ទបានជ្រាបឱ្យច្បាស់ប្រាកដថា ពិភពលោកដូចជាទូរទស្សន៍មួយគ្រឿង ដែល



យើងគ្រប់គ្នាមើលរាល់ថ្ងៃ រាល់ម៉ោង លើកលែងតែពេលដេកលក់ ព្រោះមិនមានវិថីចិត្តតែប៉ុណ្ណោះ ។

យើងនិយាយថា ៖***មើលទូរទស្សន៍*** ៖ ប៉ុន្តែមិនមែនត្រឹមតែមើលទេ គឺស្ដាប់សម្លេងផង ទើបដឹងរឿង យ៉ាងណាមិញពាក្យថា «ពិភពលោកដូចជាទូរទស្សន៍មួយគ្រឿង ដែលយើងគ្រប់គ្នាបានមើលរាល់ថ្ងៃ រាល់ម៉ោង» ក៏មិនមែនត្រឹមតែមើលដែរទេ គឺស្ដាប់សម្លេងផង ហិតស្រូបនូវក្លិនផង លិទ្ធនូវរសផង ប៉ះខ្ទប់នូវផោដ្ឋព្វៈផង ដឹងនូវធម្មារម្មណ៍ផង (វៀរបញ្ញត្តិទាំងពីរ) ក៏យ៉ាងនោះដែរ ។

រឿងរ៉ាវព្រមទាំងមនុស្សសត្វបញ្ញត្តិទាំងអស់ មិនមែនចេញអំពីបរមត្ថលោកគឺពិភពលោកមកទេ ដែលយើងបានដឹងរឿងថា មានមនុស្ស សត្វ វត្ថុ របស់របរគ្រប់យ៉ាងនោះ ដោយសារមនោទ្វារវិថីចិត្តកើតឡើង ដោយឡែកផ្សេងអំពីវិថីចិត្តដែលដឹងត្រឹមតែអារម្មណ៍ពិតជាបរមត្ថធម៌ ដូចជាមើលទូរទស្សន៍ ហើយបានដឹងរឿងរ៉ាវមនុស្សសត្វបញ្ញត្តិផ្សេងៗដោយមនោទ្វារវិថីចិត្ត ជាវិថីចិត្តមួយដោយឡែកផ្សេងអំពី

ចក្ខុទ្វារវិថី និង សោតទ្វារវិថីអ៊ីចឹងដែរ ។

សូមពុទ្ធបរិស័ទកុំវង្វេងចំពោះអារម្មណ៍បរមត្ថ ដើម្បីកុំឱ្យវង្វេងប្រកាន់ខុសផ្សេងៗ ត្រូវស្តាប់ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធឱ្យយល់ ហើយបំពេញកុសលចម្រើនសតិប្បដ្ឋាន បើបានយ៉ាងនេះ ពុទ្ធបរិស័ទនឹងមានឱកាសកម្ចាត់សេចក្តីវង្វេង ព្រមដោយកិលេសផ្សេងៗ បានជាពុំខាន ។

រូបគំនូរផ្លែឪឡឹកមួយ មិនមែនជាផ្លែឪឡឹកពិត យ៉ាងណា ផ្លែឪឡឹកមែនទែន ក៏មែនត្រឹមតែសម្មតិសច្ចៈប៉ុណ្ណោះ ដោយអំណាចបរមត្ថរូប៩ ប្រជុំគ្នាក្នុងអាកាសធាតុ រូបបរមត្ថ៩ គឺ ដី ទឹក ភ្លើង ខ្យល់ ពណ៌ សម្លេង ក្លិន រស និង ឱជា (អាហាររូប) ។ រូបបរមត្ថតែងកើតឡើងហើយរលត់ទៅវិញ តាមសំណុំៗ (កលាបៈ) របស់វា ប៉ុន្តែដែលថា បរមត្ថរូប៩ ប្រជុំគ្នាក្នុងអាកាស ហើយបាននូវការសន្មតមួយថា ជាផ្លែឪឡឹកនោះ វាជាការរួបរួមដោយវិថីចិត្តនៅក្នុងមនោទ្វារ ចាំអារម្មណ៍បន្តគ្នាហ្នឹងឯង គឺថា វិថីចិត្តក្នុងមនោទ្វារនេះ វាមានតួនាទីចាំនូវអារម្មណ៍បរមត្ថផ្សេងៗ ដែលកន្លងទៅហើយថ្មីៗក្តី



យូរហើយក្តី ទោះជារូបគឺពណ៌ក្តី សម្លេងក្តី ក្លិនក្តី រសក្តី ផោដ្ឋព្វៈក្តី ហើយរួបរួមចូលគ្នាក្នុងរូបដែលកំពុងមើល ព្រោះមនោទ្វារវិថីចិត្តនេះ វាកើតប្តូរផ្លាស់គ្នាយ៉ាងលឿនរហ័ស ជាមួយនឹងចក្ខុទ្វារវិថីចិត្តដែលមានរូបារម្មណ៍បច្ចុប្បន្នជាអារម្មណ៍នោះ ម្ល៉ោះហើយ អត្ថគ្គហណមនោទ្វារវិថីចិត្តក៏ដឹងថាជាផ្លែឪឡឹក ដែលបានមើលឃើញក្នុងចំការ ឬគេដាក់លក់នៅផ្សារជាដើម អ៊ីចឹងទៅ ពុំនោះសោតទេ បើមនោទ្វារវិថីចិត្តបានគិតដល់អារម្មណ៍ផ្សេងៗ ហើយរួបរួមចូលក្នុងរសដែលកំពុងបរិភោគ អត្ថគ្គហណមនោទ្វារវិថីចិត្ត ក៏ដឹងថា កំពុងតែបរិភោគនូវផ្លែឪឡឹក អ៊ីចឹងដែរទៅ ។ សតិប្បដ្ឋាន រលឹកត្រង់លក្ខណៈនៃបរមត្ថធម៌ តាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ និង ផ្លូវចិត្ត ឃើញរូបធម៌ នាមធម៌កើត និង រលត់មានការបាត់ទៅជាធម្មតា កម្ចាត់បង់បាននូវ **ឃនសញ្ញា** ដែលប្រកាន់ថាជាដុំមែនទែន ។

ក្នុងការអធិប្បាយអំពីបញ្ញត្តិ ២យ៉ាង អត្ថប្បញ្ញត្តិបានអធិប្បាយមកច្រើនហើយ នៅសទ្ទប្បញ្ញត្តិដែលហៅម្យ៉ាង

ទៀតថា **បញ្ញាបនតោបញ្ញត្តិ** មិនទាន់បានរៀបរាប់ថា មានប៉ុន្មានពួកក្រុមនៅឡើយ ដូច្នេះ សូមពុទ្ធបរិស័ទសិក្សាបន្ត បន្តិចទៀត ហើយក៏ជាការសិក្សាសរុបអំពីបញ្ញត្តិទាំង២ប្រការ ផងដែរ ។ ពាក្យថា **បញ្ញាបនតោបញ្ញត្តិ** គឺការតែងតាំង ឈ្មោះឱ្យដឹងនូវអត្ថតាមរយៈសម្លេង បានដល់ *សទ្ទប្បញ្ញត្តិ ឬ នាមប្បញ្ញត្តិ* ហ្នឹងឯង ។

**សទ្ទប្បញ្ញត្តិ** គឺជាឈ្មោះ ជាពាក្យសំដីនិយាយ ដើម្បី ឱ្យដឹងនូវសេចក្តីថាជាអ្វី តាមលោកវោហារមាន *ចិត្តជសទ្ទរូប* គឺសម្លេងដែលកើតអំពីចិត្ត ជាប្រធាន ។

**នាមប្បញ្ញត្តិ, នាម** ប្រែថា ឈ្មោះ (មិនមែនជា នាមបរមត្ថទេ) **បញ្ញត្តិ** ប្រែថា ការតែងតាំងឱ្យដឹងសេចក្តី ដូច្នេះ **នាមប្បញ្ញត្តិ** គឺការតែងតាំងនូវឈ្មោះ សម្រាប់ឱ្យ ដឹងសេចក្តី ។

បើមិនមានសទ្ទប្បញ្ញត្តិទេ អ្វីៗទាំងអស់ក្នុងលោកនេះ មិនមានឈ្មោះឡើយ ហើយបើមិនមានឈ្មោះសោះ យ៉ាងនេះ តើនឹងឱ្យដឹងសេចក្តីដល់គ្នានិងគ្នាបានយ៉ាងដូចម្តេចទៅ ព្រះ



ធម៌មិនបានសំដែងប្រាប់ថា ធម៌មួយគឺឈ្មោះ បានគ្របដណ្តប់ទៅ លើធម៌ទាំងអស់ ឯចំណែកធម៌ទាំងអស់ក៏ប្រមូលចុះមកក្នុង ធម៌មួយវិញ គឺឈ្មោះហ្នឹងឯង ពាក្យនេះបានសេចក្តីថា អង្គ បរមត្ថធម៌ទាំងអស់ក្តី អត្ថប្បញ្ញត្តិទាំងអស់ក្តី គ្មានអ្វីមួយ ដែលថាមិនមាននូវឈ្មោះនោះឡើយ ព្រោះហេតុដូច្នេះហើយ ទើបព្រះធម៌សំដែងថា ធម៌ទាំងអស់ប្រមូល ចូលក្នុងធម៌មួយ គឺនាម បានដល់ឈ្មោះទាំងឡាយទាំងពួង ។

បើមានត្រឹមតែឈ្មោះបរមត្ថធម៌ទេនោះ ក៏មិនអាចប្រើ ការឱ្យស្តាប់គ្នាបាន ដូចពាក្យថា បញ្ចក្ខន្ធកំពុងមើលរូបារម្មណ៍ ក៏មិនដឹងថាចង់និយាយអំពីបញ្ចក្ខន្ធពួកណា ហើយរូបារម្មណ៍ ទៀតសោត វាជារូបផ្នែកអ្វីក៏មិនដឹងផងដែរ បើយ៉ាងនេះ ព្រះពុទ្ធអង្គទ្រង់បញ្ញត្តព្រះវិន័យមិនបានឡើយ ទាល់តែមាននូវ សម្មតិប្បញ្ញត្តិទៀត ដូចជានិយាយថា ភិក្ខុកំពុងមើលព្រះ ចេតិយ សាមណេរកំពុងមើលគម្ពីរធម៌ ព្រះពុទ្ធបញ្ញត្តវិន័យ មិនឱ្យអ្នកបួសមើលនូវរបាំទេ បើពោលដូច្នេះ ទើបអាចស្តាប់ គ្នាបាន ហើយក៏មិនមែនជាការកែប្រែបរមត្ថធម៌ ឱ្យមកជាភិក្ខុ

ឬ សាមណេរនោះដែរ ភិក្ខុសាមណេរ មានត្រឹមតែឈ្មោះប៉ុណ្ណោះ ធាតុពិតនៅតែជាបញ្ចក្ខន្ធ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណដដែល បង្គាប់ ឬ កែប្រែឱ្យទៅជាយ៉ាងដទៃ តាមគិតចង់យ៉ាងណាៗនោះ ពុំបានឡើយ ។

ព្រះអរិយបុគ្គលទាំងឡាយមិនវង្វេងប្រកាន់នូវបរមត្ថធម៌ មិនវង្វេងច្រឡំក្នុងឈ្មោះ ព្រោះលះបង់នូវសក្កាយទិដ្ឋិអស់ហើយព្រមទាំងអវិជ្ជាផង ការសម្រេចនូវគុណវិសេសយ៉ាងនេះ ព្រោះហេតុតែ បានអប់រំនូវបញ្ញា សន្សំបុណ្យកុសលសព្វគ្រប់ប្រការ សិក្សាបរមត្ថធម៌ ដឹងនូវបរមត្ថធម៌ដែលប្រាកដតាមទ្វារទាំង៦ គឺដឹងរឿយៗក្នុងជីវិតប្រចាំថ្ងៃ យ៉ាងនេះទើបអាចបើកបញ្ញត្តិចេញអំពីបរមត្ថបាន ព្រមដោយបារមីគ្រប់គ្រាន់ ក៏បានសម្រេចជាព្រះអរិយបុគ្គលទៅ ។

សូមពុទ្ធបរិស័ទទាំងឡាយ រៀនអប់រំចម្រើននូវសតិប្បដ្ឋាន៤ ប្រយោជន៍ដើម្បីជាក់ច្បាស់ចំពោះបរមត្ថធម៌ មិនវង្វេងក្នុងបញ្ញត្តិដោយប្រកាន់ថា សត្វបុគ្គលតួខ្លួន ឬវត្ថុនេះនោះមានឡើយ ។ ការអប់រំចម្រើននូវសតិប្បដ្ឋាន៤



មិនមែនជាការបដិបត្តិដើម្បីហាមឃាត់ មិនឱ្យដឹងនូវអារម្មណ៍នោះទេ ព្រោះការដឹងនូវអារម្មណ៍បញ្ញត្តិ ធាតុដឹង អាការដឹងនោះជាបរមត្ថធម៌ គឺជាមនោទ្វារវិថីចិត្ត នៅក្នុងវិថីចិត្តដែលដឹងនូវអារម្មណ៍បញ្ញត្តិ មានលោភជវនៈ ទោសជវនៈ មោហជវនៈ ហើយក៏មាននូវកុសលជវនៈផ្សេងៗ ដូចជាកុសលថ្នាក់ទានសីល ឬកុសលថ្នាក់សមថភាវនា តាមតែជវនៈណាមួយមានឧបនិស្សយប្បច្ច័យឱ្យកើត ក៏កើតឡើងទៅ ។

ចំពោះព្រះអរហន្តគ្រប់ព្រះអង្គ ក៏នៅតែមានមនោទ្វារវិថីចិត្តដឹងអារម្មណ៍បញ្ញត្តិដែរ ប៉ុន្តែមិនមានកុសលជវនៈ និងអកុសលជវនៈកើតឡើងឡើយ ដោយសារការកើតឡើងនៃអរហត្តមគ្គ កម្ចាត់បង់នូវអកុសលអស់ពីសន្តាន ក៏បញ្ចប់កិច្ចកុសលត្រឹមអរហត្តមគ្គនោះឯងទៅ នៅតែអព្យាកតជវនៈប៉ុណ្ណោះ មិនមានពូជសម្រាប់ដុះបន្តជាតិភពកំណើតឱ្យកើតក្នុងភពថ្មីទៀតឡើយ ។

គ្រប់បុគ្គលទាំងអស់ក្នុងលោកនេះ រមែងមានការដឹងបញ្ញត្តិដោយមនោទ្វារវិថីចិត្ត ប៉ុន្តែកុសលថ្នាក់សតិប្បដ្ឋានពុំ

បានដឹងអារម្មណ៍បញ្ញត្តិទេ ព្រោះកុសលនេះ ជាកុសលថ្នាក់ស្រាវជ្រាវរាវរកសេចក្ដីពិត នៅក្នុងជីវិតដែលប្រជុំដោយបញ្ចក្ខន្ធ តាមទ្វារទាំង៦ទ្វារណាមួយ ដូច្នេះទោះបីជាមនោទ្វារវិថីចិត្តដឹងអារម្មណ៍បញ្ញត្តិ ច្រើនលើកច្រើនដង ញឹកញាប់ជាប់តវិថីគ្នាយ៉ាងណាក៏ដោយ ក៏មនោទ្វារវិថីចិត្តនោះត្រឹមតែជាសភាវធម៌ ដែលកើតឡើងហើយរលត់ទៅវិញ សតិរលឹកដឹងបានរឿយៗនូវបរមត្ថធម៌ ដែលជាសភាវធម៌ពិត មានការកើតឡើងហើយ រមែងរលត់បាត់ មិនមានតាំងនៅឋិតថេរទៀងទាត់ ជាសត្វ ជាវត្ថុអ្វីៗឡើយ ។

បើមិនប្រចក្សលក្ខណៈសភាវបរមត្ថដែលកើតរលត់ ដូចជាមិនប្រចក្សលក្ខណៈចក្ខុទ្វារវិថីចិត្ត ដែលមានតែ រូបារម្មណ៍មកកាន់គន្លងនៃចក្ខុប៉ុណ្ណោះ ឬ ដូចជាសោតទ្វារវិថីចិត្តដែលមានតែសទ្ទារម្មណ៍មកកាន់គន្លងនៃសោតប្បសាទ ជាដើមទេ គឺមិនអាចចែកបរមត្ថឱ្យដាច់អំពីបញ្ញត្តិបានឡើយ ម្ល៉ោះហើយក៏វង្វេងក្នុងបញ្ចក្ខន្ធ ឃើញបញ្ចក្ខន្ធស្ថិតនៅទៀងទាត់ឥតប្រែប្រួល ជាការឃើញខុសដោយអំណាចមិច្ឆាទិដ្ឋិ ហ្នឹងឯង រមែង



ប្រកាន់នូវបញ្ចក្ខន្ធដែលជាអនត្តា ថាជាមនុស្សជាសត្វទៅវិញ ។

សតិប្បដ្ឋាន៤ ប្រៀបដូចជាផាលនង្គ័លដែលភ្ជួរបំបែកដីស្រែចំការ ព្រោះសតិរលឹកដឹង បានចែករំលែករូបធម៌ដោយឡែក នាមធម៌ដោយឡែក ជាពិសេសវិថីចិត្តដែលដឹងអារម្មណ៍បរមត្ថ មិនច្រឡំនឹងវិថីចិត្តដែលមានបញ្ញត្តិជាអារម្មណ៍ ដូច្នេះសតិប្បដ្ឋាន៤ គឺជាឧបករណ៍ក្នុងការធ្វើស្រែ ដែលមានផលជាអមតៈ ។

សទ្ធាជាគ្រាប់ពូជ សាបព្រោះក្នុងស្រែគឺសន្តានចិត្ត កាលដែលមានភ្លៀងគឺការសង្រួមឥន្ទ្រិយហើយ គ្រាប់ពូជក៏ដុះចាក់ឫសទៅក្នុងដីស្រែ បានដល់សីលដែលជាទីតាំង ជាឫសគល់ដ៏មាំ និង ជាប្រយោជន៍នៃកុសលធម៌ទាំងពួង ចំណែកពន្លកដែលដុះ ចេញពីគ្រាប់ពូជមកខាងលើ រហូតបានដុះធំបែកជាគុម្ព ហើយមានផល គឺបានដល់ពន្លកសមថៈនិងវិបស្សនា មានការចម្រើនរហូតរឹងមាំខ្លាំងក្លា ជាឧបនិស្សយប្បច្ច័យដល់មគ្គផល ដែលត្រូវសម្រេចជាចុងក្រោយ ។

ការប្រារព្ធសេចក្ដីព្យាយាម ប្រៀបដូចជាគោទាញនង្គ័ល

បញ្ញាប្រៀបដូចជានឹមនិងផ្ទៀងនង្គ័ល ហិរិឱត្តប្បៈ ខ្ចាសខ្ពើមបាប ដូចជាដងនង្គ័ល ចិត្តស្ងប់រម្ងាប់ ដូចជាខ្សែ គឺខ្សែទាមទាក់កគោឱ្យជាប់ក្នុងនឹម ខ្សែចងនឹមឱ្យជាប់នឹងដងនង្គ័ល ហើយនឹងខ្សែដែលចងគោមកអ្នកភ្ជួរ សម្រាប់បញ្ឈរគោ ឯចំណែកសតិប្រៀបដូចជាផាលផង ជន្លួញផង ផាលសម្រាប់បំបែកដី ជន្លួញសម្រាប់បំភ័យគោ យ៉ាងណាមិញ សតិរលឹកដឹងនូវរូបធម៌ នាមធម៌ ចែករូបបរមត្ថ និង នាមបរមត្ថ មិនឱ្យច្រឡំគ្នា កម្ចាត់ **អត្តសញ្ញា** សេចក្តីសំគាល់ថាជាតួខ្លួន ជាសត្វ ជាបុគ្គល និង ម្យ៉ាងទៀត ការឃើញភ័យក្នុងសង្សារវដ្ត ឃើញនាមរូបមានតែការកើតរលត់ ជាទុក្ខ ជាទោស ជាអ្នកសម្លាប់ នាំឱ្យមាននូវស្មារតី ញ៉ាំងសេចក្តីព្យាយាមឱ្យប្រព្រឹត្តទៅរឿយៗមិនដាច់ ក្នុងគន្លងផ្លូវដែលត្រូវទៅកាន់ទីបំផុតទុក្ខយ៉ាងនោះឯង ។

ការអប់រំចម្រើនសតិប្បដ្ឋាន គឺសតិរលឹកដឹងនូវបរមត្ថធម៌ ដែលមានលក្ខណៈប្រាកដ មិនមែនជាការរលឹកនូវឈ្មោះ ព្រោះឈ្មោះគឺជាបញ្ញត្តិ មិនមានការកើតការរលត់ទេ អ្វីៗ



ដែលកើតឡើងក្នុងជីវិត មានត្រឹមតែរូបក្ខន្ធ និង នាមក្ខន្ធ៤ គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ តែប៉ុណ្ណោះ ឯចំណែកឈ្មោះផ្សេងៗនោះ ពុំបានកើតឡើងឡើយ ។ ឈ្មោះជានាម-ប្បញ្ញត្តិ អាស្រ័យមានចិត្ត និង ចេតសិកក្នុងមនោទ្វារវិថី នឹកគិតក្នុងបំណងឱ្យអ្នកស្តាប់ដឹងរឿង យល់ន័យសេចក្តីអ្វីៗ ក៏បានញ៉ាំងសទ្ទរូបឱ្យកើតឡើង សទ្ទរូបនេះគឺជាសភាវបរមត្ថ ប្រាកដតាមផ្លូវត្រចៀក ហើយរលត់បាត់ទៅវិញយ៉ាងលឿនរហ័ស កាលដែលសទ្ទរូបកើតឡើងនោះ ព្រោះចិត្ត និង ចេតសិក ជាកុសលក្តី ជាអកុសលក្តី ជាអព្យាកតៈក្តី ជាសមុដ្ឋាន មិនមែនមានសត្វបុគ្គលណាជាអ្នកប្រាថ្នានិយាយ ហើយញ៉ាំងសម្លេងឱ្យកើតឡើងនោះទេ ។

សម្លេងគឺសទ្ទរូបបង្អោនទៅក្នុងអត្ថយ៉ាងណាៗ មនោ-ទ្វារវិថីចិត្តកាន់យកនូវអត្ថនោះៗជាអារម្មណ៍កើតឡើង ទាំងដែលសម្លេងនោះបានរលត់អស់ទៅហើយ តាមពិតសម្លេងដែលកើតអំពីចិត្ត វារលត់ទៅវិញលឿនរហ័សណាស់ មិនបានស្ថិតនៅរហូតដល់ប៉ះនឹងត្រចៀកយើងជាអ្នកស្តាប់នោះទេ

ប៉ុន្តែអាស្រ័យដោយអាកាសធាតុ មានប្រក្រតីជាទីអាស្រ័យដ៏មានកម្លាំង និង ឧតុខាងក្រៅជាសមុដ្ឋាន ទើបបានបន្ទរនូវសម្លេងឱ្យកើតតៗ ហើយទើបប៉ះនឹងសោតប្បសាទរូប សម្លេងដែលប៉ះនឹងសោតប្បសាទ កំណត់ត្រឹមសោតទ្វារវិថីចិត្ត កើតឡើងហើយដឹងនូវសម្លេងនោះ រួចរលត់ទៅទាំងអស់គ្នា គឺទាំងសម្លេង ទាំងសោតទ្វារវិថីចិត្ត ។

សទ្ទរូបគឺសម្លេងដែលប៉ះនឹងសោតប្បសាទ មិនមែនដូចក្លិនប៉ះនឹងច្រមុះ រសប៉ះនឹងអណ្តាត ផោដ្ឋព្វៈប៉ះនឹងកាយនោះទេ ព្រោះក្លិនក្តី រសក្តី ផោដ្ឋព្វៈក្តី ប៉ះខ្ទប់ដោយការមកដល់នឹងបសាទរូប ឯចំណែកសោតប្បសាទ ប៉ះខ្ទប់នឹងសម្លេង ទាំងដែលសម្លេងនោះមិនបានមកដល់ឡើយ ប៉ុន្តែដោយអំណាចអាកាសធាតុ ជាទីអាស្រ័យដ៏មានកម្លាំង ទើបញ៉ាំងឱ្យមានការប៉ះខ្ទប់គ្នា សោតវិញ្ញាណកើតឡើងឮនូវសម្លេងនោះ ដែលសម្លេងនោះមិនមែននៅក្នុងរន្ធត្រចៀកទេ ព្រោះមិនបានមកដល់ដោយប្រការដូច្នេះឯង របៀបដូចរូបារម្មណ៍ដែរ រូបារម្មណ៍មិនបានមកដល់ចក្ខុប្បសាទទេ ប៉ុន្តែព្រោះពន្លឺជាទីអាស្រ័យដ៏



មានកម្លាំង ទើបញ៉ាំងឱ្យមានការប៉ះខ្ទប់គ្នា ចក្ខុវិញ្ញាណក៏កើតឡើងឃើញនូវរូបនោះច្បាស់ប្រាកដ ហើយក៏រលត់ទៅវិញតាមធម្មតានៃសង្ខារធម៌ ។

រឿងរ៉ាវរបស់រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ វាជាអារម្មណ៍របស់មនោទ្វារវិថីចិត្តពិតៗ គឺមិនមែនជាអារម្មណ៍របស់បញ្ចទ្វារវិថីចិត្តទេ នេះជាការសម្តែងបញ្ជាក់ថា រឿងរ៉ាវនោះៗ គឺមិនមានជាសភាវៈក្នុងលោកឡើយ លោកភ្នែកក្តី លោកត្រចៀកក្តី លោកច្រមុះក្តី លោកអណ្តាតក្តី លោកកាយក្តី លោកចិត្តក្តី មិនមានរឿងរ៉ាវអ្វីទាំងអស់ ប៉ុន្តែវាជាស្រមោលរបស់បរមត្ថធម៌ ព្រោះបើមិនមាននូវបរមត្ថធម៌ទេ រឿងរ៉ាវបញ្ញត្តិទាំងអស់ក៏មិនមានដែរ ។

ពាក្យថាស្រមោលរបស់បរមត្ថធម៌ គឺមិនមែនជាបរមត្ថ ប៉ុន្តែកាលមានចិត្ត ចេតសិក រូប ក៏មានអត្ថឱ្យដឹងដោយប្រការនោះៗ ហើយម្យ៉ាងទៀត ព្រោះមានមនោទ្វារវិថីចិត្តកាន់យកនូវអារម្មណ៍បរមត្ថផ្សេងៗមកប្រមូលផ្តុំគ្នា ទើបអារម្មណ៍ដែលប្រមូលផ្តុំនោះ បានទៅជាអត្ថឱ្យដឹងដោយប្រការផ្សេងៗ គឺជា

បញ្ញត្តិ រួចហើយបញ្ញត្តិនោះមានឈ្មោះយ៉ាងណា។ តាមតែលោកវោហារ ព្រោះថា ឈ្មោះខ្លះយោលទៅតាមអត្ថ ឈ្មោះខ្លះក៏ទៅតាមការនិយម សរុបមក គ្រាន់តែជាឈ្មោះសម្រាប់និយាយប្រាប់គ្នាឱ្យដឹងសេចក្ដី អត្ថន័យរឿងរ៉ាវផ្សេង។ ចម្រើនការយល់ដឹងកិច្ចការនៅក្នុងលោក ឬក៏បានចេះដឹងក្នុងធម៌វិន័យព្រះពុទ្ធសាសនា ដោយការស្ដាប់ព្រះធម៌ទេសនា សម្ដែងអំពីបរមត្ថធម៌ក្ដី រឿងរ៉ាវជាតកក្ដី ដែលមានអត្ថន័យខ្លឹមសារគួរឱ្យយល់ដឹង ប៉ុន្តែ បើស្ដាប់ការនិយាយអំពីបុគ្គលណា។ក៏ដោយ ហើយខ្វះការធ្វើទុកក្នុងចិត្តដោយល្អ ក៏វានាំឱ្យចម្រើនការយល់ខុសផ្សេង។អ៊ីចឹងដែរទៅ ។

## នាមប្បញ្ញត្តិមាន ៦យ៉ាងគឺ :

**១-វិជ្ជមានប្បញ្ញត្តិ:** ប្រកាសឈ្មោះបរមត្ថធម៌គ្រប់យ៉ាង

**២-អវិជ្ជមានប្បញ្ញត្តិ:** ប្រកាសឈ្មោះអត្ថប្បញ្ញត្តិផ្សេង។

**៣-វិជ្ជមានប្បញ្ញត្តិ + អវិជ្ជមានប្បញ្ញត្តិ**

**៤-អវិជ្ជមានប្បញ្ញត្តិ + វិជ្ជមានប្បញ្ញត្តិ**

**៥-វិជ្ជមានប្បញ្ញត្តិ + វិជ្ជមានប្បញ្ញត្តិ**



**៦-អវិជ្ជមានប្បញ្ញត្តិ + អវិជ្ជមានប្បញ្ញត្តិ ។**

នាមប្បញ្ញត្តិទី៣ គឺជាការផ្សំពាក្យគ្នា ដូចពាក្យថា **«តេវិជ្ជោ»** បុគ្គលបានវិជ្ជា៣, វិជ្ជាអង្គធម៌គឺបញ្ញា ដូច្នេះជាវិជ្ជមានប្បញ្ញត្តិឯពាក្យថា បុគ្គល គឺជាអវិជ្ជមានប្បញ្ញត្តិ ។

នាមប្បញ្ញត្តិទី៤ក្ដី ទី៥ក្ដី ទី៦ក្ដី គឺគ្រាន់តែនិយាយរួមគ្នាបញ្ចូលពាក្យបញ្ញត្តិទាំងពីរខាងដើម តាមសេចក្ដីដែលត្រូវអធិប្បាយ ដូចពាក្យថា សម្លេងមនុស្ស ចក្ខុវិញ្ញាណ ព្រះរាជ-ធីតា ជាដើម សម្លេងក្ដី ចក្ខុក្ដី វិញ្ញាណក្ដី ជាវិជ្ជមានប្បញ្ញត្តិឯពាក្យថា មនុស្ស ព្រះរាជា ធីតា ជាអវិជ្ជមានប្បញ្ញត្តិ ការរៀបរាប់អំពីបញ្ញត្តិទាំងពីរមកហូរហែប៉ុណ្ណេះ បញ្ជាក់សេចក្ដីនៅក្នុងបទពិចារណានៃការចែកធាតុ ជាជំនួយស្មារតីរំលត់សេចក្ដីខឹងក្រោធ បុគ្គលដែលមាននូវស្មារតីរំលត់នូវសេចក្ដី ខឹងក្រោធ ដោយបញ្ញាពិចារណាចែកធាតុបានយ៉ាងនេះ រមែងស្ងប់រម្ងាប់នូវពៀរ ព្រោះមិនបានគិតថា អ្នកឯណោះគេបានជេរអញ គេបានវាយអញ ដូច្នេះឡើយ រមែងមានការស្ងប់ត្រជាក់ចិត្ត ដោយមិនមាននូវគំនិតថា មានបុគ្គលណាជាសត្រូវជាមួយ

នឹងខ្លួន ហើយក៏មិនបានគិតថា ខ្លួនឯងជាសត្រូវជាមួយនឹងអ្នកដទៃណាៗដែរ ។

## មេត្តាជាធម៌ទ្រទ្រង់លោក ផ្ទុយពីព្យាបាទ

មេត្តាជាកុសលធម៌ដែលអនុគ្រោះនូវប្រយោជន៍ សុខចម្រើនដល់សត្វបុគ្គលក្នុងលោក ធ្វើឱ្យផុតចាកភ័យ និងពៀរផ្សេងៗ ភ័យនិងពៀរផ្សេងៗ រមែងកើតអំពីអកុសលចិត្តដែលប្រាសចាកនូវមេត្តា ។ មេត្តាជាមិត្ត ព្យាបាទជាសត្រូវតាំងនៅក្នុងចិត្តមនុស្សសត្វគ្រប់គ្នា ដូច្នេះ ដើម្បីឱ្យបានសុខគួរជ្រើសរើសយកមិត្ត ហើយកម្ចាត់សត្រូវឱ្យអស់អំពីសន្តាន។



## ពុទ្ធភាសិត

ន បរេសំ វិលោមានិ ន បរេសំ កតាកតំ

អត្តនោ ច អវេក្ខេយ្យ កតានិ អកតានិ ច ។

បុគ្គលមិនគួរយកពាក្យអាក្រក់លាមក របស់អ្នកដទៃមកទុកដាក់ក្នុងចិត្តរបស់ខ្លួនឡើយ មិនគួរចាំឃ្លាំមើលកិច្ចការដែលធ្វើហើយ និង នៅមិនទាន់បានធ្វើ របស់អ្នកដទៃផងដែរ គប្បីពិចារណាកិច្ចការដែលធ្វើហើយ និងកិច្ចការដែលមិនទាន់បានធ្វើ របស់ខ្លួនឯងតែប៉ុណ្ណោះ ។

ពុទ្ធបរិស័ទគប្បីពិចារណា នូវពាក្យសម្តីនៃជនដទៃ បើពិចារណាទៅឃើញថា ជាពាក្យមានប្រយោជន៍ គប្បីរក្សាទុកសម្រាប់បូជា គឺសម្រាប់បដិបត្តិតាមក្នុងការកសាងខ្លួនឱ្យល្អ ប៉ុន្តែបើពិចារណាទៅឃើញថា ជាពាក្យអាក្រក់លាមក ពាក្យព្រុះព្រង់ចាក់ដោត ពាក្យឥតប្រយោជន៍ទេ មិនគប្បីប្រមូលឱ្យមូលមកស្តុកក្នុងចិត្ត ធ្វើចិត្តឱ្យសៅហ្មងនោះឡើយ ត្រូវកប់ចោលឱ្យបាត់ ដូចជាការកប់នូវលាមក ឬ សំរាម ដូច្នោះឯង ។

ម្យ៉ាងទៀត កិច្ចការរបស់អ្នកដទៃ បើថាវាអាក្រក់យ៉ាងណាយ៉ាងណាហើយ ក៏ឱ្យត្រឹមតែអាក្រក់ក្នុងគេអ្នកប្រព្រឹត្តនោះទៅ មិនចាំបាច់ចម្លងយកមកឱ្យប្រឡាក់ចិត្តខ្លួនឯងឡើយ ប៉ុន្តែសម្រាប់ខ្លួនឯងនោះ ត្រូវពិចារណាថា «យប់ថ្ងៃកន្លងទៅៗអាត្មាអញបានធ្វើអ្វីខ្លះហើយ » ។

# ការឱ្យ និង ការព្រមទទួលជួយសទ្រ្ធមចិត្ត

ការអប់រំមេត្តាចិត្ត ប្រព្រឹត្តទៅបានក៏ដោយអាស្រ័យការដឹងលក្ខណៈរបស់មេត្តា បើថាមិនដឹងនូវលក្ខណៈរបស់មេត្តាទេ ក៏មិនអាចចម្រើនមេត្តាឱ្យសម្បូរក្នុងចិត្តបានឡើយ ។

មេត្តា មានការប្រព្រឹត្តទៅនៅក្នុងការងារ ជួយឱ្យសត្វទាំងឡាយបានប្រយោជន៍ និង បានសេចក្តីសុខ មិនមានគំនុំ មិនមានព្យាបាទ នេះជាលក្ខណៈនៃចិត្តមេត្តា ។ ការអប់រំចម្រើនមេត្តាពិតៗ រមែងមានការដុសខាត់នូវកិលេសក្នុងសន្តានបានច្រើនជាអនេក ដែលប្រក្រតីធម្មតាមកយើងមិនដឹងខ្លួនថា ខ្លួនឯងមានអកុសលច្រើនសន្ធឹកសន្ធាប់ប៉ុនណា លុះបានអប់រំនូវមេត្តា ព្រមដោយការចម្រើនសតិប្បដ្ឋាន ទើបបានដឹងថា មេត្តាកើតឡើងមិនបាន សតិប្បដ្ឋានក៏មិនចម្រើន ព្រោះច្រើនទៅដោយកិលេស បាបកម្មអកុសលធម៌ផ្សេងៗ សន្ធឹកសន្ធាប់ជាប់តគ្នា គ្រប់គ្រាគ្រប់ពេលវេលាហ្នឹងឯង ។



ដោយអាស្រ័យមានឧបនិស្ស័យ បានសេពគប់ជាមួយនឹងសប្បុរស បានស្តាប់ព្រះធម៌ជាឱវាទរបស់ព្រះពុទ្ធអង្គ ក៏បានយល់ដឹងបន្តិចម្តងៗ ហើយមានសទ្ធាចេះទទួលយកនូវគុណជាធម្មជាតិដ៏ស្អាតសន្សំទុកដាក់ក្នុងសន្តាន ពុំបានធ្វើអ្វីៗគិតតែអំពីតម្លៃឈ្នួលដូចមុនៗនោះឡើយ ។ បញ្ញាកាន់តែចម្រើន សេចក្តីជ្រះថ្លានៅក្នុងគុណគឺបុណ្យកុសល ក៏កាន់តែសម្បូរជាភិយ្យោភាព រីករាយក្នុងបុណ្យកុសល ទោះទានក្តី សីលក្តី ភាវនាក្តី ប្រៀបបីដូចជារាជហង្សមាសមិនរីករាយនឹងអន្លង់ភក់ជ្រាំ ប៉ុន្តែរីករាយដ៏ក្រៃលែងនឹងស្រះដែលមានអន្លង់ទឹកជ្រៅ ប្រដាប់ទៅដោយឈូកស-ក្រហម នៅនាដែនដីនៃព្រៃហិមពាន្ត ពុំនោះសោត ដូចបុរសស្ត្រីដែលនៅវ័យក្មេង ចូលចិត្តប្រដាប់តាក់តែងកាយ ពេញចិត្តតែនឹងរបស់ល្អ មានជាតិជាអ្នកស្អាត ព្យាយាមសង្វាតសម្អាតដុសខាត់កាយជានិច្ចរាល់ថ្ងៃដូច្នោះឯង ។

ជាការសម្រេចនូវជោគជ័យ ជីវិតជាប្រក្រតីមានសតិ-ប្បដ្ឋានប្បដិបត្តិ មានចិត្តជ្រកនៅក្រោមម្លប់ដ៏ប្រសើររបស់

មេត្តាភាវនា ដុសខាត់ជម្រុះចោលនូវកិលេស ជម្រះនូវមន្ទិល ក្អែលស្នឹមរបស់ចិត្ត ធ្វើឱ្យចិត្តសស្អាតមានពន្លឺរស្មី ប្រកបដោយសេចក្ដីស្ងប់ជាមួយមនុស្ស សត្វ វត្ថុ បរិក្ខារផ្សេងៗដែលនៅជុំវិញខ្លួន ។

*ពេលណាមាននូវមានះ ពេលនោះមិនមានមេត្តាទេ* វាជាលក្ខណៈអកុសលម្យ៉ាង ដែលមិនមែនធ្វើឱ្យចិត្តទន់ភ្លន់ ដូចមេត្តាឡើយ មានះមានការលើកយកខ្លួនឯងផ្ទឹមជាមួយអ្នកដទៃ ធ្វើចិត្តឱ្យប្រាថ្នាក្នុងការលើកតម្កើងខ្លួន ភ្លេចអស់ដី ទឹក ភ្លើង ខ្យល់ អាកាសធាតុ វិញ្ញាណធាតុ នឹកច្រឡំស្មានតែខ្លួនឯងគ្រាន់បើយ៉ាងនេះ គ្រាន់បើយ៉ាងនោះ តាមឈ្មោះតាមបញ្ញត្តិមែនទែន ប៉ុន្តែដែលប្រកាន់ខ្លួនយ៉ាងណានោះ វាមិនមែនជាខ្លួនយើងទេ តែវាជាកិលេសប្រភេទ**មានះ** ។

*ឥស្សាការច្រណែនមិនមែនធម៌ល្អ* គឺវាផ្ទុយអំពីមេត្តាទាំងស្រុងផងដែរ ខណៈណាដែលមានឥស្សា ខណៈនោះដាច់មេត្តា ដាច់ភាពជាមិត្តតាមផ្លូវចិត្ត ព្រោះហេតុដូច្នេះ ក្នុងមួយថ្ងៃៗ អ្នកចម្រើនមេត្តារមែងមានការគ្រប់គ្រងចិត្ត កាល



ណាបើចិត្តមិនប្រព្រឹត្តតាំងនៅក្នុងផ្លូវនៃកុសលទេ ក៏មានសម្បជញ្ញៈដឹងភ្លាមថា ចិត្តចេញក្រៅពីគន្លងផ្លូវនៃកុសលហើយ ក៏ប្រញាប់ចាប់ទាញចិត្តឱ្យមកស្ថិតក្នុងគន្លងនៃកុសលវិញ បំពេញកិច្ចយ៉ាងនេះរឿយៗរាល់ថ្ងៃ ក្រៃលែងជាងមាតារក្សាបុត្រទៅទៀត ជាបុគ្គលមិនប្រមាទក្នុងការគ្រប់គ្រងរក្សាចិត្ត ។

ព្រះសោតាបន្នបុគ្គល រំលត់ឥស្សាជាសមុច្ឆេទ គឺដាច់អស់រលីងអំពីសន្តានហើយ ព្រោះបានត្រាស់ដឹងនូវអរិយសច្ចធម៌ ប្រចក្សលក្ខណៈរបស់សភាវធម៌តាមសេចក្ដីពិតថា ត្រឹមតែជារូបធម៌ និង នាមធម៌ ដែលកើតឡើងព្រោះហេតុ ព្រោះបច្ច័យ មិនមានអ្នកណាអាចបណ្ដាលនូវលាភសក្ការៈ ការគោរពរាប់អាន ការសំពះថ្វាយបង្គំ ការបូជា និង យសស័ក្ដិជាដើម ឱ្យដល់ខ្លួនឯង ឬ ឱ្យដល់អ្នកដទៃបាន ដោយឥតមានហេតុ ឥតមានបច្ច័យនោះឡើយ *អ្វីៗទាំងអស់ដែលកើតឡើងក្នុងលោក វាត្រឹមត្រូវណាស់ ព្រោះវាជាផលរបស់ហេតុ* ប៉ុន្តែក៏គួរឱ្យនឿយណាយ ប្រាសចាកតម្រេកផងដែរ ព្រោះថា អ្វីៗទាំងអស់ដែលកើតឡើងនោះ វា

មានអាយុរបស់វា និង ម្យ៉ាងទៀត វាកើតបន្តលែងបាន ព្រោះអស់បច្ច័យ ដូច្នេះ ទើបមិនគួរឥស្សានឹងអ្នកណាៗអំពីរឿងអ្វីឡើយ ។

**ឥស្សា** មានការពេញចិត្តចំពោះសម្បត្តិដែលអ្នកដទៃបាន ប៉ុន្តែមិនពេញចិត្តនឹងអ្នកដទៃដែលបាននូវសម្បត្តិនោះទេ ហាក់ដូចជាចោទប្រកាន់នូវធម្មជាតិថា អយុត្តិធម៌ ព្រោះថារបស់នោះមិនសមគួរដល់អ្នកដទៃដែលត្រូវទទួលបាន សមគួរតែបានមកអាត្មាអញ ម្ល៉ោះហើយក៏មានភាពជ្រួលច្របល់ក្នុងចិត្ត ត្បិតអ្នកដទៃបាន ខ្លួនឯងអត់ ក្នុងទ្រូងដូចត្រូវបន្លាមុត គិតថាទោះម្ដេចម្ដាក៏អាត្មាអញត្រូវបានដូចអ្នកដទៃដែរ ប៉ុន្តែនេះម្ដេចហើយក៏យ៉ាងហ្នឹង ... ។

ពេលខ្លះល្មោភខ្លាំង ខ្លួនឯងបានដូចអ្នកដទៃហើយ ប៉ុន្តែនៅប្រឆាំងជាមួយនឹងធម្មជាតិដដែលទៀត គិតថាគួរតែអាត្មាអញបានលើសគេ មិនសមបើអ្នកដទៃស្មើនឹងអញសោះ គំនិតប្រឆាំងនឹងធម្មជាតិ ព្រមដោយអំពើឆ្គាំឆ្គងលាមកសៅហ្មងបានចងខ្លួនឯងឱ្យជាប់ក្នុងមិច្ឆាទិដ្ឋិ ឯចំណែកទោសនៃមិច្ឆាទិដ្ឋិ



ធម្មជាតិកាត់ក្ដីឱ្យមានពីរផ្នែក បើស្រាលគ្រាន់ឱ្យកើតក្នុងកំណើតតិរច្ឆាន បើធ្ងន់ត្រូវធ្លាក់ដល់នរក យ៉ាងនេះអស់កាលជាអង្វែង រួចខ្លួនអំពីអបាយភូមិមក នៅសល់ទោសឥស្សាព្រមដោយការឆ្គាំឆ្គងផ្សេងៗ រមែងកើតជាមនុស្សក្នុងត្រកូលចណ្ឌាល ថោកទាប អត់លាភអត់យស មិនសូវខុសអំពីប្រេតប៉ុន្មានឡើយ ។

សូមពុទ្ធបរិស័ទចម្រើនព្រហ្មវិហារធម៌ មានមេត្តាជាដើម ដោយសេចក្ដីមិនប្រមាទ ព្រោះធម៌ទាំងឡាយជាអនត្តា កុសលធម៌និងអកុសលធម៌ រមែងកើតឡើងតាមហេតុតាមបច្ច័យ ដូរផ្លាស់គ្នារាល់ថ្ងៃ រាល់វេលា សូមកុំភ្លេចថា បុគ្គលដែលមិនមែនជាព្រះអរិយៈ នៅមានសេចក្ដីច្រណែន សូម្បីតែជាមួយញាតិមិត្តសន្ដានបងប្អូនបង្កើត មិនចាំបាច់ពោលថ្វីដល់អ្នកដទៃឡើយ ដូច្នេះហើយ បើចេះតែមានការបណ្ដោតបណ្ដោយចិត្តសន្ដាន ចិត្តពិតជាធ្ងន់ដោយបាប *ចងដុំថ្មសណ្ដូនកហែលកាត់ទន្លេមិនល្អទេណា ។*

*មច្ឆរិយៈក៏បដិបក្ខជាមួយនឹងមេត្តាដែរ* មេត្តា

ចិត្តពិតជាល្អ គឺល្អដល់ថ្នាក់ធ្វើឱ្យអ្នកមិនចម្រើនមេត្តា ស្មានមិនត្រូវ គិតថាបើមេត្តារបៀបហ្នឹង វានាំឱ្យស្លាប់ខ្លួនឯង «គិតតែគេ ប៉ុន្តែមិនគិតខ្លួនឯងផង» តាមពិតអ្នកចម្រើនមេត្តា ជាអ្នករក្សាខ្លួនបានជិតដល់ណាស់ ពោលគឺគ្រប់គ្រងនូវចិត្ត បង្ហាត់ចិត្តឱ្យមានមេត្តា ឱ្យគួរដល់ការងារ ដោយសារថីអ្នកបង្ហាត់គឺសតិ ។

**មច្ឆរិយៈ** មានការលាក់បិទបាំងក្នុងចិត្ត នូវសម្បត្តិរបស់ខ្លួន មិនត្រូវការឱ្យសម្បត្តិរបស់ខ្លួន ក្លាយទៅជាសម្បត្តិសាធារណៈដល់ជនដទៃទៀតឡើយ បុគ្គលដែលមានសេចក្តីកំណាញ់គឺមច្ឆរិយៈនេះ រមែងមានការហួងហែង ដោយគិតថាចូរសម្បត្តិនេះជារបស់យើងតែម្យ៉ាងប៉ុណ្ណោះ ។ មួយវិញទៀតមនុស្សកំណាញ់ជាអ្នកមិនមានការអើពើ មើលឃើញតែខ្លួនឯងប៉ុណ្ណោះ ដែលជាមនុស្សត្រូវគេឱ្យ ព្រោះគិតថា «ខ្លួនឯងជាអ្នកក្រជាងគេ» ដោយងប់ចិត្តនឹងសម្បត្តិខ្លាំងពេក មនុស្សកំណាញ់គិតតែខ្លួនឯង ជ្រុលដល់ហាមអ្នកដទៃផ្សេងទៀតផង ពោលគឺហាមការធ្វើទានរបស់គេ ។

ការហាមឃាត់ទានរបស់អ្នកដទៃ ឈ្មោះថាធ្វើសេចក្តី



វិនាសអន្តរាយ ដល់ទាយកគឺអ្នកឱ្យផង ដល់បដិគ្គាហកៈគឺអ្នកទទួលផង បានសេចក្តីថា ធ្វើឱ្យទាយកខានបានបុណ្យ ខានបានចូលទៅជិតសប្បុរស ខាតការស្តាប់ធម៌ជាដើម និង ធ្វើឱ្យបដិគ្គាហកៈមិនបាននូវលាភដែលជាទេយ្យធម៌ ដូច្នេះ បុគ្គលអ្នកដែលហាមឃាត់ទាន រមែងមានការសន្សំនូវសន្តានអាក្រក់ផង កម្មពៀរវេរាផង ។

សេចក្តីកំណាញ់ តែងប្រកបជាមួយនឹងចិត្តចង្អៀតចង្អល់ ព្រោះគិតយល់ថា «បើឱ្យទៅនឹងត្រូវអស់ នូវរបស់ដែលខ្លួនខំប្រមូលបាន» តាមពិត ព្រោះអត់សទ្ធា និង បញ្ញា ដោយពុំបានយល់ថា សូម្បីតែកំណើតមនុស្សនេះ ក៏មិនមែននៅលើខ្លួនឯង ជាអ្នកទាមទារបានផង ចាំបាច់និយាយថ្វី ដល់ទៅអ្វីៗដែលជាសម្បត្តិរបស់មនុស្សផ្សេងៗទៀតនោះ ឬ ដូចជាការដែលនៅមានជីវិតរស់ដល់សព្វថ្ងៃនេះ តើយើងបានតវ៉ាជាមួយនរណាថាកុំឱ្យយើងទាន់ស្លាប់ បើខ្វះបច្ច័យសម្រាប់ឱ្យរស់ហើយ តើវាអាចនៅរស់បានយ៉ាងម៉េចទៅ ព្រោះពេលដែលត្រូវស្លាប់នោះមានគ្រប់ៗវិនាទី ដូច្នេះ បើជីវិតនេះយើងទាមទារតវ៉ា ទុកឱ្យ

រស់នៅរហូតមិនបានអ្វីចឹង តើយើងហ្នឹង គិតថាទាមទារអ្វីបាន អំពីលោកនេះ ចង់មានចង់បានប៉ុន្តែកំណាញ់ មិនមានសទ្ធា បណ្ដុះពូជក្នុងសន្ដាន មិនមានស្មារតីកាប់ព្រៃគឺកិលេសក្នុងចិត្ត ដើម្បីដាំដំណាំគឺបុណ្យកុសល រឿងទាំងអស់នេះ សុទ្ធតែមិន ទាន់បានយល់ នៅងងឹតងងល់ខ្លាំងណាស់ ចេះតែពិចពណែន ឈ្នានីសជាមួយនឹងអ្នកដទៃតែប៉ុណ្ណោះ ។

ដើម្បីកម្ចាត់នូវពៀរវេរា សូមពុទ្ធបរិស័ទទាំងអស់ គប្បី ឱ្យទានចម្រើនមេត្តា ព្រោះការឱ្យទានរមែងមានផល គឺធ្វើឱ្យ អ្នកដទៃដែលបានទទួលនូវទេយ្យធម៌នោះ មានចិត្តទន់ភ្លន់មក រកយើងជាម្ចាស់ទាន មិនអាចចងពៀរជាមួយនឹងយើងបាន ឡើយ ប៉ុន្តែបើការចងនូវពៀរនោះ វាតឹងណែនខ្លាំងណាស់ ក៏ សូមឱ្យនៅតែក្នុងចិត្តអ្នកដទៃចុះ ចំណែកពុទ្ធបរិស័ទចម្រើន មេត្តា កម្ចាត់ពៀរវេរាក្នុងចិត្តខ្លួនឯង បើអ្នកដទៃបៀតបៀន មកលើពុទ្ធបរិស័ទ ក៏សូមឱ្យគិតថា ជាការដែលអ្នកដទៃជួយ បំពេញនូវបារមី មានសេចក្ដីអត់ធន់ និង មេត្តាជាដើម ស្ងប់ រម្ងាប់ការចងគំនុំ បន្ទុំឧបនិស្ស័យនៃកុសលទើបជាការប្រពៃ ។



ម្យ៉ាងទៀត ការទទួលនូវទេយ្យធម៌អំពីអ្នកដទៃ ក៏ជា កិច្ចមួយដែលត្រូវរៀនជាចាំបាច់ផងដែរ ព្រោះថា ពេលណា ដែលមានសេចក្ដីក្រោធកើតឡើង ពេលនោះគឺមិនព្រមទទួល នូវទេយ្យធម៌អំពីអ្នកដទៃឡើយ ទោះបីជារបស់ប្រណីតយ៉ាង ណាក៏ដោយ ក្នុងរឿងនេះក៏រមែងមានជាមួយ មាតា និង បុត្រ ឬ បុត្រ និង បិតា ផងដែរ ។ សូមមនុស្សទាំងឡាយកាន់ធម៌ ខន្ដី កុំវង្វេងគាំទ្រសេចក្ដីក្រោធឱ្យសោះ កុំគិតថាសេចក្ដីក្រោធ មិនបៀតបៀនខ្លួនឯង ។ ត្រូវយកឈ្នះខ្លួនឯងដែលមានសេចក្ដី ក្រោធវិញ ព្រោះថា បើឈ្នះអ្នកដទៃមួយលាននាក់ក្នុងសមរ-ភូមិ ក៏ព្រះមិនចាត់ទុកថាប្រសើរឡើយ ព្រះអង្គទ្រង់សរសើរ តែអំពីការឈ្នះខ្លួនឯង ។ សូមឱ្យព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ស្ថិតនៅក្នុងចិត្តនៃពុទ្ធបរិស័ទ សូមឱ្យពុទ្ធបរិស័ទស្រមៃឃើញ ព្រះសម្មាសម្ពុទ្ធ និង ព្រះសង្ឃសាវ័ករបស់ព្រះអង្គ គង់ក្បែរ ជានិច្ច សូមឱ្យព្រះធម៌ ព្រះវិន័យ ស្ថិតនៅក្នុងស្មារតី នៃពុទ្ធ-បរិស័ទទាំងអស់គ្នា ។ សូមឱ្យពុទ្ធបរិស័ទមានចិត្តដូចវាចា ដែល ពុទ្ធបរិស័ទតែងសូធ្យថា «សត្វទាំងឡាយទាំងពួង សូមកុំឱ្យ

មានពៀរវេរានឹងគ្នា សូមឱ្យបានតែសេចក្ដីសុខ កុំគប្បីមានសេចក្ដីទុក្ខឡើយ» ប៉ុណ្ណេះជាដើម ។

*រាគៈជាសត្រូវយ៉ាងជិតរបស់មេត្តា* ការតាំងចេតនាអប់រំមេត្តា ឱ្យដុះដាលក្នុងសន្ដាន ត្រូវតែអាស្រ័យសម្បជញ្ញៈរបស់ខ្លួន ស្គាល់លក្ខណៈមេត្តាខុសអំពីរាគៈ បើមិនអាស្រ័យសម្បជញ្ញៈទេ មុខតែច្រឡំចម្រើនរាគៈ ឬ លោភៈថាចម្រើនមេត្តាទៅវិញ ពោលមកដល់ត្រង់នេះ ហាក់ដូចជាទំនាស់ជាមួយផ្លូវលោក ព្រោះក្នុងលោកនេះ គេនិយមការស្រឡាញ់គ្នាដោយលោភៈ គេឱ្យតម្លៃសេចក្ដីស្នេហា ថាជាខ្លឹមសារនៃការរស់ ។

រឿងនៃសេចក្ដីស្រឡាញ់នេះ វាចាក់កណ្ដាញ់ក្នុងរវាងក្រុមគ្រួសារ ការដែលនៅគ្រប់គ្រងផ្ទះស្អេកស្កះដោយលោភៈ បើមិនសិក្សាពិចារណាដោយសម្បជញ្ញៈ ក៏រមែងស្គាល់សត្រូវមិនបានដោយពិត ដូច្នេះ ការចម្រើនមេត្តាត្រូវតែជាបុគ្គលល្អិតល្អន់ ព្រោះមិនមែនត្រឹមតែទន្ទេញសូធ្យតែមាត់នោះទេ តែត្រូវដឹងលក្ខណៈរបស់មេត្តាពិត១ កាលបើមាននូវមេត្តាដល់អ្នកណា



ក៏មិនក្រោធខឹងជាមួយនឹងអ្នកនោះ តែបើស្រឡាញ់ជាប់ជំពាក់ជាលក្ខណៈលោភៈ គឺមិនមែនជាមេត្តា ចំពោះសភាវៈលោភៈនេះ ដូចពោលហើយថា វាជាសត្រូវជិត វារមែងជាបច្ច័យនៃសេចក្ដីក្រោធដោយឧបនិស្សយប្បច្ច័យ នេះឈ្មោះថាសត្រូវជិតឱ្យដៃដល់សត្រូវឆ្ងាយ ព្រោះសេចក្ដីក្រោធ ការព្យាបាទវាជាសត្រូវឆ្ងាយ ។

បើការពិតវាយ៉ាងនេះ សួរថា មេត្តានិងលោភៈ សភាវៈមួយណាល្អ មួយណាមិនល្អ ហើយម្យ៉ាងទៀត ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ បៀតបៀនសត្វលោក ឬ ក៏ជួយស្រោចស្រង់សត្វលោកទៅវិញទេ ?

**<u>ចម្លើយៈ</u>** ធម្មតាសត្រូវរមែងបៀតបៀន ដូចជាលោភៈ ឬរាគៈជាសត្រូវជិតរបស់មេត្តានេះ នឹងថាជាសភាវៈល្អមិនបានឡើយ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះទ័យករុណា ប្រាថ្នាស្រោចស្រង់សត្វលោក ទ្រង់ត្រាស់សំដែងព្រះធម៌ទេសនា ជួយឱ្យសត្វលោកមាននូវស្មារតី ទាំងបញ្ញត្តព្រះវិន័យ ទាំងសម្ដែងព្រះធម៌ពុំមានការបៀតបៀនសត្វលោកដោយប្រការណាមួយឡើយ ។

រាគៈដែលជាសត្រូវជិតរបស់មេត្តាព្រហ្មវិហារ ព្រោះដោយសេចក្តីថា រាគៈនិងមេត្តា មានការសម្លឹងមើលក្នុងចំណែកដែលជាគុណដូចគ្នា គឺសម្លឹងមើលក្នុងចំណែកដែលល្អ រាគៈនេះ ដូចសត្រូវរបស់មនុស្សដែលត្រាច់តាមក្បែរៗ រមែងបានឱកាសបៀតបៀនដោយងាយ ព្រោះហេតុនេះ សូមពុទ្ធបរិស័ទរក្សាមេត្តាចិត្តឱ្យបានល្អ គឺឱ្យបានឆ្ងាយអំពីរាគៈ កុំឱ្យរាគៈនៅក្បែរ ត្រូវមានសម្បជញ្ញៈស្គាល់រាគៈឱ្យច្បាស់ ថាមិនមែនជាមេត្តា ។

មេត្តាមានការប្រាថ្នាល្អ ពោរពេញដោយសោភណធម៌ មានសទ្ធា សតិ ហិរិ ជាដើម រមែងព្រមដោយបញ្ញាក្នុងការញ៉ាំងប្រយោជន៍ ឱ្យសម្រេចដល់អ្នកដទៃ មេត្តាមិនជាប់ជំពាក់ដូចជាលោភៈទេ លោភៈឬរាគៈកើតឡើងប្រកបជាមួយនឹងអកុសលសុទ្ធ ប្រាសចាកមេត្តាទាំងស្រុង ព្រោះមេត្តាអង្គធម៌គឺអទោសៈ មិនកើតរួមជាមួយនឹងលោភៈឡើយ ។ មេត្តាជាធម៌ប្រឆាំងជាមួយទោសៈ មួយថ្ងៃៗ បើរឹតតែច្រើនដោយមេត្តាជំនួសលោភៈបានប៉ុនណា ក៏រមែងញ៉ាំងឱ្យសម្រេចនូវផល



ល្អបានប៉ុណ្ណោះ គឺបានសម្រេចផលល្អទាំងអ្នកដែលមានមេត្តា ទាំងអ្នកដែលបានទទួលនូវមេត្តាត្រាប្រណីនោះ ។ តែបើនិយាយអំពីលោភៈវិញ បើរឹតតែច្រើន ការខឹងក្រោធ ទោមនស្សចង្អៀតចង្អល់ចិត្ត ក៏រឹតតែសម្បូរផងដែរ ការប្រហារគ្នាទៅវិញទៅមក ដោយលំពែងគឺវាចាអាក្រក់ ការវាយតប់ដោយដៃ ឬដោយសស្ត្រា ... ព្រោះខ្វះមេត្តា ប៉ុន្តែវាមានឧបនិស្ស័យអំពីលោភៈឬរាគៈហ្នឹងឯង ទើបសម្បូររឿងអាក្រក់ផ្សេងៗនោះៗ។

មានទស្សនៈក្នុងលោកច្រើនណាស់ ដែលបានយល់ឃើញ ព្រមទាំងសរសេរនៅក្នុងសៀវភៅផងថា «សុភមង្គលក្នុងគ្រួសារ ភរិយា ស្វាមី អាស្រ័យរាគៈ» ចំណែកព្រះសម្មាសម្ពុទ្ធ ព្រះអង្គពុំបានត្រាស់សរសើររាគៈដោយបរិយាយណាមួយឡើយ ប៉ុន្តែព្រះអង្គត្រាស់សរសើរនូវមេត្តា និង បញ្ញាជាដើម ឯចំណែករាគៈវិញ ព្រះអង្គទ្រង់ត្រាស់ថា *ជាសត្រូវផ្អែកល្បួងលោមបោកបញ្ឆោត បញ្ចុះបញ្ចូលឱ្យសត្វលោកត្រេកអរក្នុងភព* ។

*ការខ្វះសម្បជញ្ញៈ មេត្តាមិនចម្រើន* នៅពេល

សូធ្យធមិឱ្យសត្វទាំងឡាយបានសេចក្ដីសុខ រួចហើយចេញអំពីវត្តទៅផ្ទះ កំពុងបើកឡាន ម៉ូតូ មិនព្រមឱ្យគេទៅមុន ឬ មិនព្រមឈប់ឱ្យគេឆ្លង ប៉ុន្ដែបើគេនៅតែប្រជែងបាន ក៏ក្រោធភ្លាម អាចនឹងពោលវាចាអាក្រក់ទៀតផង នេះមេត្តាចាំមាត់ មិនមែនជាការអប់រំនូវមេត្តាពិត១ឡើយ ។ សម្បជញ្ញៈដឹងលក្ខណៈមេត្តា ស្ងប់ ត្រជាក់ ខុសអំពីចិត្តចង្អៀតចង្អល់ ទើបអាចសន្សំ អប់រំចម្រើន ទល់គ្នាជាមួយនឹងសត្វទាំងឡាយទាំងពួងពិត១ មិនមែនសូធ្យតែមាត់ តែចិត្តមិនចម្រើននោះទេ ។

មេត្តាកាយកម្មក៏មាន មេត្តាវចីកម្មក៏មាន មេត្តាមនោ-កម្មក៏មាន គឺជាការអប់រំ ការប្រព្រឹត្ត ការបដិបត្តិ ពិត១ ក្នុងខណៈដែលមានហេតុការណ៍ចំពោះមុខកើតឡើង ត្រូវអាស្រ័យសម្បជញ្ញៈជាដរាប *ការធ្វើមិនថាដោយកាយ ឬ ដោយវាចា ទោះតិច ឬ ច្រើនយ៉ាងណា ឱ្យតែដើម្បីជាប្រយោជន៍សុខដល់ជនដទៃ និង ជាប្រយោជន៍ស្ងប់ក្នុងចិត្តរបស់ខ្លួន នេះជាសម្ប-ជញ្ញៈប្រកបដោយមេត្តា* ។



*ចម្រើនឱ្យមានសិនសឹមសូធ្យផ្សាយ* ការសូធ្យជារបៀបផ្សាយមេត្តា ប៉ុន្តែមិនមែនជាការចម្រើនមេត្តាទេ មេត្តាអង្គធម៌គឺអទោសៈពិត១ កើតឡើងពិត១ ចម្រើនពិត១ ដូចជាបុគ្គលសន្សំប្រាក់គឺប្រាក់ពិត១ មានពិត១ ទើបចង់ឱ្យទៅអ្នកណា១ក៏បាន បើប្រាក់នោះគ្មានទេ តើនឹងចែកចាយឱ្យទៅអ្នកដទៃបានយ៉ាងដូចម្ដេចទៅ មេត្តាក៏ដូចជាអ៊ីចឹងដែរ មិនមែនជាការសូធ្យស្រេចហើយ ក្រសែភ្នែកក្ដី អាកប្បកិរិយាក្ដី ពាក្យសម្ដីក្ដី ផ្ទុយស្រឡះអំពីពាក្យសូធ្យនោះទេ ។

ការចម្រើនមេត្តាពិត១នោះ មិនមែនទន្ទេញសូធ្យ ប៉ុន្តែពេលបានជួបអ្នកណា ឬ ឃើញអ្នកណា ក៏មានសម្បជញ្ញៈសេចក្ដីដឹងខ្លួនដោយប្រពៃ និង សតិរលឹកដឹងសភាពរបស់ចិត្តក្នុងខណៈនោះឯង តើចិត្តក្នុងខណៈនោះ មានមើលងាយមើលថោកគេដែរទេ តើមានទាស់ចិត្តចំពោះចរិយាការប្រព្រឹត្ត ឬពាក្យសម្ដីអ្វី១របស់គេដែរឬទេ ហើយខ្លួនឯងនិយាយទៅរកគេតើនិយាយដោយសុភាពរាបសា ប្រាថ្នាសុខ ប្រាថ្នាប្រយោជន៍ជាមិត្តមេត្រីឱ្យដល់គេនោះដែរឬទេ សម្បជញ្ញៈនេះឯង ដែល

អាចសម្រួលរៀបចំចិត្តឱ្យមានមេត្តា ព្រោះមិនប្រាថ្នាឱ្យខ្លួនឯងសៅហ្មងចិត្ត មានហិរិឳត្តប្បៈខ្មាសខ្លើមចិត្តអាក្រក់ដែលកើតឡើង ហើយក៏មិនប្រាថ្នាឱ្យអ្នកដទៃមានទុក្ខ មានភ័យ ដោយប្រការណាមួយឡើយ ។

បុគ្គលដែលយល់លក្ខណៈរបស់មេត្តា ទើបចម្រើនមេត្តាបាន មេត្តាសម្បូរ ធំទូលំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ដោយសម្បជញ្ញៈថ្នាក់សមថៈ មិនមែនដោយការសូធ្យមានរបៀបរៀបបន្ទាត់ តាំងអំពីដើមដល់ចប់នោះទេ តើនៅពេលសូធ្យនោះ ចិត្តស្ងប់ឬទេ មានមេត្តាចិត្តពិតៗទេ មិនបង្អួតសម្លេងសូធ្យ ឬ មិនបង្អួតការចាំរបស់ខ្លួនដែរឬទេ មិនមើលងាយអ្នកសូធ្យខុសពិតដែរទេ ....តាមពិតការផ្សាយនូវមេត្តា ឱ្យដល់សត្វទាំងឡាយទាំងពួងបាន គឺត្រូវតែមានមេត្តាសមាធិក្នុងចិត្ត ស្ងប់រម្ងាប់នូវនីវរណធម៌ ត្រជាក់ក្រៀម *បើខ្លួនឯងគ្មានត្រជាក់ផងទេ តើបានត្រជាក់អ្វីឱ្យគេ* ។



# បទគួរយល់ដឹងចុងក្រោយ

❋បើពិចារណាឃើញថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនដ៏ក្រៃលែងហើយនោះ ក៏កុំភ្លេចគិតឱ្យឃើញថា អ្នកដទៃគេស្រឡាញ់ខ្លួនគេ ក៏ក្រៃលែងផងដែរ ព្រោះហេតុដូច្នេះ អ្នកស្រឡាញ់ខ្លួនទើបមិនគួរបៀតបៀនអ្នកដទៃ ។ សត្វខ្លារស់នៅដោយអាស្រ័យនឹងចង្កូមសម្លាប់ម្រឹគជាអាហារ ចំណែកសត្វស្វាបរិភោគផលាផល គោក្របីអាស្រ័យស្មៅសូម្បីចំបើង រីឯមនុស្សជាសត្វខ្ពង់ខ្ពស់ ប៉ុន្តែទាល់តែចេះរស់ទើបប្រពៃ បើរស់ដោយសារការបៀតបៀនអ្នកដទៃ សូមឱ្យចេះខ្មាសគោក្របី និង ស្វាព្រៃ ផង ។

តាមពិតធម្មជាតិគឺបុណ្យ បង្កើតមនុស្សមក មិនមែនឱ្យអន់ជាងសត្វទាំងពួងឡើយ មនុស្សអាចសាងសមត្ថភាពបានគ្រប់យ៉ាង មិនមែនគ្រាន់តែចិញ្ចឹមខ្លួនឯងឱ្យបានរស់ទាល់តែបៀតបៀនគេនោះទេ មនុស្សអាចជាព្រះសម្មាសម្ពុទ្ធ ជាគ្រូ ជា

សាស្តា លើអស់ទេវតាឥន្ទព្រហ្ម ជាព្រះបច្ចេកពុទ្ធ ជាព្រះអរហន្ត ជាមនុស្សបរិសុទ្ធ ដូច្នេះ បើយើងមិនមានសមត្ថ-ភាពជួយអ្នកដទៃបានពីរ ឬ បីនាក់ទេនោះ ក៏សូមជួយតែខ្លួនឯងម្នាក់ឱ្យបានទៅចុះ ដាច់ខាតកុំបៀតបៀនអ្នកដទៃ សូមឱ្យអ្នកដទៃបានរស់នៅ ដោយការមិនភិតភ័យផង ដោយការមិនត្រូវនឹងសស្ត្រាវុធផង និង បាននៅឃើញពន្លឺថ្ងៃតទៅទៀត ក្នុងកំណើតមនុស្សទាំងអស់គ្នាផង ឬសូម្បីតែកំណើតសត្វតិរច្ឆាន ។

αសត្វតូចធំព្រមទាំងមនុស្ស ដែលយើងបានសម្លាប់ហើយ កាលពីជាតិមុនក្តី ក្នុងជាតិនេះក្តី អាចមកកើតជាមនុស្សនៅជុំវិញយើងសព្វថ្ងៃនេះបាន ដូច្នេះ ជាមួយគ្នាក្នុងការរស់នៅគេអាចស្អប់យើង មិនចូលចិត្តយើង ឬ ធ្វើនូវអំពើអ្វីមួយ ជាលក្ខណៈពៀរវេរាមកលើយើង ។ ជំនួសការសូមអភ័យទោសដល់មនុស្សសត្វដែលយើងបានសម្លាប់ហើយនោះ គប្បីចម្រើននូវមេត្តា ទល់គ្នាជាមួយនឹងសត្វលោកទាំងអស់ ដែលកំពុងនៅរស់ជុំគ្នានេះ ដូច្នេះ ទើបពៀរវេរាអាចស្ងប់រម្ងាប់ទៅបាន ដែលពៀរវេរាទាំងអស់មានក្នុងលោកព្រោះឥតមេត្តាហ្នឹងឯង ។



✵ *ពេលស្លាប់* គឺត្រូវព្រាត់ប្រាសនូវគ្រប់អ្វីៗទាំងអស់ដែលមានក្នុងជាតិនេះ មិនមានអ្វីសល់ជារបស់បុគ្គលនេះតទៅទៀតឡើយ សូម្បីតែការចាំ ។ ជាតិនេះកើតមកហើយចាំបានទេថា ជាតិមុនជានរណា នៅទីណា ធ្វើអ្វីខ្លះ មានអ្នកណាជាញាតិខ្លះ ...ត្រូវបានបាត់បង់អស់ទៅហើយ ព្រមទាំងការចងចាំ ដូច្នេះ ទោះបីជាតិនេះមាននូវការប្រកាន់ក្នុងជាតិត្រកូលវណ្ណៈ យសស័ក្តិយ៉ាងណាក៏ដោយចុះ ក៏នឹងត្រូវអស់រលីងដែរមិនមានសេសសល់អ្វីៗក្នុងជាតិនេះ ភពនេះទៀតទេ ។

ការស្លាប់បានធ្វើឱ្យព្រាត់ចាកគ្រប់យ៉ាង ដោយគ្មានសល់អ្វីទាំងអស់ ទាំងការគិត ទាំងការចាំ ទាំងការប្រកាន់យ៉ាងណាៗ គឺគ្រប់យ៉ាងដែលធ្លាប់ជាប់ជំពាក់ទាក់ទិន តាំងពីកើតមកដល់សព្វថ្ងៃនេះនោះ ក៏នឹងជាប់ជំពាក់ប្រកាន់ថា ជាតួយើងទៀតតទៅមិនបានឡើយ ដូច្នេះ ជំនួសការសោកស្តាយចំពោះអ្វីៗ ក៏គួររីករាយក្នុងព្រះសទ្ធម្ម ដែលជាធម៌របស់សប្បុរសជាធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង ជាការប្រកាសនូវសច្ចធម៌ គឺថា « *បានកើតមកហើយដែលនឹងមិន*

*ស្លាប់នោះ រមែងមិនមាន កាលបើបានយល់នូវការពិត ក៏ដឹងថា សេចក្តីពិតជាសច្ចធម៌* » ។

αជីវិតយើងជាក្រសែចិត្ត ដែលកើតរលត់បន្តគ្នា មួយខណៈៗជាប់ជានិច្ចមិនដាច់តាំងពីកើតរហូតដល់ស្លាប់ ចាកកំណើតមួយ ទៅកាន់កំណើតមួយទៀត ។ ចំពោះរឿងរបស់កិលេសវិញ គឺកិលេសគ្រប់យ៉ាងកើតឡើង ព្រោះបានសន្សំមកហើយអំពីអតីតៈ កាលបញ្ញានៅមិនទាន់បានចម្រើន ដល់ថ្នាក់រំលត់ជាសមុច្ឆេទទេនោះ កិលេសក៏កើតទៀត ចេះតែកើតបន្តរឿយៗទៅក្នុងអនាគត ដូច្នេះ ទើបគួរសិក្សាព្រះធម៌ដើម្បីលះកិលេស ព្រោះកិលេសរបស់យើង បានធ្វើឱ្យយើងមិនមានសេចក្តីសុខ អស់កាលជាអង្វែងមកហើយ ក្នុងសង្សារវដ្ត ។



# នាមពុទ្ធបរិស័ទដែលមានសទ្ធា
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយធម្មទានប្រចាំឆ្នាំ

១- ឧបាសក យូស៊ាង ងួនលី និង ឧបាសិកា លីម យីម
២- ឧបាសក ឆាយ អ៊ីវស៊ាង និង ឧបាសិកា ហុង គឹមសែ
៣- ឧបាសក ឆាយអ៊ីវ ស្រេងលីម និង ឧបាសិកា ហួត យីម
៤- ឧបាសក ហៃ ប៊ុនណារិន និង ឧបាសិកា អោង ស៊ីថាន់
៥- ឧបាសក យន្ត សួន និង ភរិយា ព្រមទាំងបុត្រ
៦- ឧបាសក អ៊ុត ឆៃវ៉ាន និង ភរិយា ព្រមទាំងបុត្រ
៧- ឧបាសក ប្លោក ងួនថៃ និង ភរិយា ព្រមទាំងបុត្រ
៨- ឧបាសក ជឹម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ
៩- ក្រុមឧបាសក ឈុំ កុសល និង ឧបាសក អ៊ុន ឆាយគ្រី
១០- ក្រុមឧបាសក លឹម ស៊ាង ហៅ ទូច
១១- ក្រុមឧបាសក មួងយេន
១២- ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន